CAO COMPLIANCE ADVISOR OMBUDSMAN

*The Independent Accountability Mechanism for IFC & MIGA*

ខែវិច្ឆិកា ឆ្នាំ២០២៤

# របាយការណ៍ស៊ើបអង្កេតភាពអនុលោម

## ទៅលើការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ប្រទេសវៀតណាម ពាក់ព័ន្ធនឹងអនុគម្រោង វារីអគ្គិសនីសេសានក្រោម២ នៅកម្ពុជា

គម្រោង IFC លេខ ២៩៧៤៥

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២៤

## អំពីស៊ីអេអូ

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកក្រុមធនាគារពិភពលោក។ យើងធ្វើការសម្របសម្រួលដោះស្រាយបណ្តឹងពីប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ដោយយុត្តិធម៌ ឥតលម្អៀង និងប្រកបដោយភាពស្ថាបនា លើកកម្ពស់លទ្ធផលផ្នែកបរិស្ថាន និងសង្គមនៃគម្រោងទាំងនោះ និងបង្កើនគណនេយ្យភាពសាធារណៈ និង ការរៀនសូត្រនៅ IFC និង MIGA។

ស៊ីអេអូ គឺជាការិយាល័យឯករាជ្យ ដែលរាយការណ៍ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ IFC និង MIGA ដោយផ្ទាល់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល www.cao-ombudsman.org។

## អំពីមុខងារភាពអនុលោម

មុខងារភាពអនុលោមរបស់ស៊ីអេអូ ត្រួតពិនិត្យឡើងវិញលើភាពអនុលោមរបស់ IFC និង MIGA ចំពោះគោលនយោបាយបរិស្ថាន និងសង្គម វាយតម្លៃលើការខូចខាតដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍អំពីវិធានការដោះស្រាយដែលសមស្រប។

មុខងារអនុលោមភាពរបស់ស៊ីអេអូអនុវត្តតាមអភិក្រមបីជំហាន៖

| ការវាយតម្លៃ | ការស៊ើបអង្កេត | ការពិនិត្យតាមដាន |
|---|---|---|
| ត្រួតពិនិត្យជាបឋម ដើម្បីកំណត់ថា តើពាក្យបណ្តឹង ឬសំណើផ្ទៃក្នុង ចាំបាច់ត្រូវធ្វើការស៊ើបអង្កេតភាពអនុលោម ដែរឬទេ។ | ការកំណត់ជាប្រព័ន្ធ និងប្រកបដោយសត្យានុម័ត ថាតើ IFC/MIGA បានអនុលោមតាមគោលនយោបាយបរិស្ថាន និងសង្គមរបស់ខ្លួនដែរឬទេ និងថាតើមានការខូចខាត ពាក់ព័ន្ធនឹងបដិលោមភាពណាមួយ ដែរឬទេ។ | ការផ្ទៀងផ្ទាត់អំពីការអនុវត្តវិធានការគ្រប់គ្រង ដែលត្រូវបានបង្កើតឡើង ឆ្លើយតបនឹងរបកគំហើញ និងអនុសាសន៍ពីការស៊ើបអង្កេតអំពីភាពអនុលោមប្រកបដោយប្រសិទ្ធភាព។ |

# តារាងមាតិកា


1. សារតារ ....... 1
 1.1 បរិបទ និងការវិនិយោគរបស់ IFC ....... 1
  1.1.1 ការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank និងការវិនិយោគរបស់ ABBank នៅក្នុង EVNI. 2
  1.1.2 ការអភិវឌ្ឍទំនប់នៅអាងទន្លេមេគង្គ ....... 7
  1.1.3 គម្រោងវារីអគ្គិសនីសេសានក្រោម២ ....... 11
  1.1.4 បរិបទរបស់ធនាគារពិភពលោកសម្រាប់ការអភិវឌ្ឍន៍វារីអគ្គិសនី ក្នុងឆ្នាំ២០១០ ....... 14
 1.2 បន្ទាត់ពេលវេលានៃព្រឹត្តិការណ៍សំខាន់ៗ ....... 17
2. ក្របខ័ណ្ឌស៊ើបអង្កេតភាពអនុលោម ....... 20
 2.1 បណ្ដឹងសហគមន៍ ....... 20
 2.2 ការឆ្លើយតបរបស់ IFC ....... 24
 2.3 ដំណើរការរបស់ ស៊ីអេអូ ....... 25
 2.4 វិសាលភាពនៃការស៊ើបអង្កេត ....... 26
 2.5 វិធីសាស្រ្តស៊ើបអង្កេត ....... 27
 2.6 ស៊ីអេអូ ខ្វះលទ្ធភាពក្នុងការជួបជាមួយអតិថិជនបន្ត និងអនុគម្រោងរបស់ IFC ....... 28
 2.7 គោលនយោបាយ IFC ដែលអាចអនុវត្តបាន ....... 30
3. ការវិភាគ និងគំហើញ ....... 38
 3.1 ការត្រួតពិនិត្យរបស់ IFC មុនពេលវិនិយោគ ....... 38
  3.1.1 សេចក្តីសង្ខេបនៃសកម្មភាពរបស់ IFC ....... 38
  3.1.2 ការវិភាគរបស់ ស៊ីអេអូ និងគំហើញពីការពិនិត្យមុនពេល IFC ធ្វើការវិនិយោគ (ESDD) ....... 41
  3.1.3 ការបាត់បង់ឱកាសក្នុងការជះឥទ្ធិពលទៅលើការអភិវឌ្ឍន៍គម្រោង ....... 46
 3.2 ការត្រួតពិនិត្យគម្រោង IFC ....... 49
  3.2.1 កាតព្វកិច្ចរបស់ IFC ទាក់ទងនឹងការវិនិយោគរបស់ធនាគារ ABank ....... 50
  3.2.2 សេចក្តីសង្ខេបនៃសកម្មភាពត្រួតពិនិត្យរបស់ IFC ....... 55
  3.2.3 ការវិភាគភាពអនុលោមនៃការត្រួតពិនិត្យរបស់ IFC និងគំហើញរបស់ ស៊ីអេអូ ....... 61
4. ការវាយតម្លៃរបស់ ស៊ីអេអូ ទៅលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ ....... 75
 4.1 អ្នកភូមិក្បាលរមាស និងស្រែគរ ក្នុងតំបន់អាងទន្លេ (ដើមបណ្ដឹងដែលបានតាំងទីលំនៅថ្មី និងដើមបណ្ដឹងដែលមិនព្រមតាំងទីលំនៅថ្មី) ....... 76
 4.2 អ្នកភូមិក្បាលរមាស និងស្រែគរចាស់ ដែលមិនព្រមតាំងទីលំនៅថ្មី ....... 80
 4.3 អ្នកភូមិដែលតាំងលំនៅថ្មី នៅក្បាលរមាស និងស្រែគរថ្មី ....... 87
 4.4 ភូមិដែលស្ថិតនៅខ្សែទឹកខាងលើ ....... 93

5. មូលហេតុឫសគល់នៃភាពមិនអនុលោម....98
6. អនុសាសន៍ចំពោះផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រងរបស់ IFC....102
ឧបសម្ព័ន្ធ កៈ សកម្មភាព និងព័ត៌មានកម្រិតអនុគម្រោង.... 111
ឧបសម្ព័ន្ធ ខៈ ផលប៉ះពាល់ជលផល រាយការណ៍ដោយសហគមន៍....135
ឧបសម្ព័ន្ធ គៈ ទិដ្ឋភាពទូទៅនៃដំណើរការស៊ើបអង្កេត ស៊ីអេអូ ....141
ឧបសម្ព័ន្ធ ឃៈ គំហើញរបស់ស៊ីអេអូ ស្តីពីភាពមិនអនុលោម គ្រោះថ្នាក់ដែលពាក់ព័ន្ធ និងអនុសាសន៍ ....146

## អក្សរកាត់

| | |
|---|---|
| ABBank | ធនាគារ An Binh Joint Stock Commercial Bank |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AEPR | របាយការណ៍លទ្ធផលការងារបរិស្ថានប្រចាំឆ្នាំ |
| AH | គ្រួសាររងផលប៉ះពាល់ |
| amsl | លើនីវូទឹកសមុទ្រជាមធ្យម |
| AVI | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| CAO | ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) (IFC និង MIGA) |
| CPS | យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស |
| CRP | គោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ |
| CSR | ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម |
| E&S | បរិស្ថាន និងសង្គម |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| ESAP | ផែនការសកម្មភាពបរិស្ថាន និងសង្គម |
| ESDD | ការត្រួតពិនិត្យបរិស្ថាន និងសង្គម |
| ESMS | ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESRP | នីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម |
| EVN | អគ្គិសនីវៀតណាម |
| EVNI | ក្រុមហ៊ុន Vietnam Electricity International Joint Stock Company |
| FI | អន្តរការីហិរញ្ញវត្ថុ |
| GN | កំណត់សម្គាល់ណែនាំអំពីស្តង់ដារសមិទ្ធិកម្មរបស់ IFC ស្តីពីនិរន្តរភាព E&S |
| Ha | ហិកតា |
| IBRD | ធនាគារអន្តរជាតិសម្រាប់កសាងឡើងវិញ និងអភិវឌ្ឍ |
| ICLT | ប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពសហគមន៍ជនជាតិដើមភាគតិច |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| IFReDI | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប |
| IP | ជនជាតិដើមភាគតិច |
| IRM | កិច្ចប្រជុំត្រួតពិនិត្យការវិនិយោគ |
| IUCN | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |
| Km | គីឡូម៉ែត្រ |

| | |
|---|---|
| Lao PDR | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ |
| LS2 | គម្រោងវារីអគ្គិសនីសេសានក្រោម២ (អនុគម្រោងរបស់ IFC) |
| $M^2$ | ម៉ែត្រការ៉េ |
| MAP | ផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង |
| MIGA | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| MSME | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| MW | មេហ្គាវ៉ាត់ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| PS | ស្តង់ដារសមិទ្ធិកម្ម (IFC) |
| PS1 | ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃសង្គម និងបរិស្ថាន |
| PS4 | សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ |
| PS5 | លទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត |
| PS6 | ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព |
| PS7 | ជនជាតិដើមភាគតិច |
| PS8 | បេតិកភណ្ឌវប្បធម៌ |
| RAP | ផែនការសកម្មភាពស្តីពីការដោះស្រាយផលប៉ះពាល់ |
| Sacombank | ធនាគារ Saigon Thuong Tin Commercial Joint Stock |
| SME | សហគ្រាសធុនតូច និងមធ្យម |
| SEMS | ប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន |
| SPI | សេចក្តីសង្ខេបអំពីសំណើវិនិយោគ |
| UN | អង្គការសហប្រជាជាតិ |
| VND | រូបិយប័ណ្ណដុងវៀតណាម |
| WBG | ក្រុមធនាគារពិភពលោក |
| WCD | គណៈកម្មការពិភពលោកស្តីពីទំនប់ |

# សង្ខេប

*ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០២៤ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានវិនិយោគលើអន្តរការីហិរញ្ញវត្ថុ (FI) នៅក្នុងធនាគារ An Binh Joint Stock Commercial Bank (ABBank) នៅប្រទេសវៀតណាម។ ជាកិច្ចឆ្លើយតប ធនាគារ ABBank បានដាក់ទុនវិនិយោគនៅក្នុងក្រុមហ៊ុន Vietnam Electricity International Joint Stock Company (EVNI) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Vietnam Electricity (EVN) ដែលត្រូវបានបង្កើតឡើងដើម្បីអភិវឌ្ឍគម្រោងក្រៅប្រទេស រួមទាំងគម្រោងវារីអគ្គិសនីសេសានក្រោម២ (LS2) នៅភាគឦសានប្រទេសកម្ពុជា ផងដែរ។ ការស៊ើបអង្កេតភាពអនុលោមនេះ ឆ្លើយតបទៅនឹងពាក្យបណ្តឹងចំនួនបីពីសហគមន៍ ក្នុងតំបន់អាងស្តុកទឹក និងខ្សែទឹកខាងលើនៃគម្រោង LS2 ដែលបានលើកឡើងពីកង្វល់អំពីផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គម (E&S) បណ្តាលមកពីអនុគម្រោងរបស់ IFC ។ ស៊ីអេអូ រកឃើញថា IFC មិនបានអនុវត្តការត្រួតពិនិត្យបរិស្ថាន និងសង្គម ឱ្យបានគ្រប់គ្រាន់ មុនពេលការវិនិយោគរបស់ធនាគារ ABBank ហើយក្នុងអំឡុងពេលនៃការត្រួតពិនិត្យ មិនបានត្រួតពិនិត្យតាមដានការប្តេជ្ញាចិត្ត E&S នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួន ជាមួយអតិថិជន ដែលនេះផ្ទុយទៅនឹងគោលនយោបាយនិន្តរភាព។ ស៊ីអេអូ រកឃើញគ្រោះថ្នាក់ដែលពាក់ព័ន្ធទៅលើដើមបណ្តឹង ជុំវិញការតាំងទីលំនៅថ្មីក្នុងសហគមន៍ ផលប៉ះពាល់លើជីវភាពរស់នៅ និងជីវចម្រុះ ការគំរាមកំហែងដល់សមាជិកសហគមន៍ដែលប្រឆាំងគម្រោង និងការធ្វើឱ្យខូចខាតដល់ទីតាំងសង្គម-វប្បធម៌សំខាន់ៗ។ ស៊ីអេអូ សូមផ្តល់អនុសាសន៍ទាំងទៅលើសកម្មភាពកម្រិតគម្រោង និងកម្រិតប្រព័ន្ធ ជូន IFC ដែលបានចាកចេញពីការវិនិយោគនេះ នៅក្នុងខែឧសភា ឆ្នាំ២០២៤។*

### បរិបទ និងការវិនិយោគរបស់ IFC

ក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ២០០០ IFC បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការផ្លាស់ប្តូររបស់វៀតណាមឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារ រួមទាំងការផ្លាស់ប្តូរប្រព័ន្ធធនាគាររបស់ប្រទេសនេះ ទៅជាការចូលរួមភាគច្រើនពីវិស័យឯកជន ផងដែរ។ នៅក្នុងខែធ្នូ ឆ្នាំ២០១០ IFC បានធ្វើការវិនិយោគប្រមាណ ៤០,៦ លានដុល្លារអាមេរិក នៅក្នុងធនាគារ ABBank ដែលជាធនាគារពាណិជ្ជជាតិខ្នាតមធ្យម តាមរយៈមូលបត្របំណុលអាចបំប្លែងបានជាកាតព្វកិច្ច ដែលបានបំប្លែងទៅជាភាគហ៊ុននៅក្នុងខែមេសា ឆ្នាំ២០១៣ (គម្រោង IFC #២៩៧៤៥)។ IFC បានកាន់កាប់ភាគហ៊ុន ១០ ភាគរយនៅក្នុងធនាគារ ABBank ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២១ និង ៨,២ ភាគរយ ចាប់ពីខែធ្នូ ឆ្នាំ២០២១ ដល់ឆ្នាំ២០២៣ បន្ទាប់ពីបានសម្រេចចិត្តមិនចូលរួមនៅក្នុងបញ្ហាសិទ្ធិ នៅឆ្នាំ២០២១ របស់ ABBank។ ភាពជាដៃគូយូរអង្វែងរបស់ IFC ជាមួយ ABBank មានគោលបំណងអនុញ្ញាតឱ្យអតិថិជនរក្សាអនុបាតភាពគ្រប់គ្រាន់នៃមូលធនរឹងមាំ ខណៈកំពុងរីកចម្រើនផលប័ត្រឥណទានរបស់ខ្លួន និងគាំទ្រគំនិតផ្តួច

ផ្តើមបម្រែបម្រួលអាកាសធាតុ និងគម្រោងប្រសិទ្ធភាពថាមពល។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ IFC បានដកហ៊ុនទាំងស្រុងពីភាគហ៊ុនរបស់ខ្លួន នៅក្នុងធនាគារ ABBank ។

នៅពេលដែល IFC បានវិនិយោគនៅក្នុង ABBank ក្នុងឆ្នាំ២០១០ ធនាគារមានការវិនិយោគភាគហ៊ុនដែលមានស្រាប់ចំនួន ១០,៣១ ភាគរយនៅក្នុង EVNI ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ EVN ដែលជាម្ចាស់ភាគហ៊ុនរបស់ ABBank និងជាអតិថិជនធំជាងគេបំផុតរបស់ធនាគារ នៅពេលនោះផងដែរ។ EVNI ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៧ ដើម្បីសាងសង់ និងដំណើរការគម្រោងថាមពលអន្តរជាតិ រួមទាំង LS2 នៅក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងពេលនៃការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ក្រុមធនាគារពិភពលោក បានចូលរួមនៅក្នុងគំនិតផ្តួចផ្តើមជាបន្តបន្ទាប់យ៉ាងទូលំទូលាយ ដើម្បីដោះស្រាយផលប៉ះពាល់ E&S និងហានិភ័យនៃការអភិវឌ្ឍវារីអគ្គិសនីទ្រង់ទ្រាយធំ ដែលជំរុញដោយការត្រួតពិនិត្យជាសាធារណៈលើគម្រោងវារីអគ្គិសនីដែលមានលទ្ធភាពខ្ពស់ទទួលបានជោគជ័យមួយចំនួន ដែលក្រុមធនាគារពិភពលោក បានផ្តល់ហិរញ្ញប្បទាន។ IFC ខ្លួនឯង បានបោះពុម្ពផ្សាយយុទ្ធសាស្ត្រវារីអគ្គិសនី ក្នុងឆ្នាំ២០០៧ ជាពេលដែលខ្លួនបានទទួលស្គាល់ថា វារីអគ្គិសនីត្រូវតែអភិវឌ្ឍដោយប្រុងប្រយ័ត្ន ជាមួយនឹងលក្ខខណ្ឌ E&S គ្រប់គ្រង ប្រកបដោយការទំនួលខុសត្រូវ ក្នុងចំណោមលក្ខខណ្ឌផ្សេងៗទៀត។

## អនុគម្រោង

LS2 គឺជាគម្រោងវារីអគ្គិសនីដ៏ធំបំផុតរបស់កម្ពុជា ដែលជាទំនប់វារីអគ្គិសនី ៤០០ មេហ្គាវ៉ាត់ មានទីតាំងស្ថិតនៅស្រុកសេសាន លើទន្លេសេសាន ប្រមាណ ២៥ គីឡូម៉ែត្រ នៅខ្សែទឹកខាងលើទន្លេមេគង្គ ដែលជាទន្លេគាំទ្រដល់ការនេសាទត្រីទឹកសាបដ៏ធំបំផុតនៅលើពិភពលោក។

EVNI បានបង្កើតគម្រោង LS2 ពីឆ្នាំ២០០៧ ដល់ខែមករា ឆ្នាំ២០១១ ជាពេលដែលក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ (Hydropower Lower Sesan 2 Co. Ltd.) ត្រូវបានបង្កើតឡើង រវាង EVNI (៥១ ភាគរយ) និងក្រុមហ៊ុន រ៉ូយ៉ាល់គ្រុបរបស់កម្ពុជា (៤៩ ភាគរយ) ។ រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០១២ EVNI គឺជាម្ចាស់ភាគហ៊ុនច្រើនជាងគេ ហើយបានគ្រប់គ្រងដំណើរការរៀបចំផែនការ និងការអនុម័ត។ ក្រោយមកទៀត ក្រុមហ៊ុននេះបានក្លាយជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា រវាងក្រុមហ៊ុន Hydrolancang International Energy របស់ប្រទេសចិន (៥១ ភាគរយ) និងក្រុមហ៊ុន រ៉ូយ៉ាល់គ្រុបរបស់កម្ពុជា(៣៩ ភាគរយ) ដោយភាគហ៊ុនរបស់ EVNI បានធ្លាក់ចុះមកនៅត្រឹម ១០ ភាគរយ។

ក្នុងអំឡុងពេលដែល EVNI ជាម្ចាស់ភាគហ៊ុនច្រើនជាងគេ និងជាអ្នកអភិវឌ្ឍគម្រោង EVNI បានទទួលការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើការសិក្សាសមិទ្ធិលទ្ធភាព ដែលខ្លួនបានបញ្ចប់ជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ក្នុងឆ្នាំ២០០៨។ EIA ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុម័ត នៅខែមិថុនា ឆ្នាំ២០១០ ហើយនៅឆ្នាំ២០១១ EVNI បានបញ្ចប់ជាស្ថាពរនូវគោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ (CRP) សម្រាប់គម្រោង LS2 ។ ការសាងសង់គម្រោងបានធ្វើឡើង ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ ដែលនាំឱ្យមានការផ្លាស់ទីលំនៅរូបវន្ត ឬសេដ្ឋកិច្ចរបស់ប្រជាជនជិត ៥.០០០ នាក់ និងប៉ះពាល់ដល់សហគមន៍នេសាទរស់នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម។ ខណៈការតាំងទីលំនៅថ្មីនៃគ្រួសារភាគច្រើន បានធ្វើ

ឡើងចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ប្រជាពលរដ្ឋចំនួន ១៣៦គ្រួសារ នៅតំបន់អាងស្តុកទឹក បានបដិសេធមិនព្រមតាំងលំនៅថ្មី និងបានប្តូរទីលំនៅទៅជិតភូមិលិចទឹករបស់ពួកគេ ដែលនៅខាងក្រៅក្បែរតំបន់ទឹកជំនន់។ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ សមាជិកសហគមន៍បានតវ៉ាប្រឆាំងនឹងគម្រោងនេះ ហើយរបាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយ ការសិក្សា និងក្រុមសង្គមស៊ីវិល បានលើកឡើងពីក្តីកង្វល់អំពីផលប៉ះពាល់ E&S របស់គម្រោងនេះ។

## ពាក្យបណ្តឹង

នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ស៊ីអេអូ បានទទួលពាក្យបណ្តឹងចំនួន ៣ ចោទប្រកាន់ពីផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន និងសង្គម (E&S) ដែលរីករាលដាលចេញពីប្រតិបត្តិការរបស់គម្រោងវារីអគ្គិសនី មកលើសហគមន៍។ ក្រុមអ្នកដាក់ពាក្យបណ្តឹងទាំងនេះរួមមាន៖ (១) អ្នកភូមិដែលបានតាំងទីលំនៅថ្មី (២) អ្នកភូមិដែលមិនព្រមតាំងទីលំនៅថ្មី និង (៣) អ្នកភូមិនៅខ្សែទឹកខាងលើ។

1. *អ្នកភូមិដែលបានតាំងទីលំនៅថ្មី* ចោទប្រកាន់ថា ជីវភាពថ្មីរបស់ពួកគេមានភាពខ្វះខាត និងថាពួកគេ មិនបានទទួលកម្មវិធីស្តារ និងទ្រទ្រង់ជីវភាពរស់នៅ ឬការគាំទ្រ នោះទេ។ ពួកគេក៏បានអះអាងដែរថា ពួកគេមិនអាចចូលរួមក្នុងការសម្រេចចិត្តលើការបែងចែកដីបានទេ។
2. *អ្នកភូមិដែលមិនព្រមតាំងទីលំនៅថ្មី* អះអាងថា មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ បានរងផលប៉ះពាល់ដោយការធ្លាក់ចុះយ៉ាងខ្លាំងចំពោះបរិមាណត្រីក្នុងស្រុក។ ដើមបណ្តឹងមួយចំនួន ដែលបានកំណត់អត្តសញ្ញាណថាជាជនជាតិដើមភាគតិច ព្យាយាមការពារអត្តសញ្ញាណវប្បធម៌ និងទឹកដីកន្លែងដ៏ពិសិដ្ឋរបស់ពួកគេ។ ដើមបណ្តឹងខ្លះទៀត ចោទថាពួកគេខ្វះខាតហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងមិនមានដីស្រែចម្ការគ្រប់គ្រាន់ ដោយសារទឹកជំនន់បង្កឡើងដោយទំនប់។
3. *អ្នកភូមិរស់នៅខ្សែទឹកខាងលើ* ចោទប្រកាន់ថា មានផលប៉ះពាល់ចំពោះមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ដោយសារការប្រែប្រួលនៃកម្រិតទឹក ហើយត្រីនៅទន្លេសេសាន និងទន្លេស្រែពក មានចំនួនតិចជាងមុន។ ពួកគេបានអះអាងថា ពួកគេមិនធ្លាប់ទទួលបានការជូនដំណឹង ឬការពិគ្រោះយោបល់អំពីគម្រោងវារីអគ្គិសនី ឬគោលនយោបាយសំណងរបស់គម្រោង នោះទេ។

ក្រុមទាំងបីនេះ រួមទាំងក្រុមជនជាតិដើមភាគតិច បានស្នើសុំរក្សាការសម្ងាត់ ដោយភ័យខ្លាចការគំរាមកំហែង និងការសងសឹក។

## ការឆ្លើយតបរបស់ IFC

ស៊ីអេអូ បានទទួលការឆ្លើយតបទៅនឹងពាក្យបណ្តឹងទាំងនោះ ពីគណៈគ្រប់គ្រងរបស់ IFC នៅខែកក្កដា ឆ្នាំ២០២២។ IFC អះអាងថា មិនមានទំនាក់ទំនងរវាងការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank និងគម្រោងវារីអគ្គិសនីសេសានក្រោម២ទេ ដូច្នេះលក្ខខណ្ឌតម្រូវ E&S របស់ IFC មិនអនុវត្តចំពោះគម្រោងវារីអគ្គិសនីនេះទេ។ IFC អះអាងដូច្នេះ ដោយសំអាងលើហេតុផលថា ការវិនិយោគរបស់ធនាគារ ABBank នៅក្នុង EVNI បានកើតឡើងមុនការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ក្នុងឆ្នាំ២០១០។

ABBank មិនបានធ្វើការឆ្លើយតបជាផ្លូវការចំពោះពាក្យបណ្តឹងទាំងនោះ ដែលជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យភាពអនុលោម របស់ស៊ីអេអូ នោះទេ។ លើសពីនេះ ស៊ីអេអូ បានព្យាយាមជាច្រើនលើកច្រើនសារ ដើម្បីទាក់ទងទៅ EVNI និងក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ និងដើម្បីទទួលបានឯកសារគម្រោង រួមទាំងតាមរយៈធនាគារ ABBank ប៉ុន្តែការប៉ុនប៉ងទាំងនេះមិនបានជោគជ័យឡើយ។

## គំហើញរបស់ស៊ីអេអូ

ស៊ីអេអូ រកឃើញថា IFC មិនបានធ្វើការត្រួតពិនិត្យបរិស្ថាន និងសង្គម (ESDD) ឱ្យបានគ្រប់គ្រាន់ទេ មុនពេលធ្វើការវិនិយោគនៅក្នុងធនាគារ ABBank ហើយក្នុងអំឡុងពេលត្រួតពិនិត្យ IFC មិនបានត្រួតពិនិត្យតាមដានការប្តេជ្ញាចិត្ត E&S ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួន ជាមួយ ABBank ដូចដែលបានតម្រូវនៅក្នុងគោលនយោបាយស្តីពីនិរន្តរភាពឡើយ។

ពាក់ព័ន្ធនឹងអំណះអំណាងរបស់ IFC ដែលលើកឡើងថា មិនមានទំនាក់ទំនងរវាងការវិនិយោគរបស់ IFC នៅក្នុងធនគារ ABBank និង LS2 ស៊ីអេអូ បានរកឃើញថា ការប្តេជ្ញាចិត្ត E&S នៅក្នុងផែនការប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន (SEMS Plan) ដែលបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ រវាង IFC និង ABBank បញ្ជាក់ថា អតិថិជននឹងធានានូវភាពអនុលោម នៃ "គ្រប់ឥណទាន និងការវិនិយោគដែលមានស្រាប់ទាំងអស់" ស្របតាមស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦ (PS) ។ ភាគហ៊ុនរបស់ ABBank នៅក្នុង EVNI គឺជា "ការវិនិយោគដែលមានស្រាប់" ។ ដោយអនុវត្តតាមគោលនយោបាយនិរន្តរភាព IFC មានកាតព្វកិច្ចតាមដានត្រួតពិនិត្យការប្តេជ្ញាចិត្ត E&S របស់អតិថិជន ដូចដែលបានបង្ហាញនៅក្នុងផែនការសកម្មភាព ដែលត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់នេះ។

### ការត្រួតពិនិត្យ (Due Diligence)

**ស៊ីអេអូ រកឃើញថា IFC មិនបានអនុវត្ត ESDD ឱ្យបានគ្រប់គ្រាន់ មុនពេលការវិនិយោគរបស់ខ្លួននៅក្នុង ABBank ទៅតាមលក្ខខណ្ឌតម្រូវ នៅក្នុងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ របស់ IFC (កថាខណ្ឌ ២៨) ។**

ឯកសារនានារបស់គម្រោង បង្ហាញថា IFC បានដឹងថា ABBank បានចូលរួមនៅក្នុងគម្រោងវារីអគ្គិសនី ដែលមានផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គម (E&S) ។ ទោះជាយ៉ាងនេះក្តី IFC មិនបានពិនិត្យមើលផលប័ត្ររបស់អន្តរការីហិរញ្ញវត្ថុ (FI) សម្រាប់ហានិភ័យ E&S តាមរយៈនីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម (ESRP) ស្របតាមលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងគោលនយោបាយនិរន្តរភាព នោះទេ។ ជាក់ស្តែង IFC មិនបានកំណត់សកម្មភាពអាជីវកម្មរបស់ ABBank ជាមួយនឹងផលប៉ះពាល់ E&S ដែលមានសក្តានុពល និងលក្ខខណ្ឌតម្រូវអនុវត្តការងារសមស្របរបស់ពួកគេទេ ហើយក៏មិនបានពិនិត្យមើលផងដែរ ថាតើអនុគម្រោងរបស់ ABBank បំពេញតាមលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធ នៃស្តង់ដារសមិទ្ធិកម្មរបស់ IFC បន្ថែមលើច្បាប់ និងបទប្បញ្ញត្តិជាតិនានាដែលពាក់ព័ន្ធ ដែរឬទេ។

ការខកខាននេះ បង្កើតបានជាចន្លោះប្រហោងដ៏ចម្បងមួយនៅក្នុងការត្រួតពិនិត្យរបស់ IFC។ ជាលទ្ធផល គណៈ

គ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់ IFC បានយល់ព្រមលើការវិនិយោគ ដោយមិនបានយល់ដឹងអំពីហានិភ័យ E&S នៅក្នុងផលប័ត្រអតិថិជនអនាគតរបស់ខ្លួន រួមទាំងនៅក្នុងការវិនិយោគវារីអគ្គិសនីដូចជា LS2។ លើសពីនេះ ស្របពេលដែលគណៈគ្រប់គ្រងរបស់ IFC បានជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលថា ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ E&S របស់ ABBank មាន "ចំណុចកែលម្អ" នោះ IFC មិនមានមូលដ្ឋានពិតប្រាកដ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌ E&S របស់អតិថិជននោះទេ ដោយសារតែអតិថិជន មិនមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) គោលនយោបាយ E&S ឬមានបុគ្គលិក E&S រហូតដល់ក្រោយការវិនិយោគរបស់ IFC ហើយ IFC មិនបានយល់ដឹងអំពីហានិភ័យ E&S របស់ផលប័ត្រ ដែលចាំបាច់ដើម្បីកែលម្អ ESMS របស់អតិថិជន នោះទេ។

ជាងនេះទៅទៀត នៅរយៈពេលនៃការវិនិយោគរបស់ IFC នៅក្នុង ABBank ក្រុមធនាគារពិភពលោក កំពុងស្វែងរកដំណោះស្រាយហានិភ័យនៃគម្រោងវារីអគ្គិសនី ជាពិសេសគម្រោងដែលពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីធំៗ។ នៅក្នុងបរិបទនេះ IFC គួរតែបានពង្រឹងការត្រួតពិនិត្យរបស់ខ្លួន ដើម្បីកំណត់ហានិភ័យ E&S របស់ធនាគារអតិថិជនដែលខ្លួនបានដឹង៖ (ក) មានការវិនិយោគវារីអគ្គិសនី (ខ) មិនដែលមាន ESMS ឬមន្ត្រី E&S ទេ និង (គ) មិនមានបទពិសោធន៍ក្នុងការពិនិត្យមើលហានិភ័យ E&S នៃការវិនិយោគហិរញ្ញវត្ថុរបស់ខ្លួន។

ដោយផ្អែកលើបរិបទដែលបង្កើតការវិនិយោគនេះ និងផ្អែកលើកង្វះខាតបទពិសោធន៍ និងសមត្ថភាព E&S ដែលបានរាយការណ៍របស់ ABBank ការពិនិត្យឡើងវិញមុនការវិនិយោគរបស់ IFC អាចក្លាយជាឱកាសមួយសម្រាប់ IFC ធ្វើការកំណត់ការចូលរួមរបស់ ABBank នៅក្នុងគម្រោង LS2 និងអាចបង្កើនការការពារ E&S របស់អនុគម្រោងនេះ ខណៈដែលអតិថិជន គឺជាអ្នកផ្តល់ហិរញ្ញប្បទានដ៏សំខាន់មួយរបស់គម្រោង LS2 ។ ការកែលម្អ អាចធ្វើឡើងទៅលើបញ្ហាពាក់ព័ន្ធមួយចំនួន រួមមាន ការចូលរួមពីភាគីពាក់ព័ន្ធ យន្តការបណ្តឹងសារទុក្ខ ការដោះស្រាយផលប៉ះពាល់ដោយស្ម័គ្រចិត្ត ការវាយតម្លៃផលប៉ះពាល់ជីវចម្រុះ និងផលប៉ះពាល់បង្គរ ព្រមទាំងផលប៉ះពាល់លើប្រជាជន និងជនជាតិដើមភាគតិចដែលងាយរងគ្រោះ ។

## ការត្រួតពិនិត្យលើការអនុវត្ត (supervision)

**ស៊ីអេអូ រកឃើញថា IFC មិនបានតាមដានត្រួតពិនិត្យការប្តេជ្ញាចិត្តអនុវត្ត E&S នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួនជាមួយធនាគារ ABBank ដូចតាមលក្ខខណ្ឌតម្រូវមានចែងនៅក្នុងគោលនយោបាយនិរន្តរភាព (SP ឆ្នាំ ២០០៦, កថាខណ្ឌ ២៦; SP ឆ្នាំ២០១២, កថាខណ្ឌ ២៤) នោះទេ។**

កិច្ចព្រមព្រៀងផ្លូវច្បាប់របស់ IFC និង ABBank រួមបញ្ចូលផែនការសកម្មភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន (ហៅថាផែនការ SEMS) ដែលក្នុងនោះ អតិថិជននឹងធានានូវភាពអនុលោម នៃឥណទាន និងការវិនិយោគដែលមានស្រាប់របស់ខ្លួន ស្របតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC រួមទាំងស្តង់ដារសមិទ្ធិកម្ម (PS) ផងដែរ។ ទោះជាយ៉ាងនេះក្តី ក្នុងអំឡុងពេលត្រួតពិនិត្យ IFC មិនបានតម្រូវឱ្យ ABBank អនុវត្ត PS ទៅក្នុងការវិនិយោគដែលមានស្រាប់របស់ខ្លួន រួមទាំង EVNI និង LS2 ឡើយ។ ពេញមួយវដ្តនៃការវិនិយោគនេះ IFC មិនបានធ្វើការតាមដានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់ទៅលើការអនុវត្ត E&S របស់អតិថិជនខ្លួន ដូចទៅនឹងការប្តេជ្ញាចិត្តក្នុង

ផែនការ SEMS ដូចខាងក្រោម៖

- ក្នុងឆ្នាំ២០១១ អតិថិជនបានខកខានព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងផែនការ SEMS ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រង E&S ប្រកបដោយប្រសិទ្ធភាព ដែលជាលទ្ធផលធ្វើឱ្យ IFC ខកខានការអនុវត្តសកម្មភាពត្រួតពិនិត្យនានា នៅឆ្នាំនោះ។
- នៅចន្លោះរវាងឆ្នាំ២០១១ ដល់ ២០១៦ ការត្រួតពិនិត្យរបស់ IFC មិនបានត្រួតពិនិត្យឡើងវិញប្រកបដោយប្រសិទ្ធភាពនូវការត្រួតពិនិត្យ E&S របស់ធនាគារ ABBank សម្រាប់ការវិនិយោគរបស់ខ្លួន នៅក្នុងវិស័យដែលមានហានិភ័យខ្ពស់។ កង្វះការត្រួតពិនិត្យនេះ បានរួមចំណែកដល់ការបរាជ័យរបស់អតិថិជនក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រង E&S ដែលមានសមត្ថភាពធានាភាពអនុលោមតាម PS សម្រាប់គម្រោងដែលមានហានិភ័យខ្ពស់ ស្របតាមលក្ខខណ្ឌតម្រូវរបស់គោលនយោបាយនិរន្តរភាព។
- រហូតមកដល់ឆ្នាំ ២០១៧ IFC មិនបានពិនិត្យឱ្យបានហ្មត់ចត់នូវព័ត៌មាន E&S ដែលដាក់ជូនដោយ ABBank ទេ ដូច្នេះហើយ មិនបានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់លើការអនុវត្ត E&S និងការអនុវត្ត PS របស់អតិថិជន នៅក្នុងអនុគម្រោងរបស់ខ្លួនឡើយ។ IFC មិនបានចាត់វិធានការភ្លាមៗ នៅពេលដឹងថា ABBank កំពុងចាត់ថ្នាក់គម្រោងវារីអគ្គិសនីធំៗ ជាការវិនិយោគដោយគ្មានហានិភ័យ E&S ដោយអនុវត្តតែបទប្បញ្ញត្តិ E&S ថ្នាក់ជាតិ និងប្រើប្រាស់ស្តង់ដារសមិទ្ធិកម្ម គ្រាន់តែជាអនុសាសន៍ប៉ុណ្ណោះ។ បញ្ហាដ៏រាំរ៉ៃនេះ គឺជាហេតុផលសំខាន់មួយ សម្រាប់ IFC បន្ទាបការអនុវត្ត E&S របស់ FI ក្នុងឆ្នាំ២០២០ ប្រាំបួនឆ្នាំបន្ទាប់ពីបានដឹងជាលើកដំបូងអំពីកង្វះខាតនានានៃផែនការ SEMS។
- ក្នុងឆ្នាំ២០១៧ IFC បានរកឃើញជាលើកដំបូងថា ផលប័ត្ររបស់ ABBank បានរួមបញ្ចូលឥណទានដល់វិស័យដែលមានហានិភ័យខ្ពស់ ដូចជាគម្រោងវារីអគ្គិសនី និងបានរកឃើញទៀតថា SEMS របស់ ABBank គឺមិនគ្រប់គ្រាន់ក្នុងការគ្រប់គ្រងបញ្ហាទាំងនោះទេ។ ចាប់ពីពេលនោះ រហូតដល់ឆ្នាំ២០២៤ IFC បន្តលើកទឹកចិត្តអតិថិជនឱ្យត្រលប់មករកភាពអនុលោមវិញ។ ទោះជាយ៉ាងនេះក្តី IFC បានបរាជ័យក្នុងការប្រើប្រាស់អានុភាព និងឥទ្ធិពលរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ក្នុងនាមជាម្ចាស់ភាគហ៊ុនមួយ ដើម្បីធានាបាននូវភាពអនុលោម ដោយមិនបានកំណត់លក្ខខណ្ឌតម្រូវ E&S សំខាន់ៗ ដូចជាការអនុវត្ត SEMS រហូតដល់ការប្តេជ្ញាចិត្ត ឬការទូទាត់ចំណាយ និងការមិនប្រើប្រាស់ឧបករណ៍ ឬវិធីសាស្ត្រមានឥទ្ធិពលផ្សេងទៀត ទៅលើអតិថិជន ដូចជាកិច្ចប្រជុំម្ចាស់ភាគហ៊ុន ឬការផ្តល់អាទិភាពលើបញ្ហា E&S ក្នុងការតែងតាំងក្រុមប្រឹក្សាភិបាល ដើម្បីបង្កើនការយល់ដឹងអំពីចំណុចខ្វះខាតរបស់ធនាគារ ABBank ទៅលើភាពអនុលោម E&S ។
- ជាចុងក្រោយ ខណៈដែលការត្រួតពិនិត្យរបស់ IFC មានភាពប្រសើរឡើងបន្ទាប់ពីឆ្នាំ២០១៧ IFC បានបន្តបង្រួមការយកចិត្តទុកដាក់ត្រួតពិនិត្យផែនការ SEMS របស់ខ្លួន ទៅលើការអនុវត្ត និងការជ្រើសរើសបុគ្គលិក E&S និងមិនបានតម្រូវឱ្យ ABBank អនុលោមតាមការប្តេជ្ញាចិត្តនានាដែលមានពេលវេលាកំណត់របស់ផែនការ ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព និង ESRP ឡើយ។

ដោយសារតែបណ្តាចំណុចដូចបានបង្ហាញខាងលើ IFC ក្នុងអំឡុងពេលនៃត្រួតពិនិត្យរបស់ខ្លួន មិនពេញចិត្តចំពោះការតាមដានត្រួតពិនិត្យទៅលើ EVNI របស់ ABBank ហើយជាលទ្ធផល គម្រោងអនុគម្រោងសេសានក្រោម២ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ ឡើយ។

សុីអេអូ រកឃើញថា ការត្រួតពិនិត្យមិនគ្រប់គ្រាន់របស់ IFC នាំឱ្យខកខានឱកាសដែលនឹងជះឥទ្ធិពលជាវិជ្ជមានទៅលើការរចនា ការធ្វើផែនការ ការសាងសង់ និងការអនុវត្តរបស់គម្រោង LS2 ដូចជា៖

- ចន្លោះឆ្នាំ ២០១១ ដល់ ២០១២ នៅពេលដែល EVNI គឺជាម្ចាស់ភាគហ៊ុនធំជាងគេ និងជាអ្នកអភិវឌ្ឍគម្រោង LS2 ពេលនោះ IFC និង ABBank មានឱកាសកែសម្រួលការរចនារោងចក្រវារីអគ្គិសនី និងការធ្វើផែនការដំបូង ឱ្យស្របតាមលក្ខខណ្ឌតម្រូវ PS ។ ផ្ទុយទៅវិញ មិនមានការចាត់វិធានការណាមួយដើម្បីដោះស្រាយចំណុចខ្វះខាតនៃគោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ ឆ្នាំ ២០១១ របស់ EVNI ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវរបស់ PS១ (ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃសង្គម និងបរិស្ថាន) និង PS៥ (លទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត)។ ចំណុចខ្វះខាតទាំងនេះនៅតែមិនទាន់ដោះស្រាយបាននៅឡើយ។
- ក្រោយពី EVNI បានក្លាយជាម្ចាស់ភាគហ៊ុនតូច នៅក្នុងគម្រោង LS2 ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ការតម្រូវឱ្យអនុវត្ត PS កាន់តែមានភាពប្រឈម។ ទោះបីជាយ៉ាងនេះក្តី តាមរយៈតំណែងជាបន្តរបស់ EVNI នៅក្នុងក្រុមប្រឹក្សាប្រតិបត្តិការរបស់ក្រុមហ៊ុន IFC នៅតែមានឱកាសខ្លះដើម្បីមានឥទ្ធិពលជាវិជ្ជមានទៅលើការធ្វើផែនការ ការសាងសង់ និងការអនុវត្តគម្រោង LS2 ។ ការមិនផ្តល់ហិរញ្ញប្បទានបន្ថែមរបស់IFC និងគោលបំណងមួយក្នុងចំណោមគោលបំណងចម្បងៗនៃការត្រួតពិនិត្យ E&S របស់ IFC គឺច្បាស់លាស់ណាស់សម្រាប់ IFC ផ្តល់ការណែនាំ និងដំបូន្មានដល់អតិថិជនអំពីរបៀបដោះស្រាយបញ្ហាហានិភ័យ E&S និងកំណត់ឱកាសកែលម្អ និងឱកាសអនុវត្តល្អៗ ដែលអាចត្រូវបានអនុវត្តចំពោះគម្រោងស្រដៀងគ្នានេះ។ ទោះយ៉ាងណាក៏ដោយ សុីអេអូ បានរកឃើញភស្តុតាងតិចតួចប៉ុណ្ណោះ ដែលបង្ហាញថា IFC បានណែនាំ ឬផ្តល់ការណែនាំដល់ ABBank ឬ EVNI លើការអនុវត្តតាមលក្ខខណ្ឌតម្រូវ PS ក្នុងអំឡុងពេលនេះ។

## គ្រោះថ្នាក់ដែលពាក់ព័ន្ធ

គោលនយោបាយរបស់សុីអេអូ តម្រូវឱ្យរបាយការណ៍សើុបអង្កេតភាពអនុលោម ដាក់បញ្ចូលការរកឃើញស្តីពីគ្រោះថ្នាក់ដល់សហគមន៍ដែលរងផលប៉ះពាល់គម្រោងទាក់ទងនឹងភាពមិនអនុលោម។ សុីអេអូ រកឃើញគ្រោះថ្នាក់ចំពោះដើមបណ្តឹង ពាក់ព័ន្ធនឹងភាពមិនអនុលោមរបស់ IFC អំឡុងពេលនៃការត្រួតពិនិត្យ និងការពិនិត្យលើការប្តេជ្ញាចិត្តផ្លូវច្បាប់របស់ ABBank ក្នុងការអនុវត្តផែនការ SEMS របស់ខ្លួន និងស្តង់ដារសមិទ្ធិកម្ម ចំពោះការវិនិយោគដែលមានស្រាប់ នៅក្នុង EVNI និងអនុគម្រោងសេសានក្រោម២។ ដូចដែលបានរៀបរាប់ខាងលើ IFC

បានខកខានឱកាសដើម្បីបញ្ចៀស កាត់បន្ថយ និង/ឬដោះស្រាយគ្រោះថ្នាក់ដែលសហគមន៍បានជួបប្រទះ ដោយសារអនុគម្រោង ដែលបានបង្កើតឡើងគ្មានការកំណត់អត្តសញ្ញាណត្រឹមត្រូវ និងការកាត់បន្ថយហានិភ័យ E&S និងផលប៉ះនានាទៅលើប្រជាពលរដ្ឋរងផលប៉ះពាល់។

យោងតាមបណ្តឹងរបស់ក្រុមដើមបណ្តឹងនីមួយៗ ស៊ីអេអូ រកឃើញថា៖

1. អ្នកភូមិដែលបដិសេធការតាំងលំនៅថ្មី បានរងគ្រោះដោយសារការខ្វះការពិចារណាអំពីបំណងរបស់ពួកគេចង់តាំងទីលំនៅថ្មីនៅក្នុងដីប្រពៃណីរបស់ខ្លួន ឬទស្សនៈរបស់ខ្លួនទៅលើជម្រើសជំនួស ចំពោះគម្រោង LS2 ដោយសារការបាត់បង់ទឹកដីដ៏ពិសិដ្ឋ និងជារបស់ដូនតា និងពិធីសាសនាសំខាន់ៗដែលផ្សារភ្ជាប់ជាមួយពួកគេ ដោយសារកង្វះការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ព្រោះភាគច្រើនគឺជាជនជាតិដើមភាគតិច ដោយសារគ្មានសំណងសម្រាប់ការផ្លាស់ទីលំនៅរូបវ័ន្ត និងសេដ្ឋកិច្ច ព្រមទាំងដោយសារការបំភិតបំភ័យ និងការសងសឹក ក្នុងអំឡុងឆ្នាំ ២០១៧-២០១៨ នៅពេលដែលការសាងសង់ទំនប់នេះត្រូវបានបញ្ចប់ និងដំណើរការបានចាប់ផ្តើម។ បច្ចុប្បន្ន ការរស់នៅលើទឹកដីប្រពៃណី សហគមន៍ទាំងនេះនៅតែបន្តខ្វះសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។

2. អ្នកភូមិដែលបានតាំងលំនៅថ្មី បានរងគ្រោះ ដោយសារតែកញ្ចប់ដោះស្រាយផលប៉ះពាល់ មិនផ្អែកលើសារពើភ័ណ្ឌទ្រព្យសកម្ម និងការអង្កេតសេដ្ឋកិច្ចសង្គមគ្រប់ជ្រុងជ្រោយ អំពីទ្រព្យសម្បត្តិមុនពេលផ្លាស់ទីលំនៅ ជាហេតុធ្វើឱ្យសំណងរបស់ពួកគេមិនគ្រប់គ្រាន់។ ពួកគេមិនអាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការធ្វើការសម្រេចចិត្តតាំងលំនៅថ្មី ដោយរួមទាំងជនជាតិដើមភាគតិចពួង ពីក្បាលរមាសចាស់ ហើយបានជួបប្រទះបញ្ហាជាបន្តបន្ទាប់ជាមួយប្លង់ ហេដ្ឋារចនាសម្ព័ន្ធ និងគុណភាពរបស់ទីកន្លែងតាំងទីលំនៅថ្មី ដែលនៅតែមិនទាន់ដោះស្រាយ។ គម្រោងនេះ ខ្វះយន្តការបណ្តឹងសារទុក្ខ ដែលធ្វើឱ្យសមត្ថភាពរបស់ពួកគេមានកម្រិត ក្នុងការលើកបញ្ហាទាំងនេះជាមួយប្រតិបត្តិករទំនប់។ សហគមន៍ដែលតាំងលំនៅថ្មី មានទីតាំងជាច្រើនគីឡូម៉ែត្រពីទន្លេ ដែលកម្រិតសកម្មភាពនេសាទ ហើយដីកសិកម្មថ្មីដែលពួកគេទទួលបានមិនមានជីវជាតិដូចដីពីមុនរបស់ពួកគេឡើយ។ ដើម្បីប៉ះប៉ូវដល់ការថយចុះនៃទិន្នផលនេសាទ និងទិន្នផលកសិកម្ម បច្ចុប្បន្ន ពួកគេទិញរបស់របរជាច្រើនដែលពួកគេធ្លាប់នេសាទបាន ឬធ្វើស្រែចំការបាន ព្រមទាំងត្រូវទិញទឹកផងដែរ។ ពួកគេមិនបានទទួលជំនួយស្តារជីវភាពរស់នៅ ដើម្បីធ្វើការស្តារជីវភាពរបស់ពួកគេឡើងវិញឱ្យដល់កម្រិតមុនពេលមានគម្រោងទេ។

3. ភាគច្រើននៃអ្នកភូមិរស់នៅខ្សែទឹកខាងលើ មិនធ្លាប់បានទទួលការប្រឹក្សាយោបល់ពីគម្រោងនេះទេ (មានតែបីភូមិប៉ុណ្ណោះក្នុងចំណោមភូមិខ្សែទឹកខាងលើ ចំនួន១៨ភូមិ របស់ដើមបណ្តឹង បានទទួលការប្រឹក្សាយោបល់អំពីដំណើរការ EIA)។ ពួកគេបានជួបប្រទះផលប៉ះពាល់អវិជ្ជមានចំពោះជីវភាពរស់នៅ ដោយសារតែការធ្លាក់ចុះនៃបរិមាណត្រីផ្លាស់ទី និងការប្រែប្រួលលំហូរទឹកទន្លេ ដែលបង្ខំឱ្យពួកគេទិញអាហារ និងទឹក នៅលើទីផ្សារ។ ពួកគេមិនបានទទួលសំណងសម្រាប់ផលប៉ះពាល់ទាំងនេះ ឬការទទួលស្គាល់ថាពួកគេជាអ្នកទទួលរងផលប៉ះពាល់ពីគម្រោងនេះទេ។

## មូលហេតុឫសគល់នៃភាពមិនអនុលោម

ស៊ីអេអូ រកឃើញថាមានមូលហេតុឫសគល់មួយចំនួន ដែលនាំឱ្យ IFC ខ្វះភាពអនុលោម នៅក្នុងករណីនេះ៖

1. IFC ខ្វះការយល់ដឹងអំពីទំនាក់ទំនងផលប័ត្ររបស់ FI ទៅនឹងហានិភ័យ E&S នៅពេលដែលខ្លួន បានអនុម័តការវិនិយោគនេះ ដោយធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ IFC ក្នុងការធានានូវភាពគ្រប់គ្រាន់នៃ ESMS របស់ ABBank ក្នុងការផ្ដល់ការគាំទ្រដែលត្រូវការ ដល់អតិថិជនមានបទពិសោធន៍ និងសមត្ថភាពពីមុនតិចតួច ដើម្បីបង្កើត ESMS ដែលមានសមត្ថភាពគ្រប់គ្រងគម្រោងមានហានិភ័យខ្ពស់ ស្របតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC ។
2. IFC បានបរាជ័យក្នុងការត្រួតពិនិត្យការប្ដេជ្ញាចិត្តអនុវត្ត E&S ដែលបានបង្កើតឡើងនៅក្នុងកិច្ចសន្យារបស់ខ្លួនជាមួយធនាគារ ABBank ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព។ ការត្រួតពិនិត្យតាមដានត្រឹមត្រូវនៃការប្ដេជ្ញាចិត្តអនុវត្ត E&S ទាំងនេះ នឹងផ្ដល់ឱកាសឱ្យ IFC ដោះស្រាយចំណុចខ្វះខាត E&S ចម្បងៗ នៅក្នុងអនុគម្រោងសេសានក្រោម២ និងផ្ដល់ព័ត៌មានសំខាន់ៗអំពីសក្ដានុពល E&S និងហានិភ័យកេរ្តិ៍ឈ្មោះរបស់ធនាគារដែលខ្លួនមានភាគហ៊ុន អស់រយៈពេលជាង ១០ ឆ្នាំ។
3. ក្នុងអំឡុងពេលនៃការរៀបចំរចនាសម្ព័ន្ធ និងការត្រួតពិនិត្យលើការវិនិយោគ IFC បានបរាជ័យក្នុងការពិចារណាឱ្យបានគ្រប់គ្រាន់ និងប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដើម្បីធានានូវភាពអនុលោមរបស់អតិថិជនជាមួយនឹងការប្ដេជ្ញាចិត្តអនុវត្ត E&S ។ IFC មិនបានរៀបចំរចនាសម្ព័ន្ធនៃការវិនិយោគដើម្បីបង្កើតលក្ខខណ្ឌតម្រូវ E&S សំខាន់ៗ ដែលជាលក្ខខណ្ឌនៃការប្ដេជ្ញាចិត្ត ឬការទូទាត់ចំណាយទេ លើកលែងតែការតែងតាំងមន្ត្រី SEMS ប៉ុណ្ណោះ ហើយក៏មិនបានប្រើប្រាស់ឧបករណ៍មានឥទ្ធិពលផ្សេងទៀតទៅលើអតិថិជន ក្នុងអំឡុងពេលនៃការត្រួតពិនិត្យ ក្រៅតែពីការលើកទឹកចិត្តអតិថិជន ឱ្យអនុលោមតាមសកម្មភាពត្រួតពិនិត្យតាមដានជាប្រចាំរបស់ខ្លួន។ ការមិនបានប្រើប្រាស់អានុភាពឱ្យបានគ្រប់គ្រាន់ បានប៉ះពាល់ដល់សមត្ថភាពរបស់ IFC ក្នុងការធ្វើឱ្យមានការផ្លាស់ប្ដូរការអនុវត្តរបស់អតិថិជនរបស់ខ្លួន និងបានបន្ថយលទ្ធភាពរបស់ IFC ក្នុងការអនុលោមតាមកាតព្វកិច្ចគោលនយោបាយនិរន្តរភាពរបស់ខ្លួនចំពោះតែសកម្មភាពហិរញ្ញប្បទានទាំងឡាយណា ដែលរំពឹងថានឹងបំពេញតាមលក្ខខណ្ឌតម្រូវរបស់ PS ក្នុងរយៈពេលសមស្របណាមួយប៉ុណ្ណោះ។
4. អតិថិជនមិនធ្លាប់ទទួលបានការយល់ដឹងទូលំទូលាយអំពីលក្ខខណ្ឌតម្រូវ E&S របស់ IFC នោះទេ។ យ៉ាងណាក៏ដោយ អភិក្រមរបស់ IFC ចំពោះការគ្រប់គ្រងហានិភ័យ E&S នៃការវិនិយោគ FI របស់ខ្លួនគឺស្ថិតនៅលើសមត្ថភាពរបស់អតិថិជនក្នុងការគ្រប់គ្រងហានិភ័យ E&S នៃឥណទាន និងការវិនិយោគរបស់ខ្លួន។ IFC គួរពិចារណាដោយប្រុងប្រយ័ត្នលើការអនុម័តការវិនិយោគដែលមានគោលបំណងទូទៅដូចជាការវិនិយោគភាគហ៊ុននៅក្នុង FIs ដែលមានផលប័ត្រហានិភ័យមធ្យម ឬខ្ពស់ ជាមួយនឹងសមត្ថភាពគ្រប់គ្រងហានិភ័យ E&S តិចតួចបំផុត។ បើមិនដូច្នេះទេ IFC ប្រឈមហានិភ័យធ្វើឱ្យប្រជាពលរដ្ឋរងផលប៉ះពាល់ដោយសារអនុគម្រោង ជួបប្រទះផលប៉ះពាល់ E&S ដែលមិនមានការវាយតម្លៃ និងគ្មានការ

កាត់បន្ថយផលប៉ះពាល់ ហើយធ្វើឱ្យ IFC ប្រឈមហានិភ័យនៃការរួមចំណែកបង្គ្រោះថ្នាក់ នៅកម្រិតអនុគម្រោង ផងដែរ។

## អនុសាសន៍របស់ស៊ីអេអូ ជូន IFC

ដោយបានពិចារណាទៅលើគំហើញខាងលើ ស៊ីអេអូ សូមផ្តល់ជាអនុសាសន៍ជូន IFC ឱ្យចាត់វិធានការទាំងនៅកម្រិតគម្រោង និងកម្រិតស្ថាប័ន ដូចខាងក្រោម៖

## អនុសាសន៍កម្រិតគម្រោង

នៅក្នុងគោលនយោបាយស៊ីអេអូ (កថាខណ្ឌ ១២០) ក្នុងករណីដែល IFC បានចាកចេញពីការវិនិយោគ "អនុសាសន៍នឹងពិចារណាទៅលើផលបច្ច័យ នៃការចាកចេញរបស់ IFC/MIGA Exit។" ដោយសារតែការចាកចេញរបស់ IFC ពីការវិនិយោគរបស់ខ្លួនជាមួយធនាគារ ABBank នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ អនុសាសន៍កម្រិតគម្រោងរបស់ ស៊ីអេអូ មានតិចតួចប៉ុណ្ណោះ និងស្នើឱ្យ IFC ចូលរួមជាមួយភាគីពាក់ព័ន្ធក្នុងស្រុកជាច្រើន ដើម្បីស្វែងយល់ពីរបៀបដែលខ្លួនអាចរួមចំណែកដល់ការស្នើឡើងនូវសកម្មភាពដំណោះស្រាយនានា។ ទន្ទឹមនឹងនេះ ស៊ីអេអូ កត់សម្គាល់ថា IFC បានតាំងចិត្តថា ការចាកចេញរបស់ខ្លួនពី ABBank នឹងមិនមានឥទ្ធិពលអាក្រក់ទៅលើសំណុំរឿងស៊ីអេអូ នោះទេ ពីព្រោះ EVNI និង LS2 មិនមែនជាកម្មវត្ថុនៃលក្ខខណ្ឌតម្រូវ E&S របស់ IFC ដោយមិនបានពិចារណាលើការប្តេជ្ញាចិត្តអនុវត្ត E&S នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ ដែលពង្រីកការអនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC ទៅលើការវិនិយោគដែលមានស្រាប់ នៅពេលកិច្ចសន្យាត្រូវបានចុះហត្ថលេខា។ ការមិនពិចារណាលើកាតព្វកិច្ចនេះ នៅពេលសម្រេចចិត្តចាកចេញពីការវិនិយោគនៅក្នុងធនាគារ ABBank គឺមិនមានសង្គតិភាពទៅនឹងការចាកចេញប្រកបដោយការទទួលខុសត្រូវ នោះទេ។

ស៊ីអេអូ ក៏កត់សម្គាល់ផងដែរថា ក្នុងសំណុំរឿងនេះ ដោយសារតែ IFC គឺជាម្ចាស់ភាគហ៊ុននៅក្នុង ABBank អស់រយៈពេលជាង ១០ ឆ្នាំមកហើយ IFC បានទទួលអត្ថប្រយោជន៍ដោយប្រយោលពីប្រាក់ចំណូលនៃទំនប់ LS2 ។ EVNI គឺជាការវិនិយោគដ៏ជោគជ័យរបស់ ABBank ដែលបានផ្តល់ភាគលាភដល់ ABBank ពីប្រាក់ចំណេញដែលភាគច្រើនបានមកពីគម្រោង LS2 ។ IFC គួរតែយកចំណុចនេះមកពិចារណា នៅពេលសម្រេចចិត្តលើវិធានការដោះស្រាយ រួមជាមួយនឹងអាណត្តិអភិវឌ្ឍន៍ដ៏ទូលំទូលាយរបស់ខ្លួន។

ស៊ីអេអូ ទទួលស្គាល់ថា សំណុំរឿងនេះបង្ហាញពីបណ្តុំនៃកាលៈទេសៈដែលមានលក្ខណៈពិសេស និងស្មុគស្មាញមួយ។ ទោះជាយ៉ាងណាក៏ដោយ ស៊ីអេអូ ចាត់ទុកថាភាពមិនអនុលោមរបស់ IFC និងការខូចខាតពាក់ព័ន្ធ ដែលសហគមន៍បានជួបប្រទះ ដោយសារអនុគម្រោង LS2 សមនឹងទទួលបានកិច្ចខិតខំប្រឹងប្រែងពិតប្រាកដ ជាចំណែកមួយ របស់ IFC ក្នុងការស្វែងរក និងទាក់ទងភាគីពាក់ព័ន្ធជាច្រើន រួមទាំងសហគមន៍រងផលប៉ះពាល់ដើម្បីរួមចំណែកដល់ការដោះស្រាយ នៅកម្រិតអនុគម្រោង។ អនុសាសន៍របស់ស៊ីអេអូ ត្រូវបានរៀបចំឡើងដោយគិតគូរពីការរឹតត្បិតរបស់ IFC ខណៈដែលនៅតែយកចិត្តទុកដាក់ទៅលើការពិចារណានានាដែលបានលើក

ឡើងពីពេលមុន ព្រមទាំងទៅលើសំណើ និងមិតយោបល់របស់ដើមបណ្តឹង ផងដែរ។

1. ស្វែងយល់ជាមួយធនាគារអន្តរជាតិសម្រាប់កសាងឡើងវិញ និងអភិវឌ្ឍ (IBRD) នូវលទ្ធភាពដាក់បញ្ចូលសហគមន៍ក្បាលរមាសចាស់ទៅក្នុងគម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន III (LASED III) ដែលមានធាតុផ្សំប័ណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច (ICLT) ដើម្បីជួយសហគមន៍ក្នុងការបំពេញ និងទទួលបាន ICLT របស់ពួកគេ ដោយមានការយល់ព្រម ពី IFC។
2. តាមរយៈ ABBank EVNI ឬតាមរយៈការទាក់ទងគម្រោង LS2 ទំនាក់ទំនងម្ចាស់ភាគហ៊ុនរបស់ពួកគេ ឬភាគីពាក់ព័ន្ធក្នុងតំបន់ផ្សេងទៀតដោយផ្ទាល់ ផ្តល់ជំនួយសម្រាប់បង្កើតយន្តការបណ្តឹងសារទុក្ខ ដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ អនុលោមតាមលក្ខខណ្ឌតម្រូវ PS១ និង PS៥ ហើយនឹងអនុញ្ញាតឱ្យសហគមន៍រងផលប៉ះពាល់ ដែលក្នុងនោះរួមទាំងសហគមន៍រស់នៅខ្សែទឹកខាងលើ ផ្ញើសំណួរ កង្វល់ និងសារទុក្ខរបស់ពួកគេ។ តាមរយៈយន្តការនេះ គម្រោងអាចទទួលបាន និងសម្របសម្រួលការដោះស្រាយបណ្តឹងពីសហគមន៍រងផលប៉ះពាល់ និងផ្តល់ព័ត៌មានអំពីវិធានការនានារបស់គម្រោង។
3. តាមរយៈ IBRD ចូលរួមជាមួយអាជ្ញាធររដ្ឋាភិបាលដើម្បីផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រ ដើម្បីធ្វើសវនកម្មបញ្ចប់ដោះស្រាយផលប៉ះពាល់ និងកម្មវិធីស្តារជីវភាពរស់នៅរបស់ LS2 ទៅតាមលក្ខខណ្ឌតម្រូវ PS5 ។ សវនករខាងក្រៅ គប្បីផ្តល់អនុសាសន៍ និងស្នើវិធានការកែតម្រូវ ចំពោះចំណុចខ្វះខាតណាមួយដែលបានរកឃើញ។ វិធានការទាំងនោះ គប្បីត្រូវបានពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ មានការកំណត់ពេលវេលាច្បាស់លាស់ និងប៉ាន់ស្មានចំណាយ ព្រមទាំងរួមបញ្ចូលការកំណត់ប្រភពហិរញ្ញប្បទានសម្រាប់សកម្មភាពទាំងនោះ តាមលទ្ធភាពដែលអាចធ្វើទៅបាន។
4. ស្វែងយល់ជាមួយ IBRD និងភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងអាជ្ញាធររដ្ឋាភិបាល ព្រមទាំងការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ នូវឱកាសបង្កើត និងអនុវត្តផែនការសកម្មភាពជីវចម្រុះសម្រាប់ការស្តារឡើងវិញនូវទីជម្រកតាមដងទន្លេ និងវិធានការកាត់បន្ថយផលប៉ះពាល់គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបនឹងការបាត់បង់ជីវចម្រុះ។ ផែនការនេះ គួររួមបញ្ចូលតាមការចាំបាច់នូវសកម្មភាពផ្តល់សំណងដល់អ្នកប្រើប្រាស់ពីសហគមន៍រងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ដែលជីវភាពរស់នៅរបស់ពួកគេ បានរងផលប៉ះពាល់ដោយសារការបាត់បង់ជីវចម្រុះ ដោយការយកចិត្តទុកដាក់សមស្របទៅលើផលប៉ះពាល់ផ្សេងៗមកលើជនជាតិដើមភាគតិច និងស្ត្រី។

## អនុសាសន៍កម្រិតស្ថាប័ន

ដើម្បីដោះស្រាយមូលហេតុឫសគល់នៃការរកឃើញភាពមិនអនុលោម ស៊ីអេអូ សូមផ្តល់ជាអនុសាសន៍ឱ្យ IFC៖

1. ពង្រឹងសមត្ថភាព និងនីតិវិធី E&S សម្រាប់ការវិនិយោគ FI ដើម្បីធានាបាននូវការយល់ដឹងគ្រប់គ្រាន់អំពីហានិភ័យ E&S និងសមត្ថភាព E&S របស់អតិថិជន ក្នុងអំឡុងពេលត្រួតពិនិត្យ និងការពិនិត្យ

តាមដានដ៏ត្រឹមត្រូវលើការប្តេជ្ញាចិត្តអនុវត្ត E&S ទាំងអស់ ក្នុងអំឡុងពេលត្រួតពិនិត្យការអនុវត្ត។ គប្បីអភិវឌ្ឍសមត្ថភាព ដើម្បីធានាថា IFC មានមន្ត្រីឯកទេសក្នុងការគ្រប់គ្រងហានិភ័យ E&S របស់ FI ជាមួយនឹងការបណ្តុះបណ្តាល ចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធ ដើម្បីពិនិត្យ និងតាមដានការវិនិយោគរបស់ FI ។

2. បង្កើត និងផ្សព្វផ្សាយក្នុងចំណោមបុគ្គលិក E&S នូវសេចក្តីណែនាំលម្អិតស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ត្រួតពិនិត្យ E&S ចំពោះការវិនិយោគមានគោលបំណងទូទៅរបស់អតិថិជន FI ដូចជាការវិនិយោគលើភាគហ៊ុនជាដើម។ សេចក្តីនាំនេះគួរតែរួមបញ្ចូលការណែនាំច្បាស់លាស់អំពីបណ្តាចំណុចខាងក្រោមក្នុងចំណោមការរួមបញ្ចូលផ្សេងទៀត៖

    a. របៀបពិនិត្យមើលគំរូសំណាកតំណាងឱ្យការវិនិយោគ ប្រតិបត្តិការ ផលិតផល និងវិស័យនានាដែលមានហានិភ័យខ្ពស់ នៅក្នុងផលប័ត្ររបស់ FI ក្នុងអំឡុងពេលត្រួតពិនិត្យ ដើម្បីកំណត់សមត្ថភាព E&S ដែលត្រូវការសម្រាប់អតិថិជន និងដើម្បីកំណត់ការចំណាយនៃគម្រោងផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) និងការចំណាយប្រចាំឆ្នាំជាមធ្យមនៃការអនុវត្ត ESMS របស់អតិថិជន។

    b. របៀបវាយតម្លៃបុគ្គលិក E&S ដែលចាំបាច់ក្នុងកម្រិតអប្បបរមា សម្រាប់ FI ដោយផ្អែកលើហានិភ័យ E&S នៃផលប័ត្រ និងចំណូល ព្រមទាំងសមត្ថភាពរបស់ FI ទាក់ទាញការចូលរួមពីបុគ្គលិក E&S ថ្មី។ ក្នុងករណីនេះ និងករណីផ្សេងទៀត ស៊ីអេអូ បានសង្កេតឃើញថា កង្វះខាតសមត្ថភាព E&S របស់អតិថិជន រមែងតែងជាបញ្ហាដែលកើតឡើងដដែលៗ។ IFC គួរបង្កើតឧបករណ៍ និងប៉ារ៉ាម៉ែត្រសម្រាប់បុគ្គលិក E&S របស់ខ្លួន ដើម្បីវាយតម្លៃតម្រូវការបុគ្គលិក E&S របស់អតិថិជនទាក់ទងនឹងផលប័ត្រហានិភ័យ E&S របស់អតិថិជន។

3. ធ្វើការពិនិត្យឡើងវិញនូវផលប័ត្រនៃការវិនិយោគ FI ដែលមានភាគហ៊ុនសកម្មរបស់ IFC ចាប់តាំងពីឆ្នាំ២០០៦ ដោយរួមបញ្ចូលកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ (ESAP ឬចំណុចផ្សេងទៀត) សម្រាប់អតិថិជនដើម្បីអនុវត្ត ESMS របស់ខ្លួន ទៅលើ "ឥណទាន និងការវិនិយោគដែលមានស្រាប់" និងធានាឱ្យមានការតាមដានត្រួតពិនិត្យគ្រប់គ្រាន់ទៅលើការប្តេជ្ញាចិត្តផ្លូវច្បាប់។

4. ធ្វើបច្ចុប្បន្នភាព ESRP របស់ខ្លួនដើម្បីផ្តល់ការណែនាំច្បាស់លាស់បន្ថែមទៀតដល់បុគ្គលិក E&S អំពីរបៀបរៀបចំរចនាសម្ព័ន្ធការវិនិយោគ ដើម្បីប្រើប្រាស់អានុភាពរបស់ IFC ឱ្យបានល្អបំផុត ក្នុងអំឡុងពេលវដ្តនៃការវិនិយោគ ដើម្បីធានាបាននូវភាពអនុលោមរបស់អតិថិជន ទៅតាមលក្ខខណ្ឌតម្រូវ E&S ។ ដូចដែលបានផ្តល់អនុសាសន៍នៅក្នុងសំណុំរឿងមុនៗ ចំណុចនេះគប្បីរួមបញ្ចូលសេចក្តីណែនាំច្បាស់លាស់អំពីតម្រូវការក្នុងការភ្ជាប់ការប្តេជ្ញាចិត្ត E&S នៅក្នុង ESAP ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ ទៅនឹងព្រឹត្តិការណ៍សំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការទូទាត់ចំណាយដំបូង និងការទូទាត់ចំណាយ

ជាបន្តបន្ទាប់ទៀត ដើម្បីធានាថា IFC មានអានុភាពគ្រប់គ្រាន់ដើម្បីទាមទារឱ្យមានបំពេញនូវលក្ខខណ្ឌទាំងនេះ។

## ជំហានបន្ទាប់

របាយការណ៍នេះ ដូចបានកំណត់កាលបរិច្ឆេទ ត្រូវបានពិនិត្យសម្រេចជាស្ថាពរ ដោយ ស៊ីអេអូ និងបានផ្ញើជូនគណៈគ្រប់គ្រង IFC និងក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ IFC ។ អនុលោមតាមគោលនយោបាយរបស់ស៊ីអេអូ IFC នឹងតម្រូវឱ្យបញ្ជូនរបាយការណ៍របស់ថ្នាក់គ្រប់គ្រង ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិដើម្បីពិចារណា ដែលក្នុងនោះនឹងរួមបញ្ចូលផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង (MAP) ក្នុងគោលបំណងដោះស្រាយគំហើញរបស់ ស៊ីអេអូ អំពីភាពមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ MAP រួមមានសកម្មភាពដោះស្រាយតាមពេលវេលាដែលគណៈគ្រប់គ្រងបានស្នើឡើង ។ របាយការណ៍គ្រប់គ្រង គប្បីដាក់បញ្ចូលផងដែរនូវការឆ្លើយតបប្រកបដោយហេតុផលចំពោះការរកឃើញ ឬអនុសាសន៍របស់ស៊ីអេអូ ដែល IFC/MIGA មិនអាចដោះស្រាយបាននៅក្នុង MAP ។ នៅពេលដែលក្រុមប្រឹក្សាភិបាលរបស់ IFC អនុម័ត MAP ស៊ីអេអូ នឹងបោះពុម្ពផ្សាយរបាយការណ៍ស៊ើបអង្កេតនេះ និងរបាយការណ៍គ្រប់គ្រងរបស់ IFC ។ ដូច្នេះ តួនាទីរបស់ស៊ីអេអូ គឺដើម្បីផ្ទៀងផ្ទាត់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសកម្មភាព ដូចមានចែងនៅក្នុង MAP តាមរយៈការត្រួតពិនិត្យតាមដានភាពអនុលោម ។

# 1. សារតារ

ផ្នែកនេះពិពណ៌នាអំពីបរិបទរបស់ប្រទេស តំបន់ និងក្រុមធនាគារពិភពលោក សម្រាប់ការវិនិយោគរបស់ IFC នៅក្នុងធនាគារ An Binh Joint Stock Commercial Bank (ABBank) ។ បន្ទាប់មក វាពិពណ៌នាអំពីខ្សែចង្វាក់នៃការវិនិយោគ រវាង IFC ធនាគារ ABBank ក្រុមហ៊ុន Vietnam Electricity International Joint Stock Company (EVNI) និងអនុគម្រោងវារីអគ្គិសនីសេសានក្រោម២ (LS2) នៅកម្ពុជា ដែលជាកម្មវត្ថុនៃពាក្យបណ្ដឹងមកកាន់ ស៊ីអេអូ ព្រមទាំងផ្ដល់នូវបន្ទាត់ពេលវេលានៃព្រឹត្តិការណ៍សំខាន់ៗ ផងដែរ។

## 1.1 បរិបទ និងការវិនិយោគរបស់ IFC

IFC បានចាប់ផ្ដើមចូលរួមជាមួយប្រទេសវៀតណាម នៅក្នុងឆ្នាំ១៩៩២ ដើម្បីឆ្លើយតបទៅនឹងការស្វែងរកការវិនិយោគ និងបច្ចេកវិទ្យាពីបរទេស ចំពោះអន្តរកាលឆ្ពោះទៅទីផ្សារតម្រង់ទិសសេដ្ឋកិច្ចរបស់ប្រទេសនេះ[1]។ នៅក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ២០០០ IFC បានដើរតួនាទីនាំមុខគេក្នុងការអភិវឌ្ឍធនាគារភាគហ៊ុនរួមឯកជន នៅប្រទេសវៀតណាម[2]។ នៅក្នុងយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស ឆ្នាំ២០០៧-២០១១ របស់ខ្លួន ក្រុមធនាគារពិភពលោក (World Bank Group) បានសង្កត់ធ្ងន់លើតម្រូវការកំណែទម្រង់ជាបន្តទៅលើប្រព័ន្ធហិរញ្ញវត្ថុរបស់វៀតណាម ដើម្បីឱ្យវាកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យឯកជន និងធ្វើសេរីភាវូបនីយកម្មវិស័យធនាគារ[3] ។ នៅឆ្នាំ២០០៨ IFC បានបណ្ដាក់ទុនជាង ២៦០លានដុល្លារអាមេរិក នៅក្នុងវិស័យហិរញ្ញវត្ថុ ដោយផ្ដល់នូវសាច់ប្រាក់ងាយស្រួលក្នុងទម្រង់ហិរញ្ញវត្ថុពាណិជ្ជកម្ម និងការវិនិយោទុន ដល់ធនាគារ និងអ្នកចូលរួមទីផ្សារផ្សេងទៀត[4]។

---

[1]ធនាគារពិភពលោក, វៀតណាម និងធនាគារពិភពលោក៖ ភាពជាដៃគូដ៏រឹងមាំ និងយូរអង្វែង។ សេចក្ដីសង្ខេបអំពីប្រវត្តិជាមួយការពន្យល់ (2012),6,https://bit.ly/3L3rCRT។

[2]ធនាគារពិភពលោក វៀតណាម និងធនាគារពិភពលោក។ក្នុងឆ្នាំ ២០០២ IFC បានធ្វើការវិនិយោគដំបូងរបស់ខ្លួនក្នុងវិស័យធនាគារវៀតណាម។ IFC បានផ្ដល់ភាគហ៊ុនរហូតដល់ ១០,២ លានដុល្លារអាមេរិកដល់ធនាគារ Saigon Thuong Tin Commercial Joint Stock Bank (Sacombank) រួមជាមួយនឹងការវិនិយោគភាគហ៊ុនចំនួន ៥ លានដុល្លារអាមេរិកដល់ធនាគារ Asia Commercial Bank (ACB) ដែលជាធនាគារភាគហ៊ុនរួមឯកជនធំបំផុតពីរ នៅវៀតណាម នាពេលនោះ។ សូមមើលhttps://disclosures.ifc.org/project-detail/SPI/10807/sacombank និង https://disclosures.ifc.org/project-detail/SPI/11402/asia-commercial-bank-vietnam; IFC, សេចក្ដីប្រកាសព័ត៌មាន ស្ដីពី "IFC-វៀតណាម នឹងដាក់ទុនវិនិយោគភាគហ៊ុននៅធនាគារ Sacombank" កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០២) https://bit.ly/4eBg7P5។

[3]ធនាគារពិភពលោក សមាគមអភិវឌ្ឍន៍អន្តរជាតិ និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេសជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់រយៈពេល ២០០៧-២០១១ (CPS Vietnam 2007-2011), ថ្ងៃទី 3 ខែមករា ឆ្នាំ 2007), vi, vii, ២៧– ២៨,https://bit.ly/3RK5gsj។

[4]IFC "IFC នឹងកាត់បន្ថយការកាន់កាប់ភាគហ៊ុន នៅក្នុងធនាគារ Sacombank របស់វៀតណាម៖ ការពង្រឹងភាពជាដៃគូ តាមរយៈការបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងផលិតផលនវានុវត្តន៍" (ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៨)។https://bit.ly/4cAk98D.

នៅឆ្នាំ២០១០ ក្នុងអំឡុងពេលនៃការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ ABBank យុទ្ធសាស្ត្ររបស់ IFC នៅវៀតណាម បានផ្ដោតលើការពង្រឹងសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចរបស់ប្រទេសនេះ និងការលើកកម្ពស់សេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងកំណើនប្រកបដោយនិរន្តរភាព តាមរយៈការគាំទ្រដល់ការផ្លាស់ប្ដូរប្រព័ន្ធធនាគាររបស់វៀតណាម ទៅរកការចូលរួមពីវិស័យឯកជនកាន់តែច្រើន។ IFC បានបង្កើនការប្តេជ្ញាចិត្តវិនិយោគរបស់ខ្លួននៅក្នុងប្រទេសវៀតណាម ពី ៦២ លានដុល្លារ ក្នុងឆ្នាំ២០០៧ ដល់ជាង ១ ពាន់លានដុល្លារក្នុងឆ្នាំ ២០១១[5] ជាមួយនឹងការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុ ដែលគ្របដណ្ដប់លើផលប័ត្ររបស់ IFC[6] ។

### 1.1.1 ការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank និងការវិនិយោគរបស់ ABBank នៅក្នុង EVNI

ដោយត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ នៅភាគខាងត្បូងប្រទេសវៀតណាម ធនាគារ ABBank បានប្រែក្លាយពីធនាគារជនបទតូចមួយ ទៅជាធនាគារពាណិជ្ជខ្នាតមធ្យមថ្នាក់ជាតិ នៅដើមទសវត្សរ៍ឆ្នាំ២០០០។ នៅឆ្នាំ២០០៣ អគ្គិសនីវៀតណាម (EVN) ដែលជាអតិថិជនរយៈពេលវែងរបស់ធនាគារពិភពលោក[7] ទទួលបានភាគហ៊ុន ៣០ ភាគរយ របស់ធនគារ ABBank ។ ក្នុងឆ្នាំ២០០៨ ធនាគារ Maybank ដែលជាដៃគូរយៈពេលវែងមួយទៀត របស់ IFC ក៏បានក្លាយជាម្ចាស់ភាគហ៊ុនរបស់ធនាគារ ABBank ផងដែរ ដោយទទួលបានភាគហ៊ុន ១៥ ភាគរយ ដែលបន្ទាប់មកបានកើនឡើងដល់ ២០ ភាគរយក្នុងឆ្នាំ ២០០៩ និងឡើងដល់ ៣០ ភាគរយ ក្នុងឆ្នាំ២០១៣។[8]

ចាប់តាំងពីឆ្នាំ២០០៩ មក IFC បានធ្វើការវិនិយោគនៅក្នុងធនាគារ ABBank ដូចមានរៀបរាប់ខាងក្រោម៖

1. ការវិនិយោគលើកដំបូងរបស់ IFC នៅក្នុងធនាគារ ABBank គឺឥណទានពាណិជ្ជកម្មមានទឹកប្រាក់ចំនួន ១៨ លានដុល្លារអាមេរិក ដែលបានផ្ដល់ឱ្យ នៅខែមេសា ឆ្នាំ២០០៩ ក្រោមឧបករណ៍ធានាកម្មវិធីហិរញ្ញវត្ថុពាណិជ្ជកម្មសកលរបស់ខ្លួន (Global Trade Finance Program Guarantee Facility)[9] ដែល

---

[5]ធនាគារពិភពលោក សមាគមអភិវឌ្ឍន៍អន្តរជាតិ ធនាគារអន្តរជាតិសម្រាប់ការកសាងឡើងវិញ និងអភិវឌ្ឍន៍ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ទីភ្នាក់ងារធានាការវិនិយោគពហុភាគី យុទ្ធសាស្ត្រភាពជាដៃគូប្រទេសប្រទេស ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់រយៈពេល FY12–FY16 (ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១១), 51,https://bit.ly/45DRNYR.

[6]ក្រុមវាយតម្លៃឯករាជ្យ, ការពិនិត្យឡើងវិញរបស់ IEG CPSCR, វៀតណាម FY07–FY10 (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០១១), 4,https://bit.ly/4bjQhft។

[7]EVN ដែលជាក្រុមហ៊ុនគ្រប់គ្រងដោយរដ្ឋ បានក្លាយជាអតិថិជនរបស់ធនាគារពិភពលោក ចាប់តាំងពីឆ្នាំ១៩៩៦ ។ សូមមើល https://bit.ly/3RG8Qne ។

[8]សូមមើលប្រវត្តិសាជីវកម្មធនាគារ ABBank នៅ https://abbank.vn/en/corporate-history.html ។

[9] នៅចុងឆ្នាំ២០០៧ IFC បានចាប់ផ្ដើមកម្មវិធីហិរញ្ញវត្ថុពាណិជ្ជកម្មសកលរបស់ខ្លួន នៅក្នុងប្រទេសវៀតណាម។ កម្មវិធីនេះពង្រីក និងបំពេញបន្ថែមសមត្ថភាពរបស់ធនាគារ ក្នុងការផ្ដល់ហិរញ្ញប្បទានពាណិជ្ជកម្មដល់អ្នកនាំចូល និងអ្នកនាំចេញក្នុងស្រុក ដោយផ្អែកលើ

បច្ចុប្បន្ននៅតែមានដំណើរការនៅឡើយ (គម្រោង IFC លេខ ២៧៨៥១)។

2. នៅខែធ្នូ ឆ្នាំ២០១០ IFC បានជាវមូលបត្របំណុលដែលអាចបំប្លែងជាកាតព្វកិច្ច ដែលបានបំប្លែងទៅជាភាគហ៊ុន នៅខែមេសា ឆ្នាំ២០១៣ (គម្រោង IFC លេខ២៩៧៤៥)។ ការវិនិយោគមូលធននេះ មានចំនួនប្រហែល ៤០,៦ លានដុល្លារអាមេរិក[10] បានផ្តល់ភាគហ៊ុន ១០ ភាគរយ ដល់ IFC នៅក្នុង ABBank ពីឆ្នាំ២០១៣ ដល់ឆ្នាំ ២០២១ និងភាគហ៊ុន ៨,២ ភាគរយចាប់ពីខែធ្នូ ឆ្នាំ២០២១ ដល់ខែឧសភា ឆ្នាំ ២០២៤ បន្ទាប់ពី IFC បានសម្រេចចិត្តមិនចូលរួមនៅក្នុងបញ្ហាសិទ្ធិ នៅឆ្នាំ២០២១ របស់ ABBank ។ ការវិនិយោគរបស់ IFC ត្រូវបានរៀបចំឡើង ដើម្បីបង្កើតភាពជាដៃគូរយៈពេលវែងរវាង IFC និង ABBank ដែលនឹងអនុញ្ញាតឱ្យ ABBank រក្សាអនុបាតភាពគ្រប់គ្រាន់នៃមូលធនរឹងមាំ ខណៈដែលបង្កើនផលប័ត្រឥណទានរបស់ខ្លួន ដែលគាំទ្រគំនិតផ្តួចផ្តើមដោះស្រាយការប្រែប្រួលអាកាសធាតុ និងការបង្កើនការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងប្រសិទ្ធភាពថាមពលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់[11] ។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ IFC បានដកខ្លួនចេញទាំងស្រុងពី ABBank ដោយលក់ភាគហ៊ុនរបស់ ABBank ជិត ៨៥ លានដុល្លារ ស្មើនឹង ៨,២ ភាគរយ នៃមូលធនរបស់ធនាគារ ABBank[12]។

3. នៅក្នុងខែតុលា ឆ្នាំ២០១៧ IFC បានផ្តល់ឥណទានរហូតដល់ ១៥០ លានដុល្លារអាមេរិក (គម្រោង IFC #៤០០៨១) ដើម្បីពង្រីកផលប័ត្រឥណទានរបស់ធនាគារ ABBank សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) និងសហគ្រាសធុនតូច និងមធ្យម (SMEs) ដែលគ្រប់គ្រងដោយស្ត្រី។ ធនាគារ ABBank យល់ព្រមប្រើប្រាស់តែមូលនិធិនៃឥណទានរបស់ IFC ឆ្នាំ ២០១៧ ប៉ុណ្ណោះ ដើម្បីគាំទ្រដល់

---

មូលដ្ឋានប្រតិបត្តិការនីមួយៗ។ កម្មវិធីនេះគាំទ្រដល់លក្ខខណ្ឌតម្រូវសាច់ប្រាក់ងាយស្រួលរបស់ធនាគារវិស័យឯកជន ក្នុងការបង្កើនសមត្ថភាពរបស់ពួកគេគ្របដណ្តប់ហានិភ័យនៃការទូទាត់ក្នុងការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្ម ដល់ក្រុមហ៊ុនក្នុងស្រុក ដែលភាគច្រើនជាសហគ្រាសធុនតូច និងមធ្យម។ IFC "IFC ផ្តល់មូលនិធិយ៉ាងច្រើនសម្រាប់ហិរញ្ញវត្ថុពាណិជ្ជកម្ម ដល់អាជីវកម្មខ្នាតតូច នៅវៀតណាម" (ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១)។ ក្រុមវាយតម្លៃឯករាជ្យ, ការពិនិត្យឡើងវិញ IEG Vietnam CPSCR, CPS Period FY០៧-FY១០, p.3, https://bit.ly/4bjQhft ។

[10] ចំនួនទឹកប្រាក់ដែលបានអនុម័ត គឺជិត ៤៩ លានដុល្លារអាមេរិក ប៉ុន្តែចំនួនទឹកប្រាក់ដែលបានបញ្ចេញពិតប្រាកដគឺ ៤០,៦ លានដុល្លារអាមេរិក។ សូមមើលការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC (ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២), 7, និងសេចក្តីសង្ខេបនៃសំណើវិនិយោគ (SPI) សម្រាប់គម្រោង #២៩៧៤៥" https://disclosures.ifc.org/project-detail/SPI/29745/abbank-equity-cb ។

[11] សូមមើល SPI សម្រាប់គម្រោង #២៩៧៤៥ នៅhttps://disclosures.ifc.org/project-detail/SPI/29745/abbank-equity-cb ។

[12] លោក Han Dong "ការបំបែកភាគហ៊ុនជិត ៨៥ លានភាគហ៊ុន IFC លែងជាម្ចាស់ភាគហ៊ុនរបស់ ABBank ទៀតហើយ" Vietstock (ថ្ងៃទី ២២ ឧសភា ឆ្នាំ 2024)។https://bit.ly/45KNFGC.

សហគ្រាសធុនមីក្រូ តូច និងមធ្យម នៅប្រទេសវៀតណាម[13]។ ឥណទាននេះត្រូវបានសងវិញទាំងស្រុងនៅចុងឆ្នាំ២០២២។

4. នៅចន្លោះឆ្នាំ២០១០ ដល់ឆ្នាំ២០២១ IFC បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មប្រឹក្សាយោបល់ចំនួនប្រាំមួយ ជាមួយ ABBank លើបញ្ហាមួយចំនួន ដូចជាការផ្តល់ហិរញ្ញប្បទានទៅលើប្រសិទ្ធភាពថាមពល និងអភិបាលកិច្ចសាជីវកម្ម ជាដើម ដើម្បីជួយ ABBank អភិវឌ្ឍខ្លួនប្រែក្លាយទៅជាធនាគារឯកទេស ដែលផ្តល់សេវាដល់សហគ្រាសធុនតូច និងមធ្យម ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចវៀតណាមមិនទទួលបានសេវាហិរញ្ញវត្ថុគ្រប់គ្រាន់[14] ។

ការស៊ើបអង្កេតភាពអនុលោមនេះ ពិនិត្យតែលើការវិនិយោគមូលធននៅឆ្នាំ២០១០ របស់ IFC នៅក្នុង ABBank ប៉ុណ្ណោះ ដែលភាគហ៊ុននេះមានផលប៉ះពាល់ជាទូទៅលើប្រតិបត្តិការរបស់ FI និងបានផ្តល់ឱកាសដល់ IFC ឱ្យមានឥទ្ធិពលជាវិជ្ជមានទៅលើការអនុវត្តផ្នែកបរិស្ថាន និងសង្គម (E&S) នៃផលប័ត្ររបស់ធនាគារ ABBank ព្រមទាំងមានតួនាទីនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ ផងដែរ[15] ។

នៅពេលដែល IFC បានយល់ព្រមលើការវិនិយោគទូទៅរបស់ខ្លួនក្នុងឆ្នាំ២០១០ ធនាគារ ABBank បានកាន់កាប់ភាគហ៊ុន ១០,៣១ ភាគរយរួចទៅហើយ នៅក្នុងក្រុមហ៊ុន Vietnam Electricity International (EVNI)។ EVNI គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ EVN ដែលជាម្ចាស់ភាគហ៊ុនរបស់ ABBank និងជាអតិថិជនធំជាងគេរបស់ធនាគារនៅពេលនោះ។ ក្រុមហ៊ុន EVNI ត្រូវបានបង្កើតឡើង នៅឆ្នាំ២០០៧ ដើម្បីសាងសង់ និងដំណើរការ

---

[13] ស៊ីអេអូ បានបិទបញ្ចប់នៅក្នុងរបាយការណ៍វាយតម្លៃរបស់ខ្លួនថា ក្រុមហ៊ុន EVNI មិនអាចចាត់ទុកថាជាអនុគម្រោង នៃផលប័ត្រឥណទាន SME របស់ ABBank បានទេ ព្រោះមូលនិធិពីឥណទាននេះ របស់ IFC មិនអាចប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងវារីអគ្គិសនីសេសានក្រោម២ EVNI ឬ EVN បានទេ។ លក្ខខណ្ឌតម្រូវជាក់លាក់ដែល MSMEs និង SMEs ត្រូវតែបំពេញដើម្បីចាត់ទុកថាមានសិទ្ធិទទួលបានមូលនិធិពីឥណទាននេះ ត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់គម្រោង។ យោងតាមព័ត៌មានសាធារណៈបានឱ្យដឹងថា EVNI មានទ្រព្យសកម្មលើសពីទ្រព្យអតិបរមា សម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលមានសិទ្ធិទទួលបានឥណទានក្រោមកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ឥណទាននេះ។ លើសពីនេះ បើយោងតាមតំណាងដែលធ្វើឡើងដោយ IFC, ក្រុមហ៊ុន EVNI មិនបានស្នើសុំ ឬទទួលបានឥណទាន ពី ABBank នៅចន្លោះពីឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្ននេះទេ។ ទំនប់វារីអគ្គិសនីសេសានក្រោម២ ក៏មិនអាចចាត់ទុកថាជា MSME ឬ SME ដែលមានសិទ្ធិទទួលបានឥណទានដែរ ដោយសារវាត្រូវបានដំណើរការ តាមរយៈក្រុមហ៊ុនសាជីវកម្មនៅប្រទេសកម្ពុជា និងមានទ្រព្យសកម្មលើសពីចំនួនអតិបរមាសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលមានសិទ្ធិទទួលឥណទាននៅក្រោមកិច្ចព្រមព្រៀងផ្លូវច្បាប់នៃឥណទាននេះ។ ដូច្នេះ ការវិនិយោគនេះមិនត្រូវបានត្រួតពិនិត្យនៅក្នុងការស៊ើបអង្កេតភាពអនុលោមនេះទេ។ សូមមើល SPI សម្រាប់គម្រោង #40081 នៅ https://disclosures.ifc.org/project-detail/SII/40081/abbank-sr-loan។

[14]IFC "ការវិនិយោគនៅក្នុងធនាគារ An Binh Bank របស់វៀតណាម លើកកម្ពស់ការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម" សេចក្តីប្រកាសព័ត៌មាន (ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១) https://bit.ly/3KX0a8p ។

[15] ដោយសារលក្ខខណ្ឌតម្រូវរបស់ធនាគារជាតិ ការវិនិយោគនេះត្រូវបានធ្វើឡើង តាមរយៈមូលបត្របំណុលដែលអាចបំប្លែងបាន ដែលភ្លាមៗក្រោយមកពីបានបំប្លែងទៅជាភាគហ៊ុន។

គម្រោងថាមពលអន្តរជាតិ ភាគច្រើននៅក្នុងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ឡាវ) ដែលក្នុងនោះរួមទាំងគម្រោងវារីអគ្គិសនីសេសានក្រោម២ ផងដែរ[16] ។

EVN ដែលជាសហគ្រាសដ៏ធំមួយគ្រប់គ្រងដោយរដ្ឋវៀតណាម មានឯកទេសខាងផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី បានទទួលភារកិច្ចពីរដ្ឋាភិបាលវៀតណាមឱ្យបង្កើនថាមពលអគ្គិសនីទ្វេដង នៅត្រឹមឆ្នាំ២០២០ និងបង្កើនទំនាក់ទំនងអន្តរកម្មជាមួយប្រទេសកម្ពុជា និងឡាវ[17]។ នៅក្នុងឆ្នាំ២០០៧ EVN និងដៃគូនានា រួមទាំងធនាគារ ABBank បានជំរុញឱ្យបង្កើតក្រុមហ៊ុនភាគហ៊ុនរួម EVN Cambodia Joint Stock Company ដែលជាអ្នកកាន់តំណែងមុន នៃក្រុមហ៊ុន EVNI[18]។ ការវិនិយោគរបស់ក្រុមហ៊ុន EVNI នៅក្នុង LS2 គឺជាការវិនិយោគដ៏ធំបំផុតមួយ នៅក្នុងវិស័យវារីអគ្គិសនីរបស់កម្ពុជា ដែលជាគ្រោងការវិនិយោគដ៏ធំបំផុតរបស់ក្រុមវៀតណាមនៅក្នុងប្រទេសកម្ពុជា ហើយជាគម្រោងវារីអគ្គិសនីតែមួយគត់របស់ក្រុមហ៊ុន នៅកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ[19]។

ABBank បានទិញភាគហ៊ុន ៦ ភាគរយ នៃក្រុមហ៊ុន EVNI ក្នុងឆ្នាំ២០០៧ ក្នុងនាមជាសមាជិកស្ថាបនិក នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ EVN និងបានបង្កើនភាគហ៊ុនរបស់ខ្លួនដល់ ១០,៣១ ភាគរយ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ភ្លាមៗមុនពេលក្រុមប្រឹក្សាភិបាលរបស់ IFC បានអនុម័តការវិនិយោគភាគហ៊ុននៅក្នុង ABBank កាលថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០។[20]

ក្រុមហ៊ុន EVNI ទទួលបានភារកិច្ចតែមួយគត់ គឺអភិវឌ្ឍគម្រោង LS2 ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១១។ នៅខែមករា ឆ្នាំ២០១១ ក្រុមហ៊ុនបណ្ដាក់ទុនរួមគ្នាមួយ ពោលគឺក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ ត្រូវបានបង្កើតឡើងរវាងក្រុមហ៊ុន EVNI (៥១ ភាគរយ) និងក្រុមហ៊ុន រ៉ូយ៉ាល់គ្រុបរបស់កម្ពុជា (៤៩ ភាគរយ) ដើម្បីអភិវឌ្ឍ LS2 ។ [21] រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០១១ ក្រុមហ៊ុន EVNI បានកាន់កាប់ភាគហ៊ុនភាគច្រើន និងបានគ្រប់គ្រងដំណើរការរៀបចំផែនការ និងការអនុម័ត សម្រាប់ LS2។[22]

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ភាគហ៊ុនរបស់ EVNI នៅក្នុង LS2 ត្រូវបានកាត់បន្ថយមកនៅត្រឹម ១០ ភាគរយ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាបានសម្ដែងការព្រួយបារម្ភអំពី "សមត្ថភាពមូលធន" របស់ EVNI ដោយសារតែរដ្ឋាភិបាល

---

[16]សូមមើលគេហទំព័រ EVNI "អំពីក្រុមហ៊ុនយើង៖ ទំព័រ http://evni.vn/en/about-us (បានពិភាក្សាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០២៤); សូមមើលរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០១១ របស់ EVNI ។ របាយការណ៍ប្រចាំឆ្នាំ EVNI ឆ្នាំ ២០២១ ទំព័រ ១៦ (https://bit.ly/3s4hej5)។

[17]ទីស្ដីការនាយករដ្ឋមន្ត្រីវៀតណាម "សេចក្តីសម្រេចលេខ ១២០៨/QD-TTg របស់នាយករដ្ឋមន្ត្រី អនុម័តលើផែនការមេជាតិ សម្រាប់ការអភិវឌ្ឍថាមពល ក្នុងរយៈពេល ២០១១-២០២០ អាចពិចារណាដល់ឆ្នាំ ២០៣០" (ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១១), ៣ ,https://bit.ly/4ceUpPl។

[18]សូមមើលគេហទំព័រ EVNI នៅ http://evni.vn/gioi-thieu ។

[19] សារព័ត៌មាន Business Monitor Online, "EVN អន្តរជាតិ បានចូលរួមនៅក្នុងវិស័យថាមពលរបស់កម្ពុជា" Business Monitor Online ចេញផ្សាយថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១។

[20]ការឆ្លើយតបពីគណៈគ្រប់គ្រងរបស់ IFC កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២, ១០។

[21]T. Bennan "ទំនប់សេសាននឹងដំណើរការនៅឆ្នាំនេះ" ភ្នំពេញប៉ុស្ដិ៍ (២៥ មេសា ២០១១)។

[22]DH Chen "វៀតណាមបញ្ជាក់ភាគហ៊ុននៅក្នុងទំនប់សេសាន ដែលបានទិញដោយក្រុមហ៊ុនចិន" Cambodia Daily (១១ ធ្នូ ២០១២)។

វៀតណាម កំពុងកាត់បន្ថយការវិនិយោគរបស់ខ្លួន ក្នុងពេលដំណាលគ្នានេះ។[23] យោងតាមក្រុមហ៊ុន EVNI បានឱ្យដឹងថា ១០ ភាគរយដែលនៅសល់ គឺតំណាងឱ្យការងាររុករក និងការសិក្សាសមិទ្ធិលទ្ធភាពអនុវត្តគម្រោងដែលក្រុមហ៊ុន EVNI បានបំពេញមកដល់ចំណុចនោះ។[24] ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ ខូអិលធីឌី បានក្លាយជាក្រុមហ៊ុនបណ្ដាក់ទុនរួមគ្នា រវាងក្រុមហ៊ុន Hydrolancang International Energy របស់ប្រទេសចិន (៥១ ភាគរយ) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ Huaneng Group របស់ប្រទេសចិន[25] ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុបរបស់កម្ពុជា (៣៩ភាគរយ) និងក្រុមហ៊ុន EVNI (១០ ភាគរយ) ។ ជាមួយគ្នានេះផងដែរ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបរបស់កម្ពុជា និងក្រុមហ៊ុន Hydrolancang International Energy បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ សម្រាប់ការសាងសង់ និងការអភិវឌ្ឍទំនប់នេះ ដែលរំពឹងថានឹងចំណាយពេលប្រាំឆ្នាំ និងក្រោយមកទៀត ធ្វើប្រតិបត្តិការរបស់ខ្លួន ក្នុងនាមជាក្រុមហ៊ុនឯកជន សម្រាប់រយៈពេល ៤០ ឆ្នាំ មុនពេលប្រគល់វាមកឱ្យរដ្ឋាភិបាលកម្ពុជា។[26]

ហេតុដូច្នេះហើយ ចាប់តាំងពីឆ្នាំ២០១៣ មក អនុគម្រោង EVNI របស់ IFC មិនបានចូលរួមដោយផ្ទាល់នៅក្នុងការគ្រប់គ្រង និងប្រតិបត្តិការគម្រោង LS2 ប្រចាំថ្ងៃទេ បើទោះបីជាការកាន់កាប់ភាគហ៊ុន ១០ ភាគរយដែលនៅសល់របស់ក្រុមហ៊ុន មានសិទ្ធិតែងតាំងនាយកមួយរូបនៅក្នុងក្រុមប្រឹក្សារបស់ក្រុមហ៊ុនបណ្ដាក់ទុនរួមគ្នានេះក៏ដោយ។ ព័ត៌មានដែលទទួលបានជាសាធារណៈបង្ហាញថា ៧២-៨០ ភាគរយនៃប្រាក់ចំណូលរបស់ក្រុមហ៊ុន EVNI នៅតែ

---

[23] មានទស្សនៈផ្ទុយគ្នាអំពីថាតើវាគឺជាការសម្រេចចិត្តរបស់ EVNI ក្នុងការដកខ្លួនចេញពីអនុគម្រោង LS2 ឬថាតើវាជាសំណើរបស់រដ្ឋាភិបាលកម្ពុជា។ Joshua Wilwohl, "អគ្គិសនីវៀតណាមលែងពាក់ព័ន្ធនឹងទំនប់សេសានក្រោម២ ទៀតហើយ" ខេមបូឌាដេលី ចុះថ្ងៃទី២៨ វិច្ឆិកា ២០១២ នៅhttps://bit.ly/4bkslsr; Chen, "វៀតណាមបញ្ចាក់ភាគហ៊ុនក្នុងទំនប់សេសានដែលបានទិញដោយក្រុមហ៊ុនចិន", ខេមបូឌាដេលី ចុះថ្ងៃទី១១ ធ្នូ ២០១២ នៅ https://bit.ly/4dQbkYy។

[24] Joshua Wilwohl, "អគ្គិសនីវៀតណាមលែងពាក់ព័ន្ធក្នុងទំនប់សេសានក្រោម២ទៀតហើយ" ខេមបូឌាដេលី ចុះថ្ងៃទី២៨ វិច្ឆិកា ២០១២ នៅ https://bit.ly/4bkslsr ។

[25] Hydrolancang International Energy គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលគ្រប់គ្រងទាំងស្រុង (១០០ ភាគរយ) របស់វារីអគ្គិសនីទន្លេ Huaneng Lancang ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធ មានភាគហ៊ុនច្រើន (៥០,៤ ភាគរយ) នៃក្រុមហ៊ុន China Huaneng Group Co., Ltd។ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន China Huaneng Group និង Huaneng Lancang River Hydropower Inc. នៅ www.sse.com.cn; China Huaneng Group, "គម្រោងវារីអគ្គិសនីធំបំផុតរបស់កម្ពុជា—ស្ថានីយ៍វារីអគ្គិសនី Huaneng Lower Se-San River II ចាប់ផ្តើមបង្ហូរទឹកចូលក្នុងអាងស្តុកទឹក" (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧) នៅ https://bit.ly/4gZYmKFនិង China Huaneng Group "អង្គភាពទាំងអស់នៃស្ថានីយ៍វារីអគ្គិសនី Huaneng Sesan Cascade II ដាក់ឱ្យដំណើរការ" សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី២១ តុលា ២០១៨ នៅ https://bit.ly/3zYSVeh ។

[26] ក្រុមហ៊ុន China Huaneng Group និង Huaneng Lancang River Hydropower Inc. របាយការណ៍ប្រចាំឆ្នាំ នៅ www.sse.com.cn; China Huaneng Group, "គម្រោងវារីអគ្គិសនីធំបំផុតរបស់កម្ពុជា—ស្ថានីយ៍វារីអគ្គិសនី Huaneng Lower Se-San River II ចាប់ផ្តើមបង្ហូរទឹកចូលក្នុងអាងស្តុកទឹក" (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០១៧) នៅ https://bit.ly/4gZYmKF និង China Huaneng Group "អង្គភាពទាំងអស់នៃស្ថានីយ៍វារីអគ្គិសនី Huaneng Sesan Cascade II ដាក់ឱ្យដំណើរការ" សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី២១ តុលា ២០១៨ នៅ https://bit.ly/3zYSVeh ។

បន្តមកពីអនុគម្រោងវារីអគ្គិសនីសេសានក្រោម២។[27]

**រូបភាព១៖ ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុរបស់ IFC ជាមួយគម្រោងវារីអគ្គិសនីសេសានក្រោម២ តាមរយៈធនាគារ ABBank**




### 1.1.2 ការអភិវឌ្ឍទំនប់នៅអាងទន្លេមេគង្គ

ការវិនិយោគនានាដោយធនាគារ ABBank ជាអតិថិជនរបស់ IFC នៅក្នុងតំបន់នេះ ត្រូវបានធ្វើឡើងក្នុងបរិបទនៃការអភិវឌ្ឍទំនប់ដ៏សម្បូរបែប។ ការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គ មានការកើនឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដល់ឆ្នាំ២០០០ ដោយសារតម្រូវការថាមពល កើតចេញពីការពង្រីកសេដ្ឋកិច្ច កំណើនប្រជាជន និងការធ្វើចំណាកស្រុកជនបទ-ទីក្រុង ព្រមទាំងការផ្លាស់ប្តូរពីការផ្តល់មូលនិធិសាធារណៈទៅជាភាពជាដៃគូពាណិជ្ជកម្ម រវាងរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនដែលផ្តល់មូលធនសម្រាប់គម្រោងកសាងទំនប់។[28] នៅក្នុងឆ្នាំ២០១០ ការ

[27] EVNI, របាយការណ៍ប្រចាំឆ្នាំ២០២០ (ខែមេសា ២០២១), ២៣, នៅ https://bit.ly/3NtfLOk; EVNI, របាយការណ៍ប្រចាំឆ្នាំ២០២១ (ខែមេសា ២០២២), ៥-៧, នៅ https://bit.ly/3XEZXOl; EVNI, របាយការណ៍ប្រចាំឆ្នាំ២០២៣ (ខែមីនា ២០២៤), ៧) នៅ https://bit.ly/3NitTd7។

[28] Ang, WJ, Park, E., Pokhrel, Y., Tran, DD, និង Loc, HH, "ទំនប់ទឹកក្នុងទន្លេមេគង្គ៖ មូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយ លក្ខណៈនៃការប្រែប្រួលភូមិសាស្ត្រតាមពេលវេលា និងសក្តានុពលវារីអគ្គិសនី ទិន្នន័យវិទ្យាសាស្ត្រប្រព័ន្ធផែនដី (ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤) នៅ ,https://bit.ly/3L74S3b ។

អភិវឌ្ឍវារីអគ្គិសនី បានកើនឡើងយ៉ាងខ្លាំង នៅប្រទេសឡាវ ចិន និងកម្ពុជា[29] ដែលកើតចេញពីការរួមបញ្ចូលគ្នានៃការវិនិយោគក្នុងវិស័យឯកជនដែលកំពុងកើតឡើង ការគាំទ្រយ៉ាងខ្លាំងក្លាពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងការផ្លាស់ប្តូរគោលនយោបាយទាក់ទាញការវិនិយោគ។[30]

ចរន្តទឹកទន្លេមេគង្គ ដែលជាប្រព័ន្ធទន្លេធំជាងគេមួយនៅលើពិភពលោក មានប្រវែងជាង ៤.៨០០ គីឡូម៉ែត្រ កាត់ផ្នែកខ្លះនៃប្រទេសចិន មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម។[31] អាងទន្លេមេគង្គក្រោមនៅខាងក្រៅប្រទេសចិន រួមមានដៃទន្លេជាង ២៥.០០០ គីឡូម៉ែត្រ ហើយតំបន់ទំនាប និងតំបន់ទំនាបលិចទឹកមានជាង ៨០ ភាគរយនៃផ្ទៃដីប្រទេសឡាវ និងកម្ពុជា និងប្រហែល ៥០ ភាគរយនៃផ្ទៃដីប្រទេសថៃ។[32]

[29] ខណៈដែលចិនបានកើនឡើងសមត្ថភាពធំបំផុត ពីទសវត្សរ៍ឆ្នាំ២០០០ ដល់ឆ្នាំ២០១០ (+១៦ ៨៥៤ MW) ប្រទេសឡាវមានទំនប់វារីអគ្គិសនីដែលបានគ្រោងទុកច្រើនជាងគេ និងកំណើនដែលត្រូវបានព្យាករណ៍ខ្ពស់បំផុត ក្រោយឆ្នាំ២០២០ (+១៨ ២២៣ MW)។ សូមមើល៖Ang, WJ, Park, E., Pokhrel, Y., Tran, DD, និង Loc, HH, "ទំនប់ទឹកក្នុងទន្លេមេគង្គ"។ នៅប្រទេសចិន ទំនប់ទឹកធំៗជាច្រើនត្រូវបានសាងសង់នៅលើចរន្តទឹកទន្លេ Lancang (មេគង្គ) ក្នុងអំឡុងទសវត្សរ៍ឆ្នាំ២០១០ រួមទាំងទំនប់ធំបំផុតពីរ គឺទំនប់ Xiaowan និង Nuozhadu ដែលទំនប់នីមួយៗផ្ទុកចំណុះលើសពី ១១ គីឡូម៉ែត្រគូប។ សូមមើល៖ Chen, Xiaoxian et al., "ការធ្វើឱ្យមានតុល្យភាពផលប្រយោជន៍ប្រកួតប្រជែងនៅក្នុងអាងទន្លេមេគង្គ តាមរយៈប្រតិបត្តិការនៃអាងស្តុកទឹកវារីអគ្គិសនីទឹកល្បាក់ នៅប្រទេសចិន៖ ការយល់ដឹងចេញពីគំរូប្រព័ន្ធ" ទិនានុប្បវត្តិនៃផលិតកម្មកាន់តែស្អាត ភាគ ២៥៤ (ឧសភា 2020) https://bit.ly/3AZlgkS ។ ក្រៅពីទំនប់ទឹកល្បាក់នៅតាម ទន្លេ Lancang (មេគង្គ) ចំនួន១១ ក្នុងប្រទេសចិន ទំនប់ផ្សេងទៀតក៏ត្រូវបានសាងសង់នៅលើដៃទន្លេ Lancang ដែលជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងតំបន់ទាក់ទងនឹងការផ្ទុកដីសកម្ម។ សូមមើល Brian Eyler និង Courtney Weatherby, "ភស្តុតាងថ្មី៖ វិធីសាស្ត្រដែលចិនរឹតត្បិតលំហូរទឹកនៅទន្លេមេគង្គ," Stimson (១៣ មេសា ២០២០) https://bit.ly/3RITUym ។

[30]V. Merme et al., "ភាគហ៊ុនឯកជន, កិច្ចការសាធារណៈ៖ ការផ្តល់ហិរញ្ញប្បទានថាមពលវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គ," ការផ្លាស់ប្តូរបរិស្ថានសកល ២៤ (២០១៤), ២០–២៩ (សូមមើលជាពិសេសទំព័រ ២២) https://bit.ly/3VY4Fph ។

[31]Fred Pearce, នៅពេលទន្លេខ្វះខាតទឹក៖ ទឹក, ការកំណត់និយមន័យវិបត្តិក្នុងសតវត្សរ៍ទី២១ (Boston: Beacon Street, ២០០៦)។

[32]Merme et al., "ការផ្តល់ហិរញ្ញប្បទានវារីអគ្គិសនីក្នុងអាងទន្លេមេគង្គ", ២១; B. Eyler, "ការបំផ្លាញទន្លេមេគង្គដល់ចំណុចអេកូឡូស៊ីរបស់វា" Stimson (ខែមករា ឆ្នាំ២០២១) https://bit.ly/3XI4eAO ។

### ផែនទី១៖ អាងទន្លេមេគង្គ




(ប្រភព៖មជ្ឈមណ្ឌល Stimson)[33]

បច្ចុប្បន្ននេះ ទំនប់វារីអគ្គិសនីប្រមាណ ៧៤៥ កន្លែង ត្រូវបានបញ្ចប់ ឬកំពុងសាងសង់នៅលើដងទន្លេ និងដៃទន្លេនៃអាងទន្លេមេគង្គទាំងមូល។ ការអភិវឌ្ឍនេះ បានប្រែក្លាយប្រព័ន្ធទន្លេធម្មជាតិទៅជាតំបន់ទឹកដែលមានវិស្វកម្មខ្ពស់ ប្រើសម្រាប់ផលិតថាមពលវារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកក្នុងទីក្រុង និងការគ្រប់គ្រងទឹកជំនន់ [34] ស្របពេលដែលវានៅតែបន្តគាំទ្រដល់ការនេសាទត្រីទឹកសាបដ៏ធំបំផុតនៅលើពិភពលោក។

ការសិក្សាបានពិពណ៌នាអំពីរបៀបអភិវឌ្ឍយ៉ាងឆាប់រហ័សនៃទំនប់ទាំងនេះក្នុងរយៈពេលបីទសវត្សចុងក្រោយ ដែលបានកើតឡើង ដោយគ្មានការសម្របសម្រួលច្រើន ក្នុងចំណោមបណ្តាប្រទេសជាប់ទន្លេដូចជា ចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា និងវៀតណាម។[35]

ទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលជាកម្មវត្ថុរងពាក្យបណ្តឹងនេះ មានទីតាំងនៅជិតចំណុចប្រសព្វនៃដៃទន្លេសេសាន និងទន្លេស្រែពក ដែលមានចម្ងាយប្រហែល ២៥ គីឡូម៉ែត្រពីទន្លេមេគង្គលើ (សូមមើលផែនទី២)។ វាស្ថិតនៅក្នុងអាងទន្លេ 3S ដែលគ្របដណ្តប់លើប្រព័ន្ធទន្លេសេសាន ទន្លេសេកុង និងទន្លេស្រែពក នៅភាគឦសាននៃប្រទេសកម្ពុជា តំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម និងភាគខាងត្បូងប្រទេសឡាវ ហើយបង្កើតបានជា

[33] ផែនទីនេះត្រូវបានផលិតដោយ មជ្ឈមណ្ឌល Stimson ។ ព្រំដែន ពណ៌ ការកំណត់ឈ្មោះ និងព័ត៌មានផ្សេងទៀតដែលបង្ហាញនៅលើផែនទីនេះ មិនមែនជាការបញ្ជាក់ពីផ្នែកណាមួយនៃក្រុមធនាគារពិភពលោក ទៅលើការវិនិច្ឆ័យឋានៈផ្លូវច្បាប់នៃដែនដីណាមួយ ឬការយល់ព្រម ឬការទទួលយកព្រំដែនបែបនេះទេ។

[34] B. Eyler និង R. Kwan "ផែនទីទំនប់ទឹកទាំងអស់នៃអាងទន្លេមេគង្គ ខ្សែទឹក និងដៃទន្លេ" Stimson (ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤) https://bit.ly/3XF27hi ។

[35] Ang, WJ, Park, E., Pokhrel, Y., Tran, DD, និង Loc, HH, "ទំនប់ទឹកក្នុងទន្លេមេគង្គ;" Eyler និង Kwan, "ផែនទីទំនប់ទឹកទាំងអស់នៃអាងទន្លេមេគង្គ" (២០២៤), ៤។

អាងទឹកដៃទន្លេដ៏ធំបំផុតនៃប្រព័ន្ធមេគង្គ រួមចំណែកប្រមាណ ២០% នៃលំហូរទឹកប្រចាំឆ្នាំរបស់ទន្លេ។[36]

ដោយសារវានៅជិតបឹងទន្លេសាបរបស់កម្ពុជា និងដីសណ្តទន្លេមេគង្គរបស់វៀតណាម អាង 3S បម្រើជាផ្លូវដ៏សំខាន់សម្រាប់ដំណើរការអេកូឡូស៊ី ដូចជាការផ្លាស់ទីរបស់ត្រី ការចិញ្ចឹមត្រី ការពងកូនត្រី និងការនាំមកនូវដីល្បាប់។[37]

ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ ទំនប់វារីអគ្គិសនីចំនួន ២០ កន្លែង ត្រូវបានសាងសង់នៅលើទន្លេ 3S ដែលសរុបជាឃ្លាំងផ្ទុកសកម្ម[38] ប្រហែល ៦,៥៩៧ គីឡូម៉ែត្រគូប[39] ដែលបរិមាណដ៏ធំបំផុតទីបីនៅក្នុងអាងទន្លេមេគង្គ។[40]

ទំនប់ធំជាងគេក្នុងអាង 3S គឺ Xekaman 1 (១,៥៣៨ គីឡូម៉ែត្រគូប ឆ្នាំ២០១៥) នៅក្នុងអាងសេកុង ជាមួយនឹងទំនប់វារីអគ្គិសនីសេសានក្រោម២ (១,០៣៧ គីឡូម៉ែត្រគូប ២០១៨) ជាប់ចំណាត់ថ្នាក់ទីពីរទាក់ទងនឹងការផ្ទុកសកម្ម នៅក្នុងអាង 3S និងទី១០ ជាទំហំអាងស្តុកទឹកធំ ក្នុងអាងទន្លេមេគង្គ។[41]

**ផែនទី២៖** អាង 3S



ប្រភព៖ ក្រុមធនាគារពិភពលោក, IBRD 48225, ខែមិថុនា ឆ្នាំ២០២៤

[36] B. Eyler et. al., "ការវិភាគផលប៉ះពាល់វារីអគ្គិសនីនៅក្នុងអាង 3S នៃទន្លេមេគង្គ" Stimson (ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣) https://bit.ly/45L8nWS ។

[37] Eyler et. al., "ការវិភាគផលប៉ះពាល់វារីអគ្គិសនី។"

[38] ការផ្ទុកសកម្ម គឺជាទឹកដែលលើសពីកម្រិតលំហូរចេញ ហើយអាចប្រើបង្ហូរតាមទំនប់សម្រាប់ផលិតវារីអគ្គិសនី ឬយកទៅប្រើប្រាស់ផ្សេងទៀត។ ការផ្ទុកសកម្ម ត្រូវបានគណនាដោយការស្វែងរកភាពខុសគ្នារវាងការពិនិត្យបរិមាណទឹកសរុបសម្រាប់១សប្តាហ៍ដែលបានកំណត់ និងកម្រិតស្តុកទឹកដែលត្រូវបានគេស្គាល់ ឬប៉ាន់ស្មាន សម្រាប់អាងស្តុកទឹកនីមួយៗ។ Eyler et.al., "ការវិភាគផលប៉ះពាល់វារីអគ្គិសនី។"

[39] Eyler et. al., "ការវិភាគផលប៉ះពាល់វារីអគ្គិសនី។"

[40] សម្រាប់ធ្វើការប្រៀបធៀប ការផ្ទុកសកម្មរបស់ទំនប់ Lancang Cascade គឺស្មើជិត ៤ ដងនៃអាង 3S ហើយមាន ៤៩,៥ ភាគរយនៃទំហំផ្ទុកសកម្មប៉ាន់ស្មានទាំងអស់នៅក្នុងទន្លេមេគង្គ។ Eyler et. al., "ការវិភាគផលប៉ះពាល់វារីអគ្គិសនី។"

[41] Eyler et. al., "ការវិភាគផលប៉ះពាល់វារីអគ្គិសនី។"

### 1.1.3 គម្រោងវារីអគ្គិសនីសេសានក្រោម២

នៅឆ្នាំ១៩៩៩ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបោះពុម្ពផ្សាយផែនការមេសម្រាប់អភិវឌ្ឍទំនប់វារីអគ្គិសនីនៅតំបន់អាងទឹក ណាំធួន (Nam Theun) សេកុង និងសេសាន ដែលបានកំណត់សម្គាល់ LS2 ជាគម្រោងដ៏មានសក្តានុពលមួយ នៅក្នុងប្រទេសកម្ពុជា ទោះបីជាវាស្ថិតនៅទីតាំងផ្សេងពីកន្លែងដែលវាក្រោយមកត្រូវបានអភិវឌ្ឍក៏ដោយ ដែលនៅខ្សែទឹកខាងលើនៃចំណុចប្រសព្វរវាងទន្លេសេសាន និងទន្លេស្រែពក។[42]ក្នុងឆ្នាំ២០០៧ EVN តាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន គឺក្រុមហ៊ុន EVNI បានស្វែងរកអនុវត្តគម្រោង LS2 និងបានទទួលការអនុញ្ញាតឱ្យធ្វើការសិក្សាសមិទ្ធិលទ្ធភាព ។[43]

LS2 មានទីតាំងនៅស្រុកសេសាន ខេត្តស្ទឹងត្រែង ហើយជាគម្រោងវារីអគ្គិសនីធំជាងគេបង្អស់នៅកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ។ ជាមួយនឹងសមត្ថភាពដំឡើង ៤០០ MW ទីតាំងរបស់វានៅលើទន្លេសេសានក្រោម ដែលស្ថិតនៅខាងក្រោមចំណុចប្រសព្វនៃដៃទន្លេសេសាន និងទន្លេស្រែពក មានន័យថាវាទទួលបានលំហូរពីអាងទន្លេទាំងពីរ។[44]

ទំនប់ LS2 ដែលសម្បូរទៅដោយដីនិងថ្ម លាតសន្ធឹងលើផ្ទៃដីជាង ៨ គីឡូម៉ែត្រ និងមានកំពូលទំនប់កម្ពស់ ៨៣ ម៉ែត្រ ពីលើនីវ៉ូទឹកសមុទ្រមធ្យម (amsl) ។ យោងតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ២០០៨ របស់គម្រោង (EIA) ទំនប់នេះត្រូវបានរំពឹងថានឹងបង្កើតអាងស្តុកទឹកដែលគ្របដណ្តប់លើផ្ទៃដី ៣៣៥ គីឡូម៉ែត្រការ៉េ នៅកម្ពស់ ៧៥ ម៉ែត្រ លើនីវ៉ូទឹកសមុទ្រជាមធ្យម ដែលបណ្តាលឱ្យមានការតាំងទីលំនៅថ្មីចំនួន ១.០៥៩ គ្រួសារមកពីប្រាំមួយភូមិ។ [45] គេរំពឹងថា LS2 នឹងរួមចំណែកប្រមាណមួយភាគប្រាំមួយ នៃការផលិតថាមពលសរុបរបស់

---

[42] Halcrow (Sir William) និងដៃគូ និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ *សិក្សាវារីអគ្គិសនីអាងទន្លេសេកុង សេសាន និងណាំធួន។ ការពិនិត្យហេតុប៉ះពាល់បរិស្ថានបឋម (១៩៩៨)* ; Halcrow (Sir William) និងដៃគូ និង ADB, របាយការណ៍ស្ថាពរស្តីពីការសិក្សាវារីអគ្គិសនីអាងទន្លេសេកុង សេសាន និងណាំធួន (១៩៩៩)។ ការសិក្សារបស់ ADB នេះ មានគោលបំណងជ្រើសរើសទីតាំងទំនប់ទឹកសម្រាប់អភិវឌ្ឍគម្រោងវារីអគ្គិសនី នៅតំបន់អាងទឹកណាំធួន សេកុង និងសេសាន។ ការសិក្សាក៏បានបង្កើតសន្ទស្សន៍មួយ សម្រាប់ថ្លឹងថ្លែងពីផលចំណេញសេដ្ឋកិច្ច និងផលប៉ះពាល់សង្គម និងបរិស្ថាន របស់គម្រោង ផងដែរ។ ទំនប់ ២ កន្លែង ក្នុងចំណោមទំនប់ទាំង ១៣ ដែលត្រូវបានត្រួតពិនិត្យ នៅក្នុងការសិក្សារបស់ ADB នេះ គឺមានទំនប់សេសានក្រោម២ និងទំនប់ទឹកស្រែពកក្រោម២ ដែលស្ថិតនៅទីតាំងចំនួនពីរកន្លែងនៅខ្សែទឹកខាងលើនៃចំណុចប្រសព្វសេសាន-ស្រែពក។ នៅក្នុងចំណាត់ថ្នាក់នៃគម្រោងទាំង ១៣ របស់ខ្លួន ការសិក្សារបស់ ADB បានចាត់ទុកទំនប់ទាំងពីរនេះជាជាទំនប់ដែលមានលក្ខណៈសេដ្ឋកិច្ចតិចបំផុត។ សូមមើលផងដែរ Joakim Öjendal, Vikrom Mathur, និង Mak Sithirith, អភិបាលកិច្ចបរិស្ថាននៅទន្លេមេគង្គ, ដំណើរការជ្រើសរើសទីតាំងវារីអគ្គិសនីនៅក្នុងអាងសេសាន និងស្រែពក, របាយការណ៍ជាសេរី SEI/REPSI No. ៤, វិទ្យាស្ថាន Stockholm Environment Institute (២០០២), ៤៣–៤៥។

[43] ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់ការសិក្សាលទ្ធភាពនៃគម្រោងវារីអគ្គិសនីសេសានក្រោម២ ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា (ខែតុលា ឆ្នាំ២០០៨, [EIA], ទំព័រ៣; ទីភ្នាក់ងារសារព័ត៌មានវៀតណាម, "EVN នឹងសំឡឹងមើលគម្រោងថាមពលកម្ពុជា។ ទីភ្នាក់ងារសារព័ត៌មានវៀតណាម (ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០០៧)។

[44] EIA, ទំព័រ S-២។

[45] EIA, ទំព័រ S-២។

កម្ពុជា។[46] ទោះជាយ៉ាងនេះក្តី កម្រិតផលិតកម្មជាក់ស្តែងគឺខុសពីការរំពឹងទុកខាងលើ ហើយត្រូវបានរាយការណ៍ថាទាបជាងការរំពឹងទុកឆ្ងាយណាស់។[47]

### ផែនទី៣៖ ទីតាំងគម្រោងវារីអគ្គិសនីសេសានក្រោម២




ប្រភព៖ ក្រុមធនាគារពិភពលោក, IBRD ៤៦៩២២, ខែវិច្ឆិកា ឆ្នាំ២០២២។

ក្នុងការត្រៀមលក្ខណៈសម្រាប់គម្រោង LS2 ក្រុមហ៊ុន EVNI បានធ្វើសេចក្តីព្រាង EIA ក្នុងឆ្នាំ២០០៨ និងគោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ (CRP) ក្នុងឆ្នាំ២០១១។ នៅខែមករា ឆ្នាំ២០១១

[46]Stimson, "ប្រវត្តិប្រទេសកម្ពុជា ទិដ្ឋភាពទូទៅនៃគោលនយោបាយ និងនិន្នាការលើថាមពល ការដឹកជញ្ជូន ទឹក និងហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា" Stimson (ខែមករា ឆ្នាំ២០២១) https://bit.ly/4bpFvo2 ។

[47]អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង—ផលប៉ះពាល់សិទ្ធិមនុស្សនៃគម្រោងខ្សែក្រវាត់ និងផ្លូវរបស់ចិន នៅកម្ពុជា" អង្គការឃ្លាំមើលសិទ្ធិមនុស្ស (១០ សីហា ២០២១) https://bit.ly/3XBzh1j ។

ក្រសួងផែនការ និងវិនិយោគវៀតណាមបានអនុម័តថវិកាសាងសង់ចំនួន ៨១៦ លានដុល្លារ[48] ហើយគម្រោងនេះទទួលបានការអនុម័តពីរដ្ឋាភិបាល ក្នុងខែវិច្ឆិកា ឆ្នាំ២០១២។[49] ការសាងសង់បានចាប់ផ្តើមនៅឆ្នាំ២០១៣។ នៅឆ្នាំ២០១៧ ទ្វារទំនប់បានចាប់ផ្តើមបិទ បណ្តាលឱ្យជន់លិចអាងស្តុកទឹក និងលំនៅដ្ឋានដែលធ្លាប់រស់នៅ មុនពេលបិទទ្វារទំនប់។[50]

**រូបភាព១៖ ទិដ្ឋភាពពីលើអាកាសនៃគម្រោងវារីអគ្គិសនីសេសានក្រោម២**



ប្រភព៖រូបថតផ្តល់ដោយ Chen Gang, Xinhua / Alamy។[51]

ដោយត្រូវបានសាងសង់រួចរាល់នៅឆ្នាំ២០១៨ ទំនប់វារីអគ្គិសនីសេសានក្រោម២ ជាចុងក្រោយបានជម្លៀសប្រជាជនជិត ៥.០០០ នាក់ និងប៉ះពាល់ដល់សហគមន៍នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ដែលពឹងផ្អែកលើផលផលនៃទន្លេសេសាន និងទន្លេស្រែពក ដើម្បីជាអាហារ និងប្រាក់ចំណូល។[52] ការផ្លាស់ទីលំនៅរបស់គ្រួសារដែលទទួលយកកញ្ចប់ការតាំងទីលំនៅថ្មី បានកើតឡើងនៅចន្លោះឆ្នាំ ២០១៥-១៦ ប៉ុន្តែ ១៣៦ គ្រួសារដែលរស់នៅក្នុងតំបន់អាងស្តុកទឹក បានបដិសេធមិនព្រមតាំងទីលំនៅថ្មី ហើយជំនួសមកវិញបានផ្លាស់ប្តូរទីតាំងទៅកន្លែងក្បែរៗនោះ គឺនៅក្បែរៗខាងក្រៅតំបន់ទឹកជំនន់។

ចាប់ពីឆ្នាំ ២០០៨ មក រហូតបញ្ចប់ទំនប់នៅឆ្នាំ ២០១៨ មានការតវ៉ាជាបន្តបន្ទាប់ដោយសមាជិកសហគមន៍ដែលបង្ហាញការប្រឆាំងនឹងគម្រោងនេះ ដោយមានសេចក្តីរាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយ ការសិក្សា និងក្រុមសង្គម

---

[48] Adam Miller និង Phak Seangly, "អគ្គិសនីសម្រាប់ប្រទេសវៀតណាម, ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១)។

[49] ព័ត៌មាន BBC, "កម្ពុជាអនុម័តទំនប់វារីអគ្គិសនីសេសានក្រោម២" (០២ វិច្ឆិកា ២០១២) https://bit.ly/45F6U4j ។

[50] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង ឆ្នាំ២០២១"។

[51] ប្រើប្រាស់ដោយមានការអនុញ្ញាតពី Alamy Stock Photo។ តម្រូវឱ្យសុំការអនុញ្ញាតជាថ្មី សម្រាប់ការប្រើប្រាស់រូបថតឡើងវិញ។

[52] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង ឆ្នាំ២០២១"។

ស៊ីវិលលើកឡើងពីក្តីកង្វល់នៃហេតុប៉ះពាល់ E&S របស់ទំនប់។[53]

### 1.1.4 បរិបទរបស់ធនាគារពិភពលោកសម្រាប់ការអភិវឌ្ឍន៍វារីអគ្គិសនី ក្នុងឆ្នាំ២០១០

នៅអំឡុងពេលនៃការត្រួតពិនិត្យហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់ IFC សម្រាប់ការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ ABBank ហានិភ័យ និងផលប៉ះពាល់ដែលពាក់ព័ន្ធកើតចេញពីការអភិវឌ្ឍវារីអគ្គិសនី ត្រូវបានដឹងយ៉ាងច្បាស់។[54] ធនាគារពិភពលោកបានផ្តល់ហិរញ្ញប្បទានដល់គម្រោងវារីអគ្គិសនីមួយចំនួនដែលមើលឃើញថាមានលទ្ធភាពទទួលបានជោគជ័យខ្ពស់ ស្ថិតក្រោមការត្រួតពិនិត្យជាសាធារណៈ ហើយទំនប់វារីអគ្គិសនីធំៗបានស្ថិតក្នុងចំណោមប្រភេទគម្រោងអភិវឌ្ឍន៍ដ៏ចម្រូងចម្រាសបំផុត។ [55] ភាពចម្រូងចម្រាសបានផ្តោតលើការប្រែប្រួលបរិមាណ និងគុណភាពទឹក សំណឹកដី និងដីល្បាប់ ការបាត់បង់ជីវចម្រុះ ការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងការរំខានដល់ជីវភាពសហគមន៍ និងគ្រឹះសង្គម។

ភាពចម្រូងចម្រាសទាំងនេះ បាននាំឱ្យធនាគារពិភពលោកដកខ្លួនចេញយ៉ាងច្រើនពីវិស័យនេះ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយក្រោយមកក៏បានវិនិយោគយ៉ាងសកម្មទៅលើការអភិវឌ្ឍចំណេះដឹងអំពីផលប៉ះពាល់នៃទំនប់ និងរបៀបគ្រប់គ្រងវា។ ក្នុងឆ្នាំ១៩៩៨ ធនាគារពិភពលោកបានចូលរួមជាមួយសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ (IUCN) ដើម្បីបង្កើតគណៈកម្មការពិភពលោកស្តីពីទំនប់ ដែលដឹកនាំដោយរដ្ឋមន្ត្រីទឹក របស់ប្រទេសអាហ្វ្រិកខាង

[53] Mean Meach, ទំនប់វារីអគ្គិសនីសេសានក្រោម២៖ ផលប៉ះពាល់មានសក្តានុពលនៃការផ្លាស់ទីលំនៅរបស់សហគមន៍រងផលប៉ះពាល់ (សាលា EarthRight Mekong, EarthRights International,២០០៨); Neou Vannarin និង Paul Vrieze, "គម្រោងទំនប់ជាបញ្ហាទ្វេគ្រោះសម្រាប់អ្នកភូមិស្ទឹងត្រែង" ខេមបូឌាដេលី (ខែសីហា ឆ្នាំ ២០០៩), ២២-២៣; David Boyle "ទំនប់អនាគតនៃភូមិនៅតាមមាត់ទន្លេសេសាន" ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១០);May Titthara និង Adam Miller, "ការភ័យខ្លាចកើតមានទឹកជំនន់ពីទំនប់វារីអគ្គិសនី," ភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី ២០ ឧសភា ២០១១)។ ភ្នំពេញប៉ុស្តិ៍, "ព័ត៌មានតិចតួចអំពីទំនប់វារីអគ្គិសនីសេសានក្រោម២៖ របាយការណ៍," ភ្នំពេញប៉ុស្តិ៍ (២៥ មករា ២០១៣); K. Ham, S. Hay, និង T. Sok, "នយោបាយទំនប់វារីអគ្គិសនីសេសានក្រោម២នៅកម្ពុជា," នៅក្នុងការអភិវឌ្ឍវារីអគ្គិសនី នៅក្នុងតំបន់មេគង្គ៖ *ទស្សនៈនយោបាយ សេដ្ឋកិច្ចសង្គម និងបរិស្ថាន* កែសម្រួលដោយ N. Matthews និង K. Geheb ( Routledge, ២០១៥), ១៥៣–៧២; Sithirith Mak "ទំនប់ និងសន្តិសុខរដ្ឋ៖ ការកសាងទំនប់ទន្លេ 3S គឺជាការគំរាមកំហែងដល់សន្តិសុខប្រទេសកម្ពុជា" ទស្សនៈអាស៊ីប៉ាស៊ីហ្វិក ៥៧ លេខ ១ (២០១៦), ៦០–៧៥; Oliver Hensengerth, "តំបន់ អត្តសញ្ញាណ និងទំនប់វារីអគ្គិសនី៖ ទំនប់វារីអគ្គិសនីសេសានក្រោម២ សាង់សង់ដោយចិនសាងសង់ នៅកម្ពុជា" ទិនានុប្បវត្តិកិច្ចការចិនបច្ចុប្បន្ន លេខ ៤៦ លេខ ៤៦ ៣ (២០១៧), ៨៥–១១៨; W. Nathan Green និង Ian G. Baird, "នយោបាយដ៏ចម្រូងសម្រាសនៃការវាយតម្លៃទំនប់វារីអគ្គិសនី នៅក្នុងអាងទន្លេ", ភូមិសាស្ត្រនយោបាយ ៨៣ (២០២០)។

[54] នៅខែឧសភា ឆ្នាំ ១៩៩៨ ក្រុមធនាគារពិភពលោក និង IUCN បានដឹកនាំការបង្កើតគណៈកម្មការពិភពលោកស្តីពីទំនប់ (WCD) ដើម្បី៖ (i) ពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ទំនប់ធំ និងវាយតម្លៃជម្រើសជំនួសសម្រាប់ការអភិវឌ្ឍធនធានទឹក និងថាមពល។ និង (ii) បង្កើតលក្ខណៈវិនិច្ឆ័យ គោលការណ៍ណែនាំ និងស្តង់ដារដែលអាចទទួលយកបានជាអន្តរជាតិ ដែលសមស្របសម្រាប់ការធ្វើផែនការ ការរចនា ការវាយតម្លៃ ការសាងសង់ ប្រតិបត្តិការ ការត្រួតពិនិត្យ និងការរុះរើទំនប់។

[55] នៅឆ្នាំ១៩៩៣ ធនាគារពិភពលោកបានដកខ្លួនចេញពីទំនប់ Sardar Sandovar ដោយសារតែក្តីកង្វល់ជាសាធារណៈទាក់ទងនឹងការបាត់បង់ដីមានជីជាតិ និងការតាំងទីលំនៅថ្មីរបស់សហគមន៍ជាទ្រង់ទ្រាយធំ។

ត្បូង ឯកឧត្តម Kader Asmal។ គណៈកម្មការ ដែលរួមមានអ្នកជំនាញមកពីរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល បានចេញរបាយការណ៍មួយ ក្នុងឆ្នាំ២០០០ ដែលកំណត់ស្តង់ដារមូលដ្ឋាន សម្រាប់កំណត់ពេលវេលា និងវិធីសាស្រ្តកសាងទំនប់ធំៗ ដោយមានគោលការណ៍ណែនាំចំនួន ២៦ចំណុច សម្រាប់ការអនុវត្តល្អៗ។[56] ដោយឡែក ពាក់ព័ន្ធនឹងការចោទប្រកាន់ក្នុងសំណុំរឿងសេសានក្រោម២ របាយការណ៍បានរកឃើញថា៖

- ក្នុងករណីជាច្រើនលើសលុប មានការចំណាយ ដែលមិនអាចទទួលយកបាន និងជាញឹកញាប់មិនចាំបាច់ នៅក្នុងលក្ខខណ្ឌសង្គម និងបរិស្ថាន ដើម្បីផលប្រយោជន៍អភិវឌ្ឍទំនប់។
- វាចាំបាច់ណាស់ក្នុងការពិគ្រោះយោបល់ និងចរចារវិធានការកាត់បន្ថយផលប៉ះពាល់ ជាមួយអ្នករងផលប៉ះពាល់ទាំងអស់ ដើម្បីសម្រេចបាននូវលទ្ធផលវិជ្ជមាននៃការអភិវឌ្ឍទំនប់។
- ការវាយតម្លៃ E&S គ្រប់ជ្រុងជ្រោយ ការយកចិត្តទុកដាក់ជាពិសេសចំពោះការថែរក្សាធនធានជលផល និងការផ្តល់លំហូរបរិស្ថាន ដើម្បីឆ្លើយតបនឹងគោលបំណងសង្គម និងប្រព័ន្ធអេកូឡូស៊ី គឺជាទិដ្ឋភាពសំខាន់ៗទាំងអស់នៃការរចនា និងអនុវត្តគម្រោងទទួលបានជោគជ័យ។[57]

ការត្រួតពិនិត្យបរិស្ថាន និងសង្គម (ESDD) ឆ្នាំ២០១០ របស់ IFC សម្រាប់ការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ ABBank បានប្រព្រឹត្តទៅ ចំពេលដែលធនាគារពិភពលោកកំពុងបន្តដោះស្រាយក្តីកង្វល់ E&S នានា ពាក់ព័ន្ធនឹងការវិនិយោគវារីអគ្គិសនី ដែលរួមទាំងគម្រោង Nam Theun 2 នៅប្រទេសឡាវ និងគម្រោង Bujagali នៅប្រទេសអ៊ូហ្គង់ដា ផងដែរ។ គម្រោងទាំងពីរបានលើកឡើងក្តីកង្វល់ស្រដៀងគ្នាទៅនឹងក្តីកង្វល់ដែលបានលើកឡើងដោយដើមបណ្តឹងក្នុងគម្រោង LS2 រួមទាំងការតាំងទីលំនៅថ្មី ព្រមទាំងការបាត់បង់ដី និងជីវចម្រុះ។ ជាកិច្ចឆ្លើយតបទៅនឹងក្តីកង្វល់អំពីគម្រោង Nam Theun 2 ធនាគារពិភពលោកបានបង្កើតក្រុមអ្នកជំនាញបរិស្ថាន និងសង្គមអន្តរជាតិ ដើម្បីផ្តល់ការត្រួតពិនិត្យឯករាជ្យ និងផ្តល់ការណែនាំទៅលើការដោះស្រាយបញ្ហា E&S របស់គម្រោង។ ក្រុមនេះបានចេញរបាយការណ៍ ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០១៨ ជាមួយនឹងរបាយការណ៍ទី១៦ ត្រូវបានបោះពុម្ព

[56] គណៈកម្មការពិភពលោកស្តីពីទំនប់ ត្រូវបានកើតចេញពីសិក្ខាសាលាមួយ ធ្វើឡើងនៅក្នុងខែមេសា ឆ្នាំ១៩៩៧ នៅទីក្រុង Gland ប្រទេសស្វីស ដែលធនាគារពិភពលោក និង IUCN បានអញ្ជើញតំណាងប្រហែល ៤០ រូប មកពីឧស្សាហកម្មទំនប់ រដ្ឋាភិបាល គ្រឹះស្ថានសិក្សា អង្គការក្រៅរដ្ឋាភិបាល និងចលនារបស់ប្រជាជន ដែលរងផលប៉ះពាល់ដោយទំនប់ ដើម្បីពិភាក្សាអំពីការពិនិត្យឡើងវិញលើកការផ្តល់ឥណទានសម្រាប់សាងសង់ទំនប់របស់ធនាគារពិភពលោក។ នៅក្នុងសិក្ខាសាលានេះ អ្នកចូលរួមបានឯកភាពលើតម្រូវការឱ្យមានគណៈកម្មការឯករាជ្យមួយដើម្បីត្រួតពិនិត្យទំនប់ទឹកធំៗជាទូទៅ។ សិក្ខាសាលា Gland បានផ្តល់ការតព្វកិច្ចដល់ធនាគារពិភពលោក និង IUCN គ្រប់គ្រងលើការបង្កើតគណៈកម្មការពិភពលោកស្តីពីទំនប់ ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកមានវត្តមាន។ សូមមើល WCD, "ទំនប់ និងការអភិវឌ្ឍន៍, ក្របខ័ណ្ឌថ្មីសម្រាប់ការសម្រេចចិត្ត របាយការណ៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់" WCD (ខែវិច្ឆិកា ឆ្នាំ២០០០) https://bit.ly/3XFBzfB ។

[57] WCD ២០០០៖ ទំនប់ និងការអភិវឌ្ឍ ទំព័រ xxviii-xxxv ។

ផ្សាយ ក្នុងឆ្នាំ២០១០ ជាពេលឆ្នាំដែល IFC បានធ្វើ ESDD របស់ខ្លួនទៅលើ ABBank។[58] ស្របពេលជាមួយគ្នានេះ នៅខែធ្នូ ឆ្នាំ២០០៨ ក្រុមប្រឹក្សាភិបាលរបស់ធនាគារពិភពលោក បានពិភាក្សាអំពីរបាយការណ៍ដែលចេញផ្សាយដោយក្រុមអធិការកិច្ចរបស់ខ្លួន ស្តីពីគម្រោងទំនប់ Bujagali ដែលបានត្រួតពិនិត្យបញ្ហា E&S មានលក្ខណៈទូទៅ ចំពោះគម្រោងវារីអគ្គិសនីធំៗ។

| តារាង១៖ គណៈកម្មការពិភពលោក ស្តីពីការណែនាំអំពីទំនប់ សម្រាប់ការអនុវត្តល្អ | | |
|---|---|---|
| **អាទិភាពយុទ្ធសាស្ត្រ១៖ ការទទួលបានការយល់ព្រមជាសាធារណៈ**<br>១ ការវិភាគភាគីពាក់ព័ន្ធ<br>២ ដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលបានចរចា<br>៣ ការយល់ព្រមដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់<br><br>**អាទិភាពយុទ្ធសាស្ត្រ២៖ ការវាយតម្លៃជម្រើសគ្រប់ជ្រុងជ្រោយ**<br>៤ ការវាយតម្លៃផលប៉ះពាល់ជាយុទ្ធសាស្ត្រទៅលើបញ្ហាបរិស្ថាន សង្គម សុខភាព និងបេតិកភណ្ឌវប្បធម៌<br>៥ ការវាយតម្លៃផលប៉ះពាល់កម្រិតគម្រោងទៅលើបញ្ហាបរិស្ថាន សង្គម សុខភាព និងបេតិកភណ្ឌវប្បធម៌ | ៦ ការវិភាគពហុលក្ខណៈវិនិច្ឆ័យ<br>៧ ការវាយតម្លៃវដ្តជីវិតគម្រោង<br>៨ ការបំភាយឧស្ម័នផ្ទះកញ្ចក់<br>៩ ការវិភាគលើការបែងចែកគម្រោង<br>១០ ការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន<br>១១ ការកែលម្អការវាយតម្លៃហានិភ័យសេដ្ឋកិច្ច<br><br>**អាទិភាពយុទ្ធសាស្ត្រ៣៖ ការដោះស្រាយទំនប់ដែលមានស្រាប់**<br>១២ ការធានានូវវិធានប្រតិបត្តិ ឆ្លុះបញ្ចាំងពីក្តីកង្វល់សង្គម និងបរិស្ថាន<br>១៣ ការកែលម្អប្រតិបត្តិការអាងស្តុកទឹក<br>**អាទិភាពយុទ្ធសាស្ត្រ៤៖ និរន្តរភាពទន្លេ និងជីវភាពរស់នៅ**<br>១៤ ការស្ទង់មតិប្រព័ន្ធអេកូឡូស៊ីមូលដ្ឋាន<br>១៥ ការវាយតម្លៃលំហូរបរិស្ថាន<br>១៦ ការរក្សាបានផលនេសាទ | **អាទិភាពយុទ្ធសាស្ត្រ៥៖ ការទទួលស្គាល់សិទ្ធិ និងការចែករំលែកអត្ថប្រយោជន៍**<br>១៧ លក្ខខណ្ឌសង្គមមូលដ្ឋាន<br>១៨ ការវិភាគហានិភ័យនៃភាពក្រីក្រ<br>១៩ ការអនុវត្តផែនការសកម្មភាពកាត់បន្ថយផលប៉ះពាល់ ការតាំងទីលំនៅថ្មី និងការអភិវឌ្ឍ<br>២០ យន្តការចែករំលែកអត្ថប្រយោជន៍គម្រោង<br><br>**អាទិភាពយុទ្ធសាស្ត្រ៦៖ ការធានាភាពអនុលោម**<br>២១ ផែនការភាពអនុលោម<br>២២ ក្រុមប្រឹក្សាត្រួតពិនិត្យឯករាជ្យសម្រាប់បញ្ហាសង្គម និងបរិស្ថាន<br>២៣ ប័ណ្ណធានាប្រតិបត្តិការ<br>២៤ បរធនបាលកិច្ច<br>២៥ កតិកាសញ្ញាសុច្ចរិតភាព<br>**អាទិភាពយុទ្ធសាស្ត្រ៧៖ ការចែករំលែកទន្លេ ដើម្បីសន្តិភាព ការអភិវឌ្ឍ និងសន្តិសុខ**<br>២៦ នីតិវិធីសម្រាប់បែងចែកទន្លេ |

[58] David McDowell, Thayer Scudder, និង Lee M. Talbot, "គម្រោងពហុបំណងនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ Nam Theun 2, របាយការណ៍ទី១៦ នៃក្រុមអ្នកជំនាញបរិស្ថាន និងសង្គមអន្តរជាតិ" សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០) https://bit.ly/4cLwfMl។ សូមមើលផងដែរសៀវភៅបោះពុម្ពដោយក្រុមធនាគារពិភពលោក នៅពេលត្រួតពិនិត្យមេរៀនដែលបានរៀនសូត្រ ពីដំណាក់កាលរៀបចំនៃគម្រោង Nam Theun 2៖ Ian. C. Porter and Jauasankar Shivakumar (eds.), កសាងទំបន់កាន់តែប្រសើរ៖ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងរឿងរ៉ាវគម្រោង Nam Theun 2 (Washington, DC: World Bank, 2010), https://bit.ly/45JBLMR ។

ប្រភព៖ គណៈកម្មការពិភពលោកស្តីពីទំនប់ "ទំនប់ និងការអភិវឌ្ឍ ក្របខ័ណ្ឌថ្មីសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត របាយការណ៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់" WCD (ខែវិច្ឆិកា ឆ្នាំ២០០០)។

IFC ក៏បានវាយតម្លៃហេតុប៉ះពាល់ E&S និងហានិភ័យដែលមាននៅក្នុងការអភិវឌ្ឍវារីអគ្គិសនីទ្រង់ទ្រាយធំ មុនពេលការវិនិយោគរបស់ខ្លួននៅក្នុង ABBank។ យុទ្ធសាស្រ្តវារីអគ្គិសនីឆ្នាំ២០០៧ របស់ខ្លួន "ទទួលស្គាល់ថាវារីអគ្គិសនី ដូចគ្នាទៅនឹងគម្រោងធនធានធម្មជាតិជាច្រើន បង្កហានិភ័យ ជាពិសេសនៅពេលដែលវាពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃទន្លេ ឬការតាំងទីលំនៅថ្មីរបស់សហគមន៍មូលដ្ឋាន។ ដូច្នេះ វារីអគ្គិសនីត្រូវតែអភិវឌ្ឍដោយប្រុងប្រយ័ត្ន ក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍កាន់តែទូលំទូលាយ រួមមាន៖ (ក) ការគ្រប់គ្រងបរិស្ថានប្រកបដោយការទទួលខុសត្រូវ (ខ) ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម (គ) ការគ្រប់គ្រងទឹក និងថាមពលរួមបញ្ចូលគ្នា និង (ឃ) ការអភិវឌ្ឍស្ថាប័ន"។ យុទ្ធសាស្រ្តនេះផ្តល់ចក្ខុវិស័យដល់ក្រុមធនាគារពិភពលោក ក្នុងការរួមចំណែកដល់ការអភិវឌ្ឍវារីអគ្គិសនី តាមរយៈការរួមបញ្ចូលគ្នានៃការផ្តល់ឥណទាន ជំនួយបច្ចេកទេស និងសេវាប្រឹក្សាយោបល់ផ្នែកវិភាគ រួមទាំងតាមរយៈអន្តរការីផ្នែកហិរញ្ញវត្ថុ ព្រមទាំងក្នុងការប្តេជ្ញាចិត្ត "យកចិត្តទុកដាក់លើការគ្រប់គ្រងបរិស្ថាន និងសង្គម និងបញ្ហាអន្តរវិស័យ ដូចជាការគ្រប់គ្រងចំណូល និងការចែករំលែកអត្ថប្រយោជន៍នៅគ្រប់ភាគីពាក់ព័ន្ធ ការរក្សាលំហូរទឹកដើម្បីនិរន្តរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។[59]

បរិបទនេះ គឺមានភាពពាក់ព័ន្ធ ពីព្រោះនៅឆ្នាំ២០១០ ជាពេលដែល IFC បានវិនិយោគនៅក្នុង ABBank គម្រោងវារីអគ្គិសនីធំៗ មានចំនួនជាងពាក់កណ្តាលនៃឥណទានរបស់អតិថិជន សម្រាប់ផលិតថាមពល។[60]

## 1.2 បន្ទាត់ពេលវេលានៃព្រឹត្តិការណ៍សំខាន់ៗ

តារាងពេលវេលាខាងក្រោមបង្ហាញពីដំណាក់កាល និងព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុង ABBank និងអនុគម្រោងវារីអគ្គិសនីសេសានក្រោម២ របស់អតិថិជន។

---

[59] IFC, "ការកសាងភាពជាដៃគូវារីអគ្គិសនីប្រកបដោយនិរន្តរភាព", IFC (ខែមិថុនា ឆ្នាំ២០០៧): ២៩–៣១ https://bit.ly/4eGXYiJ ។

[60] William Rex, Vivian Foster, Kimberly Lyon, Julia Bucknell, និង Rikard Liden, "ការគាំទ្រវារីអគ្គិសនី៖ ទិដ្ឋភាពទូទៅនៃការចូលរួមរបស់ក្រុមធានាគារពិភពលោក," LiveWire (World Bank, ២០១៤), ២.https://bit.ly/3VZXYTW ។

## ខ្សែបន្ទាត់ពេលវេលានៃការវិនិយោគរបស់IFCនៅក្នុងABBankនិងការអភិវឌ្ឍគម្រោងវារីអគ្គិសនីសេសានក្រោម២

### ABBankនិង IFC

ការវិនិយោគរបស់ IFCនៅក្នុង ABBank · ការវិនិយោគរបស់ ABBankនៅក្នុង EVNI · ការអភិវឌ្ឍទំនប់វារីអគ្គិសនីដែលពាក់ព័ន្ធ

1999

**ខែវិច្ឆិកា ឆ្នាំ២០០០**
គណៈកម្មការពិភពលោកស្តីពីទំនប់ទឹក ចេញរបាយការណ៍ស្នាដៃរបស់ខ្លួន (ទំនប់ទឹក និងការអភិវឌ្ឍ, ក្របខ័ណ្ឌថ្មីមួយសម្រាប់ការសម្រេចចិត្ត )

2000

**ខែកក្កដា ឆ្នាំ២០០១**
ពាក្យបណ្តឹងលើកដំបូង ទាក់ទងនឹងគម្រោង វារីអគ្គិសនី Bujagali ត្រូវបានទទួល ដោយក្រុមអធិការកិច្ច

2001

**ខែមីនា ឆ្នាំ២០០៥**
WB អនុម័តទំនប់ ណាមធឿន ២ នៅប្រទេស ឡាវ

2005

**ខែមិថុនា ឆ្នាំ២០០៧**
ឥណទានរបស់ WBG (រួមទាំង IFC) សម្រាប់អភិវឌ្ឍ Bujagali (HPP នៅប្រទេសអ៊ូហ្គង់ដា )

IFC បោះពុម្ពផ្សាយយុទ្ធសាស្ត្រវារីអគ្គិសនីរបស់ខ្លួន - ការកសាងភាពជាដៃគូវារីអគ្គិសនីប្រកបដោយនិរន្តរភាព

2007

**ខែកញ្ញា ឆ្នាំ២០០៧**
ABBank ទិញ ៦% នៃ EVNI ជាសមាជិកស្ថាបនិកនៃអង្គភាពទើបតែបង្កើត ថ្មី

2008

2009

2010

**ខែមិថុនា ឆ្នាំ២០១០**
IFC និង ABBank ចុះហត្ថលេខាលើលិខិតផ្តល់ អាណត្តិ

**ខែមិថុនា-កក្កដា ឆ្នាំ២០១០**
ការវាយតម្លៃ E&S ស្របតាមក្របខ័ណ្ឌនិរន្តរភាព ឆ្នាំ ២០០៦ របស់ IFC

**ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១០**
ABBank បង្កើតភាគហ៊ុនរបស់ខ្លួននៅក្នុង EVNI រហូតដល់ ១០,៣១%

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០**
ក្រុមប្រឹក្សាភិបាលIFC អនុម័តការវិនិយោគភាគហ៊ុននៅក្នុង ABBank

**ខែធ្នូ ឆ្នាំ២០១០**
IFC ជាវមូលបត្របំណុលអាចបំប្លែងបានរបស់ ABBank (បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លូវច្បាប់)

**ខែធ្នូ ឆ្នាំ២០១០**
សម្ពោធទំនប់ ណាមធឿន ២

2011

2012

**ខែកុម្ភៈ ឆ្នាំ២០១២**
ផ្នែកត្រួតពិនិត្យទីតាំងរបស់ IFC បានចុះត្រួតពិនិត្យ ABBank

**ខែកុម្ភៈ ឆ្នាំ២០១២**
Bujagali បញ្ចប់ការសាងសង់

**ខែកញ្ញា ឆ្នាំ២០១២**
ផ្នែកត្រួតពិនិត្យទីតាំងរបស់ IFC បានចុះត្រួតពិនិត្យ ABBank

### ការអភិវឌ្ឍគម្រោងវារីអគ្គិសនីសេសានក្រោម២

ការវិនិយោគរបស់EVNIនៅក្នុង LS2 · សកម្មភាពសហគមន៍

1999

**ខែកក្កដា ឆ្នាំ១៩៩៩**
ការសិក្សាអំពីទំនប់វារីអគ្គិសនីនៅអាងទន្លេ សេសាន បានទទួលមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ុ (ADB)។ LS2 ត្រូវបានកត់សម្គាល់ជាលើកដំបូង សម្រាប់ការអភិវឌ្ឍដែល អាចកើតឡើង។

2000

2000

2005

**ខែមិថុនា ឆ្នាំ២០០៧**
EVN ចុះហត្ថលេខាលើ MoU ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនៃប្រទេស កម្ពុជា ដើម្បីសិក្សាសមិទ្ធលទ្ធភាពលើ LS2

2007

**ឆ្នាំ២០០៨**
ការតវ៉ាបានចាប់ផ្តើម បន្តរហូតដល់ឆ្នាំ ២០១៨

2008

**ខែមករា-តុលា ឆ្នាំ២០០៨**
EIA សម្រាប់ LS2 សម្គាល់ឃើញផលប៉ះពាល់ដែលអាចកើតឡើងជាច្រើន រួមទាំងការផ្លាស់ទីលំនៅក្នុងទ្រង់ទ្រាយធំ ការបាត់បង់មុខរបរចិញ្ចឹមជីវិត និងការថយចុះនៃបរិមាណត្រី - ផលប៉ះពាល់ដោយប្រយោល ត្រូវបានប៉ាន់ស្មានថានឹងកើតឡើងចំពោះប្រជាជនប្រមាណ ៣០០.០០០ នាក់

**ខែឧសភា ឆ្នាំ២០០៩**
ការសិក្សាមួយត្រូវបានរៀបចំសម្រាប់សន្និសីទទន្លេកម្ពុជា រកឃើញការប្រឆាំងយ៉ាងខ្លាំងក្លាចំពោះគម្រោង ពីសហគមន៍ជុំវិញ និងផលប៉ះពាល់ផ្នែកបរិស្ថាន ដែលមានសក្តានុពលធំធេង

2009

2010

**ខែមិថុនា ឆ្នាំ២០១០**
EIA ត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជា

**ខែមករា ឆ្នាំ២០១១**
ក្រុមហ៊ុនអាជីវកម្មរួមទុន ក្រុមហ៊ុនវារីអគ្គិសនីកម្ពុជា-វៀតណាម ត្រូវបានបង្កើតឡើងដើម្បីអភិវឌ្ឍLS2 ដោយ ៥១% កាន់កាប់ដោយ EVNI និង ៤៩% ត្រូវបានកាន់កាប់ដោយក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប កម្ពុជា

2011

2012

**ឆ្នាំ២០១២**
នគរបាលត្រូវបានចោទប្រកាន់ថា បានកោះហៅប្រជាជនមកសាកសួរ

**ខែវិច្ឆិកា ឆ្នាំ២០១២**
LS2 បានក្លាយជាអាជីវកម្មរួមទុនរវាងក្រុមហ៊ុនHydrolancang International Energyរបស់ប្រទេសចិន(៥១%) ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប (៣៩%) និង EVNI (១០%)

LS2 ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។ កិច្ចព្រមព្រៀងរួមគ្នាសម្រាប់ការសាងសង់ទំនប់ ត្រូវបានចុះហត្ថលេខារវាងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប និងក្រុមហ៊ុនHydrolancang International Energy

នៅមាន ត

របាយការណ៍ស៊ើបអង្កេតភាពអនុលោម របស់ការិយាល័យ ស៊ីអេអូ -ការស៊ើបអង្កេតលើការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ប្រទេសវៀតណាម និងទំនាក់ទំនងរបស់ IFC ជាមួយគម្រោងវារីអគ្គិសនីសេសានក្រោម២ នៅកម្ពុជា

## ខ្សែបន្ទាត់ពេលវេលានៃការវិនិយោគរបស់ IFC នៅក្នុង ABBank និងការអភិវឌ្ឍគម្រោងវារីអគ្គិសនីសេសានក្រោម២

### ABBank និង IFC

ការវិនិយោគរបស់ IFC នៅក្នុង ABBank · ការវិនិយោគរបស់ ABBank នៅក្នុង EVNI · ការអភិវឌ្ឍន៍វារីអគ្គិសនីដែលពាក់ព័ន្ធ

2013

**ខែមេសា ឆ្នាំ២០១៣**
IFC ក្លាយជាម្ចាស់ភាគហ៊ុនរបស់ ABBank ដែលមានមូលបត្រកម្មសិទ្ធិទូទៅចំនួន ១០% (មូលបត្របំណុល បំប្លែងទៅជាមូលបត្រកម្មសិទ្ធ)

**ខែឧសភា ឆ្នាំ២០១៣**
របាយការណ៍សមិទ្ធកម្មបរិស្ថានប្រចាំ ឆ្នាំ២០១២ ត្រូវបានត្រួតពិនិត្យដោយ IFC (AEPR ទីមួយ)

2014

**ខែឧសភា ឆ្នាំ២០១៤**
ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៣

**ខែតុលា ឆ្នាំ២០១៤**
IFC ចុះទស្សនកិច្ចពិនិត្យទីតាំង ABBank

2015

**ខែមេសា ឆ្នាំ២០១៥**
ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៤

2016

**ខែមេសា ឆ្នាំ២០១៦**
ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៥

**ខែមិថុនា ឆ្នាំ២០១៦**
ពាក្យបណ្ដឹង Bujagali លើកទីពីរ ត្រូវបានទទួលដោយក្រុមអធិការកិច្ច

2017

**ខែកក្កដា ឆ្នាំ២០១៧**
ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៦

2018

**ខែមិថុនា ឆ្នាំ២០១៨**
IFC ចុះទស្សនកិច្ចពិនិត្យទីតាំង ABBank+ ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៧

2019

**ខែឧសភា ឆ្នាំ២០១៩**
IFCចុះទស្សនកិច្ចពិនិត្យទីតាំង ABBank+ ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៨

**ខែធ្នូ ឆ្នាំ២០១៩**
IFC ចុះទស្សនកិច្ចពិនិត្យទីតាំង ABBank

2020

**ខែឧសភា ឆ្នាំ២០២០**
ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០១៩

**ខែឧសភា ឆ្នាំ២០២១**
IFC ចុះទស្សនកិច្ចពិនិត្យទីតាំង ABBank + ការពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០២០

2021

**ខែធ្នូ ឆ្នាំ២០២១**
IFC ធ្វើទស្សនកិច្ចពិនិត្យទីតាំង ABBank តាមអនឡាញ
IFC សម្រេចចិត្តមិនចូលរួមក្នុងបញ្ហាសិទ្ធិតំណែងរបស់ខ្លួននៅក្នុង ABBank បានថយចុះមកត្រឹម ៨,២%

**ខែមីនា ឆ្នាំ២០២៣**
IFC ចុះទស្សនកិច្ចពិនិត្យទីតាំង ABBank និងពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០២២

2023

**ខែឧសភា ឆ្នាំ២០២៣**
ពិនិត្យ AEPR ឡើងវិញ ឆ្នាំ២០២៣

**ខែវិច្ឆិកា ឆ្នាំ២០២៣**
IFC ចុះទស្សនកិច្ចពិនិត្យទីតាំង ABBank

**ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤**
IFC បានដកការវិនិយោគចេញពី ABBank ទាំងស្រុង

2024

### ការអភិវឌ្ឍគម្រោងវារីអគ្គិសនីសេសានក្រោម២

ការវិនិយោគរបស់ EVNI នៅក្នុង LS2 · សកម្មភាពសហគមន៍

2013

**ខែកុម្ភៈ ឆ្នាំ២០១៣**
ក្រុមហ៊ុនសេសានក្រោម២ បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម
ការផ្លាស់ទីលំនៅលើកទីមួយត្រូវបានផ្តល់ជូន

**ខែមេសា ឆ្នាំ២០១៣**
ការសាងសង់ LS2 បានចាប់ផ្តើម។ ការកាប់ឈើនៅតំបន់អាងស្តុកទឹកបានចាប់ផ្តើមនៅដើមឆ្នាំ២០១៣

2014

**ខែមករា ឆ្នាំ២០១៤**
LS2 និងរដ្ឋាភិបាលកម្ពុជាក្នុងមូលដ្ឋាន តាមសេចក្តីរាយការណ៍ បានបញ្ចប់ផែនការតាំងទីលំនៅថ្មី និងសំណងប៉ុន្តែត្រូវបានចោទប្រកាន់ថា មិនបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទេ។

**ឆ្នាំ២០១៤-២០១៥**
មេដឹកនាំជនជាតិដើមភាគតិចសរសេរសំបុត្រទៅកាន់ក្រុមហ៊ុន មន្ត្រីកម្ពុជា និងចិនដោយបញ្ជាក់ថា ពួកគេប្រឆាំងនឹងគម្រោង

2015

**ឆ្នាំ២០១៥**
សហគមន៍បានចោទប្រកាន់ថា បានរងការគៀបសង្កត់ឲ្យទទួលយកកញ្ចប់ដោះស្រាយផលប៉ះពាល់

2016

**ត្រឹមឆ្នាំ២០១៨**
ប្រជាជនប្រហែល ៧០០ គ្រួសារបានតាំងទីលំនៅថ្មី
ប្រជាជនប្រហែល ១៨០ គ្រួសារបានបដិសេធមិនតាំងទីលំនៅថ្មី
ទ្វារទំនប់វារីអគ្គិសនីបានចាប់ផ្តើមបិទ

2017

2018

**ឆ្នាំ២០១៨**
ដីសហគមន៍បានលិចទឹក

**ឆ្នាំ២០១៨**
អ្នកភូមិដែលបានតាំងទីលំនៅថ្មី និងអ្នកដែលបានបដិសេធមិនតាំងទីលំនៅថ្មី រាយការណ៍អំពីផលប៉ះពាល់ជាច្រើនលើមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ
អ្នកភូមិនៅខ្សែទឹកខាងលើរាយការណ៍អំពីទឹកជំនន់ញឹកញាប់ និងកម្រិតទឹកជំនន់កាន់តែខ្ពស់

**ខែធ្នូ ឆ្នាំ២០១៨**
គម្រោងវារីអគ្គិសនីដំណើរការទាំងស្រុង

2019

**ខែវិច្ឆិកា ឆ្នាំ២០២០**
វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) បោះពុម្ពផ្សាយរបាយការណ៍ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម ដែលបានចាត់ចែងដោយក្រុមហ៊ុន Huaneng Group ពាក់ព័ន្ធនឹង LS2 ។

2020

2021

2023

2024

## 2. ក្របខ័ណ្ឌស៊ើបអង្កេតភាពអនុលោម

ផ្នែកនេះ ផ្តល់ព័ត៌មានអំពីដំណើរការ និងបរិបទសម្រាប់ការស៊ើបអង្កេតភាពអនុលោមភាពរបស់ ស៊ីអេអូ ទៅលើការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ។ វាពិពណ៌នាអំពីវិសាលភាព វិធីសាស្ត្រ និងបន្ទាប់មកទៀតសេចក្តីសង្ខេបនៃគោលនយោបាយ និងនីតិវិធីរបស់ IFC ដែលអាចអនុវត្តបានចំពោះសំណុំរឿងនេះ ហេតុដូច្នេះពាក់ព័ន្ធទៅនឹងការវិភាគរបស់ ស៊ីអេអូ។

### 2.1 បណ្តឹងសហគមន៍

នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ស៊ីអេអូ បានទទួលពាក្យបណ្តឹងពីអ្នកភូមិបីក្រុមចោទប្រកាន់ពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម និងបរិស្ថាន ដែលរីករាលដាលចេញពីគម្រោងសេសានក្រោម២ ដែលពួកគេបានផ្សារភ្ជាប់ទៅនឹងការវិនិយោគរបស់ IFC នៅក្នុង ABBank ។[61] ពួកគេបានដាក់ពាក្យបណ្តឹង ដោយមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិចំនួនបី គឺទន្លេអន្តរជាតិ (International Rivers) គម្រោងគណនេយ្យភាពអន្តរជាតិ (International Accountability Project) និងអង្គការឃ្លាំមើលមេគង្គ (Mekong Watch ) ។

ដើមបណ្តឹងដែលបានស្នើសុំឱ្យ ស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាសម្ងាត់ រួមមានៈ

ក) អ្នកភូមិតាំងទីលំនៅថ្មីជាអចិន្ត្រៃយ៍ មកពីភូមិក្បាលរមាស និងភូមិស្រែគរចាស់ ដោយសារគម្រោងវារីអគ្គិសនី

ខ) អ្នកភូមិក្បាលរមាស និងស្រែគរចាស់ ដែលមិនព្រមតាំងទីលំនៅថ្មី

គ) អ្នកភូមិមកពីស្រុកតាវែង ស្រុកលំផាត់ ស្រុកកូនមុំ ស្រុកអណ្តូងមាស និងស្រុកវើនសៃ ក្នុងខេត្តរតនគិរី ដែលមានទីលំនៅតាមដងទន្លេសេសាន និងទន្លេស្រែពកស្ថិតនៅខ្សែទឹកខាងលើទំនប់។[62]

សេចក្តីសង្ខេបខាងក្រោម គឺផ្អែកលើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ និងការរៀបរាប់ដោយពាក្យសម្តីរបស់ពួកគេមកកាន់ ស៊ីអេអូ។

[61] បណ្តឹងក៏បានចោទប្រកាន់ផងដែរថា IFC មានការទំនាក់ទំនងជាមួយគម្រោងវារីអគ្គិសនី តាមរយៈអតិថិជន FI ពីរនាក់ផ្សេងទៀត។ មួយក្នុងចំនោមពួកគេត្រូវបានដកចេញពីសិទ្ធិចូលរួម ដោយសារ ស៊ីអេអូ បានកំណត់ថា ធម្មជាតិនៃការវិនិយោគរបស់ IFC នៅក្នុងអតិថិជននោះ មិនអាចផ្តល់នូវការពាក់ព័ន្ធទៅនឹងគម្រោងនេះទេ ខណៈដែលអតិថិជនមួយទៀត (ធនាគារ Vietinbank) ត្រូវបានដកចេញក្នុងអំឡុងពេលវាយតម្លៃភាពអនុលោមភាព ដោយសារ ស៊ីអេអូ មិនបានរកឃើញមូលដ្ឋានគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា IFC មានការពាក់ព័ន្ធនឹងគម្រោងវារីអគ្គិសនីសេសានក្រោម២ តាមរយៈទំនាក់ទំនងបែបនេះ ក្នុងការផ្តល់មូលដ្ឋានសម្រាប់ការស៊ើបអង្កេតភាពអនុលោមនៃការវិនិយោគរបស់ IFC នៅក្នុង FI ទីពីរ។

[62] អក្ខរាវិរុទ្ធនៃឈ្មោះសហគមន៍ ភូមិ ឃុំ និងស្រុក អាចមានការខុសគ្នាបន្តិចបន្តួចរវាងឯកសារ និងប្រភពផ្សេងៗគ្នា ដោយសារភាពស្មុគស្មាញនៃការសរសេរឈ្មោះពីភាសាដើមទៅជាភាសាអង់គ្លេស។ ឧ. ឃុំស្រែអង្រ្គង ក៏លេចចេញជាឃុំស្រែអង្រ្គងក្នុង EIA; ស្រុកកូនមុំ ក៏អាចលេចឡើងជាស្រុកកូនមំ និងស្រុកវើនសៃ ជាវឹមសៃ ក្នុងចំណោមអក្ខរាវិរុទ្ធផ្សេងៗទៀត។

a) អ្នកភូមិដែលតាំងទីលំនៅថ្មី បញ្ជាក់ថា ជីវភាព និងហេដ្ឋារចនាសម្ព័ន្ធនៅកន្លែងផ្លាស់ទីលំនៅរបស់ពួកគេ គឺមិនគ្រប់គ្រាន់។ ជាពិសេសពួកគេចោទប្រកាន់ថា៖

- ជីវភាពរស់នៅមិនដូចអ្វីដែលបានសន្យាដោយពាក្យសម្តីរបស់មន្ត្រីមូលដ្ឋាន។ ក្តីកង្វល់របស់ពួកគេ រួមមាន កង្វះអណ្តូងទឹកស្អាត កង្វះសមត្ថភាពនៅតាមមណ្ឌលសុខភាព លំនៅដ្ឋានគ្មានគុណភាព ការជន់លិចដីស្រែថ្មី និងកង្វះប្រព័ន្ធលូបង្ហូរទឹកមានដំណើរការត្រឹមត្រូវ។
- ពួកគេមិនបានទទួលកម្មវិធីស្តារជីវភាព និងការគាំទ្រ រួមទាំងប្រព័ន្ធធារាសាស្ត្រ សម្រាប់ភ្ជួរស្រែ ហើយអះអាងថា ដីស្រែដែលមាន មិនបានរាប់បញ្ចូលដើមឈើដែលបានដាំ ឬកន្លែងចិញ្ចឹមសត្វទេ។
- ពួកគេមិនអាចចាប់ត្រីក្នុងស្រះដែលបានផ្តល់ឱ្យ នៅទីកន្លែងតាំងលំនៅថ្មីបានទេ ដោយសារទឹកជ្រៅពេក។ ទីកន្លែងតាំងទីលំនៅក្បាលរមាសថ្មី ស្ថិតនៅចម្ងាយ ៣ គីឡូម៉ែត្រពីអាងស្តុកទឹក LS2 និង ៧ គីឡូម៉ែត្រពីការធ្វើដំណើរដោយទូកម៉ាស៊ីនទៅកន្លែងនេសាទចាស់របស់ពួកគេ។ ចាប់តាំងពីទ្វារទំនប់បានបិទ នៅឆ្នាំ២០១៧ ពួកគេបានសង្កេតឃើញការធ្លាក់ចុះនៃប្រភេទត្រីដែលផ្លាស់ទី។ បន្ទាប់ពីការកើនចំនួនត្រី ពីពេលដំបូង ពួកគេនិយាយថា ស្តុកត្រីរបស់អាងស្តុកទឹកក៏បានធ្លាក់ចុះ ផងដែរ។ មេភូមិបានបង្ហាញថា អ្នកភូមិប្រមាណ ៣០នាក់ បាត់បង់ជីវិត នៅចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ ដែលមូលហេតុចម្បងគឺជំងឺលើសឈាម ដោយសារការផ្លាស់ប្តូររបបអាហាររបស់ពួកគេ។
- ពួកគេមិនបានទទួលការពិគ្រោះយោបល់ត្រឹមត្រូវ ឬត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងការបែងចែកដីធ្លី ទីតាំង ប្លង់ និងហេដ្ឋារចនាសម្ព័ន្ធនៃកន្លែងតាំងទីលំនៅថ្មី ការរចនា និងទំហំនៃផ្ទះជំនួស ជំនួយស្តារជីវភាពរស់នៅ ឬការអនុវត្ត និងការត្រួតពិនិត្យសកម្មភាពតាំងទីលំនៅថ្មីទាំងនេះទេ។
- ជម្រើសសម្រាប់កញ្ចប់តាំងទីលំនៅថ្មី មិនបានផ្អែកលើទ្រព្យសម្បត្តិ និងជីវភាពរស់នៅ មុនការផ្លាស់ទីលំនៅរបស់ពួកគេទេ ហើយជាលទ្ធផល ស្ថានភាពរស់នៅ និងជីវភាពរបស់ពួកគេមិនត្រូវបានស្តារឡើងវិញឱ្យមកដល់កម្រិតមុនមានការអនុវត្តគម្រោងនេះទេ។ ជម្រើសផ្លាស់ប្តូរទីលំនៅចំនួនបី (ផ្ទះឈើ ផ្ទះបេតុង ឬសាច់ប្រាក់) សុទ្ធតែមានតម្លៃ និងទំហំដូចគ្នា ដែលបណ្តាលឱ្យអ្នកភូមិលក់ផ្នែកខ្លះនៃដីជំនួស និងធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពនៃជីវភាពរស់នៅរបស់ពួកគេ។ ដីជំនួសដែលមានទំហំប្រាំហិកតា នៃដីគ្មានប្រព័ន្ធធារាសាស្ត្រ ក្នុងមួយគ្រួសារ ត្រូវបានបែងចែកតាមប្រព័ន្ធចាប់ឆ្នោត ដោយមានទីតាំងដីល្អមួយចំនួននៅជិតអាងស្តុកទឹក និងទីតាំងដីផ្សេងទៀតមិនមានជីជាតិល្អ បណ្តាលឱ្យទិន្នផលទទួលបានទាបជាងកម្រិតផលិតកម្ម មុនការផ្លាស់ទីលំនៅ។ ដើមបណ្តឹងក៏បានអះអាងផងដែរថា ប្រព័ន្ធបែងចែកនេះ មិនឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរប្រជាសាស្ត្រ រវាងការស្ទង់មតិទិន្នន័យមូលដ្ឋានធ្វើឡើងក្នុងឆ្នាំ២០០៩-២០១០ និងការតាំងទីលំនៅថ្មី ក្នុងឆ្នាំ២០១៦-២០១៧ ទេ។
- ដោយសារតែមិនមានយន្តការបណ្តឹងសារទុក្ខមានសុវត្ថិភាពនៅក្នុងតំបន់តាំងលំនៅថ្មី ដើមបណ្តឹងមិនបាន និងនៅតែមិនមានអារម្មណ៍សុវត្ថិភាពក្នុងការបង្ហាញពីបញ្ហា និងក្តីកង្វល់របស់ពួកគេអំពីការរស់នៅក្នុងភូមិតាំងទីលំនៅថ្មី។ អ្នកខ្លះចោទប្រកាន់ថា ពួកគេកំពុងត្រូវបានគេតាមឃ្លាំមើលយ៉ាង

យកចិត្តទុកដាក់ ហើយត្រូវបានគេប្រាប់ថា ការតវ៉ាអំពីស្ថានភាពរស់នៅទាំងនេះ អាចនាំឱ្យមានការដកហូតដី និងផ្ទះសម្បែងពីពួកគេវិញ។

b) អ្នកភូមិដែលបដិសេធការតាំងទីលំនៅថ្មី រួមមានប្រហែល ១៣៦ គ្រួសារ ដែលមិនចង់ចាកចេញពីផ្ទះសម្បែង និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ ហើយបន្តរស់នៅក្នុងតំបន់ជុំវិញអាងស្តុកទឹក។ ពួកគេចោទប្រកាន់ថាៈ

- អាងស្តុកទឹកបានជន់លិចភូមិចាស់ និងវាលស្រែរបស់ពួកគេ ហើយពួកគេមិនទទួលបានការពិគ្រោះយោបល់អំពីព្រំប្រទល់នៃសម្បទានកាប់ឈើនៅលើដីប្រពៃណីពួកគេ ដែលបានកាត់បន្ថយទំហំទំនេរសម្រាប់ការតាំងទីលំនៅថ្មីនៅក្នុងដីប្រពៃណីរបស់ពួកគេ។
- ពួកគេមិនដឹងថាតើតំបន់ទ្រនាប់នៃអាងស្តុកទឹកមានព្រំប្រទល់ដល់ទីណាទេ (៧៥ ម៉ែត្រលើនីវ៉ូទឹកសមុទ្រជាមធ្យម[63]) ដូច្នេះហើយបានជាមិនដឹងអំពីទីកន្លែងមានសុវត្ថិភាពដើម្បីសាងសង់ផ្ទះថ្មីរបស់ពួកគេ។
- អ្នកភូមិស្រែគរចាស់ ប្តឹងថា ពួកគេខ្វះហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងដីគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ ដោយសារទឹកជំនន់ ដែលពួកគេយល់ថាបណ្តាលមកពីគម្រោងវារីអគ្គិសនី ហើយពួកគេចង់ទាមទារសំណងពីការខូចខាតដោយសារទឹកជំនន់នេះ។
- ដើមបណ្តឹងមកពីភូមិក្បាលរមាសចាស់ និងស្រែគរចាស់ បង្ហាញថា ការប្រែប្រួលពីទន្លេមានទឹកហូរទៅជាអាងស្តុកទឹកដែលនៅទ្រឹង បានកាត់បន្ថយលទ្ធភាពទទួលបានទឹកស្អាត និងផលិតភាពនៃដីស្រែដែលនៅសេសសល់របស់ពួកគេ។ អ្នកខ្លះមិនត្រូវបានអនុញ្ញាតឱ្យប្រមូលសម្ភារចាស់ៗរុះរើចេញពី ផ្ទះចាស់របស់ពួកគេទេ។ ពួកគេយល់ថា នេះគឺដោយសារតែពួកគេទទួលបានសំណងរួចហើយ ហើយផ្ទះទាំងនោះក្លាយជារបស់រដ្ឋាភិបាល។ ពួកគេមិនបានទទួលការផ្តល់សំណងជារបស់របរ ឬសេវាកម្ម ចំពោះការបាត់បង់ដីកសិកម្ម និង/ឬមិនបានទទួលជំនួយក្នុងកិច្ចខិតខំប្រឹងប្រែងពួកគេទិញ/ទទួលបានដីជំនួស ពីក្រុមហ៊ុនដែលជួលដីពីរដ្ឋាភិបាល នៅជុំវិញភូមិចាស់របស់ពួកគេនោះទេ។ គម្រោងនេះមិនបានជួយអ្នកដែលមិនព្រមផ្លាស់ទីលំនៅ ស្តារជីវភាពរស់នៅរបស់ពួកគេឡើងវិញ ឱ្យដល់កម្រិតមុនពេលមានគម្រោង និង/ឬស្វែងរកមុខរបរចិញ្ចឹមជីវិតផ្សេងទៀតនោះទេ។
- ដើមបណ្តឹងពីភូមិទាំងពីរបានចោទប្រកាន់ថា មានការធ្លាក់ចុះយ៉ាងខ្លាំងនៃបរិមាណត្រីក្នុងមូលដ្ឋាន ដែលប៉ះពាល់ទាំងការហូបចុក និងចំណូលរបស់ពួកគាត់។
- ដើមបណ្តឹងទាំងពីរភូមិចោទថាបានរងការបំភិតបំភ័យ ដោយសារការប្រឆាំងនឹងគម្រោងនេះ រួមមានការគំរាមកំហែងពីអាជ្ញាធរ និងកន្លែងត្រួតពិនិត្យនគរបាល ដែលរារាំងការផ្លាស់ទីដោយសេរីរបស់

[63]EIA, ទំព័រ S-2 ។

អ្នកភូមិ និងអ្នកក្រៅភូមិមិនឱ្យចូល។ សមាជិកសហគមន៍បញ្ជាក់ថា ពួកគេត្រូវបានគេចោទប្រកាន់ថាប្រឆាំងនឹងរដ្ឋាភិបាល និងត្រូវបានចោទពីបទញុះញង់។ ពួកគេក៏អះអាងដែរថា បុគ្គលិកពីសាលារៀន និងមណ្ឌលសុខភាពនៅក្នុងភូមិចាស់របស់ពួកគេ ត្រូវបានដកចេញឱ្យទៅកាន់ទីកន្លែងតាំងទីលំនៅថ្មី ខណៈដែលគ្រួសារមួយចំនួននៅតែស្ថិតក្នុងភូមិចាស់ ដូច្នេះហើយពួកគេបាត់បង់លទ្ធភាពទទួលបានសេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធ។

c) ដើមបណ្តឹងអ្នករស់នៅខ្សែទឹកខាងលើ ដែលរួមមានប្រហែល ៨០០ គ្រួសារ នៅក្នុងភូមិចំនួនប្រាំពីរ តាមដងទន្លេសេសាន និង១.៣០០ គ្រួសារនៅក្នុងភូមិចំនួន ១១ តាមបណ្តោយដងទន្លេស្រែពក ដែលភូមិទាំងអស់នៅខាងលើទំនប់ LS2 រួមគ្នាចោទប្រកាន់អំពី កង្វះការពិគ្រោះយោបល់ និងគ្រោះថ្នាក់ពាក់ព័ន្ធនឹងទំនប់ដល់ប្រភពនានានៃមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ពួកគេចោទប្រកាន់ថា៖

- ពួកគេមិនត្រូវបានគេជូនដំណឹង ឬពិគ្រោះយោបល់អំពីគម្រោងវារីអគ្គិសនីនេះ អំពីផលប៉ះពាល់ដែលបានកំណត់ពីការធ្លាក់ចុះបរិមាណត្រីផ្លាស់ទី ឬអំពីវិធានការកាត់បន្ថយផលប៉ះពាល់ និងគោលនយោបាយសំណងរបស់គម្រោងឡើយ។ ពួកគេអះអាងថា ប្រភពព័ត៌មានតែមួយគត់របស់ពួកគេគឺអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក នៅក្នុងឆ្នាំ២០០៨ ដែលក្រោយមកអង្គការនោះបានប្រឈមនឹងការគំរាមកំហែងពីអាជ្ញាធររដ្ឋាភិបាល។ ជាក់ស្តែង អ្នកភូមិរស់នៅខ្សែទឹកខាងលើបានចោទប្រកាន់ថារដ្ឋាភិបាលមូលដ្ឋានបានរៀបចំវេទិកាសាធារណៈមួយ ហើយបានស្នើឱ្យអ្នកភូមិនៅតាមដងទន្លេសេសាន និងទន្លេស្រែពក ចង្អុលបង្ហាញថាតើអ្នកណាកំពុងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអ្នកណាប្រឆាំងនឹងគម្រោង LS2 ។ ពួកគេបន្ថែមថា ការបំភិតបំភ័យពីសំណាក់អាជ្ញាធរ និងការឃ្លាំមើលរបស់ប៉ូលីស បានកម្រិតសមត្ថភាពរបស់ពួកគេក្នុងការរៀបចំកិច្ចប្រជុំអំពី LS2 ។
- កម្ពស់ទឹកកំពុងផ្លាស់ប្តូរ និងប្រែប្រួល សម្រាប់បណ្តាសហគមន៍រស់នៅជិតអាងស្តុកទឹក ហើយមានត្រីតិចជាងមុន នៅខាងលើឆ្ងាយពីខ្សែទឹក នៅតាមទន្លេសេសាន និងទន្លេស្រែពក ដែលប៉ះពាល់ដល់អាហារូបត្ថម្ភ និងមុខរបរចិញ្ចឹមជីវិត ព្រមទាំងខូចខាតទ្រព្យសម្បត្តិរបស់ពួកគេ។ ពួកគេអះអាងថាទឹកជំនន់បង្ខំឱ្យពួកគេផ្លាស់ទីលំនៅក្នុងរយៈពេលពីមួយទៅពីរសប្តាហ៍ជារៀងរាល់ឆ្នាំ ហើយបានកាត់បន្ថយផលិតភាពនៃវាលស្រែរបស់ពួកគេដែលមានទីតាំងនៅជិតទន្លេ ព្រមទាំងលទ្ធភាពទទួលបានទឹកស្អាត ក្នុងអំឡុងពេលនោះ។ ពួកគេក៏បានចោទប្រកាន់ផងដែរថា កុមារ និងស្ត្រី មានជំងឺរាគរូស បញ្ហាស្បែក និងគ្រុនក្តៅជាញឹកញាប់ ព្រមទាំងលើកឡើងអំពីការលំបាកក្នុងការទទួលបានទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងផ្ទះ ដែលប៉ះពាល់យ៉ាងខ្លាំងដល់អនាម័យ និងសុខភាពបន្តពូជស្ត្រី។
- ខណៈដែលពាក្យបណ្តឹងឆ្នាំ២០១៨ របស់សហគមន៍រស់នៅខ្សែទឹកខាងលើ បានរាយការណ៍ថាមានត្រីច្រើនជាងធម្មតា បន្ទាប់ពីទ្វារទំនប់បិទនៅឆ្នាំ២០១៧ ពួកគេបានបញ្ជាក់ថា កម្ពស់ទឹកខ្ពស់និងប្រែប្រួល ធ្វើឱ្យពិបាកប្រើឧបករណ៍នេសាទប្រពៃណី។ នៅពេលដាក់ពាក្យបណ្តឹងនេះ ទំនប់នេះទើបតែបិទថ្មីៗ ដែលនេះមានន័យថាពាក្យបណ្តឹង មិនបានគ្របដណ្តប់លើផលប៉ះពាល់នាពេលក្រោយដូចជាការធ្លាក់ចុះនៃប្រភេទត្រីផ្លាស់ទី និងស្តុកត្រីក្នុងអាងស្តុកទឹក ដែលអ្នកភូមិបានសង្កេតឃើញ

នៅពេលក្រោយនោះទេ។

***ផលប៉ះពាល់លើសហគមន៍ជនជាតិដើមភាគតិច***

ក្រុមសហគមន៍ទាំងបីចោទប្រកាន់ពីផលប៉ះពាល់របស់គម្រោង LS2 លើសហគមន៍ជនជាតិដើមភាគតិច។

ដើមបណ្តឹងមកពីក្បាលរមាស គឺជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច (ព្នង) ដែលរដ្ឋាភិបាលបានទទួលស្គាល់ ក៏ដូចជាដើមបណ្តឹងមកពីភូមិនៅខ្សែទឹកខាងលើ (ប្រៅ គ្រឹង លន់ ទំពួន ចារ៉ាយ និងកាចាក)។[64] ចំណែកសហគមន៍មកពីស្រែគរចាស់ រួមមានជនជាតិភាគតិចឡាវ និងសហគមន៍នៅខ្សែទឹកខាងលើក៏រួមបញ្ចូលជនជាតិភាគតិចផ្សេងទៀត ផងដែរ។ ក្រុមទាំងអស់នេះបានចោទប្រកាន់ថា ពួកគេមិនបានទទួលការពិគ្រោះយោបល់សមរម្យ ក្នុងអំឡុងពេលធ្វើផែនការ និងដំណើរការអភិវឌ្ឍគម្រោង។ ពួកគេអះអាងថា ទំនប់នេះ បណ្តាលឱ្យមានការផ្លាស់ទីលំនៅរូបវ័ន្ត និង/ឬសេដ្ឋកិច្ចរបស់ពួកគេ ជះឥទ្ធិពលអវិជ្ជមានលើមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ រំខានដល់ការរៀបចំសង្គម-វប្បធម៌របស់ពួកគេ និងបណ្តាលឱ្យមានការបំផ្លិចបំផ្លាញទីតាំងមានតម្លៃបេតិកភណ្ឌវប្បធម៌សំខាន់ៗ។

សមាជិកសហគមន៍ជនជាតិដើមភាគតិចព្នង មកពីក្បាលរមាសចាស់ ដែលបដិសេធមិនព្រមតាំងទីលំនៅថ្មី បញ្ជាក់ថា ពួកគេស្វែងរកការការពារអត្តសញ្ញាណវប្បធម៌ និងទីកន្លែងពិសិដ្ឋរបស់ពួកគេ។ ពួកគេបានបញ្ជាក់ថា ពួកគេសុខចិត្តបូជាជីវិតដើម្បីការពារទឹកដី និងផ្នូរដូនតា។ ពួកគេអះអាងថា គម្រោងវារីអគ្គិសនី និងការជន់លិចដែលពាក់ព័ន្ធ បានប៉ះពាល់ដល់ព្រំប្រទល់នៃព្រៃសហគមន៍ និងការចូលទៅកាន់ទីកន្លែងស័ក្តិសិទ្ធិ និងកន្លែងបញ្ចុះសពដូនតា ដែលប៉ះពាល់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។ ពួកគេក៏សង្កត់ធ្ងន់ផងដែរថា ពួកគេបានដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពសហគមន៍ជនជាតិដើមភាគតិច (ICLT) ដែលមានតែជនជាតិដើមភាគតិចដែលមានការទទួលស្គាល់ប៉ុណ្ណោះ មានសិទ្ធិទទួលបាន។ ទោះជាយ៉ាងនេះក្តី ពាក្យស្នើសុំរបស់ពួកគេត្រូវបានពន្យារពេល និងមានការកែប្រែយ៉ាងច្រើន ដោយសារតែការសម្បទានដីសេដ្ឋកិច្ចដែលរដ្ឋាភិបាលកម្ពុជាផ្តល់ទៅឱ្យក្រុមហ៊ុនឯកជន។

## 2.2 ការឆ្លើយតបរបស់ IFC

ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC ទៅនឹងពាក្យបណ្តឹងខាងលើ[65] អះអាងថា មិនមានទំនាក់ទំនងរវាង IFC និងអនុគម្រោងវារីអគ្គិសនីសេសានក្រោម២ ដែលត្រូវតម្រូវឱ្យធនាគារ ABBank អនុវត្តតាមលក្ខខណ្ឌតម្រូវ E&S

---

[64]ក្រៅពីក្រុមដែលបានលើកឡើងក្នុងពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ដើមបណ្តឹងនៅខ្សែទឹកខាងលើ បានរាយការណ៍ថា អ្នកភូមិខ្លះជាជនជាតិព្នង គ្រឹងប្រៅ លន់ ឬ ការិត ដែលជាជនជាតិដើមភាគតិច ត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា ក៏ដូចជាខ្មែរ ខេ ដែលជាជនជាតិដើមភាគតិច។

[65]សូមមើលការឆ្លើយតបរបស់គណៈគ្រប់គ្រងរបស់ IFC ពីថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២២ នៅក្នុងឧបសម្ព័ន្ធ២ នៃប្រទេសកម្ពុជា៖ អន្តរការីហិរញ្ញវត្ថុ ០១-០៣ ការវាយតម្លៃភាពអនុលោមភាពនៃបណ្តឹងទាក់ទងនឹងការមានទំនាក់ទំនងរបស់ IFC ទៅនឹងគម្រោងវារីអគ្គិសនីសេសានក្រោម២ នៅកម្ពុជា តាមរយៈធនាគារ ABBank និង Vietinbank ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២២ https://bit.ly/4gidUJa ។

របស់ IFC រួមទាំងស្តង់ដារសមិទ្ធិកម្ម (PS) ដែលពាក់ព័ន្ធ នោះទេ។

គណៈគ្រប់គ្រង IFC បានអះអាងដូច្នេះ ដោយផ្អែកលើមូលដ្ឋានថា ការវិនិយោគរបស់ ABBank នៅក្នុង EVNI បានកើតឡើងមុនការវិនិយោគគោលបំណងទូទៅ របស់ IFC នៅក្នុង ABBank ។ IFC បានជាវមូលបត្របំណុលដែលអាចបំប្លែងបាន ដែលចេញដោយ ABBank នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ហើយបានក្លាយជាម្ចាស់ភាគហ៊ុនមួយរូប បន្ទាប់ពីអនុវត្តជម្រើសនៃការបំប្លែងប័ណ្ណបំណុល នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣។ ដូច្នេះ IFC អះអាងថា មូលនិធិរបស់ខ្លួនមិនត្រូវបានប្រើដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគដែលមានស្រាប់របស់ ABBank នៅក្នុង EVNI ទេ ហើយការវិនិយោគរបស់ ABBank នៅក្នុង EVNI គឺមិនមែនជាកម្មវត្ថុចំពោះលក្ខខណ្ឌតម្រូវ E&S នៅក្នុងគោលនយោបាយនិរន្តរភាពរបស់ IFC ទេ។

IFC, ABBank និង EVNI មិនបានឆ្លើយតបទៅនឹងការចោទប្រកាន់របស់ដើមប្តឹងអំពីគ្រោះថ្នាក់ ដែលកើតចេញពី LS2 នោះទេ។

ព័ត៌មានលម្អិតបន្ថែមអំពីការឆ្លើយតប និងទស្សនៈរបស់គណៈគ្រប់គ្រង IFC លើបញ្ហាដែលបានលើកឡើងលើក៏ដូចជាការឆ្លើយតបរបស់ ស៊ីអេអូ ចំពោះគោលជំហរនេះ មានរៀបរាប់នៅក្នុងផ្នែកវិភាគ និងគំហើញ (ផ្នែករង 3.2.1 កាតព្វកិច្ចភាពអនុលោមរបស់ IFC ទាក់ទងនឹងការវិនិយោគរបស់ ABBank)។

ABBank មិនបានផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលដំណើរការភាពអនុលោមទេ ។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងដំណាក់កាលវាយតម្លៃនៃដំណើរការរបស់ស៊ីអេអូ ABBank បានអះអាងថា ទំនាក់ទំនងភាគហ៊ុនភាគតិចរបស់ខ្លួន ជាមួយក្រុមហ៊ុន EVNI បានកើតឡើងមុនការវិនិយោគរបស់ IFC ដូច្នេះតាមគំនិតរបស់ពួកគេ គឺថាវាមិនបានផ្សារភ្ជាប់ទៅនឹងការវិនិយោគរបស់ IFC នោះទេ។[66]

## 2.3 ដំណើរការរបស់ ស៊ីអេអូ

នៅខែកក្កដា ឆ្នាំ២០១៨ ស៊ីអេអូ បានរកឃើញថា ពាក្យបណ្តឹងរបស់អ្នកភូមិមានសិទ្ធិទទួលបានការវាយតម្លៃទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុង ABBank និង Vietinbank ។ លុះក្រោយមក ដើមបណ្តឹងបានព្យាយាមចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទ ដែលស៊ីអេអូបានរៀបចំឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងអតិថិជនរបស់ IFC និងប្រតិបត្តិករគម្រោងវារីអគ្គិសនី មិនចង់ចូលរួមក្នុងដំណើរការនេះទេ ដោយសារពួកគេជឿថា រដ្ឋាភិបាលកម្ពុជា មានលក្ខណៈល្អប្រសើរក្នុងការដោះស្រាយហេតុប៉ះពាល់ E&S របស់គម្រោង នៅក្នុងបរិបទនៃដំណើរការដោះស្រាយវិវាទរបស់ ស៊ីអេអូ។ ដោយសារមិនមានការឯកភាពគ្នា និងដោយមានការយល់ព្រមពីដើមបណ្តឹងផង សំណុំរឿងនេះត្រូវបានផ្ទេរទៅមុខងារភាពអនុលោមភាពរបស់ ស៊ីអេអូ នៅថ្ងៃទី៥ ខែកក្កដា

---

[66] ស៊ីអេអូ "របាយការណ៍វាយតម្លៃអំពីក្តីកង្វល់ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank (#29745, #40081) និង VietinBank (#28509, #31300, #34124) ព្រមទាំងបញ្ហាដែលបានលើកឡើង នៅក្នុងប្រទេសកម្ពុជា" ស៊ីអេអូ (ថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០២២) https://bit.ly/3AYHSSr ។

ឆ្នាំ២០២២ ដើម្បីធ្វើការវាយតម្លៃភាពអនុលោម។[67] នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ស៊ីអេអូ បានបិទបញ្ចប់ការវាយតម្លៃរបស់ខ្លួន ដោយបានសន្និដ្ឋានថា ការស៊ើបអង្កេតភាពអនុលោម គឺសមហេតុផលក្នុងសំណុំរឿងនេះ។

ការស៊ើបអង្កេតរបស់ ស៊ីអេអូ ត្រូវបានធ្វើឡើងចាប់ពីខែធ្នូ ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៤ ។ សេចក្ដីព្រាងរបាយការណ៍មួយ ត្រូវបានប្រគល់ជូន IFC និងដើមបណ្ដឹង ដើម្បីពិនិត្យជាក់ស្ដែង និងផ្ដល់យោបល់។ IFC និងដើមបណ្ដឹង បានផ្ដល់មតិយោបល់របស់ពួកគេ នៅថ្ងៃទី១១ និង១៦ ខែកញ្ញា ឆ្នាំ២០២៤ រៀងគ្នា។ របាយការណ៍ស្ថាពរ របស់ស៊ីអេអូ បានពិចារណាមតិយោបល់របស់ភាគីនានាទៅលើសេចក្ដីព្រាងរបាយការណ៍នេះ។

## 2.4 វិសាលភាពនៃការស៊ើបអង្កេត

អាណត្តិនៃភាពអនុលោមរបស់ ស៊ីអេអូ គឺដើម្បីអនុវត្តការពិនិត្យឡើងវិញនៃភាពអនុលោមរបស់ IFC ស្របតាមគោលនយោបាយ E&S របស់ខ្លួន វាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្ដល់អនុសាសន៍ទៅលើវិធានការស្វែងរកដំណោះស្រាយ តាមភាពសមស្រប។ (សូមមើលឧបសម្ព័ន្ធ គ សម្រាប់សេចក្ដីសង្ខេបនៃដំណើរការស៊ើបអង្កេតភាពអនុលោមភាពរបស់ ស៊ីអេអូ) ។ អាស្រ័យហេតុនេះ របាយការណ៍នេះចងក្រងគំហើញនៃការស៊ើបអង្កេតទាក់ទងនឹងភាពអនុលោម ភាពមិនអនុលោមរបស់ IFC និងគ្រោះថ្នាក់ដែលពាក់ព័ន្ធនានាទៅលើដើមបណ្ដឹង។ ក្នុងការកំណត់ថាតើ IFC បានអនុលោមតាមគោលការណ៍ E&S របស់ខ្លួន ឬក៏អត់ ស៊ីអេអូ នឹងរួមបញ្ចូលការវាយតម្លៃតាមដែលអាចធ្វើទៅបាន ថាតើ IFC បានបង្វែរទិសដៅជាសារវន្តពីការណែនាំ និងនីតិវិធីដែលពាក់ព័ន្ធ ឬយ៉ាងណា។[68]

របាយការណ៍នេះក៏រួមបញ្ចូលផងដែរនូវសេចក្ដីសន្និដ្ឋានរបស់ ស៊ីអេអូ អំពីមូលហេតុឫសគល់នៃភាពមិនអនុលោមដែលបានរកឃើញ និងអនុសាសន៍សម្រាប់ IFC ពិចារណាបង្កើតផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង ដើម្បីកែលម្អគម្រោង និងភាពមិនអនុលោមកម្រិតគម្រោង និងផលប៉ះពាល់ដែលពាក់ព័ន្ធ ព្រមទាំងចាត់វិធានការស្ថាប័នដើម្បីទប់ស្កាត់ភាពមិនអនុលោមនាពេលអនាគត។[69]

លក្ខខណ្ឌយោងពីខែវិច្ឆិកា ឆ្នាំ២០២២[70] កំណត់សំណួរខាងក្រោម សម្រាប់ការស៊ើបអង្កេតនេះ ដើម្បីឆ្លើយ៖

1. ថាតើ IFC បានអនុលោមតាមគោលការណ៍ E&S របស់ខ្លួន រួមទាំង៖

---

[67] ស៊ីអេអូ "របាយការណ៍វាយតម្លៃទៅលើក្ដីកង្វល់ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុង ABBank (#29745, #40081) និង VietinBank (#28509, #31300, #34124) និងបញ្ហាដែលបានលើកឡើង នៅក្នុងប្រទេសកម្ពុជា" ខែមិថុនា ឆ្នាំ ២០២២ https://bit.ly/3AYHSSr ។

[68] ស៊ីអេអូ, "IFC/MIGA គោលនយោបាយយន្ដការគណនេយ្យភាពឯករាជ្យ (CAO)" (តទៅនេះហៅថា "គោលនយោបាយ CAO"), " CAO (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១), កថាខណ្ឌ ៧៦ និង ១១២។

[69] គោលនយោបាយ CAO, កថាខណ្ឌ ១១៣។

[70] ស៊ីអេអូ, "លក្ខខណ្ឌនៃសេចក្ដីយោងសម្រាប់ការស៊ើបអង្កេតភាពអនុលោមនៃការអនុវត្តផ្នែកបរិស្ថាន និងសង្គមរបស់ IFC ទាក់ទងនឹងការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ ABBank និងការវិនិយោគរបស់ខ្លួននៅក្នុងគម្រោងវារីអគ្គិសនីសេសានក្រោម២ នៅកម្ពុជា" (ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២) https://bit.ly/4bup1uW ។

a. ថាតើ IFC បានធ្វើការត្រួតពិនិត្យ E&S មុនការវិនិយោគ ចំពោះការការវិនិយោគឆ្នាំ ២០១០ របស់ខ្លួននៅក្នុង ABBank ដូចបានតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព ដែរឬទេ និង
b. ថាតើ IFC បានគ្រប់គ្រងការវិនិយោគក្នុងឆ្នាំ ២០១០ របស់ខ្លួននៅក្នុង ABBank ដែរឬទេ រួមទាំងការប្តេជ្ញាចិត្ត E&S ដែលបានធ្វើឡើងនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួន ជាមួយអតិថិជន ដូចបានតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព។

2. ថាតើគ្រោះថ្នាក់ និងគ្រោះថ្នាក់ដែលអាចនឹងកើតឡើងនានា ដែលដើមបណ្តឹងបានលើកឡើង មានការពាក់ព័ន្ធនឹងភាពមិនអនុលោមរបស់ IFC ដែរឬទេ។[71]

ក្នុងការពិចារណាទៅលើគំហើញទាក់ទងនឹងគ្រោះថ្នាក់ និងថាតើគ្រោះថ្នាក់ណាមួយ ពាក់ព័ន្ធនឹងភាពមិនអនុលោមរបស់ IFC នោះ ស៊ីអេអូ វាយតម្លៃការពិនិត្យឡើងវិញរបស់ IFC និងការគ្រប់គ្រងលក្ខខណ្ឌតម្រូវ E&S របស់ខ្លួននៅកម្រិតគម្រោង និងអនុគម្រោង។ សម្រាប់សំណុំរឿងនេះ ស៊ីអេអូ បានពិចារណាលើការអនុវត្ត E&S កម្រិតគម្រោង ឬអនុគម្រោង ជាពិសេសដោយសារវាទាក់ទងនឹងការអនុវត្តស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ ចំពោះអនុគម្រោង។ ស្តង់ដារសមិទ្ធិកម្ម ដែលទាក់ទងនឹងបញ្ហាលើកឡើងក្នុងពាក្យបណ្តឹង មានសង្ខេបនៅក្នុងផ្នែក 2.7 ខាងក្រោម។

## 2.5 វិធីសាស្ត្រស៊ើបអង្កេត

ក្រុមស៊ើបអង្កេត ស៊ីអេអូ រួមមានបុគ្គលិកស៊ីអេអូ អ្នកបកប្រែខ្មែរមួយរូប និងទីប្រឹក្សាជំនាញខាងក្រៅចំនួនបីរូប ដូចខាងក្រោម៖

- អ្នកឯកទេសផ្នែកសង្គម និងបរិស្ថានមួយរូប ដែលមានបទពិសោធន៍ជាង ៣០ ឆ្នាំ ក្នុងការវាយតម្លៃបញ្ហា E&S នៅក្នុងការផ្តល់ហិរញ្ញប្បទានគម្រោង អន្តរការីហិរញ្ញវត្ថុ និងគម្រោងវារីអគ្គិសនីនៅក្នុងប្រទេសជាង ៧០ ។ ទីប្រឹក្សារូបនេះបានពិនិត្យគ្រប់ទិដ្ឋភាពទាំងអស់នៃពាក្យបណ្តឹង។
- សាស្ត្រាចារ្យសិក្សាភូមិសាស្ត្រ និងបរិស្ថាន ដែលមានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងការសិក្សាផលប៉ះពាល់នៃទំនប់វារីអគ្គិសនី នៅក្នុងតំបន់មេគង្គ រួមទាំងទិដ្ឋភាពជលផល និងជីវចម្រុះផ្សេងៗទៀត ក៏ដូចជាបញ្ហាទាក់ទងនឹងជនជាតិដើមភាគតិច នៅភាគឦសានប្រទេសកម្ពុជា។
- អ្នកស្រាវជ្រាវជនជាតិខ្មែរក្នុងស្រុកមួយរូប ដែលមានបទពិសោធន៍ជាង ១០ឆ្នាំ ទៅលើផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសប្រទេសកម្ពុជា។ ចំណាប់អារម្មណ៍ស្រាវជ្រាវរបស់គាត់ រួមមានការអភិវឌ្ឍប្រកបដោយសមធម៌ និងភាពងាយរងគ្រោះនៃទឹក និងផលប៉ះពាល់ឆ្លងប្រទេស នៅក្នុងតំបន់មេគង្គ។

[71] គោលនយោបាយ CAO, កថាខណ្ឌ ១១២–១៤។

របាយការណ៍ស៊ើបអង្កេតនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើ៖

- ការពិនិត្យឡើងវិញលើឯកសារគម្រោងរបស់ IFC និងសម្ភារផ្សេងទៀតផ្តល់ដោយ IFC និង ABBank ។
- ការពិនិត្យឡើងវិញលើឯកសារដែលអាចស្វែងរកបានជាសាធារណៈអំពីគម្រោងវារីអគ្គិសនីសេសានក្រោម២ និង EVNI ព្រមទាំងព័ត៌មានអនុគម្រោង ដែលបានផ្តល់ដោយភាគី និងភាគីពាក់ព័ន្ធដទៃទៀត។
- បទសម្ភាសន៍ជាមួយបុគ្គលិក IFC បុគ្គលិក ABBank ដើមបណ្តឹង មន្ត្រីរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងទៀត។

ស៊ីអេអូ បានបំពេញទស្សនកិច្ចនៅវៀតណាម និងកម្ពុជា ក្នុងខែតុលា ឆ្នាំ២០២៣។ ក្នុងដំណើរទស្សនកិច្ចនេះ ស៊ីអេអូ ជួបជាមួយបុគ្គលិក IFC និង ABBank នៅវៀតណាម។ នៅកម្ពុជា ស៊ីអេអូ បានទៅជួបសហគមន៍ដើមបណ្តឹងចំនួនប្រាំ និងបានរៀបចំកិច្ចប្រជុំនៅទីនោះ ជាមួយនឹងការចូលរួមពីសមាជិកសហគមន៍ប្រមាណ ១០៥ នាក់។ មានការរៀបចំកិច្ចប្រជុំបន្ថែមមួយទៀត ជាមួយតំណាងប្រហែល ២០ នាក់ មកពីសហគមន៍រងផលប៉ះពាល់ផ្សេងទៀត ដែល ស៊ីអេអូ មិនបានចុះទៅសហគមន៍ទាំងនោះដោយផ្ទាល់។ ស៊ីអេអូ ក៏បានជួបជាមួយអង្គការសង្គមស៊ីវិលចំនួន ១០ ដែលធ្វើការជាមួយសហគមន៍ និងមានចំណេះដឹងអំពីបរិបទ បទពិសោធន៍របស់សហគមន៍រងផលប៉ះពាល់ និងអនុគម្រោង។ លើសពីនេះ ស៊ីអេអូ បានជួបជាមួយអង្គការក្រៅរដ្ឋាភិបាលដែលគាំទ្រសហគមន៍របស់ដើមបណ្តឹង មន្ត្រីរដ្ឋាភិបាលជាតិ នៃក្រសួងបរិស្ថាន ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងរ៉ែ និងថាមពល វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប (IFReDI) និងតំណាងមូលដ្ឋាន នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង។ ដូចដែលបានពន្យល់នៅក្នុងផ្នែកបន្ទាប់ ស៊ីអេអូ មិនបានជួបបុគ្គលិក LS2 ឬទៅកាន់ទីតាំងអនុគម្រោងទេ។ ស៊ីអេអូ ក៏បានធ្វើបទសម្ភាសន៍ជាលក្ខណៈបុគ្គល ជាមួយបុគ្គលិក IFC ចំនួន ១៥ នាក់ ដែលមាន ឬជាប់ពាក់ព័ន្ធនៅក្នុងគម្រោង ឬអ្នកដែលមានព័ត៌មានពាក់ព័ន្ធ ទាក់ទងនឹងសំណុំរឿងនេះ។

## 2.6 ស៊ីអេអូ ខ្វះលទ្ធភាពក្នុងការជួបជាមួយអតិថិជនបន្ត និងអនុគម្រោងរបស់ IFC

ក្នុងអំឡុងពេលស៊ើបអង្កេតភាពអនុលោមនេះ ស៊ីអេអូ មិនបានជួបអតិថិជនរងរបស់ IFC ក្រុមហ៊ុន EVNI ឬអនុគម្រោង LS2 ទេ។ ស៊ីអេអូ បានព្យាយាមជាច្រើនលើកច្រើនដងចង់ជួបជាមួយក្រុមហ៊ុន EVNI និងក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ ដើម្បីដាក់បញ្ចូលទស្សនៈរបស់ពួកគេលើបញ្ហាដែលបានលើកឡើងក្នុងសំណុំរឿងនេះ ហើយពិចារណាលើព័ត៌មាន និងឯកសារជាក់លាក់ណាមួយនៃគម្រោង។ ការព្យាយាមទាំងនេះ ដូចមានសង្ខេបខាងក្រោម មិនបានជោគជ័យទេ៖

- ចាប់តាំងពីការចាប់ផ្តើមនៃការស៊ើបអង្កេតភាពអនុលោមនេះ ស៊ីអេអូបានស្នើសុំជាច្រើនដង នៅចន្លោះខែកុម្ភៈ ឆ្នាំ២០២៣ ដល់ខែឧសភា ឆ្នាំ២០២៤ ដោយបានស្នើ ABBank ផ្តល់ (i) ព័ត៌មានទំនាក់ទំនងសម្រាប់អ្នកតំណាង EVNI និងសមាជិកក្រុមប្រឹក្សាភិបាលរបស់ EVNI នៅក្នុងគម្រោងសេសានក្រោម២ (ii) ឯកសារគាំទ្រនៃទំនាក់ទំនងហិរញ្ញវត្ថុរបស់ ABBank ជាមួយ EVNI និងរវាង EVNI និងគម្រោង LS2

និង (iii) ឯកសារ និងកំណត់ត្រាផ្ទៃក្នុងរបស់ធនាគារ ABBank ទាក់ទងនឹងការគ្រប់គ្រងហានិភ័យ E&S និងការគ្រប់គ្រងការវិនិយោគ EVNI របស់ខ្លួន។[72] ABBank បានបញ្ជាក់នៅក្នុងកិច្ចប្រជុំជាច្រើនដងជាមួយ ស៊ីអេអូ ថាខ្លួនមានព័ត៌មានទំនាក់ទំនងសម្រាប់ប្រធាន EVNI ដែលជាអ្នកតំណាងរបស់ EVNI នៅក្នុងក្រុមប្រឹក្សាភិបាល LS2 ទេ។[73] ទោះជាយ៉ាងណាក៏ដោយ នៅក្នុងខែមិថុនា ឆ្នាំ២០២៤ ABBank បានជូនដំណឹងដល់ IFC ថា EVNI មិនបានយល់ព្រមឱ្យ ABBank ផ្តល់ជូន ស៊ីអេអូ នូវព័ត៌មានទំនាក់ទំនងដែលបានស្នើសុំ ឬឯកសារគាំទ្រ ជាពិសេសកិច្ចព្រមព្រៀងផ្លូវច្បាប់ដែលគ្រប់គ្រងទំនាក់ទំនងហិរញ្ញវត្ថុរបស់ពួកគេ ទេ។ ABBank បានពន្យល់ថា ច្បាប់ជាតិតម្រូវឱ្យពួកគេមានការយល់ព្រមពី EVNI ដើម្បីផ្តល់ព័ត៌មាននេះដល់ ស៊ីអេអូ ។ ដូច្នេះ ស៊ីអេអូ មិនអាចទាក់ទងដោយផ្ទាល់ទៅកាន់អតិថិជនបន្ត ឬអនុគម្រោងបានទេ ហើយក៏មិនអាចពិនិត្យមើលដោយផ្ទាល់នូវកិច្ចព្រមព្រៀងផ្លូវច្បាប់ ឬឯកសារគាំទ្រនៃទំនាក់ទំនងហិរញ្ញវត្ថុ រវាង EVNI និង ABBank ឬរវាង EVNI និងគម្រោង LS2 ដែរ។ ទាក់ទងនឹងកំណត់ត្រា និងឯកសារផ្ទៃក្នុងរបស់ធនាគារ ABBank អតិថិជនបានពន្យល់ថា ឯកសារភាគច្រើននៃការវិនិយោគរបស់ខ្លួននៅក្នុង EVNI គឺមិនមានទេ ដោយសារពេលវេលាកន្លងផុតទៅ និងការផ្លាស់ប្តូរបុគ្គលិក។ ទោះជាយ៉ាងនេះក្តី ស៊ីអេអូ កត់សម្គាល់ថា ព័ត៌មានភាគច្រើនដែលបានស្នើសុំ រួមមានកំណត់ត្រាផ្លូវការដូចជាដំណោះស្រាយក្រុមប្រឹក្សាភិបាល ដែលគ្រប់គ្រងទំនាក់ទំនងហិរញ្ញវត្ថុសកម្ម រវាង ABBank និង EVNI និងព័ត៌មាន E&S ទាក់ទងនឹងប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) របស់ ABBank ។

- ស៊ីអេអូ ក៏បានព្យាយាមទាក់ទងទៅ EVNI និង LS2 តាមរយៈព័ត៌មានទំនាក់ទំនងដែលអាចស្វែងរកបានជាសាធារណៈ ផងដែរ។ នៅខែកញ្ញា ឆ្នាំ២០២៣ ស៊ីអេអូ បានផ្ញើអ៊ីមែលទៅ EVNI និងក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ [74] ប៉ុន្តែមិនបានទទួលការឆ្លើយតបទេ។ បន្ទាប់ពីការព្យាយាមបន្ថែមទៀតក្នុងការទាក់ទងទៅក្រុមហ៊ុន តាមទូរស័ព្ទ តំណាង LS2 បានស្នើឱ្យ ស៊ីអេអូ ដាក់សំណើតាមរយៈក្រសួងរ៉ែ និងថាមពល នៅកម្ពុជា ដែល ស៊ីអេអូ បានអនុវត្តតាម។ មន្ត្រីនៃក្រសួងនេះ បានជួបជាមួយក្រុមការងារស៊ីអេអូ ប៉ុន្តែពួកគេមិនបានភ្ជាប់ទំនាក់ទំនង ស៊ីអេអូ ជាមួយបុគ្គលិកអនុគម្រោងទេ។
- ស៊ីអេអូ បានទាក់ទងតាមអ៊ីម៉ែល ទូរស័ព្ទ ទូរសារ និងអ្នកនាំសំបុត្រ ទៅកាន់ក្រុមហ៊ុន Hydrolancang

---

[72] នៅចន្លោះខែធ្នូ ឆ្នាំ២០២២ ដល់ខែឧសភា ឆ្នាំ២០២៤ ស៊ីអេអូ បានទាក់ទង និងតាមដានជាមួយ ABBank ជាច្រើនដង ដើម្បីស្នើសុំព័ត៌មាននេះ (អ៊ីម៉ែលស៊ីអេអូ ចុះថ្ងៃទី៨ និង១៤ ខែធ្នូ ឆ្នាំ២០២២; ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣; ថ្ងៃទី២៤, ២៥, ២៨, ២៩, ៣០ ខែសីហា ឆ្នាំ២០២៣; ថ្ងៃទី៦,១៧, ២៥, ៣០ ខែកញ្ញា ឆ្នាំ២០២៣; ថ្ងៃទី ៣ ខែតុលា ២០២៣; ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣; ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៣ និងការចុះទីតាំងភាពអនុលោមស៊ីអេអូ ថ្ងៃទី១៦-១៧ ខែតុលា ឆ្នាំ២០២៣។

[73] ស៊ីអេអូ បានធ្វើកិច្ចប្រជុំតាមអនឡាញជាមួយ ABBank នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៣ និងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ហើយបានដឹកនាំបេសកកម្មភាពអនុលោម ស៊ីអេអូ ទៅកាន់ប្រទេសវៀតណាមនៅថ្ងៃទី ១៦-១៧ ខែតុលា ឆ្នាំ២០២៣។

[74] អ៊ីម៉ែលបានផ្ញើទៅប្រធាន និងតំណាងអាជីវកម្មរបស់ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ នៅកម្ពុជា និងទៅកាន់ប្រធាន EVNI និងជនបង្គោលទាក់ទងនឹង LS2 នៅប្រទេសវៀតណាមនៅថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ២០២៣។

International Energy ដែលជាម្ចាស់ភាគហ៊ុនច្រើនជាងគេ របស់ LS2 [75] ប៉ុន្តែមិនបានទទួលការឆ្លើយតបទេ។

កិច្ចព្រមព្រៀងផ្លូវច្បាប់ រវាង IFC និង ABBank ចែងថា អតិថិជននឹងផ្តល់ឱ្យ ស៊ីអេអូ ដែលជាយន្តការគណនេយ្យភាពឯករាជ្យរបស់ IFC នូវកំណត់ត្រារបស់ ABBank ទាំងអស់ ក៏ដូចជាកំណត់ត្រារបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ បុគ្គលិក និងភ្នាក់ងារដែលអាចមានចំណេះដឹងអំពីបញ្ហាដែល ស៊ីអេអូ ស្វែងរកព័ត៌មាន។[76] ស៊ីអេអូ កត់សម្គាល់ថា គំហើញនានានៅក្នុងការស៊ើបអង្កេតនេះ មិនទទួលបានអត្ថប្រយោជន៍ពីការពិនិត្យឡើងវិញពេញលេញនៃព័ត៌មានគម្រោង និងអនុគម្រោងទេ ដោយសារកង្វះខាតរបស់ ស៊ីអេអូ ក្នុងការទទួលបានកំណត់ត្រានានា និងទាក់ទងភ្នាក់ងាររបស់អតិថិជនបន្ត និងអនុគម្រោង ដែលជាការបំពានលើកិច្ចព្រមព្រៀងផ្លូវច្បាប់នេះ។ ទោះជាយ៉ាងនេះក្តី ថ្វីត្បិត មានការខ្វះខាតព័ត៌មានទាំងនេះក៏ដោយ ក៏ស៊ីអេអូ ចាត់ទុកថា គំហើញនានារបស់ខ្លួនទៅលើបញ្ហានៃពាក្យបណ្តឹង ត្រូវបានគាំទ្រដោយភស្តុតាងពាក់ព័ន្ធគ្រប់គ្រាន់ ដែលត្រូវបានពិពណ៌នានៅក្នុងផ្នែកពាក់ព័ន្ធនីមួយៗ។

## 2.7 គោលនយោបាយ IFC ដែលអាចអនុវត្តបាន

គោលនយោបាយ ឆ្នាំ២០០៦ របស់ IFC ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម (គោលនយោបាយនិរន្តរភាព) និងស្តង់ដារសមិទ្ធិកម្ម ដែលឯកសារទាំងពីរនេះរួមគ្នាហៅថា ក្របខ័ណ្ឌនិរន្តរភាព អាចអនុវត្តបាននៅពេលដែល IFC បានធ្វើការវិនិយោគឆ្នាំ២០១០ របស់ខ្លួន នៅក្នុងធនាគារ ABBank។ ក្នុងឆ្នាំ២០១២ IFC បានធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌនិរន្តរភាពរបស់ខ្លួន។[77]

---

[75] នៅខែកញ្ញា និងខែតុលា ឆ្នាំ ២០២៣ ស៊ីអេអូ បានផ្ញើអ៊ីម៉ែល ទូរសារ និងផ្ញើសំបុត្រតាមអ្នកនាំសំបុត្រ ទៅកាន់អាសយដ្ឋានអ៊ីម៉ែលផ្សេងគ្នា និងអាសយដ្ឋានរូបវន្តពីរផ្សេងគ្នា សម្រាប់ប្រធានក្រុមប្រឹក្សាភិបាល និងនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស នៃក្រុមហ៊ុន Hydrolancang International Energy នៅប្រទេសចិន។ ស៊ីអេអូ បានទទួលការបញ្ជាក់តាមទូរស័ព្ទថា សំបុត្រទាំងនោះត្រូវបានទទួលក្នុងខែតុលា ឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយក្រុមហ៊ុន Hydrolancang International Energy មិនបានឆ្លើយតបមកកាន់ ស៊ីអេអូ ទេ។

[76] ការអនុវត្តនេះ ក្រោយមកត្រូវបានបង្កើតឡើង ជាលក្ខខណ្ឌគម្រូសម្រាប់កិច្ចព្រមព្រៀងផ្លូវច្បាប់របស់ IFC និង MIGA ទាំងអស់ នៅក្នុងកថាខណ្ឌ ២៦ នៃគោលនយោបាយ ស៊ីអេអូ ដែលបង្ហាញថា "កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន ឬការផ្តល់ការប្រឹក្សាយោបល់ និងកិច្ចសន្យានៃការធានា រវាង IFC/MIGA និងអតិថិជនរបស់ពួកគេ នឹងរួមបញ្ចូលកាតព្វកិច្ចសម្រាប់អតិថិជនក្នុងការអនុញ្ញាតឱ្យ ស៊ីអេអូ (i) មានសិទ្ធិចូលទៅកាន់កំណត់ត្រារបស់អតិថិជនដែលទាក់ទងនឹងគម្រោង និងក្នុងករណីអតិថិជនអន្តរការីហិរញ្ញវត្ថុ (FI) មានសិទ្ធិទទួលកំណត់ត្រារបស់អតិថិជន FI ពាក់ព័ន្ធនឹងអតិថិជនបន្ត និងអនុគម្រោងនានាដែលពាក់ព័ន្ធ ព្រមទាំង (ii) ចុះទៅទីតាំង និងត្រួតពិនិត្យគម្រោង ក្នុងគោលបំណងអនុវត្តតួនាទីរបស់ ស៊ីអេអូ ដូចមានចែងនៅក្នុងគោលនយោបាយនេះ តបតាមការជូនដំណឹងជាមុនដែលសមហេតុផល ដល់អតិថិជន និងជាកម្មវត្ថុនៃច្បាប់ និងបទប្បញ្ញត្តិជាធរមាន" ។

[77] ស៊ីអេអូ កត់សម្គាល់ថា IFC បានអះអាងថា គោលនយោបាយនិរន្តរភាពឆ្នាំ ២០១២ មិនអនុវត្តចំពោះការវិនិយោគនេះទេ។ ក្នុងន័យនេះ ដូចដែល ស៊ីអេអូ បានចង្អុលបង្ហាញនៅក្នុងករណីមុន (សូមមើលការវាយតម្លៃភាពអនុលោម, ប្រទេសប៉េរូ: Anglo American Quellaveco SA,

គោលនយោបាយនិរន្តរភាពឆ្នាំ២០០៦ របស់ IFC ចែងថា "កិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តសកម្មភាពវិនិយោគ និងការផ្តល់ការប្រឹក្សា ជាមួយនឹងចេតនា 'មិនបង្កគ្រោះថ្នាក់' ដល់មនុស្ស និងបរិស្ថាន" គឺជា "ចំណុចស្នូលនៃបេសកកម្មអភិវឌ្ឍន៍របស់ IFC ។"[78] ដើម្បីជួយបំពេញអាណត្តិនេះ IFC ស្វែងរកការធានាថាគម្រោងដែលខ្លួនផ្តល់ហិរញ្ញប្បទាន ត្រូវបាន "ដំណើរការស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធិកម្ម។"[79]

---

ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣, ទំព័រ៦; របាយការណ៍ស៊ើបអង្កេត ស៊ីអេអូ, IFC Investment in Minera Quellaveco SA ប្រទេសប៉េរូ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤, ទំព័រ១៧; #២៩៨៣), ពាក្យបណ្តឹង ០៤-០៧, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥, ទំព័រ៩), ថា ស៊ីអេអូ ត្រូវតែអនុវត្តគោលនយោបាយរបស់ IFC ដូចដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

- គោលនយោបាយនិរន្តរភាពឆ្នាំ២០១២ ត្រូវបានអនុម័តដោយក្រុមប្រឹក្សា ដើម្បី "ចូលជាធរមាន នៅខែមករា ឆ្នាំ២០១២" ដោយគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ក្រោយមក គណៈគ្រប់គ្រង IFC បានបង្ហាញនៅលើគេហទំព័ររបស់ខ្លួនថា គោលនយោបាយនិរន្តរភាពឆ្នាំ២០១២ នឹងអនុវត្តចំពោះ "គម្រោងវិនិយោគ និងប្រឹក្សាយោបល់ ដែលឆ្លងកាត់ដំណើរការពិនិត្យតណទានដំបូងរបស់ IFC ក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០១២"។ ទោះជាយ៉ាងនេះក្តី ស៊ីអេអូ ត្រូវតែអនុវត្តគោលនយោបាយ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងដោយគ្មានដែនកំណត់ ដែលកម្រិតបន្ថែមដោយគណៈគ្រប់គ្រង IFC ទេ។ ដូច្នេះ ក្នុងករណីនេះ កាតព្វកិច្ចត្រួតពិនិត្យរបស់ IFC ត្រូវបានគ្រប់គ្រងដោយគោលនយោបាយនិរន្តរភាពឆ្នាំ២០១២ ចាប់ពីខែមករា ឆ្នាំ ២០១២ តទៅ។
- ក្នុងការអនុវត្តជាក់ស្តែង ភាពខុសគ្នាក្នុងករណីនេះធ្វើឱ្យមានភាពខុសប្លែកគ្នាតិចតួចនៅក្នុងកាតព្វកិច្ចត្រួតពិនិត្យរបស់ IFC ដោយសារទាំងគោលនយោបាយនិរន្តរភាពឆ្នាំ២០០៦ និងឆ្នាំ២០១២ ក៏ដូចជា ESRPs ទាំងអស់ ដែលមាននៅក្នុងអំឡុងពេលវដ្តនៃការវិនិយោគនេះ (២០១០-២៤) ទាមទារថា IFC ត្រួតពិនិត្យភាពអនុលោមតាមការប្តេជ្ញាចិត្តរបស់អតិថិជន "ដូចបានបង្ហាញនៅក្នុងផែនការសកម្មភាព ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយ IFC។" IFC, គោលនយោបាយនិរន្តរភាព ២០០៦, កថាខណ្ឌ ២៦, IFC, គោលនយោបាយនិរន្តរភាពឆ្នាំ២០១២, កថាខណ្ឌ ២៤។
- ទន្ទឹមនឹងនេះ កាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់រវាង IFC និង ABBank គួរតែត្រូវបានអនុវត្ត ដូចដែលបានបង្កើតឡើងនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ ដែលមិនត្រូវបានកែប្រែឡើយ។ ចំណុចត្រង់នេះមានន័យថា កាតព្វកិច្ចរបស់អតិថិជន (ABBank) នៅតែស្ថិតក្រោមស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ ហើយអតិថិជនមានកាតព្វកិច្ចអនុវត្តគោលនយោបាយ SEMS របស់ខ្លួនចំពោះការវិនិយោគថ្មីៗ និងការវិនិយោគដែលមានស្រាប់ នៅក្នុងអំឡុងពេលវដ្តជីវិតនៃការវិនិយោគ។
- IFC បានអះអាងថា ប្រសិនបើគោលនយោបាយនិរន្តរភាពឆ្នាំ២០១២ អនុវត្តចំពោះកាតព្វកិច្ចត្រួតពិនិត្យរបស់ IFC នោះ កថាខណ្ឌ ៣៧ នៃគោលនយោបាយនិរន្តរភាពឆ្នាំ២០១២ ក៏គួរអនុវត្តផងដែរ ដែលនេះបង្ហាញថា លក្ខខណ្ឌតម្រូវ E&S នឹងអនុវត្តចំពោះផលប័ត្រទាំងមូលនៃ FI ដែលមានដើមកំណើតតាំងពីពេលដែល IFC ក្លាយជាម្ចាស់ភាគហ៊ុន ឬវិនិយោគិនមកម្ល៉េះ។ ទោះជាយ៉ាងណាក៏ដោយ ស៊ីអេអូ កត់សម្គាល់ថា ខណៈដែលគោលនយោបាយនិរន្តរភាពឆ្នាំ២០១២ អនុវត្តចំពោះកាតព្វកិច្ចត្រួតពិនិត្យរបស់ IFC ចាប់ពីខែមករា ឆ្នាំ២០១២ តទៅ កថាខ័ណ្ឌ៣៧ មិនធ្វើឱ្យគ្មានសុពលភាពនៃការប្តេជ្ញាចិត្តផ្លូវច្បាប់ ដែលបានធ្វើឡើងមុនគោលនយោបាយនិរន្តរភាពឆ្នាំ២០១២ ដែលមិនធ្លាប់បានកែប្រែ នោះទេ។

[78] IFC, "គោលនយោបាយរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីនិរន្តរភាពសង្គម និងបរិស្ថាន" IFC (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៦) កថាខណ្ឌ ៨, https://bit.ly/4fy6hgP; IFC, "គោលនយោបាយរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម" IFC (ថ្ងៃទី១ ខែមករា ឆ្នាំ២០១២) កថាខណ្ឌ ៩, https://bit.ly/40TvfTI ។

[79] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ 5។ គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ដាក់បញ្ចូលលក្ខខណ្ឌស្រដៀងគ្នា នៅពេលវាចែងថា "សំណើវិនិយោគ ដែលត្រូវបានកំណត់ថាមានហានិភ័យបរិស្ថាន និង/ឬសង្គម កម្រិតមធ្យមទៅកម្រិតខ្ពស់ ឬអាចនឹងមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និង/ឬសង្គម នឹងត្រូវអនុវត្ត ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធិកម្ម។" គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ៣។

ជាជំហានដំបូង IFC តម្រូវឱ្យធ្វើការត្រួតពិនិត្យបរិស្ថាន និងសង្គម មុនពេលសកម្មភាពវិនិយោគទាំងអស់របស់ខ្លួនកើតឡើង។ សម្រាប់អតិថិជនអន្តរការីហិរញ្ញវត្ថុដែលមានសក្តានុពល គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ ចែងថា IFC គួរតែ "ពិនិត្យឡើងវិញអាជីវកម្មរបស់អតិថិជន FI របស់ខ្លួន" "តាមរយៈនីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គមរបស់ខ្លួន" និង "កំណត់សកម្មភាពដែល FI អាចពើបប្រទះនឹងហានិភ័យបរិស្ថាន និងសង្គម ដែលជាលទ្ធផលនៃការវិនិយោគរបស់ខ្លួន។"[80] ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យបរិស្ថាន និងសង្គម IFC នឹងតម្រូវឱ្យអតិថិជន FI អនុវត្តតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយ E&S "សមាមាត្រទៅនឹងកម្រិតនៃហានិភ័យដែលអាចនឹងកើតមានឡើង" បង្កឡើងដោយសកម្មភាពអាជីវកម្មរបស់ខ្លួន។[81] ក្នុងគ្រប់ករណីទាំងអស់ FIs គឺ "តម្រូវឱ្យបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន ដើម្បីធានាថាការវិនិយោគរបស់ខ្លួនបំពេញតាមលក្ខខណ្ឌតម្រូវរបស់ IFC ។"[82]

ក្រោយពេលគម្រោងមួយត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ IFC ដោយមានការប្តេជ្ញាចិត្ត និងការបញ្ចេញថវិកា IFC តាមដានការអនុវត្តរបស់ FI តាមរយៈប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថានរបស់អតិថិជន[83] និង "ការប្តេជ្ញាចិត្តរបស់អតិថិជន នៅក្នុងផែនការសកម្មភាព [ណាមួយ] [ដែលបានយល់ព្រម] ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយ IFC ។"[84] ទាំងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ និងឆ្នាំ២០១២ កំណត់ថា ក្នុងករណីដែល

---

[80] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨។ តម្រូវការស្រដៀងគ្នានេះ ត្រូវបានដាក់បញ្ចូលនៅក្នុងគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌ ៣៤) ដែលចូលជាធរមាននាពេលបច្ចុប្បន្ន "ដើម្បីកំណត់ឱ្យបានត្រឹមត្រូវនូវហានិភ័យបរិស្ថាន និងសង្គម ពាក់ព័ន្ធនឹងការវិនិយោគរបស់ FI ក្នុងអំឡុងពេលដំណើរការវាយតម្លៃ IFC ពិនិត្យមើលផលប័ត្រដែលមានស្រាប់ និងសកម្មភាពអាជីវកម្មនាពេលអនាគតរបស់អតិថិជន FI របស់ខ្លួន ដើម្បីកំណត់សកម្មភាពដែល FIs និង IFC អាចប្រឈមនឹងហានិភ័យ ដែលជាលទ្ធផលនៃការវិនិយោគរបស់ពួកគេ និងកំណត់តម្រូវការសម្រាប់ការគ្រប់គ្រងហានិភ័យទាំងនេះ។ IFC ពិនិត្យមើលសមត្ថភាពអនុវត្តរបស់ FIs ក៏ដូចជា ESMS របស់ពួកគេ ដូចបានតម្រូវនៅក្នុងស្តង់ដារសមិទ្ធិកម្ម ១"។

[81] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨។

[82] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ ២០០៦ កថាខណ្ឌ ២៩។ សូមមើលផងដែរ គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ ២០១២ កថាខន្ឌ ៣៣ និង ៣៥។

[83] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ ២០០៦ កថាខណ្ឌ ២៨។

[84] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ ២០០៦ កថាខណ្ឌ ២៦; គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២, កថាខណ្ឌ ២៤ និង ២៥; IFC ESRP ២០០៩ ផ្នែក 10.2.7; IFC ESRP ២០១៤ ផ្នែក 2.1; IFC ESRP ២០១៦, ផ្នែក, 9.2.1; IFC ESRP ២០២២ និង IFC ESRP ២០២៣ ផ្នែក 4.2 ។ គោលនយោបាយនិរន្តរភាពឆ្នាំ ២០១២ (កថាខណ្ឌ ២៤) កំណត់ថា "កិច្ចព្រមព្រៀងរបស់ IFC ទាក់ទងនឹងការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពរបស់អតិថិជន រួមមានបទប្បញ្ញត្តិជាក់លាក់មួយចំនួន ដែលអតិថិជនត្រូវអនុលោមតាម។ បទប្បញ្ញត្តិទាំងនេះ រួមមានការអនុលោមតាមលក្ខខណ្ឌតម្រូវអាចអនុវត្តបាន នៃស្តង់ដារសមិទ្ធិកម្ម និងលក្ខខណ្ឌជាក់លាក់នានាដែលបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព ក៏ដូចជាបទប្បញ្ញត្តិពាក់ព័ន្ធសម្រាប់ការរាយការណ៍អំពីបរិស្ថាន និងសង្គម និងការចុះមូលដ្ឋានត្រួតពិនិត្យដោយបុគ្គលិក ឬតំណាងរបស់ IFC តាមការសមស្រប។ *ប្រសិនបើអតិថិជនបរាជ័យក្នុងការអនុលោមតាមការប្តេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម ដូចបានអះអាងនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងឯកសារពាក់ព័ន្ធ* នោះ IFC នឹងធ្វើការជាមួយអតិថិជនដើម្បីនាំយកពួកគេមក

អតិថិជនខកខានអនុវត្តតាមការប្តេជ្ញាចិត្ត E&S របស់ខ្លួន នៅក្នុងផែនការសកម្មភាព ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយ IFC នោះ IFC ត្រូវតែ "ធ្វើការជាមួយអតិថិជនឱ្យត្រលប់មករកភាពអនុលោមវិញ ទៅតាមកម្រិតណាមួយដែលអាចធ្វើទៅបាន ហើយប្រសិនបើអតិថិជនបរាជ័យក្នុងការបង្កើតភាពអនុលោមឡើងវិញ អនុវត្តដំណោះស្រាយនៅពេលសមស្រប។"[85]

សម្រាប់ FIs ដែលផ្តល់ហិរញ្ញប្បទានគម្រោង លក្ខខណ្ឌតម្រូវ E&S របស់ IFC ត្រូវរួមបញ្ចូល "ស្តង់ដារសមិទ្ធិកម្មដែលសកម្មភាពទទួលបានហិរញ្ញប្បទាន បង្ហាញពីហានិភ័យសង្គម ឬបរិស្ថានចម្បងៗ។"[86] ស្តង់ដារសមិទ្ធិកម្មរបស់ IFC ខាងក្រោមនេះ គឺពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ដើមបណ្តឹងអំពីគ្រោះថ្នាក់ ពាក់ព័ន្ធនឹងគម្រោងវារីអគ្គិសនីសេសានក្រោម២៖

- *PS១ (ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃសង្គម និងបរិស្ថាន)* តម្រូវឱ្យអតិថិជន និងអតិថិជនបន្ត ចូលរួមជាមួយសហគមន៍រងផលប៉ះពាល់ តាមរយៈការបង្ហាញព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមដោយមានព័ត៌មានគ្រប់គ្រាន់ ក្នុងលក្ខណៈសមស្របទៅនឹងហានិភ័យ និងផលប៉ះពាល់នានាមកលើសហគមន៍រងផលប៉ះពាល់។[87] អតិថិជនតម្រូវឱ្យបង្កើតយន្តការបណ្តឹងសារទុក្ខ ដើម្បីទទួល ឆ្លើយតប

---

អនុលោមឡើងវិញ ហើយប្រសិនបើអតិថិជនខកខានក្នុងការបង្កើតភាពអនុលោមឡើងវិញ នោះ IFC នឹងអនុវត្តសិទ្ធិ និងដំណោះស្រាយរបស់ខ្លួន តាមការគួរ។" លើសពីនេះ កថាខណ្ឌ៤៥ នៃគោលនយោបាយដូចគ្នានេះ កំណត់ថា ដើម្បីត្រួតពិនិត្យការវិនិយោគ FI, IFC ត្រូវតែ "អនុវត្តកម្មវិធីត្រួតពិនិត្យការវិនិយោគរបស់ FI ជាទៀងទាត់ ទៅលើហានិភ័យបរិស្ថាន និងសង្គម និង/ឬផលប៉ះពាល់នានា ស្របតាមលក្ខខណ្ឌតម្រូវនៃនិតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម របស់ IFC ។" ទន្ទឹមនឹងនេះ នីតិវិធី E&S របស់ IFC ដែលអាចអនុវត្តបានក្នុងអំឡុងពេលនៃជីវិតវិនិយោគទាំងអស់ បានឆ្លុះបញ្ចាំងពីកាតព្វកិច្ចក្នុងការត្រួតពិនិត្យការប្តេជ្ញាចិត្តរបស់អតិថិជន និងផែនការសកម្មភាពដែលបានព្រមព្រៀង នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់។ ESRP របស់ IFC ឆ្នាំ២០០៩ (ផ្នែកទី 10.2.7) បង្ហាញថា ការត្រួតពិនិត្យលើការវិនិយោគរបស់ FI គួរតែរួមបញ្ចូលការពិនិត្យឡើងវិញនូវការអនុវត្តរបស់អតិថិជនប្រៀបធៀបនឹងលក្ខខណ្ឌតម្រូវឱ្យមានការអនុវត្តតាមដែលអាចធ្វើបាន និងស្ថានភាពនៃការអនុវត្តផែនការ SEMS របស់អតិថិជន។ នីតិវិធីនេះត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ ២០១៤ ហើយ ESRP របស់ IFC ឆ្នាំ ២០១៤ និង ២០១៦ (ផ្នែក 9.2.1) បង្ហាញថាការត្រួតពិនិត្យរបស់ FI រួមបញ្ចូល "ការវាយតម្លៃកម្រិតនៃភាពអនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់អតិថិជន ដែលរួមទាំងលក្ខខណ្ឌទាំងអស់នៃការទូទាត់ ធាតុនានានៃផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) និងកិច្ចព្រមព្រៀង E&S ផ្សេងទៀតដែលបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់។" នីតិវិធីត្រូវបានធ្វើបច្ចុប្បន្នភាពម្តងទៀត នៅឆ្នាំ ២០២២ និង ២០២៣ ESRPs ដែលគោលបំណងដំបូងនៃការត្រួតពិនិត្យ E&S ត្រូវបានរាយបញ្ជីជា "ការវាយតម្លៃស្ថានភាពនៃភាពអនុលោមរបស់អតិថិជន ស្របតាមលក្ខខណ្ឌតម្រូវ E&S នៃកិច្ចសន្យាវិនិយោគ (រួមទាំង ESAP, COD, កិច្ចព្រមព្រៀងបញ្ជាក់ និងភាពអវិជ្ជមាន និងលក្ខខណ្ឌតម្រូវឱ្យមានរបាយការណ៍)" (បញ្ជាក់បន្ថែម)។

[85] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៦; គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ២៤។

[86] គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨។

[87] PS១ តម្រូវឱ្យអតិថិជនអនុវត្តដំណើរការបន្តនៃការចូលរួមសហគមន៍។ គោលបំណងនៃការចូលរួមសហគមន៍ គឺដើម្បីកសាង និងរក្សា

និងសម្របសម្រួលការដោះស្រាយក្ដីកង្វល់ និងបណ្ដឹងសារទុក្ខរបស់សហគមន៍រងផលប៉ះពាល់ពីការអនុវត្ត E&S របស់អតិថិជន។[88] លក្ខខណ្ឌតម្រូវទៅលើការពិគ្រោះយោបល់គម្រោង និងយន្តការបណ្ដឹងសារទុក្ខក៏មាននៅក្នុង PS ៥, ៦, ៧ និង ៨ ផងដែរ។

- *PS៤ (សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍)*៖ តម្រូវឱ្យអតិថិជនជៀសវាង ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានឱ្យនៅកម្រិតអប្បបរមា ចំពោះសកម្មភាពគម្រោងនានា ប៉ះពាល់ទៅលើដី ទឹក និងធនធានធម្មជាតិផ្សេងទៀត ដែលសហគមន៍រងផលប៉ះពាល់កំពុងប្រើប្រាស់។[89] លក្ខខណ្ឌតម្រូវទាំងនេះអនុវត្តជាចម្បងចំពោះគម្រោងទាំងឡាយណា ដែលអាចបណ្ដាលឱ្យមានការផ្លាស់ប្ដូរយ៉ាងសំខាន់ចំពោះបរិស្ថានរូបវន្ត រួមទាំងរបបធារាសាស្ត្រ ផងដែរ។ នៅក្នុងករណីទាំងនេះ ការប្រុងប្រយ័ត្នពិសេស គួរតែត្រូវបានអនុវត្តដើម្បីទប់ស្កាត់អស្ថិរភាពភូមិសាស្ត្រ គ្រប់គ្រងលំហូរទឹកដោយសុវត្ថិភាពពេលមានព្យុះ ទប់ស្កាត់ការថយចុះនៃទឹកលើផ្ទៃដី និងទឹកក្រោមដី សម្រាប់ការប្រើប្រាស់របស់មនុស្ស និងកសិកម្ម (អាស្រ័យលើប្រភពទឹក ដែលសហគមន៍ពឹងផ្អែកជាប្រពៃណី) និងការពារការរិចរិលគុណភាពនៃធនធានទាំងនេះ។ លក្ខខណ្ឌតម្រូវទាំងនេះក៏អនុវត្តចំពោះធនធានដី ដែលសហគមន៍ប្រើប្រាស់សម្រាប់កសិកម្ម ឬគោលបំណងផ្សេងទៀត ផងដែរ។[90]
- *PS៥ (លទ្ធកម្មដីធ្លី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត)*៖ តម្រូវឱ្យអតិថិជនជៀសវាង ឬកាត់បន្ថយការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត និងការផ្លាស់ទីលំនៅសេដ្ឋកិច្ច ឱ្យបានដល់កម្រិតអប្បបរមា ហើយនៅពេលដែលមិនអាចជៀសបាន អតិថិជនត្រូវរៀបចំផែនការយ៉ាងប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើអ្នកផ្លាស់ទីលំនៅ និងសហគមន៍។ នៅពេលដែលការផ្លាស់ទីលំនៅមិនអាចជៀសវាងបាន នោះ PS៥ តម្រូវឱ្យអតិថិជន "ផ្ដល់សំណងដល់អ្នកផ្លាស់ទីលំនៅ និងសហគមន៍ ចំពោះការបាត់បង់

---

ទំនាក់ទំនងប្រកបដោយការស្ថាបនាជាមួយសហគមន៍ ដែលអាចនឹងរងផលប៉ះពាល់ពីគម្រោង។ ការចូលរួមសហគមន៍ ត្រូវតែគ្មានឧបាយកលពីខាងក្រៅ ការជ្រៀតជ្រែក ការបង្ខិតបង្ខំ និងការបំភិតបំភ័យអ្វីទាំងអស់ ហើយត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋាននៃព័ត៌មានទាន់ពេលវេលា ពាក់ព័ន្ធ អាចយល់បាន និងអាចទទួលបាន។ ជាផ្នែកមួយនៃដំណើរការចូលរួមសហគមន៍របស់ខ្លួន អតិថិជនត្រូវបានតម្រូវឱ្យបង្ហាញព័ត៌មានគម្រោងពាក់ព័ន្ធ ដែលជួយសហគមន៍រងផលប៉ះពាល់ឱ្យយល់ដឹងអំពីហានិភ័យ ផលប៉ះពាល់ និងឱកាសនានានៃប្រតិបត្តិការរបស់ក្រុមហ៊ុន។ គួរបង្ហាញពី ESIA និងផែនការសកម្មភាព ដែលអតិថិជនបានរៀបចំ។ នៅពេលដែលសហគមន៍ដែលរងផលប៉ះពាល់អាចប្រឈមនឹងហានិភ័យ ឬផលប៉ះពាល់អវិជ្ជមាននានាពីគម្រោង ការចូលរួមសហគមន៍បន្ថែមទៀតតម្រូវឱ្យអតិថិជនអនុវត្តដំណើរការពិគ្រោះយោបល់ ដែលផ្ដល់ឱកាសដល់សហគមន៍ដែលរងផលប៉ះពាល់ ដើម្បីបង្ហាញពីទស្សនៈរបស់ពួកគេចំពោះហានិភ័យ ផលប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់ ដែលអនុញ្ញាតឱ្យអតិថិជនពិចារណា និងឆ្លើយតបទៅកាន់សហគមន៍។ PS១ ឆ្នាំ២០០៦ កថាខណ្ឌ ១៦, ១៩–២១។

[88] យន្តការបណ្ដឹងសារទុក្ខគួរតែដោះស្រាយក្ដីកង្វល់ភ្លាមៗ ដោយប្រើដំណើរការដែលអាចយល់បាន និងមានតម្លាភាព សមស្របតាមវប្បធម៌ និងគ្រប់ផ្នែកនៃសហគមន៍ដែលរងផលប៉ះពាល់ អាចប្រើប្រាស់បានយ៉ាងងាយស្រួល ដោយសេរី និងគ្មានការសងសឹក។ PS១ ឆ្នាំ២០០៦, កថាខណ្ឌ ២៣។

[89] PS៤ ឆ្នាំ២០០៦, កថាខណ្ឌ ៩។

[90] កំណត់សម្គាល់សេចក្ដីណែនាំ ៤ ឆ្នាំ២០០៦, សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍, (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧),កថាខណ្ឌ G១៦។

ទ្រព្យសម្បត្តិ ក្នុងតម្លៃជំនួសពេញលេញ និងជំនួយផ្សេងទៀត ដើម្បីជួយពួកគេធ្វើឱ្យប្រសើរឡើង ឬយ៉ាងហោចណាស់ស្តារកម្រិតជីវភាព ឬមុខរបរចិញ្ចឹមជីវិតរបស់ពួកគេឡើងវិញ"។ PS5 ក៏តម្រូវឱ្យធ្វើជំរឿនទិន្នន័យមូលដ្ឋានសេដ្ឋកិច្ច-សង្គម ដើម្បីកំណត់អត្តសញ្ញាណបុគ្គលរងផលប៉ះពាល់ បង្កើតផែនការសកម្មភាពតាំងទីលំនៅថ្មី និងត្រួតពិនិត្យការអនុវត្តរបស់វា។ [91] ការតាំងទីលំនៅថ្មី ត្រូវបានចាត់ទុកថាពេញលេញទាំងស្រុង នៅពេលដែលផលប៉ះពាល់អវិជ្ជមាននានា ត្រូវបានដោះស្រាយតាមរបៀបមួយដែលស្របតាម PS៥ ។[92]នៅពេលដែលអតិថិជនប្រើប្រាស់ដីធ្លី បណ្តាលឱ្យបាត់បង់ទ្រព្យសម្បត្តិ ផលិតភាព ប្រាក់ចំណូល និង/ឬមុខរបរចិញ្ចឹមជីវិត (ការផ្លាស់ទីលំនៅសេដ្ឋកិច្ច) នោះ PS៥ តម្រូវឱ្យអតិថិជន៖[93](i) ផ្តល់សំណងភ្លាមៗដល់បុគ្គលដែលបានបាត់បង់ទ្រព្យសម្បត្តិ ឬបាត់បង់ការចូលប្រើប្រាស់ទ្រព្យសម្បត្តិ ដោយតម្លៃជំនួសពេញលេញ (ii) ផ្តល់ទ្រព្យជំនួស (ដូចជាដីកសិកម្ម) ដែលមានតម្លៃស្មើ ឬធំជាង ឬសំណងជាសាច់ប្រាក់ដល់បុគ្គលដែលមានសិទ្ធិទទួលស្របច្បាប់ ឬអាចធ្វើការទាមទារដែលទទួលស្គាល់ដោយច្បាប់ជាតិ (iii) ផ្តល់សំណងដល់បុគ្គល ដែលមិនមានការទាមទារទទួលស្គាល់ដោយច្បាប់ទៅលើដីធ្លី ចំពោះការបាត់បង់ទ្រព្យសម្បត្តិ ដូចជាដំណាំ ក្នុងតម្លៃជំនួសពេញលេញ (iv) ផ្តល់ជំនួយគោលដៅបន្ថែម និងឱកាសដល់អ្នករងផលប៉ះពាល់ យ៉ាងហោចណាស់ដើម្បីស្តារសមត្ថភាពរកប្រាក់ចំណូល កម្រិតផលិតកម្ម និងកម្រិតជីវភាពរបស់ពួកគេឡើងវិញ និង (v) ផ្តល់ការគាំទ្រអន្តរកាលដល់អ្នកផ្លាស់ទីលំនៅក្នុងរយៈពេលសមហេតុផលណាមួយ ដែលត្រូវការ ដើម្បីស្តារសមត្ថភាពរកប្រាក់ចំណូល កម្រិតផលិតកម្ម និងកម្រិតជីវភាពរស់នៅរបស់ពួកគេឡើងវិញ។ PS៥ ក៏តម្រូវឱ្យអតិថិជនបង្ហាញព័ត៌មានពាក់ព័ន្ធទាំងអស់ ដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ដោយសារការតាំងទីលំនៅថ្មី ដើម្បីជួយសម្រួលដល់ការចូលរួមរបស់ពួកគេនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដោយទទួលបានព័ត៌មានគ្រប់គ្រាន់ ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅរូបវ័ន្ត និងសេដ្ឋកិច្ចរបស់ពួកគេ និងដើម្បីបង្កើតយន្តការបណ្តឹងសារទុក្ខ ដើម្បីទទួល និងដោះស្រាយក្តីកង្វល់ជាក់លាក់អំពីសំណង និងការផ្លាស់ ទីលំនៅ រួមទាំង "យន្តការឧបាស្រ័យ ដែលបានធ្វើឡើងដើម្បីដោះស្រាយវិវាទក្នុងលក្ខណៈមិនលម្អៀង"។[94]

---

[91] លក្ខខណ្ឌតម្រូវនានារួមមាន៖ (i) ការធ្វើជំរឿនជាមួយនឹងទិន្នន័យមូលដ្ឋានសេដ្ឋកិច្ចសង្គមសមស្របមួយ ដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលនឹងត្រូវផ្លាស់ទីលំនៅដោយសារគម្រោង ដើម្បីកំណត់ថាអ្នកណានឹងមានសិទ្ធិទទួលបានសំណង និងជំនួយ និងដើម្បីបង្អាក់លំហូរចូលនៃមនុស្សដែលមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ទាំងនេះ (ii) ការបង្កើតផែនការសកម្មភាពតាំងទីលំនៅថ្មី ឬក្របខ័ណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី ដោយផ្អែកលើការវាយតម្លៃ E&S ដែលគ្របដណ្តប់លើលក្ខខណ្ឌតម្រូវដែលអាចអនុវត្តបាន នៅក្នុង PS៥ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការផ្លាស់ទីលំនៅ កំណត់ឱកាសអភិវឌ្ឍន៍ និងការបង្កើតសិទ្ធិទទួលបាននៃគ្រប់ទំរង់សម្រាប់បុគ្គលរងផលប៉ះពាល់ និង (iii) ការបង្កើតនីតិវិធីត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការតាំងទីលំនៅថ្មី និងចាត់វិធានការកែលម្អ តាមការចាំបាច់។ PS៥ ឆ្នាំ២០០៦ កថាខណ្ឌ ១១ និង ១២។

[92] PS៥ ឆ្នាំ២០០៦ កថាខណ្ឌ ១២។

[93] PS៥ ឆ្នាំ២០០៦ កថាខណ្ឌ ២០។

[94] PS៥ ឆ្នាំ២០០៦ កថាខណ្ឌ ៩–១០។

- *PS៦ (ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព)*៖ តម្រូវឱ្យអតិថិជនជៀសវាង ឬកាត់បន្ថយឱ្យមកនៅកម្រិតអប្បបរមានូវផលប៉ះពាល់អវិជ្ជមាននានាចំពោះជីវចម្រុះ នៅក្នុងតំបន់រងផលប៉ះពាល់គម្រោង និងដើម្បីវាយតម្លៃភាពធ្ងន់ធ្ងរនៃផលប៉ះពាល់គម្រោងមកលើជីវចម្រុះ ក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃសង្គម និងបរិស្ថាន។ ការវាយតម្លៃបែបនេះ គួរតែគិតគូរពីតម្លៃផ្សេងៗដែលផ្សារភ្ជាប់ទៅនឹងជីវចម្រុះ ជាមួយភាគីពាក់ព័ន្ធជាក់លាក់ ហើយគួរតែកំណត់ផលប៉ះពាល់មកលើសេវាប្រព័ន្ធអេកូឡូស៊ី។ អតិថិជនមិនគួរបំប្លែង ឬបំផ្លិចបំផ្លាញជម្រកធម្មជាតិធ្ងន់ធ្ងរនោះទេ លុះត្រាតែមិនមានជម្រើសជំនួសផ្សេងទៀតដែលអាចធ្វើទៅបានតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុ។ អត្ថប្រយោជន៍រួមនៃគម្រោង មានទម្ងន់លើសពីបន្ទុកចំណាយ ដែលរួមទាំងបរិស្ថាន និងជីវចម្រុះ ហើយការបំប្លែង ឬការរិចរិលណាមួយ ត្រូវបានកាត់បន្ថយយ៉ាងសមស្រប។ វិធានការកាត់បន្ថយគួរតែត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយការបាត់បង់សុទ្ធនៃជីវចម្រុះ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ហើយអាចរួមបញ្ចូលសកម្មភាពមួយចំនួន ដូចជា ការស្តារទីជម្រកឡើងវិញក្រោយប្រតិបត្តិការ ការទូទាត់សងការខូចខាតតាមរយៈការបង្កើតតំបន់ដែលមានលក្ខណៈអេកូឡូស៊ីប្រហាក់ប្រហែល ដែលត្រូវបានគ្រប់គ្រងសម្រាប់ជីវចម្រុះ និងផ្តល់សំណងដល់អ្នកប្រើប្រាស់ជីវចម្រុះផ្ទាល់។ នៅក្នុងការកែលម្អលំនៅដ្ឋាន អតិថិជនគួរតែអនុវត្តការយកចិត្តទុកដាក់លើការកាត់បន្ថយការបំប្លែង ឬការថយចុះណាមួយ ហើយអាស្រ័យលើលក្ខណៈ និងវិសាលភាពនៃគម្រោង កំណត់ឱកាសដើម្បីបង្កើនជម្រក ព្រមទាំងការពារ និងអភិរក្សជីវៈចម្រុះ ដែលជាផ្នែកនៃប្រតិបត្តិការរបស់ខ្លួន។[95]
- *PS៧ (ជនជាតិដើមភាគតិច)*៖ តម្រូវឱ្យអតិថិជន និងអតិថិជនបន្ត ធ្វើការវាយតម្លៃថាតើសកម្មភាពអាជីវកម្មរបស់ពួកគេបង្កហានិភ័យ ឬមានផលប៉ះពាល់ដល់ជនជាតិដើមភាគតិច ដែរឬទេ។[96] បន្ថែមពីលើការកំណត់អត្តសញ្ញាណជនជាតិដើមភាគតិចដែលរងផលប៉ះពាល់គម្រោង ការវាយតម្លៃរបស់អតិថិជន IFC ត្រូវតែកំណត់ពីលក្ខណៈ និងកម្រិតនៃផលប៉ះពាល់សង្គម បរិស្ថាន និងវប្បធម៌ ដែលបានរំពឹងទុក (រួមទាំងផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានការពារក្រោម PS៨ ផងដែរ) និងជៀសវាងផលប៉ះពាល់អវិជ្ជមាន ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។[97]នៅត្រង់ចំណុចដែលការជៀសវាងមិនអាចធ្វើទៅបាន អតិថិជនត្រូវតែកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា កាត់បន្ថយផលប៉ះពាល់ ឬទូទាត់សំណងចំពោះផលប៉ះពាល់ទាំងនេះក្នុងលក្ខណៈសមស្របតាមវប្បធម៌។ សកម្មភាពរបស់អតិថិជននឹងធ្វើឡើង

[95] PS៥ ឆ្នាំ២០០៦ កថាខណ្ឌ ៤–៧។

[96] PS៧ ឆ្នាំ២០០៦ កថាខណ្ឌ ៥។ PS៧ គូសបញ្ជាក់ពីលក្ខណៈដូចខាងក្រោមនេះ ដើម្បីកំណត់ថាតើក្រុមមួយណា គួរត្រូវបានចាត់ទុកថាជាជនជាតិដើមភាគតិច៖ (i) ការកំណត់អត្តសញ្ញាណដោយខ្លួនឯងជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមភាគតិចដាច់ដោយឡែកមួយ និងការទទួលស្គាល់អត្តសញ្ញាណនេះដោយអ្នកដទៃ (ii) ការភ្ជាប់លក្ខណៈជារួមទៅនឹងទីជម្រកជាក់លាក់តាមភូមិសាស្ត្រ ឬទឹកដីដូនតាក្នុងតំបន់គម្រោង និងធនធានធម្មជាតិនៅក្នុងទីជម្រក និងទឹកដីទាំងនេះ (iii) ទំនៀមទម្លាប់វប្បធម៌ សេដ្ឋកិច្ច សង្គម ឬស្ថាប័ននយោបាយដែលដាច់ដោយឡែកពីសង្គម ឬវប្បធម៌លេចធ្លោ (iv) ភាសាជនជាតិដើមភាគតិច ដែលជារឿយៗខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។

[97] PS៧ ឆ្នាំ២០០៦ កថាខណ្ឌ ៧ ។

ដោយមានការចូលរួមពីជនជាតិដើមភាគតិចរងផលប៉ះពាល់ ដោយបានទទួលព័ត៌មានគ្រប់គ្រាន់ និងត្រូវដាក់បញ្ចូលនៅក្នុងផែនការមានពេលវេលាអនុវត្តជាក់លាក់ ដូចជា ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ឬ ផែនការអភិវឌ្ឍន៍សហគមន៍កាន់តែទូលំទូលាយ ដែលមានធាតុផ្សំដាច់ដោយឡែកសម្រាប់ជនជាតិដើមភាគតិច ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុង PS៧ ។[98] នៅកន្លែងដែលមានផលប៉ះពាល់អវិជ្ជមានលើជនជាតិដើមភាគតិច អតិថិជនត្រូវតែរៀបចំដំណើរការពិគ្រោះយោបល់ ដើម្បីធានាបាននូវការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយទទួលបានផ្តល់ព័ត៌មានគ្រប់គ្រាន់[99] និងសម្របសម្រួលការចូលរួមរបស់ពួកគេដោយទទួលបានព័ត៌មានគ្រប់គ្រាន់អំពីបញ្ហាប៉ះពាល់ពួកគេដោយផ្ទាល់។[100]

*PS៨ (បេតិកភណ្ឌវប្បធម៌)* ៖ តម្រូវឱ្យអតិថិជនការពារបេតិកភណ្ឌវប្បធម៌ពីផលប៉ះពាល់អវិជ្ជមាន កើតចេញពីសកម្មភាពគម្រោង និងគាំទ្រដល់ការអភិរក្សបេតិកភណ្ឌវប្បធម៌។[101]អតិថិជនគួរតែវាយតម្លៃផលប៉ះពាល់អវិជ្ជមានបែបនេះ នៅក្នុងតំបន់រងផលប៉ះពាល់គម្រោង ដោយប្រើអ្នកជំនាញមានគុណវុឌ្ឍិ និងពោរពេញដោយបទពិសោធន៍។[102] អតិថិជនរបស់ IFC ក៏ត្រូវតែកំណត់អត្តសញ្ញាណតំបន់បេតិកភណ្ឌវប្បធម៌ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយសហគមន៍ពាក់ព័ន្ធ និងដាក់បញ្ចូលទស្សនៈរបស់ពួកគេទៅក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅលើគម្រោង។[103]

---

[98] PS៧ ឆ្នាំ២០០៦ កថាខណ្ឌ ៨ និង ៩។

[99] ស៊ីអេអូ កត់សម្គាល់ថា ការយល់ព្រមដោយសេរី ជាមុន និងទទួលបានព័ត៌មាន គឺជាលក្ខខណ្ឌតម្រូវមួយនៅក្នុងស្តង់ដារសមិទ្ធិកម្ម ឆ្នាំ ២០១២ ។ នៅក្នុងស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ លក្ខខណ្ឌតម្រូវ គឺការពិគ្រោះយោបល់ដោយសេរី ជាមុន និងទទួលបានព័ត៌មាន។

[100] PS៧ ឆ្នាំ២០០៦ កថាខណ្ឌ ៩។ ដំណើរការពិគ្រោះយោបល់ គួរតែរួមបញ្ចូល៖ (i) ការចូលរួមរបស់ស្ថាប័នតំណាងជនជាតិដើមភាគតិច (IP) (ii) រួមបញ្ចូលស្ត្រី និងបុរស និងក្រុមអាយុផ្សេងគ្នា (iii) ផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ដំណើរការធ្វើការសម្រេចចិត្តរួម IP (iv) ជួយសម្រួលដល់ការបញ្ចេញមតិ IP លើទស្សនៈ ក្តីកង្វល់ និងសំណើជាភាសារបស់ពួកគេ ដោយមិនមានឧបាយកលពីខាងក្រៅ ការជ្រៀតជ្រែក ឬការបង្ខិតបង្ខំ និងដោយគ្មានការបំភិតបំភ័យ និង (v) ធានាថាយន្តការបណ្តឹងសារទុក្ខត្រូវបានបង្កើតឡើងសមស្របតាមវប្បធម៌ និងអាចឱ្យ IP ប្រើប្រាស់បាន។ តាមរយៈដំណើរការនៃការពិគ្រោះយោបល់ដោយសេរី ជាមុន និងទទួលបានព័ត៌មាន និងដោយមានការចូលរួមដោយទទួលបានព័ត៌មានពីសហគមន៍ជនជាតិដើមភាគតិចរងផលប៉ះពាល់ អតិថិជននឹង៖ (i) កំណត់ឱកាសសម្រាប់អត្ថប្រយោជន៍នៃការអភិវឌ្ឍសមស្របតាមវប្បធម៌ សមាមាត្រនឹងកម្រិតនៃផលប៉ះពាល់គម្រោង និងចងក្រងឯកសារអត្ថប្រយោជន៍នៃការអភិវឌ្ឍន៍ទាំងនេះ (ii) ជៀសវាង កាត់បន្ថយឱ្យនៅកម្រិតអប្បបរមា និងចងក្រងឯកសារអំពីផលប៉ះពាល់លើដី IP; ចងក្រងឯកសារនៃការប្រើប្រាស់អ្នកជំនាញដោយ IP; ជូនដំណឹងដល់ជនជាតិដើមភាគតិចអំពីសិទ្ធិរបស់ពួកគេចែងនៅក្នុងច្បាប់ជាតិ;ចរចាដោយស្មោះត្រង់ជាមួយ IPs (គ) ពិចារណាជម្រើសដែលអាចធ្វើទៅបានចំពោះការផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិច ចេញពីទឹកដីប្រពៃណី ឬទំនៀមទម្លាប់ ហើយនៅពេលមិនមានលទ្ធភាពចរចាដោយស្មោះត្រង់ជាមួយសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ចងក្រងឯកសារអំពីការចូលរួមដែលមានព័ត៌មានរបស់ពួកគេ និងលទ្ធផលជោគជ័យនៃការចរចា។ PS៧ ឆ្នាំ២០០៦ កថាខណ្ឌ ១០, ១២–១៤។

[101] PS៨ ឆ្នាំ២០០៦, គោលបំណង។

[102] ២០០៦ កំណត់សម្គាល់សេចក្តីណែនាំ៨, បេតិកភណ្ឌវប្បធម៌ (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧), កថាខណ្ឌ GN៩។

[103] PS៨ ឆ្នាំ២០០៦ កថាខណ្ឌ ៦។

## 3. ការវិភាគ និងគំហើញ

នៅពីក្រោមគោលនយោបាយនានាដែលបានសង្ខេបខាងលើ ការត្រួតពិនិត្យបរិស្ថាន និងសង្គម (ESDD) និងសកម្មភាពត្រួតពិនិត្យរបស់ IFC គួរតែកំណត់ និងវាយតម្លៃហានិភ័យ និងផលប៉ះពាល់ E&S នៃប្រតិបត្តិការរបស់ ABBank និងត្រួតពិនិត្យការអនុវត្ត E&S របស់អតិថិជនធៀបនឹងផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) និងការប្តេជ្ញាចិត្តផ្លូវច្បាប់របស់គម្រោង។ ផ្នែកនេះពិនិត្យមើលសកម្មភាពរបស់ IFC ក្នុងអំឡុងពេលនៃការត្រួតពិនិត្យបរិស្ថាន និងសង្គម មុនពេលមានការវិនិយោគ និងការត្រួតពិនិត្យអតិថិជនជាបន្តបន្ទាប់ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២៤ ទាក់ទងនឹងការចោទប្រកាន់របស់ដើមបណ្តឹងអំពីផលប៉ះពាល់ និងគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងអនុគម្រោងវារីអគ្គិសនីសេសានក្រោម២ ។

### 3.1 ការត្រួតពិនិត្យរបស់ IFC មុនពេលវិនិយោគ

#### 3.1.1 សេចក្តីសង្ខេបនៃសកម្មភាពរបស់ IFC

IFC បានអនុវត្តការត្រួតពិនិត្យបរិស្ថាន និងសង្គម (ESDD) របស់ធនាគារ ABBank ចាប់ពីថ្ងៃទី៣០ ខែមិថុនា ដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ ជាផ្នែកមួយនៃការព្រួតពិនិត្យនេះ IFC បានពិនិត្យមើលឡើងវិញព័ត៌មានខាងក្រោមដែលអតិថិជនបានផ្តល់ឱ្យ៖

1. កម្រងសំណួរនៃប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន (SEMS) របស់ FI៖ បញ្ជាក់ថា ABBank មិនមានគោលនយោបាយ ឬនីតិវិធី E&S ទេ ប៉ុន្តែបានដាក់បញ្ចូលការពិចារណាផ្នែកសង្គម និងបរិស្ថានមួយចំនួនក្នុងអំឡុងពេលវាយតម្លៃឥណទានរបស់ខ្លួន។ ការពិចារណាទាំងនេះផ្តោតលើសមត្ថភាពគ្រប់គ្រងរបស់អតិថិជន ភាពអនុលោមតាមច្បាប់ជាតិ និងការគាំទ្របច្ចេកទេសពីភាគីខាងក្រៅ។
2. កម្រងសំណួរ PS២ ទាក់ទងនឹងបញ្ហាការងារ៖ អតិថិជនបានផ្តល់ព័ត៌មានអំពីគោលនយោបាយធនធានមនុស្ស លក្ខខណ្ឌការងារ និងស្ថិតិការងារកម្លាំងពលកម្មរបស់ខ្លួន។
3. កម្រងសំណួររបស់ FI ស្តីពីប្រសិទ្ធភាពថាមពល/ថាមពលកកើតឡើងវិញ៖ ABBank បានផ្តល់ព័ត៌មានអំពីផលិតផល គោលដៅ និងយុទ្ធសាស្ត្ររបស់ខ្លួន ហើយបានសង្កត់ធ្ងន់លើការចូលរួមរបស់ធនាគារនៅក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងវារីអគ្គិសនីនានា ប៉ុន្តែមិនបានដោះស្រាយបញ្ហា E&S ដែលពាក់ព័ន្ធនោះទេ។
4. កម្រងសំណួរត្រួតពិនិត្យភាគហ៊ុនសំណាកគំរូ៖ សំណាកគំរូអតិថិជន រួមបញ្ចូលផ្នែកមួយស្តីពី "បញ្ហាបរិស្ថាន" ប៉ុន្តែមិនមានព័ត៌មាន E&S ទេ។ នៅពេលសួរអំពីការវិនិយោគភាគហ៊ុន ABBank មិនបាននិយាយអំពីក្រុមហ៊ុន EVNI ទេ។

ការត្រួតពិនិត្យ E&S មានកម្រិតនេះ មិនបានរាប់បញ្ចូលការពិនិត្យមើលឡើងវិញលម្អិតនៃផលប័ត្រអតិថិជននាពេលអនាគតរបស់ IFC និងការប្រឈមនឹងហានិភ័យ E&S នោះទេ បណ្តាលឱ្យមានខ្វះខាតច្រើនចំពោះអ្វី

ដែលត្រូវបានតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព។[104] ជាលទ្ធផល IFC មិនស្ថិតនៅជំហរមួយក្នុងការយល់ដឹងយ៉ាងច្បាស់ និងវាយតម្លៃទម្រង់ហានិភ័យ E&S របស់អតិថិជនរបស់ខ្លួន ឬផលបច្ច័យដែលកើតមាននោះទេ។

ផ្ទុយទៅនឹងការត្រួតពិនិត្យ E&S មិនបានគ្រប់គ្រាន់របស់ខ្លួន ឯកសារគម្រោង IFC បង្ហាញពីការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុដ៏រឹងមាំនៃផលប័ត្ររបស់ ABBank ។ ការវិភាគហិរញ្ញវត្ថុរបស់ IFC ពាក់ព័ន្ធនឹងការពិនិត្យឡើងវិញលម្អិតលើការពាក់ព័ន្ធធំបំផុតទាំង២៥ របស់ធនាគារ ឥណទានមិនដំណើរការធំជាងគេទាំង១០ ក្រុមសេដ្ឋកិច្ច/ភាគីពាក់ព័ន្ធចំនួន៦ និង ឥណទានដែលបានជ្រើសរើសដោយចៃដន្យចំនួន២៥ ដែលគ្របដណ្តប់ប្រមាណជា ៤០ ភាគរយនៃផលប័ត្រឥណទានរបស់ធនាគារ ABBank។ ឯកសារនានាចេញពីការវិភាគនេះ ផ្តល់នូវភស្តុតាងដែលបញ្ជាក់ថា ភាពជាដៃគូយុទ្ធសាស្ត្ររបស់អតិថិជនជាមួយ EVN ដែលជាអតិថិជន និងម្ចាស់ភាគហ៊ុនធំជាងគេរបស់ ABBank គឺជាកត្តាជំរុញដ៏សំខាន់សម្រាប់ការវិនិយោគរបស់ IFC។ ដូច្នេះ IFC បានដឹងថា EVN មានជាកម្មសិទ្ធិ និងដំណើរការយ៉ាងហោចណាស់ ២១ រោងចក្រវារីអគ្គិសនី និងថាមពលធ្យូងថ្ម ដែលក្រុមហ៊ុនបានទទួលភារកិច្ចពីរដ្ឋាភិបាលវៀតណាមឱ្យបង្កើនថាមពលទ្វេដង ត្រឹមឆ្នាំ២០២០ និងធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងអន្តរកម្មជាមួយប្រទេសកម្ពុជា និងឡាវ ហើយធនាគារ ABBank បានបញ្ចេញនូវកញ្ចប់សេវាកម្មគ្រប់ជ្រុងជ្រោយរួមមួយសម្រាប់ក្រុមហ៊ុន EVN ដែលក្នុងនោះរួមទាំងឥណទានសាជីវកម្ម ផងដែរ។[105] ឯកសារហិរញ្ញវត្ថុគម្រោងក៏បញ្ជាក់ផងដែរថា គណៈគ្រប់គ្រងរបស់ IFC បានចាត់ទុក ABBank មានពាក់ព័ន្ធជាមួយអតិថិជនជាច្រើន រួមទាំងការពាក់ព័ន្ធមានកម្រិត ជាមួយវិស័យថាមពលកកើតឡើងវិញក្នុងទម្រង់នៃគម្រោងវារីអគ្គិសនី តាមរយៈការចូលរួមរបស់ខ្លួនជាមួយ EVN ។ ការវិភាគនេះ រួមបញ្ចូលទំនាក់ទំនងរបស់ ABBank ជាមួយអនុអង្គភាពរបស់ EVN គឺ EVNI ដែលបង្កើតឡើងជាពិសេសដើម្បីអភិវឌ្ឍទំនប់វារីអគ្គិសនីសេសានក្រោម២។ របាយការណ៍ប្រចាំឆ្នាំរបស់ ABBank ពីឆ្នាំ ២០០៧-០៩ ទាំងអស់ បានរាយការណ៍ថា ABBank កាន់កាប់ភាគហ៊ុននៅក្នុង EVNI ហើយការវាយតម្លៃហានិភ័យឥណទានផ្ទាល់របស់ IFC បានចុះបញ្ជី EVNI (ក្រោមឈ្មោះមុនរបស់ខ្លួនថា EVN Cambodia JSC) ដែលជាការវិនិយោគភាគហ៊ុនមួយរបស់ ABBank ។[106]

ស៊ីអេអូ ក៏បានកត់សម្គាល់ផងដែរថា ABBank បានបង្កើនការកាន់កាប់ភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុននេះ ហេតុដូច្នេះពាក់ព័ន្ធនឹងភាគហ៊ុនក្រុមហ៊ុន EVNI ពី ៦ ទៅ ១០,៣១ ភាគរយភ្លាមៗ មុនពេល IFC អនុម័តការវិនិយោគ

---

[104] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨។

[105] ABBank បានអះអាងថា ខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសាជីវកម្មគ្រប់ជ្រុងជ្រោយមួយ ជាមួយក្រុមហ៊ុនសមាជិករបស់ EVN នៅក្នុងឆ្នាំ២០០៧។ ABBank, របាយការណ៍ប្រចាំឆ្នាំ ២០០៧ (២០០៧), ២៥,bit.ly/3XZc5K3 ។

[106] របាយការណ៍ប្រចាំឆ្នាំ ២០០៧ របស់ ABBank បានបញ្ជាក់ថា ABBank បានចូលរួមចំណែកក្នុងការបង្កើតក្រុមហ៊ុន EVN Cambodia Joint Stock Company ដែលបានក្លាយជាក្រុមហ៊ុន EVNI ក្នុងឆ្នាំ២០០៨។ សូមមើលរបាយការណ៍ប្រចាំឆ្នាំ ២០០៧ របស់ ABBank ទំព័រ ២១, https://bit.ly/3XZc5K3 ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ២០០៨ របស់ខ្លួន ABBank គូសបញ្ជាក់ថា ខ្លួនបានវិនិយោគចំនួន ៨៤ ពាន់លានដុង ពោលគឺ ៣,៥ ភាគរយនៅក្នុង EVN Cambodia។ សូមមើលរបាយការណ៍ប្រចាំឆ្នាំ២០០៨ របស់ ABBank ទំព័រ ២៨, https://bit.ly/3XYz8EU; របាយការណ៍ប្រចាំឆ្នាំ២០០៩ របស់ ABBank, ទំព័រ ២៦–២៩ https://bit.ly/3TMBuEa។

របស់ខ្លួន។ ABBank បានទិញភាគហ៊ុនថ្មីនៅក្នុង EVNI នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ខណៈពេលដែលក្រុមប្រឹក្សាភិបាលរបស់ IFC បានអនុម័តការវិនិយោគរបស់ IFC នៅក្នុង ABBank ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០១០។[107]

ការត្រួតពិនិត្យ E&S ស្របគ្នារបស់ IFC បានកំណត់ថា លក្ខខណ្ឌតម្រូវអនុវត្តការងារសមស្រប សម្រាប់អតិថិជនអនាគតដែលត្រូវបំពេញ រួមមាន៖ (i) បញ្ជីលើកលែង FI របស់ IFC (ii) ច្បាប់ និងបទប្បញ្ញត្តិជាតិជាធរមាន និង (iii) ស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦ ។ IFC និង ABBank បានយល់ព្រមលើផែនការប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន (SEMS Plan) (សមមូលទៅនឹង ESAP) ដែលត្រូវបានភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងជាប់កាតព្វកិច្ចផ្លូវច្បាប់របស់ពួកគេ។ ផែនការនេះ តម្រូវឱ្យធនាគារ ABBank អនុវត្តការប្តេជ្ញាចិត្តខាងក្រោម ក្នុងរយៈពេលពី ៣ ទៅ ៩ ខែ បន្ទាប់ពីទូទាត់ចំណាយ។

| ផែនការ SEMS របស់ IFC/ABBank |
|---|
| 1. តែងតាំងមន្ត្រី SEMS ដើម្បីត្រួតពិនិត្យការអនុវត្តប្រព័ន្ធគ្រប់គ្រង E&S មុនពេលការប្តេជ្ញាចិត្ត។<br>2. បង្កើតឯកសារគោលនយោបាយ SEMS ដើម្បីធានាថា ប្រតិបត្តិការធនាគារមានសង្គតិភាពតាមស្តង់ដារសមិទ្ធិកម្ម បទប្បញ្ញត្តិ E&S មានជាធរមានរបស់ប្រទេស និងបញ្ជីលើកលែងរបស់ IFC ។ គោលនយោបាយ SEMS ត្រូវការដាក់បញ្ចូលធាតុដូចខាងក្រោម ជាលក្ខណៈវិនិច្ឆ័យលើការត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ៖ (i) បញ្ជីនៃច្បាប់ E&S មានជាធរមានដែលពាក់ព័ន្ធ (ii) បញ្ជីលើកលែងរបស់ IFC និង (iii) ស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦។<br>3. បង្កើតផែនការអនុវត្ត SEMS ។<br>4. បង្កើតនីតិវិធី SEMS និងការណែនាំស្តីពីការអនុវត្ត។<br>5. បណ្តុះបណ្តាលបុគ្គលិក E&S ។<br>6. បញ្ចូលលក្ខណៈវិនិច្ឆ័យ E&S ទៅក្នុងប្រព័ន្ធព័ត៌មាន/ការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។<br>7. អនុវត្តគោលនយោបាយ SEMS ចំពោះឥណទាន និងការវិនិយោគថ្មីទាំងអស់។<br>8. ធានាបាននូវភាពអនុលោមតាមឥណទាន និងការវិនិយោគដែលមានស្រាប់ទាំងអស់ ស្របតាមលក្ខខណ្ឌតម្រូវឯកសារគោលនយោបាយ SEMS ។<br>9. ធ្វើការត្រួតពិនិត្យហានិភ័យកេរ្តិ៍ឈ្មោះប្រចាំត្រីមាស។<br>10. ធ្វើការពិនិត្យមើលឡើងវិញការអនុវត្ត SEMS ផ្ទៃក្នុង ប្រចាំឆ្នាំ ។ |

107 បន្ទាត់ពេលវេលានៃការវិនិយោគដែលផ្តល់ដោយ IFC; របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០០៩ របស់ ABBank និង របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០០៩ របស់ ABBank ។

ចំណុចស្នូលនៃការស៊ើបអង្កេតរបស់ ស៊ីអេអូ គឺជាកិច្ចព្រមព្រៀង ស្ថិតនៅក្រោមចំណុចប្រាំបីខាងលើ ដែល ABBank នឹងធានាភាពអនុលោមនៃឥណទាន និងការវិនិយោគដែលមានស្រាប់ទាំងអស់ ដែលរួមបញ្ចូលការវិនិយោគរបស់ខ្លួននៅក្នុង EVNI ជាមួយនឹងស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦។ ផលបច្ច័យភាពអនុលោមតាមការប្តេជ្ញាចិត្តផ្លូវច្បាប់នេះ ត្រូវបានពិភាក្សាបន្ថែមទៀតនៅក្នុងផ្នែក 3.2 នៃរបាយការណ៍នេះ ។

IFC ក៏បានចែករំលែកជាមួយអតិថិជននូវគំរូគោលនយោបាយបរិស្ថាន និងសង្គម ដែលបានបង្ហាញថា IFC បានពិនិត្យមើលឡើងវិញសមត្ថភាពរបស់ FI ក្នុងការគ្រប់គ្រងហានិភ័យ E&S ព្រមទាំងបង្កើត និងរក្សា SEMS ហើយបានអះអាងថា "IFC អាចស្នើឱ្យមានសកម្មភាពបន្ថែមដើម្បីដោះស្រាយចំណុចខ្វះខាតណាមួយនៅក្នុង SEMS"។[108]

កិច្ចព្រមព្រៀងផ្លូវច្បាប់រវាង IFC និង ABBank ត្រូវបានចុះហត្ថលេខា នៅខែធ្នូ ឆ្នាំ២០១០ ជាមួយនឹងផែនការ SEMS ដែលត្រូវបានភ្ជាប់ជាការប្តេជ្ញាចិត្តផ្លូវច្បាប់សម្រាប់ការវិនិយោគនេះ។

### 3.1.2 ការវិភាគរបស់ ស៊ីអេអូ និងគំហើញពីការពិនិត្យមុនពេល IFC ធ្វើការវិនិយោគ (ESDD)

**ស៊ីអេអូ រកឃើញថា IFC មិនបានពិនិត្យមើលឡើងវិញឱ្យបានគ្រប់គ្រាន់លើអាជីវកម្មរបស់ ABBank មុនការវិនិយោគ ដើម្បីកំណត់សកម្មភាពដែលមានហានិភ័យសង្គម និងបរិស្ថាន កើតចេញពីការវិនិយោគរបស់ខ្លួន ទៅតាមលក្ខខណ្ឌតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ (កថាខណ្ឌ២៨) ដោយសារហេតុផលមួយចំនួន ដូចមានពិភាក្សាខាងក្រោម។**

IFC បានធ្វើការវិនិយោគឆ្នាំ២០១០ របស់ខ្លួននៅក្នុងធនាគារ ABBank ក្រោមគោលនយោបាយនិរន្តរភាពឆ្នាំ ២០០៦។ គោលនយោបាយនិរន្តរភាពឆ្នាំ២០០៦ តម្រូវឱ្យ IFC ពិនិត្យមើលឡើងវិញអាជីវកម្មរបស់អតិថិជន FI តាមរយៈ ESRP របស់ខ្លួន ដើម្បីកំណត់សកម្មភាពដែល FI អាចនឹងប្រឈមហានិភ័យ E&S កើតចេញពីការវិនិយោគរបស់ខ្លួន ហើយផ្អែកលើមូលដ្ឋាននេះ ត្រូវការបង្កើតលក្ខខណ្ឌតម្រូវ E&S[109] ។

ESRP ដែលចូលជាធរមានក្នុងឆ្នាំ២០១០ បង្ហាញថា ការពិនិត្យមើលឡើងវិញរបស់ IFC លើសកម្មភាពអាជីវកម្ម

---

[108] ព័ត៌មានទទួលបានជាសាធារណៈអំពីផែនការ SEMS លើកឡើងតែចំណុចដូចខាងក្រោមប៉ុណ្ណោះ៖ "ផ្អែកលើការពិនិត្យឡើងវិញគម្រោងនឹងតម្រូវឱ្យ៖ (i) បង្កើត ឬបង្កើនកម្រិត ប្រសិនបើចាំបាច់ SEMS ដែលមានស្រាប់ណាមួយ មុនពេលទូទាត់ចំណាយចំពោះភាពពេញចិត្តរបស់ IFC (ii) កំណត់បុគ្គលទទួលខុសត្រូវ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីគ្រប់គ្រង និងអនុវត្ត SEMS (មន្ត្រី SEMS) (iii) ប្តេជ្ញាអនុវត្ត SEMS ដើម្បីធានាថាការវិនិយោគ/សកម្មភាពរបស់ខ្លួនដែលគាំទ្រដោយការផ្តល់ហិរញ្ញប្បទាន IFC គឺអនុលោមតាមលក្ខខណ្ឌការអនុវត្តជាធរមាន (iv) បង្ហាញពីការប្តេជ្ញាចិត្តក្នុងការអនុវត្តស្តង់ដារការងារដែលបង្កើតឡើងដោយ IFC Performance Standard 2៖ លក្ខខណ្ឌពលកម្ម និងការងារ និង (v) បញ្ជូនរបាយការណ៍តាមកាលកំណត់ទៅ IFC តាមទម្រង់ដែល IFC បានផ្តល់ជូន។" សូមមើល https://disclosures.ifc.org/project-detail/SPI/29745/abbank-equity-cb ។

[109] គោលនយោបាយនិរន្តរភាព IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨ និង ២៩។

របស់ធនាគារ ABBank ដើម្បីកំណត់ហានិភ័យដែលអាចកើតមានចំពោះបរិស្ថាន សង្គម និងកេរ្តិ៍ឈ្មោះ គួរតែមានការពាក់ព័ន្ធនឹង៖

- IFC កត់ត្រាសេចក្តីសម្រេចចិត្តរបស់ខ្លួន និងការវិភាគគាំទ្រលើលក្ខខណ្ឌតម្រូវ E&S របស់គម្រោង។
- IFC ទទួលព័ត៌មានពីនាយកដ្ឋានវិនិយោគ អំពីផលប័ត្ររបស់ FI និង ESMS រួមទាំងការអនុវត្តការងារ។
- IFC កំណត់៖ (i) ភាពធ្ងន់ធ្ងរនៃសកម្មភាពអាជីវកម្មដែលអាចនឹងមានផលប៉ះពាល់ E&S ដោយការពិនិត្យមើលឡើងវិញនូវផលប័ត្រ និងព័ត៌មានតាមវិស័យ និង (ii) លក្ខខណ្ឌតម្រូវអនុវត្តការងារសមស្រប។
- IFC ពិនិត្យមើលឡើងវិញលើ "ភតិកៈ ទំហំប្រតិបត្តិការ និងវិស័យឧស្សាហកម្ម ដែល FI កំពុងវិនិយោគ" ដូច្នេះ "នៅត្រង់ចំណុចដែលការពិនិត្យឡើងវិញលើផលប័ត្រ បង្ហាញថាការវិនិយោគរបស់ FI អាចនឹងមានប៉ះពាល់ខ្លាំង E&S ខ្លាំង" នោះ FI ធានាថាអនុគម្រោងរបស់ខ្លួន បំពេញតាមធាតុពាក់ព័ន្ធនានានៃ PS របស់ IFC បន្ថែមពីលើច្បាប់ និងបទប្បញ្ញត្តិជាតិ។[110]

---

[110] ESRP របស់ IFC ឆ្នាំ២០០៩ (ផ្នែក 7.2.8) ចែងថា "សម្រាប់ការវិនិយោគរបស់ FI ដែល FI ចូលរួមផ្តល់ភាគហ៊ុន ឥណទាន ឬក៏ផ្តល់ហិរញ្ញប្បទានផ្សេងទៀតដល់សាជីវកម្ម ឬនីតិបុគ្គល ក្រៅពីបុគ្គល ឬសម្រាប់សកម្មភាពផ្សេងទៀតដែលរំពឹងថាអាចនឹងមានផលប៉ះពាល់ E&S ៖ (ក) ចាត់ថ្នាក់គម្រោងតាមប្រភេទ Category FI ហើយតម្រូវឱ្យ FI បង្កើត ESMS ដើម្បីធានាបាននូវការអនុវត្តបញ្ជីលើកលែង FI បទប្បញ្ញត្តិ E&S ជាតិមានជាធរមាន និងអាចជា PS របស់ IFC; កត់ត្រាសេចក្តីសម្រេចចិត្ត និងការវិភាគគាំទ្រនៅក្នុង ESRD; និងផ្តល់ភាសាសម្រាប់ MOR ដូចបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ 7.5.7.i ។ សម្រាប់ FIs ដែលមានហានិភ័យ E&S ខ្លាំង ទាក់ទងនឹងសកម្មភាពផ្តល់ហិរញ្ញប្បទានរបស់ពួកគេ (ឧ. ហេដ្ឋារចនាសម្ព័ន្ធធំ ឬគម្រោងផ្នែកចម្រាញ់សារធាតុ) ឬនៅពេលដែល IFC កាន់តែប្រឈមដោយផ្ទាល់ទៅនឹងហានិភ័យ E&S នៃសកម្មភាពផ្តល់ហិរញ្ញប្បទានរបស់ពួកគេ (ឧ. ប្រតិបត្តិការមូលនិធិភាគហ៊ុនឯកជន) <u>អនុវត្តលក្ខខណ្ឌតម្រូវ ដែល IFC នឹងរក្សាសិទ្ធិក្នុងការត្រួតពិនិត្យសកម្មភាពផ្តល់ហិរញ្ញប្បទានតិចតួចដំបូងរបស់ FIs នៅក្នុងវិស័យទាំងនោះ ដើម្បីធានាការអនុវត្ត ESMS របស់ FIs</u> ។ ផ្នែក 7.2.12 និង 7.2.13 នៃ ESRP ឆ្នាំ 2009 របស់ IFC បន្ថែមថា "សម្រាប់ការវិនិយោគ FI ទាំងអស់ [...] ដែលបំពេញតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងនីតិវិធីលេខ 7.2.8: a ទទួលបានព័ត៌មានបន្ថែមទាក់ទងនឹងផលប័ត្ររបស់ FI ដោយប្រើកម្រងសំណួរផលប័ត្រអន្តរការីហិរញ្ញវត្ថុ (Financial Intermediary Portfolio Questionnaire) (ឧបសម្ព័ន្ធ 7.5.8) និង/ឬព័ត៌មានផលប័ត្រស្រដៀងគ្នាដែលអាចទទួលបានពីនាយកដ្ឋានវិនិយោគ" និង "កំណត់ភាពធ្ងន់ធ្ងរនៃសកម្មភាពអាជីវកម្មដែលអាចមានផលប៉ះពាល់ E&S តាមរយៈការពិនិត្យមើលឡើងវិញលើផលប័ត្រ និងព័ត៌មានតាមវិស័យ។ កំណត់លក្ខខណ្ឌតម្រូវការអនុវត្តមានជាធរមាន មានរៀបរាប់ដូចខាងក្រោម៖

a. FIs ទាំងអស់នឹងធានាថាការផ្តល់ហិរញ្ញប្បទាន និងការវិនិយោគរបស់ពួកគេ មិនផ្ទុយនឹងបញ្ជីលើកលែងរបស់ IFC ។
b. លើសពីនេះ ពិនិត្យមើលភតិកៈ ទំហំប្រតិបត្តិការ និងវិស័យឧស្សាហកម្មដែល FI កំពុងវិនិយោគ៖
   i. នៅចំណុចដែលការពិនិត្យមើលផលប័ត្របង្ហាញថាការវិនិយោគរបស់ FI ត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ E&S មានកម្រិត នោះ FI នឹងធានាថាអនុគម្រោងរបស់ខ្លួនអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ E&S ជាតិមានជាធរមាន។
   ii. នៅចំណុចដែលការពិនិត្យមើលផលប័ត្របង្ហាញថា ការវិនិយោគរបស់ FI អាចមានផលប៉ះពាល់ E&S យ៉ាងខ្លាំង នោះ FI នឹងធានាថាអនុគម្រោងរបស់ខ្លួន អនុវត្តតាមធាតុពាក់ព័ន្ធនានានៃ PS របស់ IFC បន្ថែមលើច្បាប់ និងបទប្បញ្ញត្តិ E&S ជាតិជាធរមាន។

- IFC ពិនិត្យមើលឡើងវិញ ESMS របស់អតិថិជន និងអនុគម្រោងដែលមានស្រាប់ នៅពេលដែលផលប័ត្ររបស់ FI តម្រូវឱ្យអនុវត្តស្តង់ដារសមិទ្ធិកម្ម ដើម្បីពិចារណាពីភាពគ្រប់គ្រាន់របស់ ESMS ក្នុងការអនុវត្តលក្ខខណ្ឌតម្រូវអនុវត្តការងារសមស្រប ដោយពិចារណាលើសមត្ថភាពអតិថិជន ដូចខាងក្រោម៖
    - គោលនយោបាយ និងនីតិវិធី E&S
    - រចនាសម្ព័ន្ធស្ថាប័ន និងបុគ្គលិកបច្ចុប្បន្ន
    - ជំនាញ និងសមត្ថភាពក្នុងវិស័យ E&S
    - ការបណ្តុះបណ្តាល និងការយល់ដឹងរបស់មន្ត្រីវិនិយោគ ច្បាប់ និងឥណទានរបស់អតិថិជន អំពីលក្ខខណ្ឌតម្រូវ E&S និង ESMS របស់ស្ថាប័ន
    - នីតិវិធីតាមដានត្រួតពិនិត្យការអនុវត្ត
    - ការរាយការណ៍លទ្ធផលទៅកាន់គណៈគ្រប់គ្រង
    - តាមដានការអនុវត្ត ESMS ។[111]
- IFC ធ្វើការកំណត់ចំណុចខ្វះខាតណាមួយនៅក្នុង ESMS ដែលនឹងចាំបាច់ត្រូវដោះស្រាយ មុនពេលការប្តេជ្ញាចិត្ត ឬជាលក្ខខណ្ឌនៃការទូទាត់ចំណាយ។ ចំណុចខ្វះខាត ESMS នៃ FIs មាននៅក្នុងគម្រោងនានា ដែលអាចនឹងមានហានិភ័យ E&S ខ្លាំង ឬហានិភ័យកាន់តែពើបប្រទះដោយផ្ទាល់ទៅលើ IFC ត្រូវតែដោះស្រាយ ដើម្បីធានាភាពអនុលោមតាមលក្ខខណ្ឌតម្រូវអនុវត្តការងារសមស្រប មុនពេលការប្តេជ្ញាចិត្តរបស់ IFC ឬជាលក្ខខណ្ឌនៃការទូទាត់ចំណាយរបស់ IFC ។[112]

កំណត់ត្រាត្រួតពិនិត្យ E&S របស់ IFC មិនរួមបញ្ចូលឯកសារនៃការពិនិត្យឡើងវិញលើឥណទាន និងការវិនិយោគជាក់លាក់នៅក្នុងផលប័ត្ររបស់ ABBank ដូចបានតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ ដែលផ្តល់អាណត្តិដល់ IFC ពិនិត្យមើលឡើងវិញលើអាជីវកម្មរបស់ FI ដើម្បីកំណត់សកម្មភាពដែលអាចនឹងមានហានិភ័យ E&S តាមរយៈដំណើរការដូចបានរៀបរាប់នៅក្នុង ESRP ។ មិនមានកំណត់ត្រានៅក្នុងឯកសារ E&S គម្រោងដែលថា IFC បានអនុវត្តតាមនីតិវិធី ESRP ស្របតាមលក្ខខណ្ឌតម្រូវគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ (កថាខណ្ឌ២៨ ) ដើម្បី៖ (i) កត់ត្រាការវិភាគរបស់ខ្លួនអំពីលក្ខខណ្ឌតម្រូវ E&S របស់គម្រោង (ii) ទទួលព័ត៌មានពីនាយកដ្ឋានវិនិយោគអំពីការពិនិត្យមើលឡើងវិញផលប័ត្ររបស់ FI (iii) កំណត់ភាពធ្ងន់ធ្ងរនៃសកម្មភាពអាជីវកម្មដែលអាចនឹងមានផលប៉ះពាល់ E&S និងលក្ខខណ្ឌតម្រូវអនុវត្តការងារសមស្របរបស់ខ្លួន និង(iv) ពិនិត្យមើលថាតើអនុគម្រោងរបស់អតិថិជន FI នាពេលអនាគត បំពេញតាមធាតុពាក់ព័ន្ធនានានៃ PS របស់ IFC បន្ថែមលើច្បាប់ និងបទប្បញ្ញត្តិជាតិ ដែរឬទេ។

ឯកសារគម្រោងបង្ហាញថា IFC បានដឹងថា ABBank មានការចូលរួមនៅក្នុងគម្រោងផលិតថាមពលនានា រួមទាំង

---

[111] ESRP ឆ្នាំ២០០៩ របស់ IFC ផ្នែក 7.2.17 ។

[112] ESRP ឆ្នាំ២០០៩ របស់ IFC ផ្នែក 7.2.18 ។

គម្រោងវារីអគ្គិសនី ដែលត្រូវបានគេដឹងពីផលប៉ះពាល់ និងហានិភ័យ E&S សំខាន់ៗ។[113] ទោះជាយ៉ាងណាក៏ដោយ ESDD របស់ IFC មិនបានវាយតម្លៃ និងកំណត់សកម្មភាពដែលអតិថិជន FI និងសមាគម IFC អាចប្រឈមនឹងហានិភ័យ E&S កើតចេញពីការវិនិយោគរបស់ខ្លួននោះទេ។

ការមិនពិនិត្យមើលឡើងវិញផលប័ត្ររបស់អតិថិជនអនាគត ស្របតាមគោលការណ៍ E&S [114] បានមើលរំលងផលប៉ះពាល់សំខាន់ៗ ក្នុងអំឡុងពេលត្រួតពិនិត្យ E&S របស់ IFC ។ ឧ. ក្នុងអំឡុងពេលដំណើរការអនុម័តការវិនិយោគ ចាប់ពីខែសីហា ឆ្នាំ២០១០ រហូតដល់មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លូវច្បាប់ ក្នុងខែធ្នូ ឆ្នាំ ២០១០ មានសំណួរចោទថាតើ ABBank បានពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុទៅនឹងប្រតិបត្តិការថាមពលកំដៅ/ធ្យូងថ្មដែរឬទេ។ ក្រុមវិនិយោគរបស់ IFC បានជូនដំណឹងម្តងហើយម្តងទៀតជូនគណៈគ្រប់គ្រង IFC ថា ABBank មិនមានការពើបប្រទះទៅនឹងប្រតិបត្តិការថាមពលកំដៅ/ធ្យូងថ្មទេ។ ដោយមើលឃើញពីហានិភ័យ E&S និងផលប៉ះពាល់នៃប្រតិបត្តិការថាមពលកំដៅ/ធ្យូងថ្ម នោះការត្រួតពិនិត្យ E&S នៃសកម្មភាពអាជីវកម្មរបស់ ABBank អាចនឹងបានរកឃើញថា គិតត្រឹមឆ្នាំ២០១០ ដែលជាឆ្នាំដូចគ្នានៃការវិនិយោគរបស់ IFC ABBank បានក្លាយជាម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុន EVN រួមទាំងក្រុមហ៊ុន EVNI និង ក្រុមហ៊ុន Pha Lai Thermal-Power Company[115] ដែលដំណើរការរោងចក្រថាមពលដើរដោយធ្យូងថ្មធំជាងគេនៅអាស៊ីអាគ្នេយ៍។[116]

លើសពីនេះ ព័ត៌មានដែល ABBank ផ្តល់ឱ្យ IFC ក្នុងអំឡុងពេល ESDD រួមបញ្ចូលភាពមិនស៊ីសង្វាក់គ្នា ដែល IFC គួរបានធ្វើការវិភាគ ដើម្បីយល់ឱ្យបានច្បាស់អំពីលក្ខណៈ និងទំហំនៃហានិភ័យ E&S កើតមាននៅក្នុងសកម្មភាពអាជីវកម្មរបស់អតិថិជន។ ឧ. នៅក្នុងកម្រងសំណួរ SEMS ធនាគារ ABBank បានបញ្ជាក់ថា ខ្លួនមិនបានផ្តល់ហិរញ្ញប្បទានដល់គម្រោងដែលពាក់ព័ន្ធនឹងលទ្ធកម្មដីនោះទេ។ ប៉ុន្តែ IFC បានដឹងនៅពេលនោះថា ABBank បានផ្តល់ឥណទានយ៉ាងច្រើនដល់ EVN ដែលបានដំណើរការគម្រោងវារីអគ្គិសនី ជាធម្មតាពាក់ព័ន្ធនឹងលទ្ធកម្ម។ ជាក់ស្តែង ធនាគារ ABBank បានបញ្ជាក់នៅក្នុងកម្រងសំណួរអំពីប្រសិទ្ធភាពថាមពលថា ខ្លួនបានផ្តល់ហិរញ្ញប្បទានដល់គម្រោងវារីអគ្គិសនី ដែលក្នុងនោះមានគម្រោងមួយចំនួនតម្រូវឱ្យធ្វើលទ្ធកម្មដី និងការតាំងទីលំនៅថ្មី ក្នុងសហគមន៍។

---

[113] WCD ២០០០៖ ទំនប់ និងការអភិវឌ្ឍន៍។

[114] លក្ខខណ្ឌតម្រូវ ESRP ជាធរមាន ត្រូវបានកត់សម្គាល់ពីមុន។ ដូចដែលបានពិពណ៌នានៅក្នុងផ្នែក 3.1.1 ESDD របស់ IFC មិនរួមបញ្ចូលការពិនិត្យឡើងវិញនូវផលប័ត្ររបស់អតិថិជន និងហានិភ័យ E&S ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួន ផ្ទុយទៅនឹងការត្រួតពិនិត្យហិរញ្ញវត្ថុ ដែលពិតជាបានពិនិត្យមើលការពាក់ព័ន្ធធំជាងគេទាំង ២៥ របស់ធនាគារ ឥណទានមិនដំណើរការច្រើនជាងគេចំនួន១០ ក្រុមសេដ្ឋកិច្ច/ភាគីពាក់ព័ន្ធចំនួនប្រាំមួយ និងឥណទានជ្រើសរើសដោយចៃដន្យចំនួន ២៥ ដែលគ្របដណ្តប់ប្រហែល ៤០ ភាគរយ នៃផលប័ត្រឥណទានរបស់ធនាគារ ABBank ។
parties, and 25 randomly selected loans, covering approximately 40 percent of ABBank’s loan portfolio.

[115] របាយការណ៍ប្រចាំឆ្នាំ២០១០ របស់ធនាគារ ABBank ទំព័រ ២៨, https://bit.ly/3N8uH3U ។

[116] Minh Hein, " ក្រុមហ៊ុន Pha Lai Thermal Power JSC៖ ប្រតិបតិការពេញលេញចំពោះសេដ្ឋកិច្ចជាតិផ្នែកថាមពល," វេទិកាធុរកិច្ចវៀតណាម (១៧ សីហា ២០១០) https://vccinews.com/news/21315/index.html ។

ស៊ីអេអូ កត់សម្គាល់ថា ការវិនិយោគនេះត្រូវបានអនុម័តដោយគណៈគ្រប់គ្រង IFC ដោយមិនគិតគូរពីហានិភ័យ E&S សំខាន់ៗនៃផលប័ត្រអតិថិជនអនាគតរបស់ខ្លួនឡើយ។ ជាពិសេសៈ

- *ហានិភ័យ និងផលប៉ះពាល់សំខាន់ៗទាក់ទងនឹងការវិនិយោគវារីអគ្គិសនី។* IFC បានដឹងថា ABBank មានការវិនិយោគវារីអគ្គិសនី ហើយត្រូវបានវិនិយោគនៅក្នុង EVNI ។ ខណៈដែលវាមិនលេចឡើងថា IFC បានភ្ជាប់ទំនាក់ទំនងរវាង EVNI និង LS2 ក្នុងឆ្នាំ២០១០ ស៊ីអេអូ បានកត់សម្គាល់ថា នៅពេលនោះ EVNI គឺជាការវិនិយោគទុនក្រៅប្រទេសដ៏ធំបំផុតរបស់ ABBank ហើយគោលបំណងចម្បងរបស់ EVNI គឺការអភិវឌ្ឍគម្រោង LS2 ។ ទោះបីជាមានទំនាក់ទំនងច្បាស់លាស់នេះក៏ដោយ ក៏ IFC មិនបានកំណត់ ឬវាយតម្លៃអំពី E&S សំខាន់ៗ និងហានិភ័យកេរ្តិ៍ឈ្មោះដែល EVNI និងទំនប់ LS2 នឹងតំណាង នៅក្នុងផលប័ត្ររបស់ ABBank នោះទេ។
- *កិច្ចប្រជុំត្រួតពិនិត្យការវិនិយោគរបស់ IFC មិនបញ្ចូលការពិចារណាលើព័ត៌មាន E&S ទេ។*[117]

សេចក្តីថ្លែងការណ៍របស់គណៈគ្រប់គ្រង IFC ទៅកាន់ក្រុមប្រឹក្សាភិបាលប្រតិបត្តិ IFC នៅពេលស្នើសុំការអនុម័តលើការវិនិយោគនេះ បានបង្ហាញថា ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ E&S របស់ ABBank មាន "កន្លែងសម្រាប់កែលម្អ" ហើយថា ABBank មានឆន្ទៈធ្វើការជាមួយ IFC ដើម្បីបង្កើត SEMS និងនីតិវិធីដែលឆ្លើយតប។ ទោះជាយ៉ាងនេះក្តី នៅពេលមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ធនាគារ ABBank មិនមានក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ E&S គោលនយោបាយ ឬនីតិវិធី សម្រាប់អនុវត្តនោះទេ។ យោងតាមព័ត៌មានដែលផ្តល់ដោយធនាគារ ABBank ក្នុងអំឡុងពេលការត្រួតពិនិត្យបានឱ្យដឹងថា ធនាគារនេះ គ្រាន់តែរួមបញ្ចូលការពិចារណាផ្នែកសង្គម និងបរិស្ថានមួយចំនួន ក្នុងអំឡុងពេលវាយតម្លៃឥណទានរបស់ខ្លួនប៉ុណ្ណោះ។ លើសពីនេះ ធនាគារ ABBank មិនមានបុគ្គលិកដែលមានភារកិច្ចវាយតម្លៃ E&S ឬតាមដានត្រួតពិនិត្យហានិភ័យ និងផលប៉ះពាល់របស់ E&S ទេ។ ដូច្នេះ IFC មិនមានមូលដ្ឋានពិតប្រាកដក្នុងការ "កែលម្អ" ក្របខ័ណ្ឌ "E&S" របស់អតិថិជនឡើយ ជាពិសេសមិនមានការយល់ដឹងដែលត្រូវគ្នាអំពីហានិភ័យ E&S នៃផលប័ត្រ ដែលខ្លួនមិនមាន ដោយសារតែខ្វះការវិភាគហានិភ័យបែបនេះ។ ខណៈដែល IFC បានប្រាប់ក្រុមប្រឹក្សាភិបាលថា អតិថិជន "នឹងបង្កើត" ឯកសារគោលនយោបាយ SEMS នោះព័ត៌មានដែលផ្តល់ទៅឱ្យក្រុមប្រឹក្សាភិបាល មិនបានបង្ហាញគ្រប់គ្រាន់នូវព័ត៌មាន ដែល IFC មាន ពាក់ព័ន្ធនឹងសមត្ថភាព ការអនុវត្ត និងនីតិវិធី E&S របស់ ABBank ទេ។

ស៊ីអេអូ កត់សម្គាល់ថា IFC ត្រូវបានតម្រូវឱ្យស្ថិតនៅក្រោម ESRP ដើម្បីពិនិត្យមើលឡើងវិញ មុនពេលការវិនិយោគ ថាតើ ESMS របស់អតិថិជនមានលក្ខណៈគ្រប់គ្រាន់សម្រាប់អនុវត្តលក្ខខណ្ឌតម្រូវអនុវត្តការងារ E&S សមស្រប នៅក្នុងផ្នែកមួយចំនួន ដូចជា គោលនយោបាយ សមត្ថភាពបុគ្គលិក រចនាសម្ព័ន្ធស្ថាប័ន និងការត្រួត

[117] កិច្ចប្រជុំត្រួតពិនិត្យការវិនិយោគ (IRM) គឺជាកន្លែងដែលក្រុមការងារគម្រោងធ្វើបទបង្ហាញអំពីគម្រោងនេះ ទៅកាន់គណៈគ្រប់គ្រង IFC ដើម្បីឱ្យគណៈគ្រប់គ្រងធ្វើការសម្រេចចិត្តលើការវិនិយោគ។ ឯកសារគាំទ្រដែលផ្តល់ដោយ IFC អំពី IRM សម្រាប់ការវិនិយោគរបស់ ABBank មិនរួមបញ្ចូលព័ត៌មាន E&S ទេ។

ពិនិត្យតាមដាន ក្នុងចំណោមផ្នែកផ្សេងៗទៀត។[118] ក្នុងអំឡុងពេល ESDD, IFC មិនបានប្រមូលព័ត៌មានអំពីទិដ្ឋភាពទាំងនេះភាគច្រើនទេ ដោយសារអតិថិជនមិនមាន ESMS ឬប្រភេទណាមួយនៃគោលនយោបាយ E&S សម្រាប់អនុវត្ត រហូតដល់ក្រោយពេលការវិនិយោគរបស់ IFC ។

ដូចបានពិពណ៌នានៅក្នុងផ្នែក 1.1.4 ក្រុមធនាគារពិភពលោក បានផ្តោតការយកចិត្តទុកដាក់លើការធ្វើផែនការយ៉ាងប្រុងប្រយ័ត្ន និងការត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារ E&S ដើម្បីកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ដែលអាចនឹងកើតមាននៅក្នុងការសាងសង់ទំនប់ និងប្រតិបត្តិការ នៅពេល IFC អនុវត្តការត្រួតពិនិត្យរបស់ខ្លួនទៅលើធនាគារ ABBank។ នៅក្នុងបរិបទនេះ និងដោយសារយុទ្ធសាស្ត្រវារីអគ្គិសនីរបស់ខ្លួន ត្រូវបានបោះពុម្ពផ្សាយកាលពីបីឆ្នាំមុន IFC គួរតែបានពង្រឹងការត្រួតពិនិត្យរបស់ខ្លួនក្នុងការកំណត់ហានិភ័យ E&S នៃការវិនិយោគរបស់ FI ។ ផ្ទុយទៅវិញ IFC បានធ្វើ ESDD មិនគ្រប់គ្រាន់ សម្រាប់អតិថិជនអនាគត ដែលខ្លួនបានដឹងថា៖ (i) មានការវិនិយោគវារីអគ្គិសនី (ii) មិនដែលមាន ESMS ឬមន្ត្រី E&S ទេ និង (iii) មិនមានបទពិសោធន៍ក្នុងការពិនិត្យមើលហានិភ័យ E&S នៃការវិនិយោគហិរញ្ញវត្ថុផ្ទាល់ខ្លួនទេ។

ជាលទ្ធផល គណៈគ្រប់គ្រង IFC បានបញ្ជូនការវិនិយោគនេះ ដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីអនុម័ត ដោយមិនបានពន្យល់ឱ្យបានសមស្របអំពីលក្ខណៈ និងទំហំនៃហានិភ័យ E&S ទាក់ទងនឹងផលប័ត្ររបស់អតិថិជន។[119] ដូច្នេះ ក្រុមប្រឹក្សាភិបាល IFC បានអនុម័តគម្រោងនេះ ដោយមិនបានទទួលព័ត៌គ្រប់គ្រាន់អំពីហានិភ័យ E&S ដែលគួរយកមកពិចារណា នៅក្នុងផលប័ត្រដែលមានស្រាប់របស់ FI ។

### 3.1.3 ការបាត់បង់ឱកាសក្នុងការជះឥទ្ធិពលទៅលើការអភិវឌ្ឍន៍គម្រោង

ស៊ីអេអូ កត់សម្គាល់ថា នៅអំឡុងពេលនៃការវិនិយោគរបស់ IFC, ធនាគារ ABBank គឺជាស្ថាបនិកផ្តល់ហិរញ្ញប្បទានរបស់អ្នកអភិវឌ្ឍសេសានក្រោម២ (សូមមើលផ្នែក 1.1.1 ខាងលើ) ហេតុដូច្នេះមានឱកាសជះ ឥទ្ធិពលជាវិជ្ជមានលើការអភិវឌ្ឍគម្រោង។

IFC បានអនុវត្តការត្រួតពិនិត្យរបស់ខ្លួន មុនពេលការវិនិយោគ ពីរឆ្នាំបន្ទាប់ពីការធ្វើសេចក្តីព្រាង EIA សម្រាប់គម្រោងសេសានក្រោម២ ក្នុងឆ្នាំ២០០៨។ ទោះជាបែបនេះក្តី គម្រោងនេះនៅតែស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍គ្រាដំបូងនៅឡើយ ដោយការសាងសង់នឹងចាប់ផ្តើមនៅឆ្នាំ២០១៣។ ក្នុងកាលៈទេសៈបែបនេះ និងដោយផ្អែកលើភាពរសើបរបស់អនុគម្រោងនេះ IFC អាចបានផ្តល់ឱ្យ ABBank នូវការណែនាំបច្ចេកទេសពាក់ព័ន្ធការចូលរួមរបស់ភាគីពាក់ព័ន្ធ ការបង្ហាញព័ត៌មាន និងយន្តការបណ្តឹងសារទុក្ខ ការផ្លាស់ទីលំនៅរូបវន្ត និងសេដ្ឋកិច្ច ផលប៉ះពាល់លើជីវចម្រុះ និងធនធានធម្មជាតិ និងផលប៉ះពាល់លើជនជាតិដើមភាគតិច ជាដើម។ ផ្ទុយទៅវិញ ឱកាស

[118] ESRP របស់ IFC ឆ្នាំ២០០៩ ផ្នែក 7.2.17 ។

[119] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៨ ។

នេះត្រូវបានខកខាន ដោយសារតែការពិនិត្យមើលឡើងវិញមុនការវិនិយោគរបស់ IFC លើសកម្មភាពអតិថិជនរបស់ ABBank មិនបានកំណត់ហានិភ័យ E&S ។

ESRP មានជាធរនៅពេលនោះ តម្រូវឱ្យ IFC ពិចារណាពិនិត្យឡើងវិញលើការអនុវត្ត E&S របស់អតិថិជនបន្តដែលមានស្រាប់ ក្នុងអំឡុងពេល ESDD ថាតើការពិនិត្យឡើងវិញនៃផលប័ត្រអតិថិជនទាំងមូល បានកំណត់ហានិភ័យ និងផលប៉ះពាល់ E&S ដែលអាចនឹងកើតមាន ដែរឬទេ។[120] ដោយមើលឃើញពីជំនាញរបស់ IFC លើបញ្ហា E&S រួមជាមួយនឹងកង្វះបទពិសោធន៍ និងសមត្ថភាព E&S របស់ធនាគារ ABBank ក៏ដូចជាការយកចិត្តទុកដាក់ខ្ពស់ទៅលើលទ្ធភាពអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាព ពីក្រុមធនាគារពិភពលោក នៅពេលនោះ ការពិនិត្យឡើងវិញនេះ អាចក្លាយទៅជាឱកាសមួយសម្រាប់ IFC ធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀតនូវគម្រោងសេសានក្រោម២ ដោយធានាថា ABBank យល់ច្បាស់អំពីលក្ខខណ្ឌតម្រូវ E&S របស់ IFC និងរបៀបគួរអនុវត្តចំពោះគម្រោងវារីអគ្គិសនី រួមទាំងផ្នែកផ្សេងទៀតនៅក្នុងផលប័ត្ររបស់ខ្លួន។

ដោយគិតគូរពីផលប៉ះពាល់ ហានិភ័យ និងវិធានការកាត់បន្ថយដែលបានកំណត់នៅក្នុង EIA ឆ្នាំ២០០៨ របស់គម្រោង LS2 (សូមមើលឧបសម្ព័ន្ធ ក សម្រាប់សេចក្តីលម្អិត) ស៊ីអេអូ ចាត់ទុកថា IFC អាចបានផ្តល់ការណែនាំដើម្បីបំពេញបន្ថែម EIA ដែលមានស្រាប់ ឬបានលើកទឹកចិត្ត ABBank ឱ្យតម្រូវអតិថិជនរបស់ខ្លួន EVNI កែលម្អការវាយតម្លៃ E&S របស់គម្រោង នៅក្នុងផ្នែកមួយចំនួនខាងក្រោម៖

1. ការពង្រីក និងបង្កើនភាពញឹកញាប់នៃការពិគ្រោះយោបល់ និងការបង្ហាញព័ត៌មានដល់សហគមន៍រងផលប៉ះពាល់ទាំងអស់ ត្រូវបានកំណត់ដោយ EIA ដោយផ្អែកលើមូលដ្ឋានជាបន្ត។ EIA បានរាយការណ៍ថា "មនុស្សប្រហែល ៣០០.០០០ នាក់ នៅផ្នែកខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមនៃតំបន់គម្រោង"

---

[120] ESRP មានជាធរមាន នៅពេលដែល ESDD សម្រាប់ការវិនិយោគនេះ លើកឡើងថា មន្ត្រី E&S របស់ IFC គួរតែ "កំណត់ភាពធ្ងន់ធ្ងរនៃសកម្មភាពអាជីវកម្មដែលអាចនឹងមានផលប៉ះពាល់ E&S តាមរយៈការពិនិត្យមើលឡើងវិញផលប័ត្រ និងព័ត៌មានតាមវិស័យ។ កំណត់លក្ខខណ្ឌតម្រូវការអនុវត្តជាធរមាន ដូចបានរៀបរាប់ខាងក្រោម៖ ក. FIs ទាំងអស់នឹងធានាថាការផ្តល់ហិរញ្ញប្បទាន និងការវិនិយោគរបស់ពួកគេ មិនផ្ទុយនឹងបញ្ជីលើកលែងរបស់ IFC ។ ខ. លើសពីនេះ ពិនិត្យមើលឡើងវិញនូវកត្តិកៈ ទំហំប្រតិបត្តិការ និងវិស័យឧស្សាហកម្មដែល FI កំពុងវិនិយោគ i. នៅចំណុចដែលការពិនិត្យមើលឡើងវិញនូវផលប័ត្រ បង្ហាញថាការវិនិយោគរបស់ FI ត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ E&S មានកម្រិត នោះ FI នឹងធានាថា គម្រោងរងរបស់ខ្លួន អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ E&S ជាតិមានជាធរមាន។ ii. នៅចំណុចដែលការពិនិត្យមើលឡើងវិញនូវផលប័ត្រ បង្ហាញថាការវិនិយោគរបស់ FI អាចនឹងមានផលប៉ះពាល់ E&S ខ្លាំង នោះ FI នឹងធានាថា គម្រោងរងរបស់ខ្លួនត្រូវគោរពតាមធាតុពាក់ព័ន្ធនានានៃ PS របស់ IFC បន្ថែមលើច្បាប់ និងបទប្បញ្ញត្តិ E&S ជាតិជាធរមាន"។ វាបញ្ជាក់បន្ថែមថា មន្ត្រី E&S របស់ IFC នឹងស្នើសុំ និងទទួលព័ត៌មានអំពី SEMS របស់អតិថិជន ដូចដែលបានផ្តល់នៅក្នុងកម្រងសំណួរដែលពាក់ព័ន្ធ ហើយ "នៅត្រង់ចំណុចដែលតម្រូវការអនុវត្តជាធរមាន រួមមាន PSs របស់ IFC និងនៅចំណុចដែលគេចាត់ទុកថាចាំបាច់ពិនិត្យមើលឡើងវិញបន្ថែម ESMS របស់អតិថិជន ឬ អនុគម្រោងដែលមានស្រាប់ LESS នឹងពិភាក្សាជាមួយប្រធានក្រុម និងទំនាក់ទំនងជាមួយប្រធានប្រតិបត្តិការ និងអតិថិជន អំពីតម្រូវការអនុវត្តការវាយតម្លៃ ទៅ FI" ។ ESRP របស់ IFC ឆ្នាំ២០០៩ ផ្នែក 7.2.15 និង 7.2.17 ។

នឹងរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល [121] ប៉ុន្តែការពិគ្រោះយោបល់មានកិច្ចប្រជុំចំនួនពីរ នៅចន្លោះខែកុម្ភៈ និងខែមេសា ឆ្នាំ២០០៨ នៅក្នុងសហគមន៍ចំនួនប្រាំប៉ុណ្ណោះ ដែលនឹងត្រូវលិចទឹកទាំងស្រុង ឬដោយផ្នែក ដោយសារអាងស្តុកទឹក។[122]

2. ការឆ្លុះបញ្ចាំងកាន់តែប្រសើរអំពីតម្រូវការជាក់លាក់ និងផលប៉ះពាល់ផ្សេងៗគ្នា មកលើបុគ្គល និងក្រុមដែលជួបការលំបាក ឬងាយរងគ្រោះ និងមកលើជនជាតិដើមភាគតិច។[123] EIA កំណត់អត្តសញ្ញាណជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយគម្រោង និងក្រុមជនភាគតិច ប៉ុន្តែមិនរួមបញ្ចូលវិធានការពិសេស ឬការពិចារណាសម្រាប់សិទ្ធិរបស់ពួកគេទេ។[124]ESDD របស់ IFC អាចកំណត់ហានិភ័យនេះ និងផ្តល់អ្នកជំនាញដើម្បីសម្រួលដំណើរការពិគ្រោះយោបល់ដល់សហគមន៍ជនជាតិដើមភាគតិចដោយគិតគូរពីតម្រូវការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់។ IFC ក៏អាចបានផ្តល់ដំបូន្មានផងដែរ អំពីផែនការជនជាតិដើមភាគតិច ក្នុងការបញ្ចូលវិធានការពិសេស និងមានលក្ខណៈខុសគ្នា ដោយគោរពតាមសិទ្ធិ និងទំនៀមទម្លាប់របស់ពួកគេ និងពិចារណាពីផលប៉ះពាល់

---

[121] EIA, ទំព័រ ១២១។ នាយកដ្ឋានត្រួតពិនិត្យ EIA និងតាមដានគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ក៏ដូចជាលក្ខខណ្ឌយោង របស់ EIA ដែលទាំងពីរនេះបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ EIA រួមមានលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ ដែលត្រូវរួមបញ្ចូល "មតិសាធារណៈចំពោះគម្រោងអភិវឌ្ឍន៍ និងការពិគ្រោះយោបល់" និងដំណាក់កាលនៃការពិគ្រោះយោបល់ចំនួនពីរ ដើម្បីចែករំលែកព័ត៌មានជាមួយ "ប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងអស់ និងអាជ្ញាធរមូលដ្ឋាន" និងទទួល "យោបល់អំពីផលប៉ះពាល់គម្រោង (...) វិធីសាស្ត្រកាត់បន្ថយ"។ គោលការណ៍ណែនាំរបាយការណ៍ EIA របស់ក្រសួងបរិស្ថាន—ការបកប្រែក្រៅផ្លូវការដោយនាយកដ្ឋាន EIA ភ្ជាប់ទៅឧបសម្ព័ន្ធ EIA ទំព័រ ៣១៦ ff., p.២–៦ និងលក្ខខណ្ឌយោង EIA ។

[122] ការចូលរួមសហគមន៍ដែលធ្វើឡើងដោយ EVNI ត្រូវបានកំណត់ចំពោះភូមិចំនួនប្រាំ ដែលមានប្រជាជនសរុបប្រហែល ១.៥០០នាក់។ EIA ក៏ស្នើផងដែរថា ក្នុងរយៈពេលបីខែ សហគមន៍ដែលបានពិគ្រោះយោបល់ទាំងប្រាំ បានផ្លាស់ប្តូរការយល់ឃើញរបស់ពួកគេចំពោះគម្រោងនេះ ពីការជំទាស់ ៨៥ ភាគរយ ទៅជាការយល់ព្រម ៨៤ ភាគរយ ទៅលើគម្រោងនេះ។ ដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធ មិនសមស្របទៅនឹងលក្ខណៈ ទំហំ និងទីតាំងនៃគម្រោងនោះទេ។ PS១ ឆ្នាំ២០០៦ កថាខណ្ឌ ៨, ១៩។ សូមមើលផងដែរ,សេចក្តីណែនាំ១ ឆ្នាំ២០០៦, ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃសង្គម និងបរិស្ថាន, (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧), កថាខណ្ឌ GN១៥, G៤៦-G៥៤, និង GN ៦៦ និង IFC, ការចូលរួមរបស់អ្នកពាក់ព័ន្ធ៖ កូនសៀវភៅណែនាំការអនុវត្តល្អសម្រាប់ក្រុមហ៊ុនធ្វើអាជីវកម្មនៅក្នុងទីផ្សារកំពុងរីកចម្រើន," (២០០៧) ។

[123] PS១ ឆ្នាំ២០០៦, PS៧ ឆ្នាំ២០០៦, សេចក្តីណែនាំ១ ឆ្នាំ២០០៦, ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃសង្គម និងបរិស្ថាន, (៣១ កក្កដា ២០០៧), កថាខណ្ឌ G៤៦។

[124]បញ្ជីត្រួតពិនិត្យបរិស្ថានសម្រាប់ការអភិវឌ្ឍវារីអគ្គិសនី ភ្ជាប់ជាមួយ EIA ទំពរ ១; របាយការណ៍សេដ្ឋកិច្ចសង្គម សម្រាប់ LS2 ភ្ជាប់ជាមួយ EIA ទំព័រ ១,៥,២១; EIA ទំព័រ ៨៤, ១០២, ១១៣។

អវិជ្ជមានលើបេតិកភណ្ឌវប្បធម៌។[125]

3. តម្រូវការឱ្យមានយន្តការបណ្តឹងសារទុក្ខ សម្រាប់ក្តីកង្វល់គម្រោងជាទូទៅ និងសម្រាប់បញ្ហាទាក់ទងនឹងការផ្លាស់ទីលំនៅ។[126] EIA មិនបានផ្តល់យន្តការនេះទេ ហើយយោងតាមភាគីពាក់ព័ន្ធ ដែលស៊ីអេអូបានជួបក្នុងអំឡុងពេលចុះមូលដ្ឋានរបស់ខ្លួន គម្រោងនេះនៅខ្វះយន្តការនេះនៅឡើយ។
4. ទាក់ទងនឹងការផ្លាស់ទីលំនៅវូបវន្ត EIA ជាទូទៅគឺស្របតាមលក្ខខណ្ឌតម្រូវ PS១។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ (CRP) របស់គម្រោងនៅតែស្ថិតក្នុងដំណើរការបង្កើតនៅឡើយ នៅពេលមានការវិនិយោគរបស់ IFC ហើយ IFC អាចណែនាំឱ្យ ABBank ត្រួតពិនិត្យការបង្កើត CRP របស់ EVNI ដែលបំពេញតាមលក្ខខណ្ឌតម្រូវ PS៥។[127]
5. ការកំណត់សេវាប្រព័ន្ធអេកូឡូស៊ី និងការបង្កើតទិន្នន័យមូលដ្ឋានជីវចម្រុះ ដើម្បីអនុញ្ញាតឱ្យមានការត្រួតពិនិត្យត្រឹមត្រូវអំពីផលប៉ះពាល់ជីវចម្រុះរបស់ទំនប់ LS2 ។ លើសពីនេះ IFC អាចសង្កត់ធ្ងន់លើតម្រូវការវាយតម្លៃផលប៉ះពាល់ពេញលេញមួយ ដោយគិតពីចំនួនទំនប់ផ្សេងទៀតដែលត្រូវបានសាងសង់ និងគ្រោងសាងសង់ សម្រាប់អាង 3S និងអាងទន្លេមេគង្គកាន់តែធំ។[128]

## 3.2 ការត្រួតពិនិត្យគម្រោង IFC

ផ្នែកនេះជាដំបូងសង្ខេបអំពីកាតព្វកិច្ចភាពអនុលោមតាម E&S របស់ IFC ក្នុងអំឡុងពេលត្រួតពិនិត្យធនាគារ ABBank និងសកម្មភាពអាជីវកម្មរបស់ខ្លួន ព្រមទាំងឆ្លើយតបទស្សនៈរបស់ IFC អំពីពាក្យបណ្តឹង។ បន្ទាប់មក វា

---

[125] PS៧ ឆ្នាំ២០០៦ តម្រូវឱ្យអតិថិជនជៀសវាងផលប៉ះពាល់អវិជ្ជមានមកលើជនជាតិដើមភាគតិច គ្រប់ពេលដែលអាចធ្វើទៅបាន ហើយនៅពេលដែលការជៀសវាងមិនអាចធ្វើទៅបាន អតិថិជននឹងកាត់បន្ថយឱ្យមកដល់កម្រិតអប្បបរមា កាត់បន្ថយផលប៉ះពាល់ ឬផ្តល់សំណងចំពោះផលប៉ះពាល់ទាំងនេះ ក្នុងលក្ខណៈសមស្របតាមវប្បធម៌ តាមរយៈផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច។ ផែនការនេះគួរតែត្រូវបានកំណត់ពេលវេលាឱ្យបានច្បាស់ បង្កើតឡើងដោយមានការចូលរួមពីជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ដោយបានទទួលព័ត៌មាន ជាកម្មវិធីឯករាជ្យ ឬមាននៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍កាន់តែទូលំទូលាយ ដែលមានធាតុផ្សំដាច់ដោយឡែក សម្រាប់ជនជាតិដើមភាគតិច ស្របតាមលក្ខខណ្ឌតម្រូវនៅក្នុង PS៧ កថាខណ្ឌ ៩ ។ PS៧ ឆ្នាំ២០០៦ កថាខណ្ឌ ៧–៩។

[126] PS១ ឆ្នាំ២០០៦, កថាខណ្ឌ ២៣; PS៥ ឆ្នាំ ២០០៦។

[127] ខណៈពេលដែល EIA ឆ្នាំ២០០៨ លើកឡើងអំពីតម្រូវការសម្រាប់ការផ្លាស់ទីលំនៅ និងការតាំងទីលំនៅថ្មី (S-៥–៦, ១០២–៥, ១៤៦–១៥៩ ff) វាបញ្ជាក់យ៉ាងច្បាស់ថាបទប្បញ្ញត្តិ និងសិទ្ធិលម្អិត នឹងត្រូវបានផ្តល់ជូននៅក្នុងក្របខ័ណ្ឌនៃការតាំងទីលំនៅថ្មី (S-៦) ។

[128] ក្នុងឆ្នាំ ២០១០ ទំនប់ចំនួន ៤៥ ត្រូវបានគ្រោងទុកនៅក្នុងអាងទន្លេ 3S ៖ ២២ នៅលើទន្លេសេកុង ១៣ នៅលើទន្លេសេសាន និង ១០ នៅលើទន្លេស្រែពក (សូមមើលផែនទីក្នុងឧបសម្ព័ន្ធ ក) ។ EIA បានពិចារណាអាងចំនួន ១៦ (៨ នៅលើទន្លេសេសាន និង ៨ នៅលើទន្លេស្រែពក)។ នៅក្នុងអាងទន្លេមេគង្គ បច្ចុប្បន្នមានទំនប់វារីអគ្គិសនីចំនួន ២០៩ និងទំនប់បន្ថែមចំនួន ៥៣៦ សម្រាប់ផ្គត់ផ្គង់ទឹក និងការប្រើប្រាស់ចម្រុះ។ ធនាគារអភិវឌ្ឍន៍អាស៊ី "ការសិក្សាអំពីការអភិវឌ្ឍអាងទន្លេសេសាន ស្រែពក និងសេកុង ក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម" របាយការណ៍របស់ទីប្រឹក្សាជំនួយបច្ចេកទេស ADB គម្រោង ៤០០៨២ (ខែកក្កដា ឆ្នាំ២០១០) https://bit.ly/3zyKtS4។ សូមមើលផងដែរ Eyler និង Kwan "ផែនទីទំនប់ទាំងអស់ នៃអាងទន្លេមេគង្គ" ។

សង្ខេបអំពីសកម្មភាពសំខាន់ៗរបស់ IFC ក្នុងអំឡុងពេលនៃការត្រួតពិនិត្យរបស់ខ្លួនលើធនាគារ ABBank ទាក់ទងនឹង EVNI និង LS2 អមដោយការវិភាគ និងគំហើញរបស់ ស៊ីអេអូ ទៅលើភាពមិនអនុលោម។

### 3.2.1 កាតព្វកិច្ចរបស់ IFC ទាក់ទងនឹងការវិនិយោគរបស់ធនាគារ ABank

គោលនយោបាយនិរន្តរភាព របស់ IFC បង្កើតលក្ខខណ្ឌតម្រូវសម្រាប់ការត្រួតពិនិត្យហានិភ័យ E&S ដែលកើតចេញពីការវិនិយោគនៅក្នុង FIs ដូចជា ABBank ជាដើម។ លក្ខខណ្ឌតម្រូវដ៏សំខាន់មួយគឺថា IFC ត្រួតពិនិត្យភាពអនុលោមរបស់អតិថិជន ស្របតាមការប្តេជ្ញាចិត្ត E&S របស់ខ្លួន ដែលត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ ដែលគ្រប់គ្រងការវិនិយោគនេះ ក៏ដូចជាផែនការសកម្មភាពរបស់អតិថិជនពាក់ព័ន្ធណាមួយ ដែល IFC បានយល់ព្រមជាមួយ ។ ប្រសិនបើអតិថិជនមិនបានអនុលោមតាមការប្តេជ្ញាចិត្តទាំងនេះទេ នោះIFC ត្រូវតែធ្វើការជាមួយអតិថិជនដើម្បីធ្វើឱ្យពួកគេត្រលប់មករកភាពអនុលោមវិញ ឬអនុវត្តដំណោះស្រាយ នៅពេលសមស្រប។[129]

ក្នុងករណីនេះ ផែនការសកម្មភាពបរិស្ថាន និងសង្គម (ហៅថាផែនការ SEMS ក្នុងការវិនិយោគនេះ) ត្រូវបានភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងផ្លូវច្បាប់នៃការវិនិយោគនេះ ហើយមានអាណត្តិថា ABBank ត្រូវ៖

1. បង្កើតឯកសារគោលនយោបាយប្រព័ន្ធគ្រប់គ្រង E&S (ហៅថាគោលនយោបាយ SEMS ក្នុងការវិនិយោគ) ដើម្បីធានាថាប្រតិបត្តិការធនាគារមានភាពសង្គតិភាពជាមួយនឹងលក្ខខណ្ឌតម្រូវរបស់ IFC និង លក្ខខណ្ឌតម្រូវ E&S របស់ប្រទេស។ ជាពិសេស គោលនយោបាយ SEMS ត្រូវដាក់បញ្ចូលធាតុខាងក្រោម ជាការត្រួតពិនិត្យហានិភ័យ និងលក្ខណៈវិនិច្ឆ័យលើការគ្រប់គ្រង៖ (i) បញ្ជីនៃច្បាប់ S&E ដែលពាក់ព័ន្ធមានជាធរមាន (ii) បញ្ជីលើកលែងរបស់ IFC និង (iii) ស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦ ។
2. អនុវត្តលក្ខខណ្ឌតម្រូវឯកសារគោលនយោបាយ SEMS ចំពោះឥណទាន និងការវិនិយោគថ្មីៗទាំងអស់។
3. ធានាភាពអនុលោមនៃ **ឥណទាន និងការវិនិយោគដែលមានស្រាប់ទាំងអស់** ស្របតាមលក្ខខណ្ឌតម្រូវឯកសារគោលនយោបាយ SEMS ។

ដូច្នេះ IFC មានកាតព្វកិច្ចនៅក្រោមកថាខណ្ឌ២៦ នៃគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ ហើយបន្ទាប់មកកថាខណ្ឌ២៤ នៃគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ដើម្បីត្រួតពិនិត្យការអនុវត្តស្តង់ដារសមិទ្ធិកម្ម ចំពោះការវិនិយោគដែលមានស្រាប់របស់ ABBank នៅពេលចុះកិច្ចសន្យាជាមួយ IFC ដោយសារការប្តេជ្ញាចិត្តដែលមាននៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយ ABBank ។

ទាំងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ និងឆ្នាំ២០១២ គឺច្បាស់ណាស់ថា IFC ត្រូវតែត្រួតពិនិត្យការវិនិយោគ

[129] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៦; គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ ២០១២ កថាខណ្ឌ ២៤។

ដោយផ្អែកលើលក្ខខណ្ឌតម្រូវ E&S ជាប់កាតព្វកិច្ចផ្លូវច្បាប់ ដែលបានព្រមព្រៀងជាមួយអតិថិជន។[130] ដូច្នេះ IFC មានកាតព្វកិច្ចដែលកើតចេញពីគោលការណ៍និរន្តរភាព តាមដានត្រួតពិនិត្យការប្ដេជ្ញាចិត្តផ្លូវច្បាប់ និងផែនការសកម្មភាព E&S របស់អតិថិជន ដូចជាផែនការ SEMS ដែលត្រូវបានដាក់បញ្ចូលនៅក្នុងការវិនិយោគ។

- មានការប្ដេជ្ញាចិត្តនៅក្នុងផែនការ SEMS ដែលជាផ្នែកមួយនៃកិច្ចសន្យាវិនិយោគ រវាង IFC និង ABBank ដែលក្នុងនោះ ABBank បានប្ដេជ្ញាបង្កើត SEMS និងអនុវត្ត SEMS នេះ ដោយរួមបញ្ចូលទាំងការអនុវត្តស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦ ចំពោះការវិនិយោគដែលមានស្រាប់ នៅពេល ABBank បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ជាមួយ IFC ។[131]

---

[130] គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ របស់ IFC (កថាខណ្ឌ២៦) កំណត់ថា "បន្ទាប់ពីការផ្ដល់ហិរញ្ញប្បទានរបស់ IFC ត្រូវបានប្ដេជ្ញានៅក្នុងឯកសារច្បាប់ និងត្រូវបានបញ្ចេញ នោះ IFC អនុវត្តសកម្មភាពខាងក្រោម ដើម្បីតាមដានត្រួតពិនិត្យការវិនិយោគរបស់ខ្លួន ជាផ្នែកនៃការត្រួតពិនិត្យផលប័ត្ររបស់ខ្លួន៖ (i) តម្រូវឱ្យគម្រោងដាក់របាយការណ៍តាមដានត្រួតពិនិត្យតាមកាលកំណត់ទៅលើការអនុវត្តសង្គម និងបរិស្ថាន ដូចបានព្រមព្រៀងជាមួយ IFC (ii) ធ្វើការចុះទៅទីតាំងគម្រោងជាក់លាក់មួយចំនួន ដែលមានហានិភ័យ និងផលប៉ះពាល់សង្គម និងបរិស្ថាន (iii) ពិនិត្យឡើងវិញនូវការអនុវត្តគម្រោង ដោយផ្អែកលើការប្ដេជ្ញាចិត្តរបស់អតិថិជននៅក្នុងផែនការសកម្មភាព ដូចបានរាយការណ៍នៅក្នុងរបាយការណ៍តាមដានត្រួតពិនិត្យរបស់អតិថិជន ហើយក្នុងករណីដែលពាក់ព័ន្ធ សូមពិនិត្យមើលជាមួយអតិថិជននូវឱកាសកែលម្អការអនុវត្តណាមួយ (iv) ប្រសិនបើមានការប្រែប្រួលស្ថានភាពគម្រោង បណ្ដាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សង្គម ឬបរិស្ថាន ធ្វើការជាមួយអតិថិជនដើម្បីដោះស្រាយផលប៉ះពាល់ទាំងនេះ (v) ប្រសិនបើអតិថិជនបរាជ័យក្នុងការអនុលោមតាមការប្ដេជ្ញាចិត្តផ្នែកសង្គម និងបរិស្ថាន ដូចបានបញ្ជាក់នៅក្នុងផែនការសកម្មភាព ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយ IFC ធ្វើការជាមួយអតិថិជនដើម្បីនាំយកពួកគេត្រឡប់មកអនុលោមវិញ តាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយប្រសិនបើអតិថិជនមិនអាចអនុលោមឡើងវិញបាន អនុវត្តដំណោះស្រាយ នៅពេលសមស្រប (vi) លើកទឹកចិត្តអតិថិជនឱ្យរាយការណ៍ជាសាធារណៈអំពីទិដ្ឋភាពសង្គម បរិស្ថាន និងផ្នែកមិនមែនហិរញ្ញវត្ថុផ្សេងទៀតនៃការអនុវត្តរបស់ខ្លួន បន្ថែមពីលើការរាយការណ៍អំពីផែនការសកម្មភាព ដូចបានតម្រូវដោយស្តង់ដារសមិទ្ធិកម្ម១ (vii) លើកទឹកចិត្តអតិថិជនឱ្យបន្តអនុវត្តតាមស្តង់ដារសមិទ្ធិកម្ម បន្ទាប់ពី IFC បានចាកចេញពីគម្រោង។ គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៦។ គោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌ២៤) កំណត់ថា "កិច្ចព្រមព្រៀងរបស់ IFC ទាក់ទងនឹងការផ្ដល់ហិរញ្ញប្បទានដល់សកម្មភាពរបស់អតិថិជន រួមមានបទប្បញ្ញត្តិជាក់លាក់ ដែលអតិថិជនត្រូវអនុលោមតាម។ ចំណុចទាំងនេះរួមមាន ការអនុលោមតាមលក្ខខណ្ឌនៃស្តង់ដារសមិទ្ធិកម្មមានជាធរមាន និងលក្ខខណ្ឌជាក់លាក់មួយចំនួន ដែលបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព ក៏ដូចជាបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីរាយការណ៍អំពីបរិស្ថាន និងសង្គម និងការចុះត្រួតពិនិត្យ ដោយបុគ្គលិក ឬតំណាង IFC តាមការសមស្រប។ ប្រសិនបើអតិថិជនបរាជ័យក្នុងការអនុលោមតាមការប្ដេជ្ញាចិត្តផ្នែកបរិស្ថាន និងសង្គម ដូចបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងឯកសារពាក់ព័ន្ធ នោះ IFC នឹងធ្វើការជាមួយអតិថិជនដើម្បីនាំយកពួកគេឱ្យមកអនុលោមវិញ ហើយប្រសិនបើអតិថិជនមិនអាចអនុលោមឡើងវិញបាន នោះ IFC នឹងអនុវត្តសិទ្ធិរបស់ខ្លួន និងមធ្យោបាយដោះស្រាយតាមការសមស្រប"។ គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២ កថាខណ្ឌ ២៤។

[131] ដូចបានបញ្ជាក់នៅក្នុង ESRP ចូលជាធរមាននៅពេលនោះ "លក្ខខណ្ឌតម្រូវការការអនុវត្តជាធរមាន" ដែល IFC ត្រូវត្រួតពិនិត្យលើការវិនិយោគ គឺ "ស្តង់ដារសមិទ្ធិកម្មរបស់ IFC (PSs) ទាំងអស់ គឺអាចអនុវត្តចំពោះគម្រោងនានា ដែលបានបញ្ជាក់ដោយកតិកាសញ្ញាកិច្ចសន្យាវិនិយោគ។ ក្នុងករណីអន្តរការីហិរញ្ញវត្ថុ (FI) ចំណុចនេះអាចនឹងជាការរួមបញ្ចូលគ្នានៃបញ្ជីលើកលែង ច្បាប់ និងបទប្បញ្ញត្តិជាតិ និង PSs ជាទូទៅ របស់ IFC រួមទាំងធាតុជាក់លាក់នៃ PSs របស់ IFC ដែលត្រូវបានកំណត់ ក្នុងអំឡុងពេលនៃការត្រួតពិនិត្យមើលឡើងវិញ ហើយនោះគឺអាចអនុវត្តចំពោះអនុគម្រោងដែលគាំទ្រដោយ FI និងអនុវត្តតាមរយៈប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម របស់ FI ។ ESRP ឆ្នាំ២០០៩ របស់ IFC (ពាក្យគន្លឹះ និងអក្សរកាត់)។

ស៊ីអេអូ មិនបានទទួលការពន្យល់សូម្បីតែម្តង អំពីមូលហេតុដែលការប្តេជ្ញាចិត្តនេះត្រូវបានដាក់បន្ថែម នៅក្នុងផែនការ SEMS នៃការវិនិយោគរបស់ ABBank ។ ការឆ្លើយតបរបស់គណៈគ្រប់គ្រង IFC មិនទទួលស្គាល់ ឬដោះស្រាយការប្តេជ្ញាចិត្តនេះ នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ទេ។ បុគ្គលិក IFC មួយចំនួន បានប្រាប់ ស៊ីអេអូ ថាការប្តេជ្ញាចិត្តនៅក្នុងផែនការ SEMS សម្រាប់ ABBank អនុវត្តស្តង់ដារសមិទ្ធិកម្ម របស់ IFC ចំពោះការវិនិយោគដែលមានស្រាប់ នៅពេលចុះហត្ថលេខា អាចជាការត្រួតពិនិត្យដោយអចេតនា ពីព្រោះ IFC មិនតម្រូវឱ្យមានការអនុវត្តតាមលក្ខខណ្ឌតម្រូវ E&S របស់ខ្លួន ចំពោះការវិនិយោគដែលបានកើតឡើង មុនពេលការផ្តល់ហិរញ្ញប្បទានរបស់ IFC ទេ។ ទោះយ៉ាងណាក៏ដោយ ស៊ីអេអូ កត់សម្គាល់ថា៖

- ការវិនិយោគរបស់ធនាគារ ABBank ត្រូវបានអនុម័ត និងបានប្តេជ្ញាចិត្ត ក្រោមគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ ដែលមានការនៅស្ងៀមទៅលើការអនុវត្ត PS ចំពោះសកម្មភាពអាជីវកម្មដែលមានស្រាប់របស់ FI ។ វាគឺស្ថិតនៅក្រោមគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ដែល IFC បានណែនាំបង្កើតបទប្បញ្ញត្តិ ដែលចែងថា "លក្ខខណ្ឌតម្រូវរបស់ IFC ទាក់ទងនឹងការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម [ក្នុងការវិនិយោគភាគហ៊ុន...] នឹងអនុវត្តចំពោះផលប័ត្រទាំងមូល នៃ FI ដែលមានប្រភពដើមតាំងពីពេលដែល IFC ក្លាយជាម្ចាស់ភាគហ៊ុន ឬជាអ្នកវិនិយោគ មកម្លេះ។"[132]
- ស៊ីអេអូ បានជួបប្រទះការវិនិយោគយ៉ាងហោចណាស់បីផ្សេងទៀត ជាមួយនឹងកិច្ចព្រមព្រៀងផ្លូវច្បាប់ ដែលរួមបញ្ចូលការប្តេជ្ញាចិត្តក្នុងការអនុវត្ត SEMS ឬ ESMS ទៅលើឥណទាន និងការវិនិយោគ "ដែលមានស្រាប់" របស់អតិថិជនអន្តរការីហិរញ្ញវត្ថុ IFC នៅពេលធ្វើការប្តេជ្ញាចិត្ត។[133] ដូច្នេះគេមិនអាចនិយាយថា វាផ្ទុយទៅនឹងការអនុវត្តដែលមានស្រាប់ មុនគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ទេ។
- ឯកសារគម្រោង និងការទំនាក់ទំនង នៅក្នុងដំណាក់កាលត្រួតពិនិត្យ និងប្តេជ្ញាចិត្ត នៃការវិនិយោគរបស់ IFC នៅក្នុង ABBank បង្ហាញថា IFC និងអតិថិជន បានពិភាក្សាយ៉ាងសកម្មអំពីផែនការ SEMS ។ ថ្វីត្បិតតែមានការពិភាក្សាអំពីការកែសម្រួលមួយចំនួនក៏ពិតមែន ក៏គ្មានការកែប្រែ ឬការកែតម្រូវណាមួយត្រូវបានធ្វើឡើងចំពោះការប្តេជ្ញាចិត្តក្នុងការអនុវត្តលក្ខខណ្ឌតម្រូវនៃគោលនយោបាយ SEMS ទៅលើឥណទាន និងការវិនិយោគដែលមានស្រាប់ ក្រៅតែពីការស្នើសុំឱ្យផ្លាស់ប្តូរពេលវេលាសម្រាប់ការបិទបញ្ចប់វាប៉ុណ្ណោះ។ ចំណុចនេះ ស្នើថា IFC និង ABBank បានដឹងអំពីកាតព្វកិច្ចនេះ នៅក្នុងផែនការ SEMS ហើយការដាក់បញ្ចូលវា គឺមិនមែនគ្រាន់តែជាការត្រួតពិនិត្យនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់នោះទេ។

---

[132] គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២, កថាខណ្ឌ ៣៧។

[133] ការប្តេជ្ញាចិត្តទាំងនេះមិនអនុវត្តតាមគំរូតែមួយ ឬមានអត្ថបទដូចគ្នាបេះបិទ ក្នុងគ្រប់ករណីទាំងអស់នោះទេ ប៉ុន្តែទាំងអស់តម្រូវឱ្យអនុវត្ត SEMS ឬ ESMS ទៅនឹងការវិនិយោគដែលមានស្រាប់នៃ FI ដែលត្រូវគ្នា។ គួរកត់សំគាល់ផងដែរថា ជាទូទៅ ស៊ីអេអូ ពិនិត្យមើលសំណាកគំរូតូចមួយ នៃការវិនិយោគរបស់ IFC (ជាធម្មតាតំណាងឱ្យប្រហែល ១-១,៦ ភាគរយនៃគម្រោងរបស់ IFC និងទំហំឥណទាន)។ ដូច្នេះ ជាក់ស្តែងគឺថា ស៊ីអេអូ បានកំណត់ការវិនិយោគចំនួន ៤ ជាមួយនឹងការប្តេជ្ញាចិត្តដូចគ្នា ក្នុងការអនុវត្ត SEMS ឬ ESMS ទៅនឹងការវិនិយោគដែលមានស្រាប់ គឺបង្ហាញថាប្រភេទនៃការប្តេជ្ញាចិត្តទាំងនេះប្រហែលជាមិនមានអ្វីអស្ចារ្យ ឬពិសេសប្លែកពីគេនោះទេ។ ក្នុងចំណោមប្រភពទិន្នន័យករណីផ្សេងៗទៀត របស់ ស៊ីអេអូ ទាក់ទងនឹងផលប័ត្ររបស់ IFC សូមមើល អាទិភាពយុទ្ធសាស្ត្រ ស៊ីអេអូ FY២៣–FY២៥, (ថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០២២), ៧,https://bit.ly/4ebM2nC។

បុគ្គលិក IFC ផ្សេងទៀតក៏ស្នើមក ស៊ីអេអូ ថា ការប្តេជ្ញាចិត្តអនុវត្ត SEMS ចំពោះ "ឥណទាន និងការវិនិយោគដែលមានស្រាប់" គួរតែត្រូវបានបកស្រាយថាជាការប្តេជ្ញាចិត្តអនុវត្ត SEMS ចំពោះ "ឥណទាន និងការវិនិយោគថ្មីៗរបស់អតិថិជនដែលមានស្រាប់" ។ យ៉ាងណាក៏ដោយ ស៊ីអេអូ កត់សម្គាល់ថា៖

- មានការប្តេជ្ញាចិត្តពីរខុសគ្នា ជាមួយនឹងកាលកំណត់ពីរផ្សេងគ្នា នៅក្នុងផែនការ SEMS ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងផ្លូវច្បាប់ រវាង IFC និង ABBank៖ (i) ការអនុវត្តលក្ខខណ្ឌតម្រូវគោលនយោបាយ SEMS ចំពោះ "ឥណទាន និងការវិនិយោគថ្មីទាំងអស់" និង (ii) ការធានាភាពអនុលោមតាម "ឥណទាន និងការវិនិយោគដែលមានស្រាប់" ស្របតាមលក្ខខណ្ឌតម្រូវគោលនយោបាយ SEMS ។
- មិនមានភស្តុតាងនៅក្នុងឯកសារគម្រោង កំណត់ហេតុកិច្ចប្រជុំ ការទំនាក់ទំនង ឬអនុស្សរណៈនៃការយោគយល់ ដែល IFC និង ABBank មានបំណងនិយាយអ្វីផ្សេង ក្រៅតែពីចំណុចដែលបានបញ្ជាក់យ៉ាងច្បាស់ និងបានប្តេជ្ញាចិត្ត នៅក្នុងផែនការ SEMS នោះទេ។
- ដូចគ្នាទៅនឹងកិច្ចសន្យានានាដែរ អត្ថន័យនៃពាក្យពេចន៍ជាលក្ខណៈទូទៅ ដែលយកមកប្រើដោយសេរីនៅក្នុងកិច្ចព្រមព្រៀង គឺមានសារៈសំខាន់ខ្លាំងក្នុងការបកស្រាយបទប្បញ្ញត្តិនានារបស់វា។

ដូច្នេះ ស៊ីអេអូ ចាត់ទុកថា IFC មានកាតព្វកិច្ចក្រោមគោលនយោបាយនិរន្តរភាព ក្នុងការតាមដានត្រួតពិនិត្យការអនុវត្តស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ ចំពោះការវិនិយោគដែលមានស្រាប់ របស់ធនាគារ ABBank តាមដែលអាចធ្វើទៅបាន។ នៅក្រោមគោលនយោបាយនិរន្តរភាពរបស់ IFC អនុគម្រោងរបស់ FI ដែលមានហានិភ័យ E&S កាន់តែខ្ពស់ គឺតម្រូវឱ្យអនុវត្តស្តង់ដារសមិទ្ធិកម្ម។[134]

នៅក្នុងរយៈពេលនៃការវិនិយោគរបស់ IFC ក្នុងឆ្នាំ២០១០ ABBank មានការវិនិយោគភាគហ៊ុនរួចទៅហើយ នៅក្នុងក្រុមហ៊ុន EVNI ដែលសកម្មភាពអាជីវកម្មចម្បងរបស់ខ្លួននៅពេលនោះ ហើយនៅតែបន្តរហូតដល់បច្ចុប្បន្ននេះ គឺនៅតែជាគម្រោងវារីអគ្គិសនីសេសានក្រោម២។ នៅពេលនោះ LS2 ស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដោយរដ្ឋាភិបាលកម្ពុជា បានអនុម័ត EIA នៅខែមិថុនា ឆ្នាំ២០១០។ ដូច្នេះ ស៊ីអេអូ ចាត់ទុកនេះជាអនុគម្រោង ដែលមានហានិភ័យ E&S ច្បាស់លាស់ ដែល IFC អាចធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីធានាភាពអនុលោមតាម PS (សូមមើលផ្នែក 3.2.3 , 3.2.3.1 និង 3.2.3.2 ខាងក្រោមសម្រាប់ព័ត៌មានលម្អិតបន្ថែម)។

ស៊ីអេអូ យល់ថាការធានាឱ្យមានភាពអនុលោមតាម E&S ស្របតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC ចំពោះការវិនិយោគពីមុន ឬការវិនិយោគនាពេលបច្ចុប្បន្នរបស់ ABBank គឺជាការប្តេជ្ញាចិត្តដ៏ប្រឈមមួយ។ ដោយគ្មានការ

---

[134] គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦, កថាខណ្ឌ ២៨; គោលនយោបាយនិរន្តរភាព របស់ IFC ឆ្នាំ២០១២, កថាខណ្ឌ ៣៥; កំណត់សម្គាល់ការបកស្រាយរបស់ IFC ស្តីពីអន្តរការីហិរញ្ញវត្ថុ ថ្ងៃទី១ ខែមករា ឆ្នាំ ២០១២ ដែលបានធ្វើបច្ចុប្បន្នភាព នៅខែវិច្ឆិកា ឆ្នាំ ២០១៨ កថាខណ្ឌ IN១២ https://bit.ly/3UY8olS ។

បន្ធូរបន្ថយកាតព្វកិច្ចភាពអនុលោមរបស់អតិថិជន ដែលមានអត្ថិភាពដោយគ្មានគុណវុឌ្ឍិ ឬករណីលើកលែង[135] ស៊ីអេអូ បានពិនិត្យមើលសកម្មភាពរបស់ IFC ក្នុងបរិបទនៃឱកាស ក្នុងអំឡុងពេលត្រួតពិនិត្យកែលម្អ ឬជះឥទ្ធិពលវិជ្ជមានលើការអនុវត្ត E&S របស់អនុគម្រោង LS2 ដោយគិតគូរពីកម្រិតអានុភាពរបស់ ABBank និង EVNI និងដំណាក់កាលនៃការអភិវឌ្ឍ។

| តារាង២៖ បន្ទាត់ពេលវេលាដែលពាក់ព័ន្ធ សម្រាប់ការត្រួតពិនិត្យ E&S របស់ IFC | |
|---|---|
| **ការវិនិយោគដែលមានស្រាប់របស់ ABBank នៅក្នុង EVNI** | **ការវិនិយោគរបស់ IFC នៅក្នុង ABBank** |
| • ABBank គឺជាម្ចាស់ហ៊ុនភាគតិច នៅក្នុង EVNI (១០,៣១ ភាគរយ) ដោយបានទិញភាគហ៊ុន ក្នុងឆ្នាំ ២០០៧ និង ២០១០ ។<br>• ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ ២០១២ EVNI គឺជាអ្នកអភិវឌ្ឍន៍ដ៏សំខាន់សម្រាប់អនុគម្រោង LS2 ហើយបានវិនិយោគលើការធ្វើផែនការគម្រោង និងការអភិវឌ្ឍដំណាក់កាលដំបូង។<br>• នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ភាគហ៊ុនរបស់ EVNI ត្រូវបានកាត់បន្ថយមកនៅត្រឹម ១០ ភាគរយ ហើយក្រុមហ៊ុន Hydrolancang International Energy បានក្លាយជាម្ចាស់ហ៊ុនភាគច្រើន និងជាប្រតិបត្តិករគម្រោង។<br>• EVNI គឺជាម្ចាស់ហ៊ុនភាគតិច នៅក្នុង LS2 តាំងពីឆ្នាំ ២០១២។ ប៉ុន្តែ LS2 តំណាងឱ្យយ៉ាងហោចណាស់ ៧៥ ភាគរយនៃប្រាក់ចំណូលរបស់ EVNI ។ | • ក្នុងខែធ្នូ ឆ្នាំ ២០១០ IFC បានជាវមូលបត្របំណុលមានអាណត្តិដែលអាចបំប្លែងបានជាមួយធនាគារ ABBank ។<br>• នៅខែមេសា ឆ្នាំ២០១៣ មូលបត្របំណុលទាំងនោះបានប្តូរទៅជាភាគហ៊ុន ហើយ IFC បានក្លាយជាម្ចាស់ហ៊ុនភាគតិចនៅក្នុង ABBank (១០ ភាគរយ)។<br>• នៅខែធ្នូ ឆ្នាំ២០២១ ភាគហ៊ុនរបស់ IFC នៅក្នុង ABBank បានថយចុះមកត្រឹម ៨.២ ភាគរយ។<br>• នៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០២៤ IFC បានដកខ្លួនចេញពីធនាគារ ABBank ដោយលក់ភាគហ៊ុនរបស់ខ្លួន។ |

[135] ការប្តេជ្ញាចិត្តនៅក្នុងផែនការ SEMS គឺដើម្បីអនុវត្តស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ ទៅលើឥណទាន និងការវិនិយោគដែលមានស្រាប់ទាំងអស់ ដោយមិនគិតពីដំណាក់កាលនៃការអភិវឌ្ឍន៍របស់អនុគម្រោង ឬកម្រិតនៃឥទ្ធិពលរបស់ ABBank តាមរយៈការកាន់កាប់ភាគហ៊ុនរបស់ខ្លួន។ ស្រដៀងគ្នានេះដែរ ទាំងគោលនយោបាយនិរន្តរភាព IFC ឆ្នាំ ២០០៦ និងឆ្នាំ២០១២ តម្រូវឱ្យអនុវត្ត PS ចំពោះគម្រោងទាំងអស់ដែលមានហានិភ័យ E&S យ៉ាងសំខាន់ ដោយមិនគិតពីដំណាក់កាលនៃការអភិវឌ្ឍន៍របស់អនុគម្រោង ឬកម្រិតនៃឥទ្ធិពលរបស់ FI តាមរយៈភាគហ៊ុនរបស់ខ្លួន។

### 3.2.2 សេចក្តីសង្ខេបនៃសកម្មភាពត្រួតពិនិត្យរបស់ IFC

IFC បានបញ្ចេញមូលនិធិទាំងអស់ សម្រាប់ការវិនិយោគនេះ តាមរយៈការទូទាត់តែមួយ នៅខែធ្នូ ឆ្នាំ២០១០[136] ភ្លាមៗក្រោយពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយធនាគារ ABBank ។

លក្ខខណ្ឌ E&S តែមួយគត់ដែល ABBank ត្រូវតែគោរពតាមសម្រាប់ការទូទាត់ចំណាយ គឺការតែងតាំងមន្ត្រី SEMS មួយរូប ដែលខ្លួនបានអនុវត្ត តាមរយៈការតែងតាំងនាយករងនៃនាយកដ្ឋានគោលនយោបាយ និងក្របខ័ណ្ឌឥណទានរបស់ខ្លួន សម្រាប់តួនាទីនេះ។ ក្នុងខែមករា ឆ្នាំ២០២១ ABBank បានតែងតាំងនាយកគោលនយោបាយឥណទានរបស់ខ្លួន នៅក្នុងតួនាទីថ្មី និងបន្ថែមជាមន្ត្រី E&S ហើយនៅខែកុម្ភៈ ឆ្នាំ២០១២ ធនាគារ ABBank បានតែងតាំងមន្ត្រីគ្រប់គ្រងផលប័ត្រឥណទានរបស់ខ្លួន ជាមន្ត្រី SEMS ។ គាត់បានបំពេញតួនាទីជាមន្ត្រី SEMS រហូតដល់ឆ្នាំ២០១៩ នៅពេលដែលទីប្រឹក្សា E&S ត្រូវបានជ្រើសរើសឱ្យបម្រើការងារពេញម៉ោង។ ចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២១ ទីប្រឹក្សានេះ ទទួលបន្ទុកអនុវត្តគោលនយោបាយ SEMS រួមជាមួយនឹងអ្នកសម្របសម្រួល E&S ក្រៅម៉ោង។ បន្ទាប់ពីការលាលែងរបស់ទីប្រឹក្សានេះ នៅឆ្នាំ២០២១ ទីប្រឹក្សាម្នាក់ទៀតត្រូវបានជ្រើសរើសឱ្យបម្រើការងារ ដែលបន្ទាប់មកបានចាកចេញ នៅខែមិថុនា ឆ្នាំ២០២២។ នៅខែសីហា ឆ្នាំ២០២២ ទីប្រឹក្សា E&S ម្នាក់ទៀតត្រូវបានតែងតាំង ក្រោយមកក៏បានលាលែងពីតំណែងនៅខែវិច្ឆិកា ឆ្នាំ២០២៣។ នៅពេល IFC បានចាកចេញនៅខែឧសភា ឆ្នាំ២០២៤ ធនាគារ ABBank គឺស្ថិតក្នុងដំណើរការជ្រើសរើសអ្នកបន្ត។

ក្នុងអំឡុងពេលនៃត្រួតពិនិត្យរបស់ខ្លួនលើការវិនិយោគរបស់ ABBank IFC បានគូសបញ្ជាក់ម្តងហើយម្តងទៀតអំពីតម្រូវការឱ្យមានមន្ត្រី E&S ដែលមានបទពិសោធន៍ បន្ថែមទៀត ជាពិសេសអ្នកដែលមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រងហានិភ័យ E&S ស្របតាមស្តង់ដារសមិទ្ធិកម្ម។

---

[136] យោងតាម ESRP ឆ្នាំ២០០៩ របស់ IFC ដែលអាចអនុវត្តបាន ក្នុងអំឡុងពេលការប្តេជ្ញាចិត្តនៃការវិនិយោគនេះ មន្ត្រី E&S របស់ IFC ចាំបាច់ត្រូវ "កំណត់សកម្មភាព SEMS ណាមួយ ដែលអតិថិជននឹងត្រូវអនុវត្ត ដើម្បីដោះស្រាយចំណុចខ្វះខាតនៅក្នុងផ្នែកទាំងនេះ [នីតិវិធី និងគោលនយោបាយ E&S របស់អតិថិជន; រចនាសម្ព័ន្ធស្ថាប័ន និងបុគ្គលិកបច្ចុប្បន្ន; ជំនាញ និងសមត្ថភាពក្នុងវិស័យ E&S; ការបណ្តុះបណ្តាល និងការយល់ដឹងរបស់មន្ត្រីវិនិយោគ ច្បាប់ និងមន្ត្រីឥណទានរបស់អតិថិជន អំពីលក្ខណ្ឌតម្រូវ E&S និង SEMS របស់ស្ថាប័ន; នីតិវិធីតាមដានត្រួតពិនិត្យការអនុវត្ត; របាយការណ៍លទ្ធផលផ្ញើជូនគណៈអ្នកគ្រប់គ្រង; និងតាមដានកំណត់ត្រារហូតមកដល់បច្ចុប្បន្នចំពោះការអនុវត្ត SEMS] ដើម្បីធានាបាននូវភាពអនុលោមតាមលក្ខខណ្ឌតម្រូវការអនុវត្តជាធរមាន។ វិធីសាស្ត្រដែលបានស្នើគឺ [ដូចតទៅ] (i) គម្លាតនៅក្នុង SEMS នៃ FIs ដែលបានចូលរួមនៅក្នុងគម្រោងដែលអាចនឹងមាន ហានិភ័យ E&S ឬការប្រឈមនឹងហានិភ័យ ចំពោះ IFC ត្រូវតែដោះស្រាយ ដើម្បីធានាបាននូវភាពអនុលោមតាមលក្ខខណ្ឌតម្រូវការអនុវត្តជាធរមាន មុនពេលការប្តេជ្ញាចិត្តរបស់ IFC ឬ ជាលក្ខខណ្ឌនៃការបញ្ចេញមូលនិធិ IFC; (ii) គម្លាតនៅក្នុង SEMS នៃ FIs ដែលមានហានិភ័យ E&S ទាប ឬមិនមានសកម្មភាពផ្តល់ហិរញ្ញប្បទានភ្លាមៗ នៅក្នុងតំបន់ដែលមានហានិភ័យបែបនេះ ត្រូវតែដោះស្រាយ តាមផែនការសកម្មភាព ESMS មានពេលវេលាច្បាស់លាស់ ដែលនឹងត្រូវដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងត្រូវបានអនុម័តដោយ TL ។ ESRP ឆ្នាំ២០០៩ របស់ IFC ផ្នែក 7.2.19 ។

ទាក់ទងនឹងការត្រួតពិនិត្យគម្រោងរបស់ IFC ស៊ីអេអូ កត់សម្គាល់ថា មិនមានសកម្មភាពត្រួតពិនិត្យក្នុងឆ្នាំ២០១១ ទេ[137] ទោះបីជាសកម្មភាពភាគច្រើននៅក្នុងផែនការ SEMS ត្រូវបានប្តេជ្ញាចិត្តសម្រេចឱ្យបាន នៅក្នុងរយៈពេលពី បី ទៅប្រាំបួនខែ បន្ទាប់ពីការទូទាត់ចំណាយក៏ដោយ។ ដូច្នេះពួកវាគួរត្រូវបានបញ្ចប់នៅឆ្នាំ២០១១។[138] ក្រៅតែពីការតែងតាំងមន្ត្រី SEMS, ABBank មិនបានបំពេញការប្តេជ្ញាចិត្តណាមួយ នៅក្នុងផែនការ SEMS ក្នុងរយៈពេលដែលបានព្រមព្រៀងនោះទេ។ មិនមានភស្តុតាង ដែលបញ្ជាក់ថា IFC បានអនុវត្តកិច្ចខិតខំប្រឹងប្រែងណាមួយ ដើម្បីអនុវត្តតាមកាលបរិច្ឆេទផុតកំណត់ទាំងនោះទេ។

## ផែនការ SEMS

1. តែងតាំងមន្ត្រី SEMS មុនពេលការប្តេជ្ញាចិត្ត។
2. បង្កើតឯកសារគោលនយោបាយ SEMS ដើម្បីធានាថាប្រតិបត្តិការធនាគារ មានសង្គតិភាពជាមួយនឹងស្តង់ដារសមិទ្ធិកម្ម បទប្បញ្ញត្តិ E&S មានជាធរមានរបស់ប្រទេស និងបញ្ជីលើកលែងរបស់ IFC ។ គោលនយោបាយ SEMS ត្រូវការដាក់បញ្ចូលធាតុខាងក្រោម ជាការត្រួតពិនិត្យហានិភ័យ និងលក្ខណៈវិនិច្ឆ័យលើការគ្រប់គ្រង៖ (i) បញ្ជីនៃច្បាប់ E&S ដែលពាក់ព័ន្ធ (ii) បញ្ជីលើកលែងរបស់ IFC និង (iii) ស្តង់ដារសមិទ្ធិកម្មឆ្នាំ២០០៦ របស់ IFC។
3. បង្កើតផែនការអនុវត្ត SEMS ។
4. បង្កើតនីតិវិធី SEMS និងសេចក្តីណែនាំអំពីការអនុវត្ត។
5. ការបណ្តុះបណ្តាលបុគ្គលិក E&S ។
6. បញ្ចូលលក្ខណៈវិនិច្ឆ័យ E&S ទៅក្នុងប្រព័ន្ធត្រួតពិនិត្យតាមដាន/ព័ត៌មានផ្ទៃក្នុងរបស់ធនាគារ។
7. អនុវត្តគោលនយោបាយ SEMS ចំពោះឥណទាន និងការវិនិយោគថ្មីៗទាំងអស់។
8. ធានាភាពអនុលោមតាមឥណទាន និងការវិនិយោគដែលមានស្រាប់ទាំងអស់ ស្របតាមលក្ខខណ្ឌតម្រូវការឯកសារគោលនយោបាយ SEMS ។
9. ធ្វើការត្រួតពិនិត្យហានិភ័យកេរ្តិ៍ឈ្មោះ ប្រចាំត្រីមាស។
10. ធ្វើការត្រួតពិនិត្យឡើងវិញលើការអនុវត្ត SEMS ផ្ទៃក្នុង ប្រចាំឆ្នាំ។

នៅខែកុម្ភៈ ឆ្នាំ២០១២ នៅពេលដែលសកម្មភាពត្រួតពិនិត្យដំបូងរបស់ IFC ត្រូវបានកត់ត្រា, ការប្តេជ្ញាចិត្ត E&S ចំនួនពីរត្រូវបានបំពេញ៖ (i) ការតែងតាំងមន្ត្រី E&S និង (ii) ការបង្កើតប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថានដំបូងរបស់ធនាគារ ABBank (SEMS)។ ប្រព័ន្ធនេះ ត្រូវបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១១ ប្រហែលប្រាំបួនខែបន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ដំបូង នៅក្នុងផែនការ SEMS ។[139] ចេញពីភស្តុតាងដែលមាន, ABBank បានដាក់ឯកសារគោលនយោបាយ SEMS ដំបូងរបស់ខ្លួន នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ ប្រគល់ជូន IFC ។ គោលនយោបាយនេះ

[137] អតិថិជនមិនបានបញ្ជូន AEPR សម្រាប់ឆ្នាំ២០១១ ទេ ដូច្នេះហើយមិនមានការពិនិត្យឡើងវិញអំពីវាទេ។ វាក៏មិនមានភស្តុតាងស្តីពីការចូលរួមរវាង IFC និងអតិថិជន ក្នុងអំឡុងឆ្នាំ២០១១ (ការទំនាក់ទំនង ការចុះពិនិត្យផ្ទាល់ ឬការឆ្លើយឆ្លងអ៊ីម៉ែល) ឬថា IFC តម្រូវឱ្យអតិថិជនបញ្ជូនព័ត៌មានទាក់ទងនឹងការបំពេញការប្តេជ្ញាចិត្តរបស់ E&S ឬ AEPR ក្នុងកំឡុងឆ្នាំ២០១១។

[138] AEPR ត្រូវបានបញ្ជូនដំបូងរបស់អតិថិជន បានគ្របដណ្តប់ឆ្នាំ២០១២។

[139] IFC បានបង្ហាញមកកាន់ ស៊ីអេអូ ថា មិនមានការចុះពិនិត្យមូលដ្ឋានណាមួយបានកើតឡើងក្នុងឆ្នាំ២០១១ ទេ។ ទោះជាយ៉ាងណាក៏ដោយ ឯកសារគម្រោង លើកឡើងពីការចុះពិនិត្យតាមមូលដ្ឋាន ដែលក្នុងនោះ អតិថិជនបានផ្តល់ IFC នូវសេចក្តីព្រាងឯកសារគោលនយោបាយ E&S លើកដំបូង ដែល IFC បានផ្តល់មតិកែលម្អ (ដែល ស៊ីអេអូ មិនមានកំណត់ត្រាអំពីវាទេ) ប៉ុន្តែមិនបានទទួលឯកសារកែសម្រួល នៅពេលក្រោយទេ។

ភាគច្រើនបានប្តេជ្ញាធ្វើការវិភាគ និងវាយតម្លៃហានិភ័យ E&S នៃប្រតិបត្តិការ ដោយយោងទៅតាមច្បាប់សុខភាព សុវត្ថិភាព និងបរិស្ថានដែលកំពុងមានជាធរមាន របស់ប្រទេសវៀតណាម ដោយអ្នកឯកទេសផ្នែកទំនាក់ទំនងអតិថិជនរបស់ ABBank ។ IFC បានរកឃើញថា គោលនយោបាយ SEMS ទទួលបានការពេញចិត្តដោយផ្នែក ហើយបានសុំឱ្យអតិថិជនកែប្រែវាឡើងវិញ។ ស៊ីអេអូ មិនមានព័ត៌មានលម្អិតអំពីមតិកែលម្អរបស់ IFC ទេ។ ទោះជាយ៉ាងណាក៏ដោយ នៅខែកញ្ញា ឆ្នាំ២០១២ IFC បានបង្ហាញថា អតិថិជនបានបង្កើតគោលនយោបាយ SEMS ថ្មី នៅក្នុងខែកក្កដា ឆ្នាំ២០១២ ដោយមានការគាំទ្រ និងការណែនាំពីអ្នកឯកទេស E&S របស់ IFC ។ ជាទូទៅ IFC បានពេញចិត្តលើគោលនយោបាយនេះ ប៉ុន្តែបានលើកឡើងពីក្តីកង្វល់ទាក់ទងនឹងការចាត់ថ្នាក់ E&S របស់គម្រោង ដែលមិនតែងតែត្រូវគ្នាជាមួយនឹងកម្រិតនៃហានិភ័យ E&S ព្រមទាំងអវត្តមានកិច្ចព្រមព្រៀង E&S ទាំងនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងនៅក្នុងដំណើរការតាមដានត្រួតពិនិត្យ E&S ផ្លូវការ។

កំណត់ត្រាត្រួតពិនិត្យរបស់ IFC បង្ហាញថា ខ្លួនបានចាត់ទុកថាចំណុចខ្វះខាតទាំងនេះត្រូវបានដោះស្រាយដោយ ABBank នៅចន្លោះឆ្នាំ២០១៤ និង២០១៥។ ក្នុងពេលជាមួយគ្នានេះ ទាំងនៅឆ្នាំ ២០១៤ និង២០១៥ IFC បានអះអាងថា ខណៈពេលដែលអតិថិជនតម្រូវឱ្យអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ E&S ជាតិ យ៉ាងតឹងរឹង ចំពោះការវិនិយោគរបស់ខ្លួន IFC បានចាត់ទុកលក្ខខណ្ឌតម្រូវស្តង់ដារសមិទ្ធិកម្ម ជាអនុសាសន៍ ហើយមិនបានអនុវត្តវាទេ។ ទោះជាយ៉ាងណាក៏ដោយ IFC បានបន្តចាត់ទុកថា អតិថិជន "អនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC" និងបានវាយតម្លៃការអនុវត្ត E&S របស់ខ្លួន និងការអនុវត្ត SEMS គឺជាការពេញចិត្ត។

ស៊ីអេអូ ក៏កត់សម្គាល់ផងដែរថា ការពិនិត្យមើលឡើងវិញលើកំណត់ត្រាត្រួតពិនិត្យរបស់ IFC ចន្លោះឆ្នាំ ២០១២ ដល់ឆ្នាំ២០១៥ បានបង្ហាញពីភាពមិនស៊ីសង្វាក់គ្នាយ៉ាងខ្លាំង នៅក្នុងរបាយការណ៍ប្រតិបត្តិការ E&S របស់អតិថិជន។ របាយការណ៍លទ្ធផលការងារបរិស្ថានប្រចាំឆ្នាំ (AEPRs) របស់ ABBank ដែលដាក់ជូន IFC ពីឆ្នាំ ២០១២ ដល់ឆ្នាំ២០១៦ បង្ហាញថា មិនមានឥណទាន ឬសកម្មភាពណាមួយ នៅក្នុងផលប័ត្ររបស់ខ្លួនពាក់ព័ន្ធនឹងហានិភ័យ E&S ទេ។ ដូចគ្នានេះដែរ AEPRs បានរាយការណ៍ក្នុងពេលដំណាលគ្នាអំពីការផ្តល់មូលនិធិនៅក្នុងវិស័យមានហានិភ័យខ្ពស់ រួមទាំងគម្រោងវារីអគ្គិសនី ស្ថានីយ៍ថាមពល បណ្តាញបញ្ជូន រោងចក្រស៊ីម៉ង់ត៍ និងចម្ការកៅស៊ូ ជាច្រើន ផងដែរ។ ការពិនិត្យមើលឡើងវិញរបស់ IFC លើ AEPRs ទាំងនេះ មិនបានកំណត់ភាពមិនស៊ីសង្វាក់គ្នាទាំងនេះទេ។ លើសពីនេះ IFC បានចាត់ទុកថា SEMS មានភាពពេញចិត្ត ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ ដែលបង្ហាញថា ខ្លួនបានពិនិត្យមើលឡើងវិញលើឥណទានជាច្រើន ហើយបានបញ្ជាក់ថា ESDD មានលក្ខណៈត្រឹមត្រូវកំពុងត្រូវបានអនុវត្ត។

ក្នុងឆ្នាំ២០១៧ មន្ត្រី E&S ថ្មី របស់ IFC បានធ្វើការពិនិត្យមើលឡើងវិញកាន់តែហ្មត់ចត់បន្ថែមទៀតលើការអនុវត្ត SEMS របស់ ABBank ហើយបានកំណត់ថាប្រព័ន្ធគ្រប់គ្រងខ្វះនីតិវិធី និងសមត្ថភាពផ្ទៃក្នុងគ្រប់គ្រាន់ ដើម្បីដោះស្រាយហានិភ័យ E&S នៃកិច្ចព្រមព្រៀងសាជីវកម្មធំៗ។ មន្ត្រីរូបនេះបានអះអាងជាថ្មីថា SEMS ផ្តោតលើភាពអនុលោម តាមច្បាប់ E&S ជាតិ ហើយថា ការចាត់ថ្នាក់នៃគម្រោងហាក់ដូចជាមិនសមាមាត្រទៅនឹងហានិភ័យ E&S ដែលត្រូវគ្នានោះទេ។ ត្រង់ចំណុចនេះ IFC បានស្នើឱ្យABBank កែលម្អ ដូចចំណុចខាងក្រោម៖

(i) ពិនិត្យមើលឡើងវិញនូវផលប័ត្រឥណទានដែលមានស្រាប់ កំណត់គម្រោងឥណទានដែលមានហានិភ័យ E&S ខ្ពស់ ដូចជាគម្រោងវារីអគ្គិសនី និងចាត់ថ្នាក់គម្រោងឥណទានទាំងនោះឡើងវិញ ថាជាហានិភ័យ E&S ខ្ពស់

(ii) បង្កើត និងអនុវត្តនីតិវិធីត្រួតពិនិត្យហានិភ័យ E&S ដាច់ដោយឡែក សម្រាប់គម្រោងឥណទានសាជីវកម្មធំៗ ដែលតម្រូវឱ្យអនុលោមតាម PS

(iii) បង្កើតសមត្ថភាព E&S ដើម្បីដោះស្រាយការផ្តល់ឥណទានសាជីវកម្មធំៗ ដោយជ្រើសរើសអ្នកជំនាញ E&S ឱ្យបម្រើការងារក្នុងធនាគារ ដែលមានប្រវត្តិសមស្រប និងប្រមូលផ្តុំទីប្រឹក្សា E&S ខាងក្រៅ ដែលគាំទ្រ ESDDs នៃគម្រោងឥណទានសាជីវកម្មធំថ្មីៗ ឬត្រូវបានបន្តឡើងវិញ។

សំណើទាំងនេះត្រូវបានបញ្ចូលទៅក្នុង ESAP សម្រាប់ឥណទាន SME ដែល IFC បានផ្តល់ដល់ ABBank ក្នុងឆ្នាំ២០១៧។ ដោយឈរលើមូលដ្ឋានលក្ខខណ្ឌតម្រូវការទាំងនេះ ABBank បានបន្តធ្វើឱ្យប្រសើរឡើង SEMS របស់ខ្លួន ដោយចេញគោលនយោបាយថ្មី នៅខែធ្នូ ឆ្នាំ២០១៩។ IFC បានចាត់ទុក SEMS ដែលបានកែសម្រួលជាទូទៅស្របតាមលក្ខខណ្ឌតម្រូវ និងសំណើរបស់ខ្លួន លើកលែងតែបទប្បញ្ញត្តិមួយ ដែលផ្អែកលើការជួលទីប្រឹក្សា E&S ខាងក្រៅ ទៅលើកម្រិតចំនួនឥណទាន។

នៅចន្លោះឆ្នាំ២០១៨ ដល់ ២០២៣ IFC បានកត់សម្គាល់យ៉ាងជាប់លាប់ថា ABBank បន្តធ្វើការវាយតម្លៃ E&S ដោយគ្រាន់តែពិចារណាលើច្បាប់ និងបទប្បញ្ញត្តិ E&S ជាតិ ប៉ុណ្ណោះ ហើយដោយមិនគិតពីលក្ខខណ្ឌតម្រូវ PS ដែលពាក់ព័ន្ធនោះទេ។ ក្នុងឆ្នាំ ២០១៩ និងឆ្នាំ ២០២០ IFC បានផ្តល់ការណែនាំមួយចំនួន តាមរយៈកិច្ចប្រជុំ និងការឆ្លងឆ្លើយតាមអ៊ីម៉ែល ទៅកាន់ទីប្រឹក្សា E&S បម្រើការងារនៅ ABBank អំពីការអនុវត្ត PS ចំពោះអនុគម្រោង ។[140] ជំបូន្មាននេះ រួមបញ្ចូលការណែនាំអំពីការអនុវត្តស្តង់ដារសមិទ្ធិកម្មចំពោះការស្នើអនុគម្រោង ដែលមានហានិភ័យខ្ពស់ចំនួនពីរ[141] ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលទីប្រឹក្សាផ្ទៃក្នុងបានចាកចេញនៅឆ្នាំ២០២១ ភាគ

[140] បទសម្ភាសន៍ជាមួយបុគ្គលិក IFC E&S ដែលពាក់ព័ន្ធ។

[141] ក្នុងឆ្នាំ២០១៩ IFC បានជួលអ្នកប្រឹក្សា ESDD ដើម្បីគាំទ្រ និងផ្តល់ប្រឹក្សាដល់ការយល់ដឹងរបស់ ABBank អំពីវិសាលភាព និងយន្តការនៃ ESDD សម្រាប់ការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ។ ទីប្រឹក្សាបានធ្វើការសិក្សាវិភាគគម្លាតសម្រាប់អនុគម្រោងរោងចក្រថាមពលជាក់លាក់មួយ ដែលត្រូវបានចែករំលែកជាមួយធនាគារ ABBank រួមជាមួយ ESAP ដើម្បីដោះស្រាយការខ្វះខាត E&S មួយចំនួន។ អ្នកប្រឹក្សាផ្នែក E&S ខាងក្រៅដែលជួលដោយ IFC មិនអាចចុះទៅពិនិត្យនៅទីតាំងអនុគម្រោងនេះបានទេ។ ABBank បានយល់ព្រមពិនិត្យមើលឡើងវិញនូវលទ្ធផល និង ESAP នៅពេលអនុវត្តអនុគម្រោង ESDD ប៉ុន្តែគិតត្រឹមឆ្នាំ២០២២ អនុគម្រោងនេះនៅតែមិនទាន់សម្រេចនៅឡើយ ដោយសារលក្ខខណ្ឌតម្រូវតាមបទប្បញ្ញត្តិជាតិ ហើយគ្មាន ESDD ត្រូវបានអនុវត្តដើម្បីបន្តណែនាំ ABBank លើការអនុវត្ត PS។

ច្រើននៃកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពនោះ ត្រូវបានបាត់បង់។ ធនាគារ ABBank មិនបានបង្កើតក្រុម E&S ដែលធន់នឹងការផ្លាស់ប្តូរបុគ្គលិក ឬកសាងសមត្ថភាពស្ថាប័ន E&S ឱ្យបានរឹងមាំ ក្នុងរយៈពេល ១០ឆ្នាំ នៃការវិនិយោគនេះទេ។[142] នៅឆ្នាំ២០២០ IFC បានទម្លាក់ចំណាត់ថ្នាក់ E&S របស់ ABBank ទៅជា "មិនពេញចិត្តដោយផ្នែក" ដោយឈរលើមូលដ្ឋានថា ESDD របស់ខ្លួន សម្រាប់គម្រោងដែលមានហានិភ័យខ្ពស់ គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ហើយធនាគារ នៅតែបន្តមិនតម្រូវឱ្យអតិថិជនអនុវត្ត PS ។ IFC ក៏បានផ្តល់អនុសាសន៍ជាបន្តបន្ទាប់អំពីសកម្មភាពកែលម្អការអនុវត្ត SEMS ដោយបានបញ្ជាក់ជាថ្មីនូវសំណើរបស់ខ្លួននៅឆ្នាំ២០២១ ឆ្នាំ២០២២[143] និងឆ្នាំ២០២៣។[144]

បន្ទាប់ពីការចុះត្រួតពិនិត្យចុងក្រោយរបស់ខ្លួន ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ មុនពេលចាកចេញពីការវិនិយោគ ក្នុងខែឧសភា ឆ្នាំ២០២៤ IFC បានកំណត់ថា មិនមានការកែលម្អណាមួយត្រូវបានសង្កេតឃើញ នៅក្នុង SEMS របស់ ABBank និងការអនុវត្តរបស់ធនាគារនេះ ក្នុងអំឡុងពេលត្រួតពិនិត្យគម្រោងនោះទេ។ IFC ក៏បានកត់សម្គាល់ផងដែរថា ចំណុចខ្វះខាតនៅក្នុងការអនុវត្ត PS សម្រាប់ប្រតិបត្តិការដែលមានហានិភ័យ E&S ខ្ពស់ នៅតែបន្ត

---

ស៊ីអេអូ មិនបានរកឃើញភស្តុតាងដែលថា IFC បានតាមដានជាមួយ ABBank ទាក់ទងនឹងអនុគម្រោងនេះ ក្រោយឆ្នាំ២០២២ ទេ។ ស្រដៀងគ្នានេះដែរ នៅក្នុងឆ្នាំ២០២០ IFC បានពិនិត្យមើលឡើងវិញការវាយតម្លៃ E&S នៃប្រភេទអនុគម្រោងវារីអគ្គិសនី ហើយបានកំណត់ថា វាមិនគ្រប់គ្រាន់លើចំណុចមួយចំនួន រួមទាំងថាវាមិនបានធ្វើឡើងទៅតាមស្តង់ដារសមិទ្ធិកម្មរបស់ IFC (និងគោលការណ៍ណែនាំ WBG បរិស្ថាន សុខភាព និងសុវត្ថិភាព -EHS ដែលពាក់ព័ន្ធ) ដែលក្នុងនោះ IFC បានផ្តល់ដំបូន្មានជាក់លាក់អំពីការអនុវត្តស្តង់ដារសមិទ្ធិកម្ម។ IFC បានបន្ទាបចំណាត់ថ្នាក់ E&S របស់ ABBank ជាបន្តបន្ទាប់ ប៉ុន្តែ ស៊ីអេអូ រកមិនឃើញការតាមដានទាក់ទងនឹងអនុគម្រោងនេះ ឬភស្តុតាងនៃការអនុវត្តគ្រប់គ្រាន់នៃ PS ចំពោះអនុគម្រោងវារីអគ្គិសនីនេះ នៅក្នុងឯកសារត្រួតពិនិត្យគម្រោងរបស់ IFC នោះទេ។

[142] ទាំងបុគ្គលិក IFC និង ABBank ដែលបាននិយាយជាមួយ ស៊ីអេអូ បានគូសបញ្ជាក់ពីរបៀបដែលរាល់ពេលមន្ត្រី E&S ចាកចេញពីធនាគារ (មានការផ្លាស់ប្តូរបុគ្គលិកញឹកញាប់ សូមមើលផ្នែក 3.2.2) ធនាគារត្រូវចាប់ផ្តើមការកសាងសមត្ថភាពស្ថាប័ន E&S ឡើងវិញ។ បទសម្ភាសន៍ជាមួយបុគ្គលិក E&S របស់ IFC និងបុគ្គលិក ABBank។

[143] ABBank បានធ្វើបច្ចុប្បន្នភាព ESMS របស់ខ្លួននៅឆ្នាំ២០២២ ប៉ុន្តែ IFC បានចាត់ទុកថាវាមិនរួមបញ្ចូលការកែលម្អចាំបាច់សម្រាប់កម្មវិធី PS ចំពោះគម្រោងនានាដែលមានហានិភ័យខ្ពស់នោះទេ។

[144] នៅឆ្នាំ ២០២០ IFCបានផ្តល់ជាអនុសាសន៍ក្នុងចំណោមសកម្មភាពផ្សេងទៀត ថា ABBank: (i) កែសម្រួលគោលនយោបាយជួលទីប្រឹក្សាខាងក្រៅរបស់ខ្លួនឡើងវិញ ដើម្បីធានាថាអ្នកជំនាញខាងក្រៅដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានចូលរួមនៅក្នុង ESDD សម្រាប់ប្រតិបត្តិការដែលមានហានិភ័យ E&S កាន់តែខ្ពស់ (ii) បង្កើតបទប្បញ្ញត្តិ/យ E&S គំរូ ដើម្បីតម្រូវឱ្យអ្នកខ្ចីអនុលោមតាមស្តង់ដារ E&S របស់ ABBank រួមទាំងស្តង់ដារសមិទ្ធិកម្ម និងអនុវត្តផែនការសកម្មភាពកែតម្រូវ E&S (iii) វិសោធនកម្មនីតិវិធីចាត់ថ្នាក់ និង (iv) រួមបញ្ចូលការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពកែតម្រូវ E&S នៅក្នុងកម្មវិធីត្រួតពិនិត្យផលប័ត្ររបស់ធនាគារ ABBank ។ នៅឆ្នាំ២០២១ IFC បានផ្តល់អនុសាសន៍ថា ABBank៖ (i) បំពេញផែនការសកម្មភាព E&S ដែលបានបង្ហាញពីមុន (ii) ប្រគល់ភស្តុតាងនៃការអនុវត្ត ESMS គ្រប់គ្រាន់ ចំពោះប្រតិបត្តិការនានាដែលមានលទ្ធភាពបង្កហានិភ័យ E&S ខ្ពស់ (iii) ផ្តល់ព័ត៌មានថ្មីៗតាមកាលកំណត់លើដំណើរការ ESDD របស់ ABBank ទាក់ទងនឹងគម្រោងដែលមានហានិភ័យខ្ពស់ជាក់លាក់ និង (iv) ជួលទីប្រឹក្សា E&S បម្រើការងារក្នុងស្ថាប័ន ដើម្បីកសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់ តាមរយៈការបណ្តុះបណ្តាល និងបទពិសោធន៍គម្រោង។

កើតមានដដែល។

ទោះបីជាមានការកើនឡើងគួរឱ្យកត់សម្គាល់នូវគុណភាពនៃការត្រួតពិនិត្យរបស់ IFC ទៅលើ ABBank ក្រោយឆ្នាំ២០១៧ ក៏ដោយ ក៏គម្រោងសេសានក្រោម២ មិនត្រូវបានគេកំណត់នៅចំណុចណាមួយ ក្នុងឯកសារត្រួតពិនិត្យ E&S ថាជាអនុគម្រោង ដែល ABBank គួរធានាឱ្យបាននូវភាពអនុលោមតាម PS ទេ។ ការលើកឡើងដំបូងនៃ LS2 នៅក្នុងឯកសារ IFC ក្នុងឆ្នាំ ២០១៧ គឺមិនមែនដោយសារតែការផ្សារភ្ជាប់របស់វាទៅនឹង IFC តាមរយៈ EVNI និង ABBank នោះទេ ប៉ុន្តែដោយសារតែហានិភ័យកេរ្តិ៍ឈ្មោះដែលអាចនឹងកើតមានចំពោះ EVN ដែលជាអតិថិជនសំខាន់មួយរបស់ ABBank និងធនាគារវៀតណាមផ្សេងទៀតប៉ុណ្ណោះ។[145]ក្រោយមកទៀត អនុគម្រោងនេះ ត្រូវបានលើកឡើងនៅក្នុងកំណត់ត្រាត្រួតពិនិត្យរបស់ IFC គឺបន្ទាប់ពី ស៊ីអេអូ បានដាក់ពាក្យបណ្ដឹង ក្នុងឆ្នាំ ២០១៨ នៅពេលដែល LS2 ត្រូវបានគេកំណត់ថាជាប្រភពនៃហានិភ័យកេរ្តិ៍ឈ្មោះចំពោះ ABBank ។ ទោះជាយ៉ាងណាក៏ដោយ មិនមានការស្នើឱ្យធ្វើការត្រួតពិនិត្យតាមដានអតិថិជននោះទេ ដោយឈរលើអង្គហេតុដែលថា ការវិនិយោគភាគហ៊ុន របស់ ABBank នៅក្នុង EVNI បានកើតឡើងមុនការចូលរួមរបស់ IFC ដូច្នេះហើយត្រូវបានគេសន្មតថាមិនស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវ E&S របស់ខ្លួនទេ។ មិនមានភស្តុតាងដែលថា IFC បានពិនិត្យមើលការប្តេជ្ញាចិត្តនានា នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងផែនការ SEMS មុននឹងប្រានចោលការផ្សារភ្ជាប់ទំនាក់ទំនងរវាង ABBank, EVNI, LS2 និងការអនុវត្តលក្ខខណ្ឌតម្រូវ E&S ចំពោះអនុគម្រោងនេះ ទេ។

ជាទូទៅ ការត្រួតពិនិត្យរបស់ IFC ទៅលើ ABBank មិនបានត្រួតពិនិត្យការប្តេជ្ញាចិត្តនៅក្នុងផែនការ SEMS ទាំងអស់នោះទេ ប៉ុន្តែផ្ទុយទៅវិញបានផ្តោតលើសកម្មភាពពីរ៖ ការជួលមន្ត្រី E&S ឬទីប្រឹក្សាខាងក្រៅ និងការអនុវត្ត SEMS ។ ខណៈពេលដែលសកម្មភាពទាំងនេះគឺជាទិដ្ឋភាពសំខាន់សម្រាប់ការត្រួតពិនិត្យ E&S នៃអន្តរការីហិរញ្ញវត្ថុ ពួកវាមិនមែនជាការប្តេជ្ញាចិត្តតែមួយគត់នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់នោះទេ។ ស៊ីអេអូ សង្កេតឃើញថា មិនត្រឹមតែ IFC មិនតម្រូវឱ្យមានការអនុវត្តគោលនយោបាយ SEMS លើឥណទាន និងការវិនិយោគដែលមានស្រាប់នោះទេ ប៉ុន្តែថែមទាំងមិនមានភស្តុតាងដែល IFC ទាមទារ ឬតាមដានត្រួតពិនិត្យ ថាតើ ABBank បានបំពេញតាមការប្តេជ្ញាចិត្តផែនការ SEMS ផ្សេងទៀត រួមទាំងការបង្កើតផែនការអនុវត្ត SEMS នីតិវិធី និងសេចក្តីណែនាំអំពីការអនុវត្ត  បន្តធ្វើការបណ្តុះបណ្តាលបុគ្គលិក E&S និងការពិនិត្យហានិភ័យកេរ្តិ៍ឈ្មោះ ប្រចាំត្រីមាស និងធ្វើការត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំលើការអនុវត្ត SEMS ដែលភ្ជាប់ទៅនឹង AEPRs ដែរឬទេ។

ចំពោះការចាកចេញពីការវិនិយោគ ក្នុងខែឧសភា ឆ្នាំ២០២៤ IFC បានពិនិត្យមើលឡើងវិញនូវគោលការណ៍ចាក

[145]របាយការណ៍ត្រួតពិនិត្យរបស់ IFC ដកស្រង់របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលដែលលើកឡើងថា "ទំនប់ LS2 ដ៏ចម្រូងចម្រាសនៅក្នុងប្រទេសកម្ពុជា ត្រូវបានគេរំពឹងថានឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្តុកត្រីទន្លេមេគង្គ និងបំផ្លាញសន្តិសុខស្បៀងសម្រាប់ប្រជាជនរាប់សែននាក់" ។

ចេញប្រកបដោយការទទួលខុសត្រូវរបស់ខ្លួន ហើយបានកំណត់ថា ការចាកចេញនេះនឹងមិនមានឥទ្ធិពលអាក្រក់ទៅលើការគ្រប់គ្រងបញ្ហា E&S របស់ ABBank នោះទេ។ ពាក់ព័ន្ធនឹងសំណុំរឿង ស៊ីអេអូ ដែលកំពុងបន្តនេះ IFC ដូចបានបញ្ជាក់ខាងលើ បានចាត់ទុកថា EVNI និងការវិនិយោគរបស់ក្រុមហ៊ុននេះនៅក្នុង LS2 មិនស្ថិតនៅក្រោមកម្មវត្ថុនៃលក្ខខណ្ឌតម្រូវ E&S របស់ IFC ទេ ពីព្រោះការវិនិយោគបានកើតឡើង នៅមុនពេលការចូលរួមរបស់ IFC ជាមួយ ABBank ។ IFC បានសន្និដ្ឋានថា ការចាកចេញនេះនឹងមិនមានឥទ្ធិពលអាក្រក់ណាមួយលើសំណុំរឿង ស៊ីអេអូ ដោយមិនបានគិតគូរពីកាតព្វកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យការប្តេជ្ញាចិត្តផ្លូវច្បាប់របស់ ABBank ដើម្បីធានាភាពអនុលោម នៃការវិនិយោគដែលមានស្រាប់ តាមស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦។ ទោះជាយ៉ាងណាក៏ដោយ ដោយសំអាងលើកាតព្វកិច្ចរបស់ ABBank នៅក្នុងផែនការ SEMS, IFC គួរតែបានគិតគូរពីផលប៉ះពាល់នៃការចាកចេញរបស់ខ្លួនលើបញ្ហា E&S ដែលមិនទាន់ដោះស្រាយ ទាក់ទងនឹងអនុគម្រោងសេសានក្រោម២ ដែលជាការវិនិយោគមួយ ក្នុងចំណោមការវិនិយោគ "ដែលមានស្រាប់" ដែលគួរតែត្រូវបានតម្រូវឱ្យមានការអនុវត្តគោលនយោបាយ SEMS ។ មិនមានភស្តុតាងណាមួយដែលថា IFC បានពិចារណាឡើងវិញនូវជំហរនេះទេ ខណៈពេលដែលសំណុំរឿង ស៊ីអេអូ បានបន្តដំណើរការ ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដោយគូសបញ្ជាក់ពីកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ និងផែនការ SEMS ។

### 3.2.3 ការវិភាគភាពអនុលោមនៃការត្រួតពិនិត្យរបស់ IFC និងគំហើញរបស់ ស៊ីអេអូ

**ស៊ីអេអូ រកឃើញថា IFC មិនបានតាមដានត្រួតពិនិត្យការប្តេជ្ញាចិត្ត E&S ដែលមាននៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ IFC ជាមួយ ABBank ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព របស់ IFC (SP ឆ្នាំ២០០៦, កថាខណ្ឌ 26; SP ឆ្នាំ២០១២, កថាខណ្ឌ ២៤) នោះទេ។ ជាពិសេសពាក់ព័ន្ធនឹងសំណុំរឿងនេះ IFC មិនបានត្រួតពិនិត្យការប្តេជ្ញាចិត្តរបស់ ABBank ដើម្បីធានាថា ការវិនិយោគដែលមានស្រាប់របស់ខ្លួនអនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC ។ ជាលទ្ធផល IFC មិនតម្រូវឱ្យ ABBank អនុវត្តស្តង់ដារសមិទ្ធិកម្ម IFC ឆ្នាំ២០០៦ ចំពោះការវិនិយោគដែលមានស្រាប់របស់ខ្លួន នៅក្នុង EVNI និងអនុគម្រោងសេសានក្រោម២ ដោយបំពានលើការប្តេជ្ញាចិត្តគោលនយោបាយនិរន្តរភាពរបស់ខ្លួន។**

ក្នុងរយៈពេលពេល ១៤ ឆ្នាំនៃការពិនិត្យគ្រប់គ្រង IFC ក៏មិនបានត្រួតពិនិត្យការអនុវត្តរបស់ ABBank ទាក់ទងនឹង SEMS និងការប្តេជ្ញាចិត្តផ្សេងទៀត នៅក្នុងផែនការ SEMS ដែលបានព្រមព្រៀងជាមួយអតិថិជន ក្នុងឆ្នាំ២០១០។ ព្រឹត្តិការណ៍សំខាន់ៗទាក់ទងនឹងការបង្កើតប្រព័ន្ធគ្រប់គ្រង E&S ប្រកបដោយប្រសិទ្ធភាព ក៏ត្រូវបានអនុញ្ញាតឱ្យពន្យារពេល ក្នុងអំឡុងឆ្នាំ២០១១ ជាឆ្នាំដែល IFC មិនធ្វើសកម្មភាពត្រួតពិនិត្យណាមួយ ដែល ផ្ទុយពីកថាខណ្ឌ២៦ នៃគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦។ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ ABBank បានបន្តវិនិយោគលើវិស័យដែលមានហានិភ័យខ្ពស់ ប៉ុន្តែការត្រួតពិនិត្យរបស់ IFC មិនបានពិនិត្យមើលឡើងវិញលើដំណើរការ និងលទ្ធផលនៃការត្រួតពិនិត្យ E&S របស់ FI សម្រាប់ការវិនិយោគរបស់ខ្លួន យ៉ាងមានប្រសិទ្ធភាពនោះទេ ហើយក៏មិនបានពិនិត្យមើលឡើងវិញលើគំរូនៃសកម្មភាពអាជីវកម្មរបស់ធនាគារ ABBank ដែលមានហា

និភ័យ E&S ខ្លាំង ដូចបានតម្រូវនៅក្នុងកថាខណ្ឌ ៤៥ នៃគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ ។[146] ជាលទ្ធផល IFC បានបរាជ័យក្នុងការកំណត់គម្រោងនានាដែលមានហានិភ័យខ្ពស់ នៅក្នុងផលប័ត្ររបស់អតិថិជនរបស់ខ្លួន ហើយការត្រួតពិនិត្យរបស់ IFC មិនសមាមាត្រទៅនឹងហានិភ័យនៃការវិនិយោគរបស់ខ្លួន ដែលផ្ទុយទៅនឹងគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌ ៤៥)។ ភាពខ្វះខាតក្នុងការត្រួតពិនិត្យរបស់ IFC បានរួមចំណែកដល់អសមត្ថភាពរបស់អតិថិជនខ្លួន ក្នុងការបង្កើត ESMS ដែលអាចធានាភាពអនុលោមតាមស្តង់ដារសមិទ្ធិកម្ម សម្រាប់គម្រោងដែលមានហានិភ័យខ្ពស់ ស្របតាមលក្ខខណ្ឌតម្រូវគោលនយោបាយនិរន្តរភាព និងចុងក្រោយចូលរួមចំណែកដល់ការអនុវត្ត E&S មិនបានល្អ របស់អតិថិជនខ្លួន នៅទូទាំងការវិនិយោគនេះ។[147]

ជាពិសេស ស៊ីអេអូ លើកឡើងពីចំណុចខ្វះខាតដូចខាងក្រោមនៅក្នុងការត្រួតពិនិត្យរបស់ IFC ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៦៖

- ដោយមិនបានបង្កើតលក្ខខណ្ឌតម្រូវ E&S គន្លឹះៗ ដូចជា គោលនយោបាយ SEMS និងនីតិវិធីអនុវត្ត ជាលក្ខខណ្ឌនៃការប្តេជ្ញាចិត្ត ឬការទូទាត់ចំណាយ នោះ IFC បានបរាជ័យក្នុងការរៀបចំរចនាសម្ព័ន្ធ នៃការវិនិយោគ នៅក្នុងលក្ខណៈមួយ ដែលនឹងផ្តល់ឱ្យខ្លួនឯងនូវអានុភាពគ្រប់គ្រាន់ដើម្បីធានាថា អតិថិជនបានអនុវត្តលក្ខខណ្ឌតម្រូវ E&S ដូចបានព្រមព្រៀងគ្នា។[148]បន្ថែមពីនេះ IFC មិនបានប្រើមធ្យោបាយជំនួសណាមួយនៃឥទ្ធិពល ឬមានឥទ្ធិពលលើអតិថិជន ដូចជា កិច្ចប្រជុំម្ចាស់ភាគហ៊ុន ឬសិទ្ធិរបស់ខ្លួនក្នុង

---

[146] យោងតាមគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ (កថាខណ្ឌ ៤៥) "IFC អនុវត្តសកម្មភាពខាងក្រោមដើម្បីត្រួតពិនិត្យតាមដានការវិនិយោគរបស់ខ្លួន និងសកម្មភាពទីប្រឹក្សា ដែលជាផ្នែកមួយនៃកម្មវិធីត្រួតពិនិត្យផលប័ត្ររបស់ខ្លួន៖ [...] *ការវិនិយោគតាមរយៈអន្តរការីហិរញ្ញវត្ថុ*—អនុវត្តកម្មវិធីត្រួតពិនិត្យជាទៀងទាត់ទៅលើការវិនិយោគរបស់ FI ដែលមានហានិភ័យ និង/ឬផលប៉ះពាល់បរិស្ថាន និងសង្គម ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃនីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គមរបស់ IFC ។ ដើម្បីកំណត់ប្រសិទ្ធភាពនៃ ESMS របស់ FI, IFC នឹងពិនិត្យមើលតាមកាលកំណត់នូវដំណើរការ និងលទ្ធផលនៃការពិនិត្យបរិស្ថាន និងសង្គម ដែលធ្វើឡើងដោយ FI សម្រាប់ការវិនិយោគរបស់ខ្លួន។ លើសពីនេះ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យរបស់ខ្លួន IFC ពិនិត្យមើលឡើងវិញតាមកាលកំណត់នូវគំរូនៃការវិនិយោគ FI ផ្សេងទៀត ជាពិសេសសម្រាប់សកម្មភាពអាជីវកម្មដែលមានហានិភ័យបរិស្ថាន និងសង្គមធ្ងន់ធ្ងរ។ ការត្រួតពិនិត្យរបស់ IFC អាចរួមបញ្ចូលការចុះពិនិត្យនៅកម្រិត FI ក៏ដូចជាការចុះទៅជួបអ្នកទទួលឥណទាន/ការវិនិយោគរបស់ FI ជាពិសេសអនុគម្រោងដែលមានហានិភ័យខ្ពស់។ ភាពញឹកញាប់ និងការផ្តោតការយកចិត្តទុកដាក់នៃការចុះត្រួតពិនិត្យ គឺមានលក្ខណៈសមស្របទៅនឹងហានិភ័យដែលបានកំណត់អត្តសញ្ញាណ។ IFC ធ្វើការជាមួយអតិថិជន FI របស់ខ្លួន ដើម្បីជួយពួកគេដោះស្រាយចំណុចខ្វះខាតណាមួយនៅក្នុង ESMS របស់ពួកគេ។ សូមមើលផងដែរ IFC ESRP ២០១៤–១៦, ផ្នែក 2.5; IFC ESRP ២០២២–២៣, ផ្នែក 4.21 ។

[147] នៅឆ្នាំ ២០២០ IFC បានសម្រេចចិត្តទម្លាក់ចំណាត់ថ្នាក់ E&S របស់ ABBank ទៅជា "មិនពេញចិត្តដោយផ្នែក" ដោយសារតែ ESDD របស់ធនាគារមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ទាក់ទងនឹងគម្រោងដែលមានហានិភ័យខ្ពស់ ដោយសារការវាយតម្លៃ E&S របស់ខ្លួនបានពិចារណាតែច្បាប់ និងបទប្បញ្ញត្តិជាតិ E&S ហើយមិនពិចារណាលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធិកម្ម (សូមមើលផ្នែក 3.2.2 )។

[148] គម្រោងទាំងពីរមានការបើកផ្តល់ឥណទានតែមួយ ដោយគ្មានលក្ខខណ្ឌតម្រូវ E&S ណាមួយនៅក្នុងផែនការ SEMS និង ESAP រៀងគ្នា ដែលត្រូវបានដាក់ជាលក្ខខណ្ឌក្នុងការទូទាត់ចំណាយ។

ការតែងតាំងនាយកក្រុមប្រឹក្សាភិបាល ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកង្វះខាត E&S របស់ ABBank[149] ។ ការបរាជ័យទាំងនេះបានធ្វើឱ្យចុះខ្សោយសមត្ថភាពរបស់ IFC ក្នុងការនាំអតិថិជនឱ្យមកអនុលោមឡើងវិញ នៅក្នុងអំឡុងពេលត្រួតពិនិត្យ។ ក្នុងឆ្នាំ២០១៧ IFC បានប្រើប្រាស់យ៉ាងសមស្របនូវឥណទាន SME ថ្មី ជាអានុភាពដើម្បីតម្រូវឱ្យអតិថិជនប្តេជ្ញាចិត្តចំពោះ ESAP ដែលភាគច្រើនឆ្លើយតបទៅនឹងសកម្មភាពដែលខ្លួនបានទាមទារពីធនាគារ ABBank ក្នុងការត្រួតពិនិត្យលើការវិនិយោគភាគហ៊ុនក្នុងឆ្នាំ២០១០ របស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ជាថ្មីម្តងទៀត IFC បានបរាជ័យក្នុងការរៀបចំរចនាសម្ព័ន្ធ នៃការវិនិយោគនោះ ដើម្បីធានាថាខ្លួនមានអានុភាពគ្រប់គ្រាន់ បន្ទាប់ពីកិច្ចសន្យាត្រូវបានចុះហត្ថលេខា ហើយចំនួនឥណទានពេញលេញ ត្រូវបានបញ្ចេញ ដោយមិនបានកំណត់លក្ខខណ្ឌតម្រូវណាមួយនៃ E&S ទៅនឹងការប្តេជ្ញាចិត្ត ឬព្រឹត្តិការណ៍សំខាន់ៗនៃការទូទាត់ចំណាយ។[150] ដូចបានពន្យល់ខាងក្រោម បន្ទាប់ពីឆ្នាំ២០១៧ ការសម្រេចបាននូវការប្តេជ្ញាចិត្តនៅក្នុងផែនការ SEMS របស់ធនាគារ ABBank បានបន្តធ្លាក់ចុះ។

- ចាប់ពីខែធ្នូ ឆ្នាំ២០១០ រហូតដល់យ៉ាងហោចខែកុម្ភៈ ឆ្នាំ២០១២ ធនាគារ ABBank មិនបានបង្កើតប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន នោះទេ បើទោះបីជាការវិនិយោគលើគម្រោងមានហានិភ័យ E&S ខ្ពស់ក៏ដោយ។ ដូច្នេះ សម្រាប់រយៈពេល ១៤ ខែដំបូង នៃការវិនិយោគរបស់ IFC មិនត្រឹមតែអតិថិជនមិនមានគោលការណ៍ ឬនីតិវិធីក្នុងការវាយតម្លៃ និងគ្រប់គ្រងហានិភ័យ E&S ប៉ុណ្ណោះទេ ប៉ុន្តែ IFC ថែមទាំងមិនមានមូលដ្ឋានលើការត្រួតពិនិត្យការអនុវត្ត E&S របស់ខ្លួន ទៀតផង។[151]
- ការត្រួតពិនិត្យរបស់ IFC លើការវិនិយោគរបស់ ABBank ភាគច្រើនត្រូវបានកម្រិតទៅលើឥណទានរបស់ខ្លួន។ IFC បានបរាជ័យក្នុងការត្រួតពិនិត្យសកម្មភាពអាជីវកម្មរបស់អតិថិជនផ្សេងទៀត រួមទាំងការវិនិយោគភាគហ៊ុន នៅក្នុងក្រុមហ៊ុននានា ដូចជា EVNI ជាដើម។ គំរូរបស់ IFC សម្រាប់ AEPRs របស់អតិថិជន មិនបានដាក់បញ្ចូលសំណួរទាក់ទងនឹងការវិនិយោគភាគហ៊ុន ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ទេ ដោយលុបចោលធាតុផ្សេងៗនៃផលប័ត្ររបស់ FI ដែលអាចប្រឈមនឹងហានិភ័យ E&S ។ ជាលទ្ធផលនៃអភិក្រមមិនពេញលេញនេះ IFC មិនបានទទួលសេចក្តីរំលឹកដាស់តឿនអំពីហានិភ័យ E&S ដែលទាក់ទងនឹងការចូលរួមរបស់ ABBank ជាមួយ EVNI និងទំនប់វារីអគ្គិសនីសេសានក្រោម២ នោះទេ។

---

[149] ស៊ីអេអូ រកមិនឃើញភស្តុតាងនៅក្នុងឯកសារគម្រោងដែល IFC បានស្នើរ ឬលើកបញ្ហាបែបនេះសម្រាប់កិច្ចប្រជុំម្ចាស់ភាគហ៊ុន ឬជាផ្នែកអាទិភាព នៅពេលតែងតាំងនាយករបស់ខ្លួន។

[150] កិច្ចព្រមព្រៀងផ្លូវច្បាប់សម្រាប់ឥណទានសហគ្រាសធុនតូច និងមធ្យម (គម្រោង #៤០០៨១) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៧ ហើយឥណទាននេះត្រូវបានផ្តល់ជូន នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧។ គ្មានសកម្មភាពណាមួយនៅក្នុង ESAP សម្រាប់ឥណទាននេះ គឺជាលក្ខខណ្ឌក្នុងការទូទាត់ចំណាយ
ឬការប្តេជ្ញាចិត្តនោះទេ។

[151] គោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ របស់ IFC កំណត់ថា "IFC នឹងត្រួតពិនិត្យតាមដានការអនុវត្តរបស់ FI ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រង [សង្គម និងបរិស្ថាន] ។ គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ២៩។

- IFC មិនបានពិនិត្យមើលឡើងវិញឱ្យបានហ្មត់ចត់នូវព័ត៌មានដែល ABBank បានដាក់ជូន ក្នុងអំឡុងឆ្នាំដំបូងៗទាំងនេះទេ ដូច្នេះមិនបានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់លើការអនុវត្ត E&S និងកម្មវិធី PS របស់អតិថិជន ចំពោះអនុគម្រោងរបស់ខ្លួនឡើយ។ ឧទាហរណ៍៖
    - ក្នុងឆ្នាំ ២០១៣ ធនាគារ ABBank បានបង្ហាញថា គ្មានគម្រោងណាមួយដែលខ្លួនផ្តល់មូលនិធិពាក់ព័ន្ធនឹងហានិភ័យ E&S ទេ ខណៈស្របពេលជាមួយគ្នានេះ បានរបាយការណ៍អំពីការផ្តល់ឥណទានដល់គម្រោងវារីអគ្គិសនីចំនួន ៤ ដែលមានកម្លាំង ១៩០ MW, ៣២ MW, ១៥,៦ MW និង ១៤ MW រៀងគ្នា។ដូចដែលបានពិពណ៌នានៅផ្នែកសាវតារ គម្រោងវារីអគ្គិសនី ជាទូទៅមានការពាក់ព័ន្ធនឹងហានិភ័យ E&S ដែលក្នុងនោះគម្រោងមួយចំនួន ត្រូវបានចាត់ថ្នាក់ប្រភេទ A (មានហានិភ័យខ្ពស់) ថែមទៀតផង។ ទោះជាបែបនេះក្តី IFC មិនបានធ្វើអត្ថាធិប្បាយលើភាពមិនស៊ីសង្វាក់គ្នា និងការបរាជ័យក្នុងការអនុវត្ត PS នោះទេ ហើយក៏មិនបានកំណត់ឱកាសនេះក្នុងការតម្រឹមប្រភេទគម្រោងរបស់ ABBank ជាមួយនឹងស្តង់ដារ IFC ដែរ។
    - នៅក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ ការត្រួតពិនិត្យរបស់ IFC លើរបាយការណ៍ប្រតិបត្តិការប្រចាំឆ្នាំរបស់ ABBank បានបញ្ជាក់ថា ផលប័ត្ររបស់ FI ប្រឈមនឹងហានិភ័យ E&S ពីកម្រិតមធ្យម ទៅខ្ពស់។ ប៉ុន្តែ IFC មិនបានចោទសួរចំពោះការបន្តអះអាងរបស់ ABBank ដែលថាគ្មានគម្រោងណាមួយរបស់ខ្លួនពាក់ព័ន្ធនឹងហានិភ័យ E&S នោះទេ។ ក្នុងអំឡុងពេលដូចគ្នានេះ IFC បានកត់សម្គាល់ថា ABBank គឺគ្រាន់តែតម្រូវឱ្យអនុលោមតាមលក្ខខណ្ឌតម្រូវ E&S ជាតិ និងប្រើប្រាស់ស្តង់ដារសមិទ្ធិកម្ម ជាអនុសាសន៍ដែលមិនអាចអនុវត្តបាន។ មិនមានភស្តុតាងដែលថា IFC បានលើកបញ្ហានេះ នៅពេលនោះ ថាជាបញ្ហាដែលត្រូវកែតម្រូវនោះទេ។ គំរូនៃការរាយការណ៍ខុសគ្នា និងមិនអនុលោម គឺជាបញ្ហារ៉ាំរ៉ៃមួយជាមួយនឹងការអនុវត្ត SEMS របស់ ABBank និងជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនទៀត ដែល IFC បានបន្ទាបចំណាត់ថ្នាក់ការអនុវត្ត E&S របស់ខ្លួនទៅជា "មិនពេញចិត្តដោយផ្នែក" ក្នុងឆ្នាំ២០២០។

ក្នុងអំឡុងនៃការវិនិយោគនៅឆ្នាំបន្តបន្ទាប់ (២០១៧-២០២២) ការត្រួតពិនិត្យរបស់ IFC មានភាពប្រសើរឡើង។ នៅឆ្នាំ២០១៧ ជាឆ្នាំដែល IFC បានយល់ព្រម និងបញ្ចេញឥណទានរហូតដល់ ១១០ លានដុល្លារអាមេរិក ដើម្បីបង្កើនផលប័ត្រឥណទានខ្នាតតូច និងមធ្យមរបស់ធនាគារ ABBank។ បុគ្គលិក E&S របស់ IFC បានធ្វើការពិនិត្យមើលឡើងវិញកាន់តែហ្មត់ចត់បន្ថែមទៀតទៅលើផលប័ត្ររបស់អតិថិជន និងការអនុវត្ត SEMS ។ ដូចបានរៀបរាប់ខាងលើ ការពិនិត្យមើលឡើងវិញនេះ គឺជាលើកទីមួយហើយ ដែល IFC កំណត់ថា ផលប័ត្ររបស់ធនាគារ ABBank រួមមានការផ្តល់ឥណទានដល់គម្រោងវារីអគ្គិសនីធំៗ រោងចក្រថាមពល និងកម្មវិធីផ្តល់សំណង និងការតាំងទីលំនៅថ្មី។ IFC ទាញចំណាប់អារម្មណ៍អតិថិជនរបស់ខ្លួន មកលើបញ្ហាធ្ងន់ធ្ងរមួយចំនួន ដូចខាងក្រោម៖

- កង្វះការអនុវត្តស្តង់ដារសមិទ្ធិកម្ម ចំពោះគម្រោងដែលមានហានិភ័យខ្ពស់។

- ការចាត់ថ្នាក់គម្រោងមិនត្រឹមត្រូវ និងលក្ខខណ្ឌតម្រូវ E&S មិនមានលក្ខណៈគ្រប់គ្រាន់ជាបន្តបន្ទាប់ ដែលនាំឱ្យមានផលប៉ះពាល់ និងហានិភ័យសំខាន់ៗ ដែលមិនបានកំណត់ និងមិនបានដោះស្រាយ
- អវត្តមានលក្ខខណ្ឌ និងបទប្បញ្ញត្តិសមស្របតាមផ្លូវច្បាប់ នៅក្នុងកិច្ចសន្យាឥណទាន
- កង្វះដំណើរការតាមដានត្រួតពិនិត្យ E&S ឱ្យគ្រប់គ្រាន់ ដោយ ABBank និងការផ្លាស់ប្តូរបុគ្គលិក E&S ញឹកញាប់ ។

ស៊ីអេអូ កត់សម្គាល់ថា ក្នុងអំឡុងពេលនេះ IFC បានខិតខំប្រឹងប្រែងជាប់លាប់ ដើម្បីនាំអតិថិជនឱ្យត្រលប់មករកភាពអនុលោមវិញ។ ទោះជាយ៉ាងនេះក្តី ការខិតខំប្រឹងប្រែងរបស់ IFC ភាគច្រើនរួមមានការលើកទឹកចិត្តអតិថិជនឱ្យអនុលោម។ IFC មិនបានប្រើប្រាស់អានុភាពរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ដើម្បីធានាភាពអនុលោម របស់ ABBank ស្របតាមកាតព្វកិច្ច E&S របស់ខ្លួន ដោយសារមូលនិធិទាំងអស់ត្រូវបានបញ្ចេញ នៅពេលដែលលក្ខខណ្ឌតម្រូវ E&S មួយប៉ុណ្ណោះក្នុងចំណោមលក្ខខណ្ឌតម្រូវ E&S ចំនួន ១០ នៅក្នុងផែនការ SEMS ត្រូវបានបំពេញ ហើយក៏មិនមានការប្រើប្រាស់ឧបករណ៍ ឬវិធីសាស្រ្តផ្សេងទៀតនៃឥទ្ធិពលទៅលើអតិថិជន ដូចជាកិច្ចប្រជុំម្ចាស់ភាគហ៊ុន ឬការតែងតាំងនាយកក្រុមប្រឹក្សាភិបាល ដើម្បីលើកកម្ពស់ការយល់ដឹងទាក់ទងនឹងកង្វះខាតភាពអនុលោមរបស់ធនាគារ ABBank ទៅតាមការប្តេជ្ញាចិត្ត E&S ។ លើសពីនេះ ខណៈពេលដែលការត្រួតពិនិត្យ មានភាពប្រសើរឡើង ក្រោយឆ្នាំ២០១៧ IFC បានបន្តអនុវត្តជ្រើសរើសយកការតាមដានត្រួតពិនិត្យការប្តេជ្ញាចិត្តអនុវត្តផែនការ SEMS ។ ដូចបានរៀបរាប់ខាងលើ IFC ផ្តោតការត្រួតពិនិត្យរបស់ខ្លួនតែលើការជួលបុគ្គលិក E&S និងការអនុវត្ត SEMS ប៉ុណ្ណោះ។ IFC មិនតម្រូវឱ្យធនាគារ ABBank អនុលោមតាមការប្តេជ្ញាចិត្តដែលមានពេលវេលាកំណត់ទាំងអស់ នៅក្នុងផែនការ SEMS ដូចត្រូវបានតម្រូវនៅក្នុងគោលនយោបាយនិរន្តរភាព និង ESRP នោះទេ។[152] ជាលទ្ធផល គ្មានចំណុចណាមួយក្នុងអំឡុងពេលពិនិត្យរបស់ IFC បានបំពេញកាតព្វកិច្ច

[152] ដូចបានកត់សម្គាល់ពីខាងដើម ទាំងគោលនយោបាយនិរន្តរភាពឆ្នាំ២០០៦ និងឆ្នាំ២០១២ តម្រូវឱ្យ IFC ត្រួតពិនិត្យតាមដានការអនុវត្ត E&S របស់អតិថិជនដោយផ្អែកលើកិច្ចព្រមព្រៀងរបស់អតិថិជននៅក្នុងផែនការសកម្មភាព ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ជាមួយ IFC បើតាមគោលការណ៍និរន្តរភាព ឆ្នាំ២០០៦ កថាខណ្ឌ ២៦ និងគោលនយោបាយនិរន្តរភាព ឆ្នាំ២០១២ កថាខណ្ឌ ២៤។ ក្នុងការបង្កើតកាតព្វកិច្ចនេះ ESRP សមស្រប នៅក្នុងអំឡុងពេលនៃការវិនិយោគនេះ បានណែនាំមន្ត្រី E&S របស់ IFC ឱ្យត្រួតពិនិត្យការវិនិយោគ FI ធៀបទៅនឹងផែនការ SEMS អតិថិជន និងការប្តេជ្ញាចិត្តផ្លូវច្បាប់។ ESRP របស់ IFC ខែសីហា ឆ្នាំ២០០៩ បង្ហាញថា មន្ត្រី E&S ត្រួតពិនិត្យតាមដានលើមូលដ្ឋាននៃ "ការអនុវត្តរបស់អតិថិជន ធៀបទៅនឹងលក្ខខណ្ឌតម្រូវការអនុវត្តសមស្រប [ដែលចែងដោយ "កតិកាសញ្ញាកិច្ចសន្យាវិនិយោគ"] ដូចបានកំណត់ក្នុងអំឡុងពេលពិនិត្យមើលឡើងវិញ និងវាយតម្លៃគម្រោង និងការអនុវត្តប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថានរបស់អតិថិជន (SEMS) យោងតាម ESRP របស់ IFC ឆ្នាំ២០០៩ ផ្នែក 9.2.6 ។ បន្ថែមពីលើបទប្បញ្ញត្តិស្រដៀងគ្នាទៅនឹង ESRP របស់

ដែលតម្រូវឱ្យធនាគារ ABBank អនុវត្តគោលនយោបាយ SEMS ចំពោះ "ឥណទាន និងការវិនិយោគដែលមានស្រាប់" រួមទាំងនៅក្នុង EVNI ដែលបានលេចចេញជាបញ្ហាទាមទារឱ្យ IFC យកចិត្តទុកដាក់ នោះទេ។

ស៊ីអេអូ ក៏បានកត់សម្គាល់ផងដែរថា IFC មិនបានបន្ទាបចំណាត់ថ្នាក់ការអនុវត្ត E&S របស់ ABBank រហូតដល់ឆ្នាំ២០២០ ប្រាំបួនឆ្នាំបន្ទាប់ពីបានដឹងជាលើកដំបូងអំពីចំណុចខ្វះខាតសំខាន់ៗរបស់អតិថិជនខ្លួន ទាក់ទងនឹងការអនុវត្ត SEMS ។ ទោះបីជា IFC បានត្រួតពិនិត្យកាន់តែរឹងមាំនាពេលក្រោយក៏ដោយ ក៏ក្ដីកង្វល់ភាគច្រើននៃ E&S ដែល IFC បានលើកឡើងជាមួយអតិថិជនទាក់ទងនឹងការវាយតម្លៃហានិភ័យ E&S នៅក្នុងគម្រោងដែលមានហានិភ័យខ្ពស់ និងការអនុវត្ត PS ចំពោះអនុគម្រោងនានា នៅតែមិនបានដោះស្រាយនៅឡើយ គិតត្រឹមពេលនៃការចាកចេញរបស់ IFC ក្នុងឆ្នាំ២០២៤ ។

### *3.2.3.1 ឧកខានឱកាសដំបូងសម្រាប់ឥទ្ធិពលវិជ្ជមានរបស់ IFC លើអនុគម្រោង LS2 ឆ្នាំ ២០១១-២០១២*

សម្រាប់ហេតុផលដែលបានពន្យល់ខាងលើ (ផ្នែករង 3.2.2) IFC មិនតម្រូវឱ្យ ABBank អនុវត្តស្តង់ដារសមិទ្ធិកម្មឆ្នាំ២០០៦ ចំពោះការវិនិយោគដែលមានស្រាប់របស់ខ្លួនទេ។ អាស្រ័យហេតុនេះ IFC មិនបានពេញចិត្ត ដែលថាការតាមដានត្រួតពិនិត្យរបស់ ABBank ទៅលើ EVNI និងអនុគម្រោងសេសានក្រោម២ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារទាំងនេះ។ ស៊ីអេអូ យល់ឃើញថា កង្វះការត្រួតពិនិត្យ PS របស់ IFC នាំឱ្យបាត់បង់ឱកាសដើម្បីមានឥទ្ធិពលជាវិជ្ជមានទៅលើការរចនាអនុគម្រោងនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំភ្លាមៗបន្ទាប់ពីការវិនិយោគរបស់ខ្លួន។

នៅចន្លោះឆ្នាំ២០១១ ដល់ឆ្នាំ២០១២ EVNI គឺជាម្ចាស់ហ៊ុនភាគច្រើន និងអ្នកអភិវឌ្ឍគម្រោង LS2 ដូច្នេះ IFC

---

IFC ឆ្នាំ២០០៩, IFC ESRP ឆ្នាំ២០១៤ បង្ហាញថា "ការត្រួតពិនិត្យ E&S ប្រកបដោយប្រសិទ្ធភាព រួមបញ្ចូលការត្រួតពិនិត្យតាមកាលកំណត់នៃការអនុវត្ត E&S របស់អតិថិជន និងភាពអនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC រួមទាំងតាមរយៈការងារត្រួតពិនិត្យសំខាន់ៗដូចខាងក្រោម៖ ( i) ការវាយតម្លៃកម្រិតភាពអនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់អតិថិជន រួមទាំងលក្ខខណ្ឌទាំងអស់ នៃការទូទាត់ចំណាយ ចំណុចនៅក្នុងផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) និងកិច្ចព្រមព្រៀង E&S ផ្សេងទៀត ដែលត្រូវបានដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ នេះបើយោងតាម IFC ESRP ឆ្នាំ២០១៤ ផ្នែក 9.2.1 និង 9.2.5 ។ IFC ESRPs ឆ្នាំ២០២២ និង ២០២៣ ចែងថា "ការត្រួតពិនិត្យ E&S គឺជាផ្នែកសំខាន់មួយនៃការគ្រប់គ្រងហានិភ័យផលប័ត្រពេញមួយជីវិតគម្រោង និងទំនាក់ទំនងជាមួយអតិថិជន។ គោលបំណងនៃការត្រួតពិនិត្យ E&S នៅកម្រិតអតិថិជនគឺដើម្បី៖ (i) វាយតម្លៃស្ថានភាពនៃភាពអនុលោមរបស់អតិថិជនទៅតាមលក្ខខណ្ឌតម្រូវ E&S នៃកិច្ចសន្យាវិនិយោគ (រួមទាំង ESAP, COD, កតិកាសញ្ញាហាមឃាត់ និងតម្រូវ (Negative and Affirmative Covenants) និងលក្ខខណ្ឌតម្រូវការរាយការណ៍) វាយតម្លៃកម្រិតហានិភ័យ E&S ជាបន្ត រួមទាំងហានិភ័យតាមបរិបទ ផ្តល់ដំបូន្មានដល់អតិថិជនអំពីរបៀបដោះស្រាយបញ្ហា E&S សំខាន់ៗ និងកំណត់ឱកាសសម្រាប់ការកែលម្អ និងការអនុវត្តល្អដែលអាចយកទៅអនុវត្តចំពោះគម្រោងស្រដៀងគ្នានេះ" យោងតាម IFC ESRP ឆ្នាំ២០២២; IFC ESRP ឆ្នាំ២០២៣ ផ្នែក 4.2 ។

និងអតិថិជនរបស់ខ្លួន ABBank មានឱកាសយ៉ាងសំខាន់ក្នុងការតម្រឹមការរចនាទំនប់វារីអគ្គិសនីខ្នាតធំ និងការរៀបចំផែនការដំបូង ឱ្យស្របតាមលក្ខខណ្ឌតម្រូវ PS និងយុទ្ធសាស្ត្រវារីអគ្គិសនី ឆ្នាំ២០០៧ របស់ IFC។ ផ្អែកលើព័ត៌មានដែល ស៊ីអេអូ បានទទួល ក្រុមហ៊ុន EVNI បានបញ្ចប់គោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ (CRP) សម្រាប់គម្រោង LS2 ក្នុងឆ្នាំ២០១១។ ការត្រួតពិនិត្យកាន់តែហ្មត់ចត់ទៅលើ E&S របស់ IFC និងការពិនិត្យគ្រប់គ្រងពីដំបូង អាចនឹងបានបង្ហាញការកាន់កាប់ភាគហ៊ុនរបស់ធនាគារ ABBank នៅក្នុង EVNI និងការប្រឈមដែលត្រូវគ្នា ទៅនឹងហានិភ័យ E&S ពាក់ព័ន្ធនឹង LS2 រួមទាំងលទ្ធភាពនៃការផ្លាស់ទីលំនៅរូបវន្ត និងសេដ្ឋកិច្ច នៃគ្រួសាររាប់ពាន់។[153]ទោះជាយ៉ាងណាក៏ដោយ មិនមានភស្តុតាងបញ្ជាក់ថា IFC ឬ ABBank បានផ្តល់ការណែនាំដល់ EVNI អំពីលក្ខខណ្ឌតម្រូវ PS៥ (លទ្ធកម្មដី និងការតាំងទីលំនៅថ្មី) សម្រាប់គោលនយោបាយតាំងទីលំនៅថ្មី និងដោះស្រាយសំណង របស់អនុគម្រោង ដែលជាទូទៅសម្រាប់គ្រប់គម្រោងមានហានិភ័យខ្ពស់ទាំងអស់ ឬជាពិសេសសម្រាប់ LS2 តែម្តង។[154]

ការពិពណ៌នាសង្ខេបនៃ CRP ត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ក ។ សរុបមក គោលនយោបាយនេះ មានចំណុចខ្វះខាតយ៉ាងខ្លាំងក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវ PS១ និង PS៥ ។ ប្រសិនបើ IFC បានដឹងពីការពើបប្រទះរបស់ខ្លួនទៅនឹង LS2 នោះ IFC អាចនឹងបានផ្តល់ការណែនាំដល់ ABBank និង EVNI ទៅលើទិដ្ឋភាព និង

---

[153] EIA បានប៉ាន់ប្រមាណថា គ្រួសារចំនួន ១.០៥៩ ចាំបាច់ត្រូវផ្លាស់ទីលំនៅរូបវន្ត។ វាមិនកំណត់ចំនួនប្រជាពលរដ្ឋដែលនឹងអាចផ្លាស់ទីលំនៅសេដ្ឋកិច្ច ប៉ុន្តែបានប៉ាន់ប្រមាណថាប្រជាពលរដ្ឋ ៣០០.០០០ នាក់នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមនៃតំបន់គម្រោង នឹងរងផលប៉ះពាល់ដោយប្រយោលពីគម្រោងនេះ។ សារព័ត៌មាន និងអត្ថបទព័ត៌មានតាមអ៊ីនធឺណេត នៅពេលនោះ បានដាក់បញ្ចូល Vannarin និង Vrieze ជា "គម្រោងទំនប់វារីអគ្គិសនីទ្វេគ្រោះសម្រាប់អ្នកភូមិស្ទឹងត្រែង" *ខេមបូឌាដេលី* ថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៩៖ https://bit.ly/3RNgIDn និង "នាយករដ្ឋមន្ត្រីវៀតណាមស្នើសុំការអនុម័តទំនប់វារីអគ្គិសនីឱ្យបានរហ័ស"។ *ខេមបូឌាដេលី* ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០ https://bit.ly/45L0Rem ។ នៅក្នុងឆ្នាំ២០០៩ ការសិក្សារបស់សង្គមស៊ីវិលធ្វើឡើងដោយសម្ព័ន្ធទន្លេ (Rivers Coalition) នៅកម្ពុជាបានរកឃើញថា ប្រជាពលរដ្ឋប្រហែល ៧៨.០០០ នាក់នឹងទទួលរងផលប៉ះពាល់ទៅលើសន្តិសុខស្បៀង និងការបាត់បង់ប្រាក់ចំណូល ដោយសារ LS2 ។ Ian G. Baird, ឧត្តមានុវត្តក្នុងការផ្តល់សំណង និងការតាំងទីលំនៅថ្មី សម្រាប់ទំនប់ធំៗ៖ ករណីនៃគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នៅភាគភាគឦសាននៃប្រទេសកម្ពុជា (ភ្នំពេញៈ ភ្នំពេញៈ សម្ព័ន្ធទន្លេ នៅកម្ពុជា, ២០០៩), ១៣៨; សូមមើលផងដែរ ទន្លេអន្តរជាតិ "ទំនប់វារីអគ្គិសនីសេសានក្រោម២ កម្ពុជា មិនបានប្រកាន់ខ្ជាប់ឧត្តមានុវត្ត" ទន្លេអន្តរជាតិ (ខែសីហា ឆ្នាំ២០០៩ https://bit.ly/4cE3nFA ។

[154] ពីព័ត៌មានដែល ស៊ីអេអូ អាចស្វែងរកបាន CRP គឺជាគោលនយោបាយ E&S តែមួយគត់ដែលបានត្រូវបានបញ្ចប់ បន្ទាប់ពី EIA និង IFC ESDD ។ EVNI បានបញ្ចប់វា នៅក្នុងឆ្នាំ២០១១ ហើយក្រោយមកត្រូវបានអនុវត្តដោយគម្រោងនេះ។ ស៊ីអេអូ មិនបានទទួលព័ត៌មានអនុគម្រោងជាក់លាក់ ក្នុងអំឡុងពេលនៃការស៊ើបអង្កេតនេះ ដើម្បីបញ្ជាក់ថាតើការកែប្រែសំខាន់ៗណាមួយត្រូវបានធ្វើឡើងដោយអ្នកអភិវឌ្ឍន៍គម្រោង ក្រោយឆ្នាំ២០១២ ឬទេ។ មានរបាយការណ៍មួយចំនួនលើកឡើងថា Hydrolancang ដែលជាអ្នកអភិវឌ្ឍន៍គម្រោងបច្ចុប្បន្ន បានបង្កើតកំណែបន្ថែម និងជាបន្តបន្ទាប់នៃ EIA ផងដែរ ក៏ដូចជាបង្កើតផែនការកាត់បន្ថយផលប៉ះពាល់ផ្ទៃក្នុង និងផែនការតាំងទីលំនៅថ្មី មួយចំនួន ផងដែរ។ ស៊ីអេអូ មិនបានទទួលសិទ្ធិចូលប្រើប្រាស់ឯកសារទាំងនេះទេ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានពីសហគមន៍ និងភាគីពាក់ព័ន្ធក្នុងមូលដ្ឋាន បង្ហាញថា កំណែនៃ CRP ដែល ស៊ីអេអូ បានទទួល ឆ្លើយតបយ៉ាងទូលំទូលាយទៅនឹងអ្វីដែលត្រូវបានអនុវត្តនៅពេលក្រោយ។

ចំណុចខ្វះខាត របស់ CRP ឆ្នាំ២០១១ ដូចខាងក្រោម៖

a) មិនមានភ័ស្តុតាងណាមួយដែលថា CRP គឺផ្អែកលើសារពើភ័ណ្ឌទ្រព្យសកម្មគ្រប់ជ្រុងជ្រោយ នៃដីធ្លី ផ្ទះ និងទ្រព្យសម្បត្តិផ្សេងទៀតដែលរងផលប៉ះពាល់ទាំងអស់ នៅក្នុងតំបន់រងផលប៉ះពាល់ដោយសារគម្រោង ហើយក៏មិនមានភស្តុតាងដែលថា ការស្ទង់មតិសេដ្ឋកិច្ចសង្គមពេញលេញមួយ ត្រូវបានធ្វើឡើងដើម្បីយល់ពីកម្រិតជីវភាពរស់នៅ មុនពេលការផ្លាស់ទីលំនៅ និងមុខរបរចិញ្ចឹមជីវិតរបស់គ្រួសាររងផលប៉ះពាល់។[155]

b) CRP ហាក់ដូចជាគ្របដណ្តប់តែគ្រួសារណាដែលបានផ្លាស់ទីលំនៅរូបវ័ន្ត (តិចជាង ៥០ ភាគរយនៃគ្រួសារដែលរងផលប៉ះពាល់ ដោយយោងតាម EIA ឆ្នាំ២០០៨) [156] ដោយទុកចោលមិនអើពើចំពោះគ្រួសារដែលបានផ្លាស់ទីដោយសេដ្ឋកិច្ច (មានន័យថា គ្រួសារដែលអាចស្នាក់នៅក្នុងផ្ទះរបស់ពួកគេ ខណៈពេលដែលពួកបានបាត់បង់ដីកសិកម្មមួយផ្នែក ឬទាំងអស់)។ CRP ក៏មិនបានដោះស្រាយភាពខុសគ្នារវាងក្រុមទាំងពីរនេះ ផងដែរ។[157]

c) CRP មិនផ្តល់ផែនទី និង/ឬគ្រោងនៃកន្លែងតាំងលំនៅថ្មី ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដែលបានគ្រោងទុក ឬតំបន់នៃដីជំនួស—ព័ត៌មានលម្អិតសំខាន់ៗដែលត្រូវបានតម្រូវសម្រាប់ផែនការសកម្មភាពតាំងទីលំនៅថ្មី អនុលោមតាម PS៥ (RAP)។[158]

d) កញ្ចប់ការតាំងទីលំនៅថ្មីរូបវ័ន្ត (ទំហំផ្ទះជំនួស ដីលំនៅដ្ឋាន និងដីកសិកម្ម) ហាក់ដូចជាមិនទាន់ស្មើនឹង

---

[155] CRP ឆ្លុះបញ្ចាំងជំរឿនទិន្នន័យមូលដ្ឋាន ដែលទំនងជាបានធ្វើឡើងក្នុងឆ្នាំ២០១០។ ទោះជាយ៉ាងណាក៏ដោយ វាមិនមានព័ត៌មានណាមួយទាក់ទងនឹងវិធីសាស្ត្រ និងប្រភព ឬមូលដ្ឋាននៃព័ត៌មានភាគច្រើនរបស់វា គឺមិនច្បាស់លាស់ ដោយសារភាពខុសគ្នានៅក្នុងទិន្នន័យជីវភាពរស់នៅ ដែលមាននៅក្នុង EIA ឆ្នាំ២០០៨ និងការសិក្សាធ្វើឡើងនៅក្នុង ឆ្នាំ២០១២ ដោយវេទិកាអង្គការសង្គមស៊ីវិល NGO Forum ។ ដូចគ្នានេះផងដែរ ខណៈពេលដែលមានការស្ទង់មតិសង្គម-សេដ្ឋកិច្ច នៅក្នុង EIA ឆ្នាំ២០០៨ វាមិនបំពេញតាមលក្ខខណ្ឌតម្រូវរបស់ IFC PS5 (កថាខណ្ឌ១១) និងសៀវភៅណែនាំរបស់ IFC សម្រាប់ការរៀបចំផែនការតាំងលំនៅថ្មី (ជាពិសេសទំព័រ ១១-២៣) (២០០២), ៣៦–៣៩,https://bit.ly/48OwNAh; វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ទំនប់វារីអគ្គិសនីសេសានក្រោម២៖ ជីវភាពរស់នៅបច្ចុប្បន្ន និងសហគមន៍មូលដ្ឋាន៖ ការសិក្សាទិន្នន័យមូលដ្ឋាន (២០១២) https://bit.ly/3xBmRvM ។

[156] CRP បានព្យាករថា ៧៩៧ គ្រួសារ នឹងត្រូវការការតាំងទីលំនៅថ្មី នៅត្រឹមឆ្នាំ២០១៤។ វាមិនច្បាស់ពីឯកសារគម្រោងដែលស៊ីអេអូអាចស្វែងរកបាន ពីរបៀបដែលចំនួនគ្រួសាររងផលប៉ះពាល់បានថយចុះពី ១.០៥៩ នៅក្នុង EIA មកនៅត្រឹម ៧៩៧ នៅក្នុង CRP ។ CRP ចាប់ផ្តើមជាមួយនឹង ៥១៥ គ្រួសារដែលបានកំណត់ជាក់ស្តែង ក្នុងឆ្នាំ២០១០ នៅក្នុងជំរឿនទិន្នន័យមូលដ្ឋាន ហើយព្យាករណ៍ថានឹងកើនឡើងដល់ ៧៩៧ គ្រួសារ។ វាមិនច្បាស់ថា ៥១៥ គ្រួសារដំបូងបានមកពីណាទេ ព្រោះ EIA បានកំណត់ថា ១.០៥៩ គ្រួសារ ដែលចាំបាច់ត្រូវតាំងទីលំនៅថ្មី។ EVNI ឆ្នាំ២០១១ CRP, ២–៣ ។

[157] PS៥ ឆ្នាំ២០០៦ របស់ IFC បញ្ជាក់ច្បាស់ថា PS៥ អនុវត្តចំពោះការផ្លាស់ទីលំនៅរូបវ័ន្ត និងសេដ្ឋកិច្ច (កថាខណ្ឌ ៥) ហើយទម្រង់នៃការផ្លាស់ទីលំនៅទាំងពីរត្រូវតែដោះស្រាយ (កថាខណ្ឌ ១៥ និង២០)។

[158] សូមមើល PS៥ ឆ្នាំ២០០៦, កថាខណ្ឌ១២; កំណត់សម្គាល់៥ ឆ្នាំ២០០៦, លទ្ធកម្មដី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧), កថាខណ្ឌ G12; និងសៀវភៅណែនាំ IFC RAP ឆ្នាំ២០០២ ៣៦-៣៩។

ទ្រព្យសកម្មមុនការផ្លាស់ទីលំនៅរបស់គ្រួសារ នោះទេ។[159]

e) ជម្រើសសំណងជាសាច់ប្រាក់ មិនផ្តល់នូវភស្តុតាងដែលបង្ហាញថា ជំរើសទាំងនេះបំពេញតាមស្តង់ដារជំនួសពេញលេញទេ—លក្ខខណ្ឌមួយ ដែលតម្រូវដោយ PS៥។[160]

f) មិនមានការចង្អុលបង្ហាញអំពីរបៀបដែលអនុគម្រោង LS2 មានគោលបំណងលើកកម្ពស់កម្រិតជីវភាព និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ឱ្យលើសពីការជំនួសអ្វីដែលបានបាត់បង់នោះទេ ដែលនេះជាសេចក្តីប្រាថ្នា ស្របតាម PS៥។[161]

g) មិនមានការចង្អុលបង្ហាញថាសេចក្តីព្រាង CRP ត្រូវបានផ្សព្វផ្សាយ ពិភាក្សាជាមួយ និង/ឬត្រូវបានធ្វើសុពលកម្ម ដោយអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ដើម្បីធានាបាននូវការចូលរួមដែលមានព័ត៌មានរបស់ពួកគេ នៅក្នុងដំណើរការធ្វើការសម្រេចចិត្តទាក់ទងនឹងការតាំងទីលំនៅថ្មី។[162]

h) មិនមានការផែនការណាមួយ រៀបរាប់អំពីរបៀប និងពេលវេលា ដែល CRP នឹងត្រូវបានលម្អិតបន្ថែមទៀត តាមរយៈផែនការសកម្មភាពតាំងទីលំនៅថ្មី នៅក្នុងការពិគ្រោះយោបល់ជិតស្និទ្ធជាមួយអ្នកដែលរងផលប៉ះពាល់។[163]

i) CRP មិនគិតគូរថា សហគមន៍ដែលបានតាំងទីលំនៅថ្មីមួយចំនួន គឺជាជនជាតិដើមភាគតិច ដូច្នេះត្រូវបានកំណត់នៅក្នុង EIA ឆ្នាំ២០០៨ សម្រាប់អនុគម្រោង LS2 ។

j) មិនមានការផ្តល់ជាយន្តការបណ្តឹងសារទុក្ខរបស់គម្រោង ដើម្បីទទួល និងដោះស្រាយក្តីកង្វល់អំពីសំណង និងការផ្លាស់ទីលំនៅ ដែលលើកឡើងដោយអ្នកផ្លាស់ទីលំនៅ ដូចត្រូវបានតម្រូវទាំងនៅក្នុង PS១ និង PS៥ នោះទេ។[164]

---

[159] PS៥ ឆ្នាំ២០០៦ កថាខណ្ឌ ១៧, ២០, កំណត់សម្គាល់ណែនាំ៥ ឆ្នាំ២០០៦, លទ្ធកម្មដី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត (ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៧) កថាខណ្ឌ G៨, G១១, និង G១២ ។

[160] PS៥ ឆ្នាំ២០០៦ កថខណ្ឌ ១៧។

[161] PS៥ ឆ្នាំ២០០៦ កថខណ្ឌ ៣។

[162] PS៥ ឆ្នាំ២០០៦ កថខណ្ឌ ៣ និង ៩។ បន្ថែមពីលើអវត្តមានភស្តុតាងនៃកំណត់ត្រានានា ឬការចងចាំនៃការពិគ្រោះយោបល់នេះ ក្នុងចំណោមសមាជិកសហគមន៍ មានធាតុកាលៈទេសៈដែលគាំទ្រដល់គំនិតដែលថា CRP មិនត្រូវបានបង្កើតឡើង ដោយមានការពិគ្រោះយោបល់ជិតស្និទ្ធជាមួយអ្នករងផលប៉ះពាល់នោះទេ។ ផែនការសកម្មភាពនៃការតាំងទីលំនៅថ្មីត្រឹមត្រូវ នឹងអាចបានកំណត់យ៉ាងងាយស្រួលនូវបំណងប្រាថ្នាដ៏ធំរបស់ប្រជាពលរដ្ឋមួយចំនួនធំក្នុងការតាំងទីលំនៅថ្មីរូបវន្ត នៅក្នុងទីតាំងដូចគ្នាជិតទៅនឹងផ្ទះពីមុនរបស់ពួកគេ ជាជាងទៅទីតាំងឆ្ងាយ ហើយវាយតម្លៃ៖ (i) ជម្រើសនៃការទទួលបានដីកសិកម្មជំនួសពីសម្បទានដី និងព្រៃឈើ ដោយប្រើប្រាស់ដីទំនៀមទម្លាប់របស់សហគមន៍ទាំងប្រាំមួយ និង (ii) លទ្ធភាពនៃមុខរបរចិញ្ចឹមជីវិតជំនួស ដើម្បីស្តារកម្រិតប្រាក់ចំណូលឡើងវិញឱ្យមកដល់កម្រិតមុនការផ្លាស់ទីលំនៅ ដោយមិនចាំបាច់ឱ្យគ្រួសារចេញពីដីទំនៀមទម្លាប់របស់ពួកគេ។

[163] PS៥ ឆ្នាំ២០០៦ កថខណ្ឌ ៩។

[164] PS៥ ឆ្នាំ២០០៦ កថខណ្ឌ១០; PS១ ឆ្នាំ២០០៦ កថខណ្ឌ ២៣។

ស៊ីអេអូ សន្និដ្ឋានថា នៅមានឱកាសសម្រាប់ដោះស្រាយចំណុចខ្វះខាតសំខាន់ៗខាងលើ នៅក្នុងលក្ខខណ្ឌតម្រូវ PS សម្រាប់អនុគម្រោងដ៏សំខាន់នេះ ដែលបានផ្លាស់ទីលំនៅប្រជាជនប្រហែល ៥.០០០ នាក់ និងប៉ះពាល់ដល់គ្រួសាររាប់ពាន់ទៀត។ ឱកាសគឺនេះមានតាំងពីឆ្នាំ២០១១មកម្លេះ នៅពេលដែលអនុគម្រោងស្ថិតក្នុងដំណាក់កាលដំបូងនៃការរចនា និងការអភិវឌ្ឍ រហូតដល់កញ្ចប់ការតាំងទីលំនៅថ្មីដំបូងត្រូវបានផ្តល់ជូន ក្នុងឆ្នាំ២០១៣។ IFC មានឱកាសពិសេសមួយក្នុងការតម្រឹមអនុគម្រោងនេះ ស្របតាមលក្ខខណ្ឌតម្រូវ PS លើការផ្លាស់ទីលំនៅរូបវ័ន្ត និងសេដ្ឋកិច្ច តាមរយៈការប្តេជ្ញាចិត្តផ្លូវច្បាប់របស់ធនាគារ ABBank ដើម្បីអនុវត្តពួកវា ចំពោះការវិនិយោគដែលមានស្រាប់។ ក្នុងនាមជាម្ចាស់ភាគហ៊ុនភាគច្រើន ក្រុមហ៊ុន EVNI មានឥទ្ធិពលយ៉ាងសំខាន់លើការរចនា និងវិធានការកាត់បន្ថយផលប៉ះពាល់ E&S របស់អនុគម្រោង។ ដោយមិនបានត្រួតពិនិត្យការប្តេជ្ញាចិត្តនេះ នៅក្នុងផែនការ SEMS និងជាពិសេសដោយមិនបានត្រួតពិនិត្យទាល់តែសោះលើការវិនិយោគរបស់ ABBank ក្នុងឆ្នាំ២០១១ IFC បានបរាជ័យក្នុងការជួយកាត់បន្ថយគ្រោះថ្នាក់នានា ដែលអ្នករងផលប៉ះពាល់គម្រោង បានជួបប្រទះ។[165]

### *3.2.3.2 ខកខានឱកាសជះឥទ្ធិពលវិជ្ជមានរបស់ IFC លើអនុគម្រោង LS2 ក្រោយឆ្នាំ២០១៣*

ស៊ីអេអូ ទទួលស្គាល់ថា ការទាមទារឱ្យមានការអនុវត្ត PS ទៅលើទំនប់វារីអគ្គិសនី កាន់តែជួបបញ្ហាប្រឈមខ្លាំងឡើងៗ ក្រោយពេលដែល EVNI ក្លាយជាម្ចាស់ភាគហ៊ុនភាគតិច ក្នុងខែវិច្ឆិកា ឆ្នាំ២០១២។ IFC មិនអាចទាមទារឱ្យ ABBank ធានាការអនុវត្ត PS ទៅលើអនុគម្រោងនេះបានទេ ដោយសារ EVNI មិនមានអានុភាពគ្រប់គ្រាន់នៅក្នុង LS2 ហើយការសម្រេចចិត្តនឹងត្រូវអាស្រ័យលើម្ចាស់ហ៊ុនភាគច្រើនថ្មី គឺក្រុមហ៊ុន Hydrolancang International Energy ។ ទោះជាយ៉ាងណាក៏ដោយ EVNI បានរក្សាកៅអីមួយ នៅក្នុងក្រុមប្រឹក្សាភិបាល LS2 ជាវេទិកាមួយ ដែល EVNI អាចបានប្រើវាដើម្បីផ្តល់ការណែនាំ និងចំណេះដឹងអំពីលក្ខខណ្ឌតម្រូវ PS ក៏ដូចជាការអនុវត្តឧស្សាហកម្មអន្តរជាតិដ៏ល្អ ផងដែរ។[166]

ដូច្នេះ តាមរយៈធនាគារ ABBank, IFC នៅតែមានឱកាសខ្លះដើម្បីមានឥទ្ធិពលជាវិជ្ជមាន មកលើការធ្វើផែនការការសាងសង់ និងប្រតិបត្តិការអនុគម្រោង។ ស៊ីអេអូ កត់ចំណាំថា ការបន្ថែមមិនមែនជាហិរញ្ញវត្ថុ របស់ IFC សម្រាប់អតិថិជន និងគោលបំណងមួយ ក្នុងចំណោមគោលបំណងគន្លឹះៗនៃការត្រួតពិនិត្យ E&S របស់ខ្លួន គឺច្បាស់ណាស់ជាការផ្តល់ការណែនាំ និងដំបូន្មាន ដល់អតិថិជនអំពីរបៀបដោះស្រាយបញ្ហាហានិភ័យ E&S និង

---

[165]សូមមើល អង្គការឃ្លាំមើលសិទ្ធិមនុស្ស ក្នុងចំណោមផ្សេងទៀត "ឥទ្ធិពលគម្រោង, ២០២១"; ភ្នំពេញប៉ុស្តិ៍, "ការភ័យខ្លាចទឹកជំនន់នៃទំនប់វារីអគ្គិសនី" ភ្នំពេញប៉ុស្តិ៍ (២០១១); ភ្នំពេញប៉ុស្តិ៍, "ព័ត៌មានតិចតួចអំពីទំនប់វារីអគ្គិសនីសេសានក្រោម២"; Ham, Hay, និង Sok, "នយោបាយទំនប់វារីអគ្គិសនីសេសានក្រោម២នៅកម្ពុជា"; Mak "ទំនប់ និងសន្តិសុខរដ្ឋ"; Hensengerth, "ភាពថ្នាក់តំបន់ អត្តសញ្ញាណ និងទំនប់វារីអគ្គិសនី"; Green និង Baird, "នយោបាយចម្រូងចម្រាសនៃការវាយតម្លៃផលប៉ះពាល់ទំនប់វារីអគ្គិសនី"។

[166] ទោះបីជាមានការស្នើសុំព័ត៌មាននេះច្រើនដងតាមរយៈ ABBank ក៏ដោយ ស៊ីអេអូ មិនបានដឹងពីបទប្បញ្ញត្តិ និងលក្ខខណ្ឌជាក់លាក់នៅក្នុងកិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុន រវាង Hydrolancang International Energy, Cambodia Royal Group និង EVNI នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ស៊ីអេអូ យល់ថា ជាទូទៅ វាមានសិទ្ធិជាទៀងទាត់របស់ម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនបន្ត LS2 និងជាពិសេសសិទ្ធិក្នុងការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមប្រឹក្សាភិបាលក្រុមហ៊ុន LS2 ។

ដើម្បីកំណត់ឱកាសសម្រាប់ការកែលម្អ និងការអនុវត្តល្អៗ ដែលអាចត្រូវបានយកទៅអនុវត្តចំពោះគម្រោងស្រដៀងគ្នានានា។[167] ទោះជាយ៉ាងណាក៏ដោយ ស៊ីអេអូ បានរកឃើញភស្តុតាងតិចតួចដែល IFC ណែនាំ ឬផ្តល់ការណែនាំដល់ ABBank លើលក្ខខណ្ឌតម្រូវ PS ក្រៅពីរយៈពេលខ្លី នៅចន្លោះឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ ហើយមិនបានរកឃើញភស្តុតាងណាមួយដែលថា IFC ផ្តល់ដំបូន្មាន ដល់ EVNI ឬអតិថិជនបន្តផ្សេងទៀត នៅចំណុចណាមួយ។

ស៊ីអេអូ គូសបញ្ជាក់ពីឱកាសមួយចំនួនដូចខាងក្រោម ដែល IFC អាចមានឥទ្ធិពលវិជ្ជមានលើការអភិវឌ្ឍ និងការអនុវត្ត LS2 ប្រកបដោយនិរន្តរភាព នៅចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០២៤៖

- **ជីវចម្រុះ៖** នៅក្នុងឆ្នាំ២០១២ ការសិក្សាមួយដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុង Proceedings of the National Academy of Sciences បានសន្និដ្ឋានថា ទំនប់វារីអគ្គិសនីសេសានក្រោម២ មិនគួរត្រូវបានសាងសង់នោះទេ ដោយសារតែអត្ថប្រយោជន៍នៃការផលិតថាមពលរបស់វា មិនលើសពីបន្ទុកចំណាយនៃការបាត់បង់ជីវចម្រុះនោះទេ។[168] មិនយូរប៉ុន្មាន ក្នុងឆ្នាំ២០១៣ ម្ចាស់ជំនួយអន្តរជាតិរបស់គណៈកម្មការទន្លេមេគង្គ រួមទាំងធនាគារពិភពលោក បានលើកទឹកចិត្តរដ្ឋាភិបាលកម្ពុជា ឱ្យរៀបចំឡើងវិញនូវអនុគម្រោង IFC "ដោយសំអាងលើលទ្ធភាពកើតមានផលប៉ះពាល់អវិជ្ជមានក្នុងតំបន់ កើតចេញពីទំនប់វារីអគ្គិសនីសេសានក្រោម២ នៅក្នុងការរចនាបច្ចុប្បន្នរបស់វា (រួមទាំង ការបំលាស់ទីរបស់ត្រី លំហូរដីល្បាប់ និង ការតាំងទីលំនៅថ្មីរបស់សហគមន៍មូលដ្ឋាន)" (សូមមើលឧបសម្ព័ន្ធ ក សម្រាប់ព័ត៌មានលម្អិត)។[169]

  គម្រោងនេះបានដំណើរការទៅមុខ ហើយការសាងសង់បានចាប់ផ្តើម នៅខែមករា ឆ្នាំ២០១៤។ សហគមន៍បានតាំងទីលំនៅថ្មី នៅចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ហើយនៅឆ្នាំ២០១៨ គេបានបង្ហូរទឹកចូលក្នុងអាងស្តុកទឹក ហើយទំនប់បានចាប់ផ្តើមដំណើរការ។

  កាលពីមួយឆ្នាំមុន ពោលគឺនៅក្នុងឆ្នាំ២០១៧ វាហាក់ដូចជាឆ្លើយតបទៅនឹងសម្ពាធសាធារណៈក្នុងការដោះស្រាយផលប៉ះពាល់របស់ LS2 លើជីវចម្រុះ អ្នកអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី បានសាងសង់ផ្លូវត្រី បើ

---

[167] IFC ESRP ឆ្នាំ២០១៤ ផ្នែក 9.1.1 (ទាក់ទងនឹង FIs ជាពិសេស); IFC ESRP ឆ្នាំ២០២២ និង២០២៣, ផ្នែក 4.2 ។

[168] PS៦, កថាខណ្ឌ ៧។ ការសិក្សាបានពិនិត្យទំនប់ចំនួន ២៧ ដែលគ្រោងនឹងសាងសង់នៅក្នុងអាងទន្លេមេគង្គ នៅចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០ ហើយបានសន្និដ្ឋានថា LS2 នឹងមានឥទ្ធិពលធំបំផុតលើជីវម៉ាសត្រី (ធ្លាក់ចុះ ៩,៣ ភាគរយនៃជីវម៉ាសត្រីនៅទូទាំងអាង) ក្នុងពេលជាមួយគ្នាដែលវាបានប៉ាន់ប្រមាណថា ទំនប់ LS2 នឹងបណ្តាលឱ្យបាត់បង់ត្រីចំនួន ៤ ភាគរយ (~២៥.៣០០ តោន/ឆ្នាំ) ក្នុងមួយ TWh/y ដែលផលិតបាន។ Guy Ziv, Eric Baran, So Nam, Ignacio Rodríguez-Iturbe, និង Simon A. Levin, "ការដោះដូរ នៃជីវចម្រុះត្រី សន្តិសុខស្បៀង និងវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គ" Proceedings of the National Academy of Sciences ១០៩ លេខ ១៥ (២០១២)៥.៦០៩-១៤។

[169] គណៈកម្មការទន្លេមេគង្គ "របាយការណ៍កិច្ចប្រជុំម្ចាស់ជំនួយក្រៅផ្លូវការ" រាជធានីភ្នំពេញ ប្រទេសកម្ពុជា (២៧-២៨ មិថុនា ២០១៣); Dene-Hern Chen, "ម្ចាស់ជំនួយអន្តរជាតិអំពាវនាវឱ្យរៀបចំឡើងវិញនូវទំនប់វារីអគ្គិសនីសេសាន២" ខេមបូឌា ដេលី (ខែកក្កដា ឆ្នាំ២០១៣) https://bit.ly/3VIqGr6 ។

ទោះបីជា EIA គម្រោង ណែនាំមិនឱ្យធ្វើបែបនេះ ហើយការសិក្សាស្រាវជ្រាវនានាកន្លងមក បានលើកឡើងថា យុទ្ធសាស្ត្រនេះមិនមានប្រសិទ្ធភាពឡើយ នៅតាមទន្លេត្រូពិច ដោយសារតែភាពចម្រុះនៃប្រភេទសត្វ ដែលធ្វើឱ្យវាពិបាកបង្កើតការរចនា ដែលសត្វគ្រប់ប្រភេទ ឬភាគច្រើន នោះអាចសម្របបាន។ [170] លុះក្រោយមកនៅឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជា បានបង្កើត "សហគមន៍នេសាទ" នៅក្នុងអាងស្តុកទឹកសម្រាប់ការអភិរក្សប្រភេទសត្វក្នុងទឹក [171] និងថ្មីៗនេះទៀត បានលែងកូនត្រីទៅក្នុងអាងស្តុកទឹក ដើម្បីបង្កើនស្តុកត្រី (សូមមើលព័ត៌មានលម្អិតបន្ថែម នៅក្នុងឧបសម្ព័ន្ធ ក ទាក់ទងនឹងសកម្មភាព និងព័ត៌មានកម្រិតអនុគម្រោង)។ ទោះជាយ៉ាងណាក៏ដោយ វិធានការទាំងនេះមិនមានការវាយតម្លៃពេញលេញ អំពីស្ថានភាពជលផល និងវិធានការចាំបាច់ដើម្បីស្តារវាឡើងវិញទេ។

ប្រសិនបើ IFC បានដឹងពីការពើបប្រទះរបស់ខ្លួនទៅនឹង LS2 នោះព្រឹត្តិការណ៍ទាំងនេះ និងភាពល្បីល្បាញរបស់អនុគម្រោង អាចនឹងបានជំរុញឱ្យ IFC ផ្តល់ការណែនាំ និងដំបូន្មានដល់អ្នកអភិវឌ្ឍន៍ទំនប់ តាមរយៈ ABBank និង EVNI ។ ឱកាសនេះមិនត្រូវបានគេដឹង នៅពេលដែលវាមានប្រយោជន៍បំផុតនោះទេ។ តាមរយៈការត្រួតពិនិត្យរបស់ខ្លួនលើ ABBank, IFC អាចប្រើប្រាស់ការប្តេជ្ញាចិត្តផ្នែកច្បាប់របស់ ABBank ក្នុងការផ្តល់ដំបូន្មាន ដើម្បីជួយដោះស្រាយក្តីកង្វល់អំពីជីវចម្រុះ និងការណែនាំលម្អិតអំពីរបៀបធ្វើការសិក្សាអំពីជីវចម្រុះឱ្យបានគ្រប់ជ្រុងជ្រោយ ព្រមទាំងជួយកំណត់អ្នកជំនាញ និងវិធានការកាត់បន្ថយផលប៉ះពាល់សមស្របនានា ដោយគោរពតាមលក្ខខណ្ឌតម្រូវ PS៦ ។[172]

---

[170] ផ្លូវត្រី ជណ្តើរត្រី និងប្រភេទផ្លូវត្រីផ្សេងទៀត មានទំនោរមិនមានប្រសិទ្ធភាពនៅក្នុងទន្លេត្រូពិច ដោយសារភាពចម្រុះនៃប្រភេទត្រីរបស់ទន្លេធ្វើឱ្យវាជាបញ្ហាប្រឈមសម្រាប់ប្រភេទត្រីមួយដើម្បីសម្របតាមត្រីប្រភេទទាំងអស់ ឬភាគច្រើន។ នៅក្នុងបរិយាកាសត្រូពិច មានឧទាហរណ៍មួយចំនួនតូចនៃជណ្តើរត្រី និងផ្លូវត្រី ដែលទទួលបានជោគជ័យ ហើយមានករណីបរាជ័យជាច្រើននៃផ្លូវត្រី ទាំងដោយសារតែការរចនាមិនល្អ ការគ្រប់គ្រងមិនល្អ ឬទាំងពីរ។ មានឧទាហរណ៍ពីអាមេរិកខាងត្បូងនោះ បង្ហាញថានៅក្នុងបរិយាកាសត្រូពិចដែលសម្បូរទៅដោយត្រីច្រើនប្រភេទ រហូតដល់ ១១៦ ប្រភេទ ត្រូវបានគេរកឃើញនៅក្នុងប្រព័ន្ធផ្លូវត្រី ប៉ុន្តែមានតែពីរបីប៉ុណ្ណោះដែលអាចឡើងដល់កំពូល។ ជណ្តើរត្រីក៏ជាទូទៅអនុវត្តមិនបានល្អ នៅក្នុងអាងទន្លេមេគង្គ ដូចជាទំនប់ Pak Mun នៅប្រទេសថៃ ដែលជាទូទៅចាត់ទុកថាជាការបរាជ័យ។ Pratch Rujivanarom, "ជម្លោះទៅលើរឿងជណ្តើរត្រីក្នុងការរក្សាប្រភេទត្រី" ។ The Nation (ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០១៧); WCD ២០០០៖ ទំនប់ និងការអភិវឌ្ឍន៍; Pelle Gätke, Eric Baran, Helio Martins Fontes Jr., Sergio Makrakis, Maristela Cavicchioli Makrakis, Timo A. Räsänen, និង Saray Samadee ។ ឱកាសផ្លូវត្រីសម្រាប់ទំនប់វារីអគ្គិសនីសេសានក្រោម ២ នៅកម្ពុជា—មេរៀនពីអាមេរិកខាងត្បូង; ទីក្រុងឡុងដ៍៖ Earthscan Publications, ២០១៣); ICEM – មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន ទីក្រុងហាណូយ ប្រទេសវៀតណាម របាយការណ៍គម្រោង៖ កម្មវិធីប្រកួតប្រជែងលើគម្រោងទឹក និងអាហារមេគង្គ MK3 "ការបង្កើនប្រសិទ្ធភាពការគ្រប់គ្រងអាងស្តុកទឹកនៅកម្រិតតំបន់មានប្រភពទឹក"។ វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី; ឆ្នាំ២០១១; TR Roberts, "នៅលើទន្លេនៃការមិនត្រឡប់មកវិញ: ទំនប់ Pak Mun និងជណ្តើរត្រីរបស់ប្រទេសថៃ។ ព្រឹត្តិបត្រ Natural History Bulletin of the Siam Society ៤៩ (២០០១), ១៨៩–២៣០។

[171] វិសាលភាព និងដែននៃអាណត្តិ សមត្ថភាព និងមុខងាររបស់ពួកគេ គឺមិនច្បាស់លាស់ចំពោះ ស៊ីអេអូ ។

[172] កំណត់សម្គាល់ការណែនាំ៦ ឆ្នាំ២០០៦ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព (ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៧), កថាខណ្ឌ G៣–G៩។

- **បញ្ហាសងសឹក៖** នៅឆ្នាំ២០១៤-១៥ មានការតវ៉ា និងបណ្ដឹងជាសាធារណៈពីជនជាតិដើមភាគតិច ជុំវិញ LS2 ដោយលើកឡើងថា គម្រោងនេះនឹងធ្វើឱ្យបាត់បង់វប្បធម៌ ប្រពៃណី និងអត្តសញ្ញាណរបស់ពួកគេ។[173] ក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ សហគមន៍ដែលបដិសេធមិនព្រមតាំងលំនៅថ្មី ក៏បានលើកឡើងពីការចោទប្រកាន់អំពីការគំរាមកំហែង និងការសងសឹក ចំពោះការបញ្ចេញសំឡេងប្រឆាំងនឹងគម្រោងនេះ[174] ហើយអ្នកភូមិបីក្រុម បានដាក់ពាក្យបណ្ដឹងទៅ ស៊ីអេអូ ។

  នៅពេលដែលការតវ៉ាប្រឆាំងនឹងអនុគម្រោងមានសន្ទុះ ដែលបណ្ដាលឱ្យមានការសងសឹកប្រឆាំងនឹងអ្នកតវ៉ា នោះ IFC ស្របពេលជាមួយគ្នាបានចេញសេចក្ដីថ្លែងការណ៍ជំហររបស់ខ្លួន ឆ្នាំ២០១៨ ស្ដីពីការសងសឹកប្រឆាំងនឹងសង្គមស៊ីវិល និងភាគីពាក់ព័ន្ធគម្រោង។[175] ប្រសិនបើ IFC បានដឹងអំពីកាពើបប្រទះរបស់ខ្លួនទៅនឹង LS2 នោះព្រឹត្តិការណ៍ទាំងនេះ និងភាពល្បីល្បាញរបស់អនុគម្រោង អាចជាឱកាសមួយសម្រាប់ IFC ទាញយកការប្ដេជ្ញាចិត្តផ្លូវច្បាប់របស់ ABBank ដើម្បីផ្ដល់ដំបូន្មានដល់ EVNI ឬ អ្នកអភិវឌ្ឍន៍ទំនប់ តាមរយៈ ABBank និង EVNI លើការដោះស្រាយបណ្ដឹងសារទុក្ខ និងការរិះគន់ទៅលើគម្រោងអភិវឌ្ឍន៍ ព្រមទាំងកាតព្វកិច្ចសិទ្ធិមនុស្ស មិនត្រូវសងសឹកអ្នកតវ៉ា។ ទោះជាយ៉ាងណាក៏ដោយ មិនមានភស្ដុតាងនៅក្នុងឯកសារត្រួតពិនិត្យរបស់ IFC ដែលថា IFC បានផ្ដល់ការណែនាំដល់ធនាគារ ABBank ឬក្រុមហ៊ុន EVNI លើគោលនយោបាយគ្មានការអត់ឱន ចំពោះការសងសឹកប្រឆាំងនឹងអ្នករងផលប៉ះពាល់គម្រោង នៅពេលនោះទេ។

- **ការដោះស្រាយហានិភ័យ E&S៖** ការទទួលស្គាល់ឆ្នាំ២០១៧ របស់ IFC អំពីទំនាក់ទំនងរបស់ធនាគារ ABBank ទៅនឹងទំនប់ LS2 នៅកម្ពុជា គឺកើតឡើងស្របពេលជាមួយនឹងការត្រួតពិនិត្យរបស់ខ្លួនដែលបានរកឃើញថា SEMS របស់ ABBank មិនគ្រប់គ្រាន់ដើម្បីដោះស្រាយហានិភ័យ E&S នៃគម្រោងដែលមានហានិភ័យខ្ពស់។ IFC បានផ្ដល់អនុសាសន៍ឱ្យ ABBank ប្រើប្រាស់ជំនាញខាងក្រៅ និងធ្វើឱ្យ

---

173 អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង, ២០២១" ដកស្រង់សេចក្ដីថ្លែងការណ៍ជាច្រើនដែលបានផ្ញើទៅកាន់រដ្ឋសភា។ សេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់សហគមន៍៖ "អ្នកភូមិជនជាតិភាគតិចព្នង នៅក្បាលរមាស និងអ្នកភូមិឡាវ នៅភូមិស្រែគរ១ និងភូមិ២ ប្រកាសជាសាធារណៈ៖ 'យើងបដិសេធមិនព្រមតាំងទីលំនៅថ្មី ផ្ដល់ដោយទំនប់វារីអគ្គិសនីសេសានក្រោម២'" (២៩ កញ្ញា ២០១៤)។ សូមមើល A. Cuddy, និង P. Seangly, "អ្នកភូមិបដិសេធការផ្លាស់ទីលំនៅ" ភ្នំពេញប៉ុស្តិ៍ (២៩ កញ្ញា ២០១៤) ។

174 ការតវ៉ាប្រឆាំងនឹងគម្រោងនេះបានចាប់ផ្ដើមនៅក្នុងឆ្នាំ២០០៨ ហើយបានបន្តរហូតដល់ឆ្នាំ២០១៨ នៅពេលដែលគម្រោងនេះបានចាប់ផ្ដើមប្រតិបត្តិការ។ មេដឹកនាំសហគមន៍ពីក្បាលរមាសចាស់ និងស្រែគរចាស់ បានត្រូវបានចោទប្រកាន់ពីបទ "ញុះញង់" ក្នុងឆ្នាំ២០១៧ ចំពោះការតវ៉ារបស់ពួកគេ និងការប្រឆាំងនឹងការតាំងទីលំនៅថ្មី។ គ្រូបង្រៀន និងបុគ្គលិកត្រូវបានដកចេញពីសាលារៀន និងមណ្ឌលសុខភាព នៅក្នុងភូមិចាស់ ខណៈដែលគ្រួសារជាច្រើននៅតែស្ថិតក្នុងភូមិចាស់។ ការបិទផ្លូវដែលត្រួតពិនិត្យដោយប៉ូលីស ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យប្រជាជនទាំងអស់ដែលប្រើប្រាស់ផ្លូវចូលទៅភូមិ ដោយកម្រិតការចូលប្រើប្រាស់សម្រាប់ប្រជាជនដែលចង់ទៅលេង និងសម្រាប់សមាជិកសហគមន៍ក្នុងការស្វែងរកសេវាសុខភាព។ (សូមមើលព័ត៌មានលម្អិតនៅក្នុងផ្នែក៤ ស្ដីពីគ្រោះថ្នាក់ពាក់ព័ន្ធ)។

175 សេចក្ដីថ្លែងការណ៍ជំហររបស់ IFC ស្ដីពីការសងសឹកប្រឆាំងនឹងសង្គមស៊ីវិល និងភាគីពាក់ព័ន្ធគម្រោង (ខែតុលា ២០១៨) https://www.ifc.org/content/dam/ifc/doc/2023/201810-ifc-position-statement-on-reprisals-en.pdf ។

ប្រសើរឡើង SEMS របស់ខ្លួន ប៉ុន្តែបានផ្តល់ការណែនាំ ឬការបណ្តុះបណ្តាលតិចតួច អំពីរបៀបអនុវត្តលក្ខខណ្ឌតម្រូវ PS ទៅលើគម្រោងនេះ ឬអនុគម្រោងផ្សេងទៀត ដែលមានហានិភ័យ E&S ខ្ពស់។ ខណៈពេលដែលដំបូន្មានគួរឱ្យកត់សម្គាល់មួយចំនួនលើការអនុវត្ត PS ត្រូវបានផ្តល់ជូន នៅចន្លោះឆ្នាំ ២០១៩ ដល់ឆ្នាំ២០២០ ការផ្លាស់ប្តូរបុគ្គលិកញឹកញាប់របស់អតិថិជន មានន័យថាភាគច្រើននៃការណែនាំរបស់ IFC ក្នុងអំឡុងពេលប៉ុន្មានឆ្នាំទាំងនោះ ត្រូវបានបាត់បង់ នៅពេលដែលទីប្រឹក្សា E&S បានចាកចេញនៅឆ្នាំ២០២១ (សូមមើលផ្នែក 3.2.2 ខាងលើ)។ មិនមានការកសាងសមត្ថភាពស្ថាប័នសម្រាប់ការគ្រប់គ្រង E&S មុនការវិនិយោគរបស់ IFC ទេ ហើយមានការកសាងសមត្ថភាពតិចតួចបំផុតនៅក្នុងអំឡុងពេលត្រួតពិនិត្យរបស់ IFC ។

លើសពីគម្រោង LS2, IFC ក៏ខកខានឱកាសក្នុងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្តគម្រោងដែលមានហានិភ័យខ្ពស់ផ្សេងទៀត នៅក្នុងផលប័ត្ររបស់ ABBank ផងដែរ។ IFC បានផ្តល់ការណែនាំ ឬអនុសាសន៍តិចតួចសម្រាប់អតិថិជនរបស់ខ្លួនក្នុងការវាយតម្លៃ និងគ្រប់គ្រងបញ្ហា E&S ឱ្យបានគ្រប់គ្រាន់ នៅកម្រិតអនុគម្រោង នៅពេលពិចារណាលើការវិនិយោគនេះលើសពី១៣ ឆ្នាំ ហើយបានបរាជ័យក្នុងការធានាថា អតិថិជនរបស់ខ្លួនបានកសាងសមត្ថភាព E&S របស់ស្ថាប័នគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងការអនុវត្ត PS សម្រាប់ការវិនិយោគរបស់ខ្លួន។[176]

សរុបមក ស៊ីអេអូ យល់ឃើញថា ចំណុចខ្វះខាតរបស់ IFC ក្នុងការត្រួតពិនិត្យធនាគារ ABBank បានបណ្តាលឱ្យខកខានឱកាសជាច្រើន ដើម្បីមានឥទ្ធិពលជាវិជ្ជមានលើការរៀបចំរចនា អភិវឌ្ឍ និងចុងក្រោយអនុវត្តគម្រោងសេសានក្រោម២។ មិនអាចមានការធានាបានទេថា ការណែនាំ និងដំបូន្មានណាមួយដែលផ្តល់ដោយ IFC ដល់ ABBank ឬ EVNI នឹងត្រូវបានអនុម័ត ឬអនុវត្តដោយ អនុគម្រោង LS2 ក្រោយឆ្នាំ២០១៣។ ទោះជាយ៉ាងណាក៏ដោយ ការខកខានរបស់ IFC ក្នុងការតាមដានត្រួតពិនិត្យការប្តេជ្ញាចិត្តផ្លូវច្បាប់របស់ ABBank ឬការអនុវត្តផែនការ SEMS ឱ្យបានពេញលេញ បានលុបបំបាត់លទ្ធភាពនេះ។

---

[176] IFC បានផ្តល់ការណែនាំលើការកែលម្អនីតិវិធី SEMS និងការជួលអ្នកប្រឹក្សាខាងក្រៅដើម្បីកែលម្អ ESDDs ។ វាបានផ្តល់ការណែនាំលម្អិតតិចតួចលើបញ្ហាសំខាន់ៗដែលបានលើកឡើង ជាពិសេសក្នុងអំឡុងពេល ១០ ឆ្នាំដំបូងនៃការវិនិយោគ (សូមមើលផ្នែក 3.2.2 សម្រាប់ព័ត៌មានលម្អិត)។ ដូចបានកត់សម្គាល់ពីខាងដើម ក្នុងឆ្នាំ២០១៩ និង ២០២០ មានករណីជាក់លាក់របស់ IFC ដែលផ្តល់ដំបូន្មានលម្អិតលើការអនុវត្តស្តង់ដារសមិទ្ធិកម្ម ប៉ុន្តែដោយសារការផ្លាស់ប្តូរបុគ្គលិកញឹកញាប់របស់អតិថិជន ដែលដឹងដល់ IFC ភាគច្រើននៃវគ្គបណ្តុះបណ្តាលនេះ លែងមានដំណើរការ បន្ទាប់ពីទីប្រឹក្សា E&S បានចាកចេញនៅឆ្នាំ២០២១ ជាមួយនឹងសមត្ថភាពស្ថាប័នតិចតួច សម្រាប់ការគ្រប់គ្រង E&S ដែលបានបង្កើតឡើងក្នុងរយៈពេលច្រើនជាង ១៣ ឆ្នាំបូកនៃការត្រួតពិនិត្យរបស់ IFC ។ (សូមមើលផ្នែក 3.2.2) ។

## 4. ការវាយតម្លៃរបស់ ស៊ីអេអូ ទៅលើគ្រោះថ្នាក់ដែលពាក់ព័ន្ធ

ស៊ីអេអូ រកឃើញថាមានគ្រោះថ្នាក់ទៅដល់ដើមបណ្តឹង ពាក់ព័ន្ធទៅនឹងភាពមិនអនុលោមរបស់ IFC ក្នុងអំឡុងពេលនៃការត្រួតពិនិត្យ មុនការវិនិយោគ និងក្នុងការត្រួតពិនិត្យការប្តេជ្ញាចិត្តផ្លូវច្បាប់របស់ ABBank ដើម្បីអនុវត្តលក្ខខណ្ឌតម្រូវក្នុងគោលនយោបាយ SEMS របស់ខ្លួន ហើយជាលទ្ធផលអនុវត្តស្តង់ដារសមិទ្ធិកម្ម ចំពោះការវិនិយោគដែលមានស្រាប់របស់ខ្លួននៅក្នុង EVNI និង LS2 ។

ជាលទ្ធផលនៃកង្វះខាតទាំងនេះ IFC បានខកខានឱកាសជាច្រើនក្នុងការរួមចំណែកដល់ការជៀសវាង កាត់បន្ថយ និង/ឬដោះស្រាយបញ្ហាគ្រោះថ្នាក់ ដែលសហគមន៍បានជួបប្រទះ ដោយសារអនុគម្រោងដែលត្រូវបានបង្កើតឡើងដោយគ្មានការកំណត់ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់ E&S ទៅលើប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ឱ្យបានត្រឹមត្រូវ។

ការពិភាក្សាអំពីគ្រោះថ្នាក់បន្ទាប់នេះ ត្រូវបានរៀបចំឡើងទៅតាមក្រុមដើមបណ្តឹងទាំងបី។ ស៊ីអេអូ ទទួលស្គាល់ថា ស្ត្រី និងកុមារី អាចនឹងទទួលរងផលប៉ះពាល់ខុសៗគ្នា ដោយសារគ្រោះថ្នាក់ភាគច្រើនទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ ភស្តុតាងដែលប្រមូលបាន និងអាចរកបានក្នុងអំឡុងពេលស៊ើបអង្កេតនេះ មិនបានផ្តល់នូវព័ត៌មានជាក់លាក់ពាក់ព័ន្ធនឹងផលប៉ះពាល់ផ្សេងៗគ្នាតាមយេនឌ័រនោះទេ។

## ផែនទី៤៖ សហគមន៍ដែលរងផលប៉ះពាល់




ប្រភព៖ ក្រុមធនាគារពិភពលោក, IBRD, ខែកញ្ញា ឆ្នាំ ២០២៤

### 4.1 អ្នកភូមិក្បាលរមាស និងស្រែគរ ក្នុងតំបន់អាងទន្លេ (ដើមបណ្តឹងដែលបានតាំងទីលំនៅថ្មី និងដើមបណ្តឹងដែលមិនព្រមតាំងទីលំនៅថ្មី)

EIA នៃទំនប់វារីអគ្គិសនីសេសានក្រោម២ ឆ្នាំ២០០៨ និងសក្ខីកម្មដែលបានចែករំលែកជាមួយ ស៊ីអេអូ ក្នុងឆ្នាំ ២០២៣ សម្រាប់ការស៊ើបអង្កេតនេះ ពិពណ៌នាអំពីរបៀបដែលអ្នកអភិវឌ្ឍន៍ទំនប់ និងតំណាងរដ្ឋាភិបាលបានចូលរួមជាមួយប្រជាពលរដ្ឋនៅភូមិក្បាលរមាស និងភូមិស្រែគរ ក្នុងតំបន់ទឹកជំនន់នៃអាងស្តុកទឹក។ ការចូលរួមនេះរួមមានការស្ទង់មតិគ្រួសារភូមិ និងដីរបស់ពួកគេ ការផ្សព្វផ្សាយព័ត៌មានអំពីកញ្ចប់ការតាំងទីលំនៅថ្មី និងការលើកទឹកចិត្តប្រជាជនឱ្យផ្លាស់ទីទៅកន្លែងតាំងលំនៅថ្មី។ ព័ត៌មានដែល ស៊ីអេអូ បានទទួល បង្ហាញថា ការពិគ្រោះយោបល់សម្រាប់ EIA បានធ្វើឡើងនៅចន្លោះខែកុម្ភៈ និងខែមេសា ឆ្នាំ ២០០៨ មុនពេល IFC វិនិយោគនៅក្នុង ABBank ។ ក្នុងឆ្នាំ ២០១១ ក្រសួងបរិស្ថាន បានធ្វើការពិគ្រោះយោបល់ថ្នាក់ជាតិលើការអភិវឌ្ឍន៍ទំនប់ ហើយកិច្ចពិភាក្សាបន្ថែមទៀត បានកើតឡើងនៅចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥ នៅពេលដែលតំណាង LS2 និង

តំណាងរដ្ឋាភិបាល បានចុះទៅពិនិត្យមើលភូមិដែលត្រូវបានកំណត់ សម្រាប់ការតាំងទីលំនៅថ្មី ដើម្បីផ្តល់កញ្ចប់សំណង។ (សម្រាប់ព័ត៌មានលម្អិត សូមមើលឧបសម្ព័ន្ធ ក)។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍បានចែករំលែកថា ក្នុងអំឡុងពេលនៃការជួបប្រជុំទាំងនេះ ពួកគេមានអារម្មណ៍ថា ការសម្រេចចិត្តត្រូវបានធ្វើរួចហើយ និងខ្វះការយល់ដឹងយ៉ាងច្បាស់ថាតើសំណងដែលផ្តល់ជូន គឺគ្រប់គ្រាន់ដើម្បីទូទាត់សងការបាត់បង់ពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីរបស់ពួកគេ ដែរឬទេ។ អង្គការសង្គមស៊ីវិល និងអ្នកសិក្សា បានរិះគន់យ៉ាងខ្លាំងទៅលើដំណើរការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងនេះ ចំពោះការមិនយកចិត្តទុកដាក់ទៅលើក្តីកង្វល់ និងការជំទាស់ដែលសហគមន៍បានលើកឡើង ដែលច្រានចោលការអំពាវនាវឱ្យស្វែងរកការរចនាគម្រោងជំនួស ការផ្តល់សំណងមិនគ្រប់គ្រាន់ដល់អ្នករងផលប៉ះពាល់ និងការខកខានបង្កើតយន្តការបណ្តឹងសារទុក្ខប្រកបដោយប្រសិទ្ធភាព។[177]

មតិយោបល់ និងការរិះគន់ទាំងនេះពីសំណាក់សហគមន៍ និងអង្គការសង្គមស៊ីវិល ត្រូវបានបញ្ជាក់បន្ថែមដោយការសិក្សា និងរបាយការណ៍ឯករាជ្យ រួមទាំងរបាយការណ៍ឆ្នាំ២០១៦ របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ដែលសង្កត់ធ្ងន់ថា "តម្រូវការច្បាស់លាស់មួយសឱ្យមានការពិគ្រោះយោបល់គ្រប់គ្រាន់ ជាមួយសហគមន៍រងផលប៉ះពាល់។"[178] អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងអង្គការផ្សេងទៀតបានអះអាងថា ទាំងរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ ដែលជាកម្មសិទ្ធិមួយផ្នែករបស់ EVNI បានបរាជ័យក្នុងការពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ជាមួយសហគមន៍រងផលប៉ះពាល់ នៅមុន ឬអំឡុងពេលសាងសង់ទំនប់នេះ។[179] របាយការណ៍ឆ្នាំ ២០១៦ របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ បានបញ្ជាក់ថា អ្នកភូមិមួយចំនួនមិនបានយល់ច្បាស់ពីព័ត៌មានលម្អិតនៃកញ្ចប់សំណងដែលត្រូវបានផ្តល់ជូននោះទេ។[180] លើសពីនេះ ដោយសារកិច្ចប្រជុំភាគច្រើនផ្តោតលើការតាំងទីលំនៅថ្មី សហគមន៍មិនត្រូវបានជូនដំណឹងឱ្យបានលម្អិតអំពីហានិភ័យ និងផលប៉ះពាល់ E&S ផ្សេងទៀតរបស់គម្រោងទេ ដូចជាផលប៉ះពាល់ដែលរំពឹងទុក

[177]អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង, ២០២១," ទំព័រ៣ Earth Rights International: គេហទំព័រទំនប់វារីអគ្គិសនីសេសានក្រោម២ https://bit.ly/3ERVMWe; Earth Rights International, Pahna, "ការកែសម្រួលច្បាប់: ការវិភាគផ្លូវច្បាប់នៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលបានស្នើ" នៅលើដី ទឹក និងសិទ្ធិ ។ សំឡេងពីខ្ពង់រាបទីបេ ទៅកាន់ដីសណ្តទន្លេមេគង្គ ១៤៣–១៤៤,https://bit.ly/3S3ClN3; Baird, ឧត្តមានុវត្តក្នុងការទូទាត់សំណង និងការតាំងទីលំនៅថ្មីសម្រាប់ទំនប់ធំៗ, ១១៦–១១៧, https://bit.ly/3gdRHl8 ។

[178] អង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" A/HRC/33/62 (ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ ២០១៦) វគ្គ១៧, https://bit.ly/4bmhfmS។

[179] អង្គការឃ្លាំមើលសិទ្ធិមនុស្ស " ឥទ្ធិពលគម្រោង, ឆ្នាំ២០២១"។

[180] អង្គការសហប្រជាជាតិ, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៅកម្ពុជា, (២០១៦), កថាខណ្ឌ១៧។

លើផលផល និងលំហូរទឹក ជាដើម។[181]

ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការបង្ហាញព័ត៌មាន និងការដោះស្រាយបណ្តឹងសារទុក្ខ គឺជាទិដ្ឋភាពសំខាន់នៃការអភិវឌ្ឍគម្រោង និងជាចំណុចស្នូល នៃអភិក្រមរបស់ IFC ។ សមាសធាតុទាំងនេះជួយធានាថា ហានិភ័យ និងផលប៉ះពាល់គម្រោង ត្រូវបានជៀសវាង និងកាត់បន្ថយ ហើយផលប៉ះពាល់ដែលនៅសេសសល់ ត្រូវបានដោះស្រាយ ដូចបានតម្រូវដោយ PS១។ ពួកវាក៏ជាការការពារដ៏សំខាន់ផងដែរ ដើម្បីផ្តល់ឱ្យអ្នករងផលប៉ះពាល់នូវចំណេះដឹង និងការយល់ដឹងអំពីរបៀបដែលគម្រោងមួយអាចប៉ះពាល់ដល់ពួកគេ និងផ្តល់ឱ្យពួកគេនូវទីភ្នាក់ងារសម្រាប់វិធានការកាត់បន្ថយដែលត្រូវការ។

ស៊ីអេអូ កត់សម្គាល់បន្ថែមទៀតថា ដើមបណ្តឹងពីក្បាលរមាសចាស់ កំណត់អត្តសញ្ញាណខ្លួនថាជាជនជាតិដើមភាគតិចព្នង ដែលត្រូវបានទទួលស្គាល់ជាជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ហើយក៏បំពេញតាមលក្ខខណ្ឌនិយមន័យ នៃស្តង់ដារសមិទ្ធិកម្ម ៧ (ជនជាតិដើមភាគតិច) របស់ IFC ផងដែរ។ សមាជិកនៃភូមិស្រែគរចាស់ កំណត់អត្តសញ្ញាណខ្លួនថាជាសមាជិកនៃជនជាតិភាគតិចឡាវរបស់កម្ពុជា និងបានបំពេញតាមលក្ខណៈមួយចំនួននៃជនជាតិដើមភាគតិច នៅក្នុងPS៧។[182]

ការតវ៉ានានានៅឆ្នាំ ២០១៤-២០១៥ និងបណ្តឹងជាសាធារណៈពីជនជាតិដើមភាគតិច ជុំវិញទីតាំង LS2 បានអំពាវនាវឱ្យផ្អាកគម្រោងនេះ ហើយបានសង្កត់ធ្ងន់លើទំនាក់ទំនងដ៏រឹងមាំរវាងវប្បធម៌ និងដីរបស់ពួកគេ ព្រមទាំង

---

[181] Share Worrell et al ។ មិនមានព័ត៌មានគ្រប់គ្រាន់អំពីទំនប់៖ របាយការណ៍ ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣; Dene-Hern Chen et al., អ្នកភូមិនៅគ្មានព័ត៌មានអំពីទំនប់វារីអគ្គិសនីសេសានក្រោម, ខេមបូឌា ដេលី, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៣; Bridget Di Certo et al., អ្នកភូមិសោកស្តាយព័ត៌មានអំពីគម្រោងទំនប់, ភ្នំពេញប៉ុស្តិ៍, ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១២; Phak Seangly et al., អ្នកភូមិនៅខ្វះទឹកពេលចាប់ផ្តើមទំនប់, ភ្នំពេញ ប៉ុស្តិ៍, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៤។

[182] កថាខណ្ឌ៥ និង ៦ នៃ PS៧ ឆ្នាំ២០០៦ បង្ហាញថា "៥. នៅក្នុងស្តង់ដារសមិទ្ធិកម្ម ពាក្យ "ជនជាតិដើមភាគតិច" ត្រូវបានប្រើក្នុងន័យទូទៅ ដើម្បីសំដៅទៅលើក្រុមសង្គម និងវប្បធម៌ផ្សេងគ្នា ដែលមានលក្ខណៈដូចខាងក្រោម នៅក្នុងកម្រិតផ្សេងៗគ្នា៖

- ការកំណត់អត្តសញ្ញាណខ្លួនឯងជាសមាជិកនៃក្រុមវប្បធម៌ជនជាតិដើមភាគតិចមានលក្ខណៈផ្សេងពីគេ និងការទទួលស្គាល់អត្តសញ្ញាណនេះដោយអ្នកដទៃ
- ការភ្ជាប់ទំនាក់ទំនងរួម ទៅនឹងទីជម្រកជាក់លាក់តាមភូមិសាស្ត្រ ឬទឹកដីដូនតាក្នុងតំបន់គម្រោង និងធនធានធម្មជាតិនៅក្នុងជម្រក និងទឹកដីទាំងនេះ
- វប្បធម៌ទំនៀមទម្លាប់ សេដ្ឋកិច្ច សង្គម ឬស្ថាប័ននយោបាយ ដែលដាច់ដោយឡែកពីសង្គម ឬវប្បធម៌ដែលមានឥទ្ធិពលគ្របដណ្តប់
- ភាសាជនជាតិដើមភាគតិច ជាញឹកញាប់ខុសពីភាសាផ្លូវការរបស់ប្រទេស ឬតំបន់។

៦. ការបញ្ជាក់ថាតើក្រុមណាមួយត្រូវបានចាត់ទុកថាជាជនជាតិដើមភាគតិចសម្រាប់គោលបំណងនៃស្តង់ដារសមិទ្ធិកម្មនេះអាចនឹងតម្រូវឱ្យមានការវិនិច្ឆ័យបច្ចេកទេស។"

សារៈសំខាន់នៃផ្នូរដូនតានៅក្នុងតំបន់ និងសិទ្ធិរបស់ពួកគេក្នុងនាមជាជនជាតិដើមភាគតិច។[183] អាងស្តុកទឹក LS2 បានជន់លិចភូមិដូនតាក្បាលរមាសចាស់ និងភូមិស្រែគរចាស់ទាំងស្រុង។[184] ផ្ទះ កន្លែងបញ្ចុះសព និងទីកន្លែងស័ក្តិសិទ្ធិរបស់ពួកគេ ត្រូវបានជន់លិច ហើយអាងស្តុកទឹកបានកាត់បន្ថយព្រំដែននៃព្រៃសហគមន៍របស់ពួកគេ ផងដែរ។ ការខ្វះខាតគម្រោងជនជាតិដើមភាគតិចរបស់អនុគម្រោងនេះ ដែលបានតម្រូវនៅក្នុង PS៧ មានន័យថាគ្មានការពិចារណាពិសេសណាមួយត្រូវបានធ្វើឡើងទាក់ទងនឹងកន្លែងសំខាន់ៗខាងវប្បធម៌ ដូចជា ផ្ទះអារក្ស និងទីកន្លែងបញ្ចុះសព ជាដើម។

ស៊ីអេអូ រកឃើញថា សហគមន៍ដែលមានទីតាំងនៅតំបន់អាងស្តុកទឹកដែលត្រូវបានរៀបចំផែនការនៅក្នុងអនុគម្រោង របស់ IFC ត្រូវបានរឹតត្បិតលើការទទួលបានព័ត៌មានគ្រប់គ្រាន់ និងការពិគ្រោះយោបល់គ្រប់គ្រាន់ ដោយសារតែការចូលរួមមិនគ្រប់គ្រាន់ពីអនុគម្រោងនេះ។ ការត្រួតពិនិត្យរបស់ IFC លើអនុគម្រោងដែលមានស្រាប់របស់ ABBank ដូចបានតម្រូវនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ អាចមានសក្តានុពលកាត់បន្ថយ និង/ឬដោះស្រាយបញ្ហាខ្វះខាតនៅក្នុងដំណើរការពិគ្រោះយោបល់ LS2 ។ IFC អាចបានគាំទ្រអតិថិជនបន្ត EVNI និងអនុគម្រោងសេសានក្រោម២ ជាមួយនឹងការណែនាំ និងបទពិសោធន៍របស់ខ្លួនទាក់ទងនឹងដំណើរការការចូលរួមរបស់ភាគីពាក់ព័ន្ធ នៅក្នុងស្ថានភាពស្មុគស្មាញបែបនេះ ដោយអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ PS១, PS៥, PS៦, PS៧ និង PS៨ ។ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ នៅពេលដែលការសាងសង់បានចាប់ផ្តើម ហើយម្តងទៀតពេញមួយឆ្នាំ២០១៨ នៅពេលដែលប្រតិបត្តិការបានចាប់ផ្តើម IFC មានឱកាសជាច្រើនលើកច្រើនដងក្នុងការជួយលើកកំពស់ដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធនៃអនុគម្រោង។ ប្រសិនបើ IFC បានធ្វើដូច្នេះ វាអាចជួយកាត់បន្ថយ ឬធ្វើឱ្យគ្រោះថ្នាក់មានកម្រិតអប្បបរមា ទៅលើសហគមន៍ទាំងនេះ ដែលបណ្តាលមកពីការចូលរួមរបស់ភាគីពាក់ព័ន្ធមិនគ្រប់គ្រាន់ ទាក់ទងនឹងការពិគ្រោះយោបល់ ការបង្ហាញព័ត៌មាន និងការទទួលបានយន្តការបណ្តឹងសារទុក្ខ។

---

[183] អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង, ឆ្នាំ២០២១" ដកស្រង់សេចក្តីថ្លែងការណ៍ជាច្រើនដែលបានផ្ញើទៅកាន់រដ្ឋសភា។ សេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍សហគមន៍៖ អ្នកភូមិជនជាតិភាគតិចព្នង នៅក្បាលរមាស និងភូមិឡាវ នៅភូមិស្រែគរ១ និងភូមិ២ ប្រកាសជាសាធារណៈ៖ "យើងបដិសេធមិនព្រមតាំងទីលំនៅថ្មីផ្តល់ដោយទំនប់វារីអគ្គិសនីសេសានក្រោម២" ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ សូមមើល៖ Cuddy, A., & Seangly, P., "អ្នកភូមិបដិសេធការផ្លាស់ទីលំនៅ" *ភ្នំពេញប៉ុស្តិ៍,* ថ្ងៃទី ២៩ ខែកញ្ញា ២០១៤ ។

[184] EIA, ទំព័រ ៧៨

**រូបភាពទី២៖ ផ្ទះអាររក្សជន់លិចនៅក្បាលរមាសចាស់**



(**ប្រភព៖** ក្រុមការងារត្រួតពិនិត្យភាពអនុលោម ស៊ីអេអូ)

## 4.2 អ្នកភូមិក្បាលរមាស និងស្រែគរចាស់ ដែលមិនព្រមតាំងទីលំនៅថ្មី

ពាក្យបណ្តឹងដែលបានដាក់ជូន ស៊ីអេអូ ក្នុងឆ្នាំ២០១៨ អះអាងថា ៥៩ គ្រួសារ នៅភូមិក្បាលរមាសចាស់ និង ៧៧ គ្រួសារ នៅស្រែគរចាស់ មិនព្រមផ្លាស់ទីលំនៅទៅកន្លែងតាំងទីលំនៅថ្មីរបស់ LS2 ទេ។[185] របាយការណ៍ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) ស្តីពី LS2 ដែលត្រូវបានប្រគល់ដោយក្រុមហ៊ុន China Huaneng Group និងត្រូវបានធ្វើឡើង និងបោះពុម្ពផ្សាយដោយ វិទ្យានស្ថានចក្ខុវិស័យអាស៊ី (AVI) ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ លើកឡើងថា ចំនួនខាងលើនេះបានធ្លាក់ចុះជាបន្តបន្ទាប់មកត្រឹម ៧៤ គ្រួសារ។[186]

គ្រួសារទាំងនេះមួយចំនួនបានចាកចេញពីផ្ទះរបស់ពួកគេ នៅពេលដែលកម្ពស់ទឹកកើនឡើង ដូច្នេះហើយបាន

[185] បណ្តឹងភូមិស្រែគរ និងភូមិក្បាលរមាស ខែមិថុនា ឆ្នាំ២០១៨។

[186] នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០ វិទ្យាស្ថានមួយដែលមានឈ្មោះថា វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) បានបោះពុម្ពផ្សាយរបាយការណ៍ស្តីពីទំនួលខុសត្រូវសង្គមសាជីវកម្ម (CSR) ស្តីពី LS2 ដែលរៀបចំដោយក្រុមហ៊ុន China Huaneng Group Co. Ltd. China Huaneng Group Co. Ltd ជាក្រុមហ៊ុនមេរបស់ Huaneng Lancang River Hydropower ដែលជាម្ចាស់តែមួយគត់របស់ក្រុមហ៊ុន Hydrolancang International Energy - ម្ចាស់ភាគហ៊ុនភាគច្រើននៃ LS2 ។ សូមមើល វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) របាយការណ៍និរន្តរភាព ឆ្នាំ២០២០ ។ ការវាយតម្លៃបឋមនៃសហគ្រាសកាន់កាប់ដោយរដ្ឋចិន នៅកម្ពុជា (ឆ្នាំ ២០២០), ៨, នៅ៖https://bit.ly/48lceeA; សូមមើលផងដែរ China Huaneng Group "របាយការណ៍និរន្តរភាព នៃសហគ្រាសចិននៅកម្ពុជាត្រូវបានចេញផ្សាយនៅទីក្រុងប៉េកាំង" *PR Newswire* (ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០២០) https://bit.ly/3YwQwkq ។

ផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត ដូចបានទទួលស្គាល់ដោយ CRP ឆ្នាំ២០១១ របស់ EVNI ដែលរាប់បញ្ចូលពួកគេក្នុងចំនោមមនុស្សរងផលប៉ះពាល់ពីគម្រោង។ [187] ពួកគេបានផ្លាស់ទីលំនៅដោយគ្មានអត្ថប្រយោជន៍ពីការតាំងទីលំនៅថ្មី ទៅកាន់តំបន់តូចៗនៅលើទីទួលមួយ នៅក្នុងដីដូនតាដែលនៅសល់របស់ពួកគេ នៅជិតតំបន់អាងស្តុកទឹកដែលទើបលិចទឹកថ្មីៗ[188] ដូច្នេះពួកគេអាចនៅតែបន្តរស់នៅជិតភូមិលិចទឹករបស់ពួកគេ។

កង្វះការពិគ្រោះយោបល់ដោយសេរី ជាមុន និងមានការជូនដំណឹង របស់សហគមន៍ជនជាតិដើមភាគតិចទាំងនេះ ក៏ដូចជាផលប៉ះពាល់នានាទៅលើការអនុវត្តវប្បធម៌ និងប្រពៃណីរបស់ពួកគេ ត្រូវបានរាយការណ៍យ៉ាងទូលំទូលាយ ដោយអ្នកសិក្សា អង្គការក្រៅរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ ចាប់តាំងពីឆ្នាំ២០០៩។[189] ពាក់ព័ន្ធនឹងពាក្យបណ្តឹង ស៊ីអេអូ គ្រោះថ្នាក់ចម្បងដែលគ្រួសារទាំងនេះជួបប្រទះ គឺទាក់ទងនឹងការព្រងើយកន្តើយរបស់គម្រោង LS2 ចំពោះបំណងប្រាថ្នារបស់ពួកគេក្នុងការតាំងលំនៅថ្មីនៅលើដីទំនៀមទម្លាប់ នៅក្បែរផ្ទះចាស់របស់ពួកគេ ឱ្យបានជិតបំផុតតាមដែលអាចធ្វើទៅបាន។ របាយការណ៍ឆ្នាំ ២០១៦ របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ បញ្ជាក់ថាអាជ្ញាធរមិនបានពិចារណាជម្រើសនេះទេ។[190]ធាតុចូល/មតិយោបល់របស់ IFC ទៅលើ CRP របស់អតិថិជនបន្ត អាចមានលទ្ធភាពស្រាយបញ្ហាកង្វះខាតនេះ ដោយទាមទារឱ្យមានការតម្រឹមតាម PS៥ ដែលធ្វើដូច្នេះកាត់បន្ថយហានិភ័យនៃគ្រោះថ្នាក់ដល់គ្រួសារទាំងនេះ។ លើសពីនេះ កង្វះការពិគ្រោះយោបល់ជាមួយសហគមន៍ទាំងនេះ ក៏បានដកហូតសិទ្ធិរបស់ពួកគេក្នុងការបញ្ចេញមតិលើជម្រើសផ្សេងទៀតចំពោះទំនប់ LS2 ផងដែរ មិនថាវាទាក់ទងនឹងការរចនា វិធានការកាត់បន្ថយ ទីតាំង ឬលទ្ធភាពនៃប្រភពថាមពលសក្តានុពលផ្សេងទៀតនោះទេ។

បន្ថែមពីលើគ្រោះថ្នាក់នេះ អ្នកភូមិដែលមិនព្រមផ្លាស់ទៅកន្លែងតាំងទីលំនៅថ្មីរបស់ LS2 បានជួបប្រទះផលប៉ះពាល់អវិជ្ជមានពីការរចនា និងការអភិវឌ្ឍរបស់អនុគម្រោង ដូចខាងក្រោម៖

---

[187] Earth Rights International, Pahna, ការកែសម្រួលច្បាប់៖ ការវិភាគផ្លូវច្បាប់នៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលបាន លើដី ទឹក សិទ្ធិ។ សំឡេងពីខ្ពង់រាបទីបេ ទៅកាន់ដីសណ្តទន្លេមេគង្គ, ទំព័រ ១៤៩–១៥០។ https://bit.ly/3S3ClN3 ។

[188] Sun Narin, "ផ្ទះដូនតារបស់យើងត្រូវបានលិចលង់"៖ ទំនប់កម្ពុជា លុបបំបាត់របៀបរស់នៅរបស់កុលសម្ព័ន្ធភ្នំ, VOA ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១៨ https://bit.ly/3RSgqLB ។

[189] បណ្តាញអង្គការមិនមែនរដ្ឋាភិបាលជនជាតិដើមភាគតិច វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា កតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ី "សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា ខែកុម្ភៈ ឆ្នាំ២០១០" របាយការណ៍ដាក់ជូនគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ (កិច្ចប្រជុំលើកទី៧៦ ឆ្នាំ២០១០) ទំព័រ ១៤. https://bit.ly/3T9uhMe; Baird, ឧត្តមានុវត្តក្នុងការទូទាត់សំណង និងការតាំងទីលំនៅថ្មីសម្រាប់ទំនប់ធំៗ, ១៣–១៥; Say Tola Sangeetha Amarthalingam "ប្រជាជនកម្ពុជាតស៊ូដើម្បីរក្សាអត្តសញ្ញាណរបស់ពួកគេ បន្ទាប់ពីត្រូវបានផ្លាស់ទីលំនៅដោយទំនប់វារីអគ្គិសនី" នៅក្នុង The Third Pole, ខែមិថុនា ២០២១។ https://bit.ly/3D6Gs73 និង John Reed and James Kynge "ទំបន់ក្រវ៉ាត់ និងផ្លូវ នៅប្រទេសកម្ពុជា បានជាប់ឈ្មោះជា "គ្រោះមហន្តរាយសម្រាប់សហគមន៍មូលដ្ឋាន" នៅក្នុង *Financial Times* ខែសីហា ឆ្នាំ២០២១។https://on.ft.com/3TpFU1e ។

[190] អង្គការសហប្រជាជាតិ, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៅកម្ពុជា, (២០១៦), កថាខណ្ឌ១៧។

### 4.2.1 ផលប៉ះពាល់សង្គមវប្បធម៌ និងផ្លូវចិត្ត

អ្នកភូមិបានចែករំលែកជាមួយ ស៊ីអេអូ ថាការជន់លិចដីពិសិដ្ឋ និងកន្លែងបញ្ចុះសពដូនតា បានប៉ះពាល់ដល់ជីវិតសហគមន៍ និតទីកន្លែងស័ក្តិសិទ្ធិរបស់ពួកគេ ហើយនាំឱ្យមានការថប់បារម្ភ ទុក្ខព្រួយ និងការភ័យខ្លាច ដោយសារតែការផ្លាស់ទីកន្លែងស័ក្តិសិទ្ធិក្នុងមូលដ្ឋាន។[191] អ្នកភូមិក្បាលរមាសចាស់ ក៏បានរាយការណ៍ថា ពួកគាត់នឹកដល់សកម្មភាពសង្គម និងពិធីប្រពៃណី ដែលធ្វើឡើងនៅតាមវាលស្រែដែលបានលិចនាពេលបច្ចុប្បន្នរបស់ពួកគេ។ លើសពីនេះ ដំណើរការផ្លាស់ប្តូរទីលំនៅ បាននាំឱ្យមានការបែកបាក់សហគមន៍ និងគ្រួសារ រវាងអ្នកភូមិដែលទទួលយកការតាំងទីលំនៅថ្មី និងអ្នកដែលបដិសេធ ធ្វើឱ្យប៉ះពាល់ដល់ភាពស្អិតរមួត និងអត្តសញ្ញាណវប្បធម៌របស់សហគមន៍។ ក្នុងអំឡុងពេលនៃដំណើរចុះពិនិត្យមូលដ្ឋានរបស់ខ្លួន ស៊ីអេអូ បានសង្កេតឃើញទំនាក់ទំនងយូរអង្វែងដែលសហគមន៍បានរក្សាជាមួយអតីតភូមិលិចទឹករបស់ពួកគេ ក៏ដូចជាក្តីសង្ឃឹមដ៏ខ្ជាប់ខ្ជួនរបស់ពួកគេក្នុងការស្តារឡើងវិញនូវអតីតសហគមន៍របស់ពួកគេ។

ស៊ីអេអូ រកឃើញថា គ្រួសារទាំងនេះត្រូវបានដកហូតសិទ្ធិក្រោម PS៥ ក្នុងការទទួលបាន "ជម្រើស ដែលអាចអនុវត្តបានតាមបច្ចេកទេស និងសេដ្ឋកិច្ច សម្រាប់ការតាំងទីលំនៅថ្មី ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ និងការវាយតម្លៃជម្រើសជំនួសផ្សេងទៀតនៃការតាំងលំនៅថ្មី"។[192] ម្យ៉ាងវិញទៀត ពួកគេបានជួបប្រទះនឹងគ្រោះថ្នាក់សេដ្ឋកិច្ច សង្គម និងផ្លូវចិត្តដោយផ្ទាល់ ពីភាពមិនប្រាកដប្រជានៃស្ថានភាពអតីតកាល បច្ចុប្បន្នកាល និងអនាគតរបស់ពួកគេ។ លើសពីនេះ មតិខុសគ្នាលើការផ្លាស់ទីលំនៅ ឬមិនផ្លាស់ទីលំនៅ បានបណ្តាលឱ្យមានការបែកបាក់សហគមន៍ និងទីបំផុតការបែកបាក់សហគមន៍ក្បាលរមាស និងស្រែគរ។

### 4.2.2 ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច

ក្រោយពេលបាត់បង់ភូមិលិចទឹករបស់ពួកគេ ទៅក្នុងគម្រោង LS2 សមាជិកសហគមន៍ក្បាលរមាសចាស់ ដែលមិនព្រមតាំងទីលំនៅថ្មី បានចូលរួមនៅក្នុងជម្លោះដ៏រ៉ាំរ៉ៃសម្រាប់ដីសហគមន៍ដែលនៅសេសសល់របស់ពួកគេ។

នៅឆ្នាំ២០១២ មុនពេលការសាងសង់ LS2 បានចាប់ផ្តើម អ្នកភូមិជនជាតិដើមភាគតិចពួងនៅក្បាលរមាសចាស់

---

[191] របាយការណ៍ស្រដៀងគ្នានេះអំពីបញ្ហាទាំងនេះនៅក្នុងភូមិក្បាលរមាស ក៏ត្រូវបានរាយការណ៍ដោយ Mahanty, Sango, Sopheak Chann និង Sopsophea Suong ។ (២០២៣) ជីវិតរំជួលចិត្តនៅទំនប់វារីអគ្គិសនីសេសានក្រោម២ របស់កម្ពុជា។ បរិស្ថាន និងការធ្វើផែនការបរិស្ថាន៖ ធម្មជាតិ និងលំហ។

[192] កំណត់សម្គាល់៥ ឆ្នាំ២០០៦, លទ្ធកម្មដី និងការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត, (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ០០៧), កថាខណ្ឌ G28។

បានដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពសហគមន៍ជនជាតិដើមភាគតិច (ICLT) សម្រាប់ទឹកដីរបស់ពួកគេ [193] ប៉ុន្តែដំណើរការនេះត្រូវបានបញ្ឈប់ ដោយសារការអភិវឌ្ឍទំនប់វារីអគ្គិសនី និងផែនការដែលពាក់ព័ន្ធក្នុងការតាំងទីកន្លែងភូមិឡើងវិញ។ នៅឆ្នាំ២០១៧ គ្រួសារចំនួន ៥៥ ដែលបដិសេធមិនផ្លាស់ប្តូរទីលំនៅទៅកន្លែងតាំងទីលំនៅថ្មី បានចាប់ផ្តើមដំណើរការដាក់ពាក្យសុំ ICLT ឡើងវិញ។ ពួកគេត្រូវបានទទួលស្គាល់ជាផ្លូវការ ថាជាអង្គភាពជនជាតិដើម ក្នុងឆ្នាំ២០១៩ ប៉ុន្តែពាក្យសុំ ICLT របស់ពួកគេនៅតែរង់ចាំដំណើរការ។ ដំណើរការនេះបានជាប់គាំង ដោយសារដីភាគច្រើននៅជុំវិញអាងស្តុកទឹក ដែលពួកគាត់កំពុងទាមទារនោះ ត្រូវបានផ្តល់ជាដីសម្បទានសេដ្ឋកិច្ចសម្រាប់អភិវឌ្ឍចម្ការឱ្យក្រុមហ៊ុនឯកជន។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានសម្តែងការព្រួយបារម្ភថា ដីរបស់ជនជាតិដើមភាគតិចនៅតែត្រូវបានបន្តផ្តល់ឱ្យប្រើប្រាស់ជាឯកជន នៅក្នុងប្រទេសកម្ពុជា ដោយមិនមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិច។[194]

### 4.2.3 ផលប៉ះពាល់សេដ្ឋកិច្ចលើការធ្វើកសិកម្ម និងនេសាទ

ទ្រព្យសម្បត្តិសម្ភាររបស់អ្នកភូមិក្បាលរមាសចាស់ និងស្រែគរចាស់ ដែលមិនព្រមតាំងទីលំនៅនោះ បានរងផលប៉ះពាល់ជាអវិជ្ជមាន ដោយទឹកជំនន់ភូមិរបស់ពួកគាត់។ ពួកគេត្រូវតែតាំងទីលំនៅថ្មីដោយខ្លួនឯង សាងសង់ផ្ទះថ្មីដោយគ្មានសំណង ឬជំនួយណាមួយឡើយ ហើយនៅតែមិនប្រាកដថា ពួកគេអាចស្នាក់នៅក្នុងទីតាំងបច្ចុប្បន្នរបស់ពួកគេ។ បន្ថែមពីលើការផ្លាស់ទីលំនៅរូបវន្តដែលមិនមានសំណង ពួកគេមិនបានទទួលសំណងជារបស់របរ/សេវា ឬជាសាច់ប្រាក់ ចំពោះការបាត់បង់ទ្រព្យសម្បត្តិផលិតភាព និង/ឬការស្តារមុខរបរចិញ្ចឹមជីវិតឡើងវិញ សម្រាប់ការផ្លាស់ទីលំនៅសេដ្ឋកិច្ច ដោយសារទឹកជំនន់នៃដីស្រែរបស់ពួកគេទេ។

ទាក់ទងនឹងផលប៉ះពាល់នេសាទ សមាជិកសហគមន៍ក្បាលរមាស និងស្រែគរចាស់បានប្រាប់ ស៊ីអេអូ ថា ពីរបីឆ្នាំបន្ទាប់ពីទ្វារទំនប់បិទ ស្តុកត្រី និងជលផលក្នុងស្រុក បានធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ចំណុចនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់មុខរបរចិញ្ចឹម ការនេសាទបែបប្រពៃណី និងទំនៀមទម្លាប់ធ្វើម្ហូបរបស់ពួកគេ។ ពួកគេបានពន្យល់ថា ត្រីភាគច្រើនដែលគេចាប់បាននាពេលនេះ មិនមែនជាប្រភេទធ្វើបំលាស់ទេ ប៉ុន្តែជាប្រភេទត្រីតូចៗដែលមានតម្លៃទាប។ (សម្រាប់ព័ត៌មានលម្អិត សូមមើលឧបសម្ព័ន្ធ ខ។ )

---

[193] អនុក្រឹត្យស្តីពីការផ្តល់ប័ណ្ណកម្មសិទ្ធិលើដីសហគមន៍ជនជាតិដើមភាគតិច ឆ្នាំ២០០៩ មានគោលបំណងបង្កើតគោលការណ៍ណែនាំសម្រាប់ការចុះបញ្ជីដីធ្លី និងផ្តល់សិទ្ធិកម្មសិទ្ធិដល់សហគមន៍ជនជាតិដើមភាគតិច និងសម្រាប់គោលបំណងកសិកម្ម។ ដំណើរការនេះពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណដំបូងនៃភូមិដែលស្វែងរកការចុះឈ្មោះ ICLT ជាអង្គភាពជនជាតិដើមភាគតិច បន្តដោយពាក្យសុំរបស់នីតិបុគ្គលសម្រាប់ ICLT ។

[194] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "ការបិទបញ្ចប់ការសង្កេតលើរបាយការណ៍តាមកាលកំណត់ទីពីររបស់កម្ពុជា" (២៧ មេសា ២០១៥), CCPR/C/KHM/CO/2, កថាខណ្ឌ ២៨,https://bit.ly/3L6Oq2Y ។

**រូបភាពទី៣៖ ភូមិស្រែគរចាស់**



(ប្រភព៖ ក្រុមការងារត្រួតពិនិត្យភាពអនុលោម ស៊ីអេអូ)

#### 4.2.4 *ការសងសឹកចំពោះការបដិសេធមិនផ្លាស់ប្តូរទីលំនៅ*

ដើមបណ្តឹងមកពីក្បាលរមាស និងស្រែគរចាស់ បានចោទថាមានគ្រោះថ្នាក់បន្ថែមទៀត ដោយសារក្រុមហ៊ុនវារីអគ្គិសនី និងរដ្ឋាភិបាល ប្រើសម្ពាធ គំរាមកំហែង និងសងសឹកមកលើអ្នកប្រឆាំងគម្រោង នៅចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០១៨។ អ្នកភូមិដែលមិនព្រមផ្លាស់ទីលំនៅ ត្រូវបានគេរាយការណ៍ថាបានជួបប្រទះនូវទម្រង់ នៃការបំភិតបំភ័យដូចខាងក្រោម ក្នុងគោលបំណងបង្ខិតបង្ខំពួកគេឱ្យផ្លាស់ទីទៅកន្លែងតាំងលំនៅថ្មី។

b. របៀបវាយតម្លៃបុគ្គលិក E&S ដែលចាំបាច់ក្នុងកម្រិតអប្បបរមា សម្រាប់ FI ដោយផ្អែកលើហានិភ័យ E&S នៃផលប័ត្រ និងចំណូល ព្រមទាំងសមត្ថភាពរបស់ FI ទាក់ទាញការចូលរួមពីបុគ្គលិក E&S ថ្មី។ ក្នុងករណីនេះ និងករណីផ្សេងទៀត ស៊ីអេអូ បានសង្កេតឃើញថា កង្វះខាតសមត្ថភាព E&S របស់អតិថិជន រមែងតែងជាបញ្ហាដែលកើតឡើងដដែលៗ។ IFC គួរបង្កើតឧបករណ៍ និងប៉ារ៉ាម៉ែត្រសម្រាប់បុគ្គលិក E&S របស់ខ្លួន ដើម្បីវាយតម្លៃតម្រូវការបុគ្គលិក E&S របស់អតិថិជនទាក់ទងនឹងផលប័ត្រហានិភ័យ E&S របស់អតិថិជន។

3. ធ្វើការពិនិត្យឡើងវិញនូវផលប័ត្រនៃការវិនិយោគ FI ដែលមានភាគហ៊ុនសកម្មរបស់ IFC ចាប់តាំងពីឆ្នាំ២០០៦ ដោយរួមបញ្ចូលកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ (ESAP ឬចំណុចផ្សេងទៀត) សម្រាប់អតិថិជនដើម្បីអនុវត្ត ESMS របស់ខ្លួន ទៅលើ "ឥណទាន និងការវិនិយោគដែលមានស្រាប់" និងធានាឱ្យមានការតាមដានត្រួតពិនិត្យគ្រប់គ្រាន់ទៅលើការប្តេជ្ញាចិត្តផ្លូវច្បាប់។

4. ធ្វើបច្ចុប្បន្នភាព ESRP របស់ខ្លួនដើម្បីផ្តល់ការណែនាំច្បាស់លាស់បន្ថែមទៀតដល់បុគ្គលិក E&S អំពីរបៀបរៀបចំរចនាសម្ព័ន្ធការវិនិយោគ ដើម្បីប្រើប្រាស់អានុភាពរបស់ IFC ឱ្យបានល្អបំផុត ក្នុងអំឡុងពេលវដ្តនៃការវិនិយោគ ដើម្បីធានាបាននូវភាពអនុលោមរបស់អតិថិជន ទៅតាមលក្ខខណ្ឌតម្រូវ E&S ។ ដូចដែលបានផ្តល់អនុសាសន៍នៅក្នុងសំណុំរឿងមុនៗ [229] ចំណុចនេះគប្បីរួមបញ្ចូលសេចក្តីណែនាំច្បាស់លាស់អំពីតម្រូវការក្នុងការភ្ជាប់ការប្តេជ្ញាចិត្ត E&S នៅក្នុង ESAP ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ ទៅនឹងព្រឹត្តិការណ៍សំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការទូទាត់ចំណាយដំបូង និងការទូទាត់ចំណាយជាបន្តបន្ទាប់ទៀត ដើម្បីធានាថា IFC មានអានុភាពគ្រប់គ្រាន់ដើម្បីទាមទារឱ្យបំពេញនូវលក្ខខណ្ឌទាំងនេះ។

## ជំហានបន្ទាប់

របាយការណ៍នេះ ដូចបានកំណត់កាលបរិច្ឆេទ ត្រូវបានពិនិត្យសម្រេចជាស្ថាពរ ដោយ ស៊ីអេអូ និងបានផ្ញើជូនគណៈគ្រប់គ្រង IFC និងក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ IFC ។ អនុលោមតាមគោលនយោបាយរបស់ស៊ីអេអូ

---

[229] សូមមើលរបាយការណ៍ស៊ើបអង្កេត ស៊ីអេអូ សម្រាប់មីយ៉ាន់ម៉ា៖ ក្រុមហ៊ុន Myanma Awba Group Ltd.-01,https://bit.ly/40TpKnL; ប្រទេសកេនយ៉ា៖ Bridge International Academies-01,https://bit.ly/4hW0OCb និងលីបេរីយ៉ា៖ Salala Rubber Corporation (SRC)-01/Margibi & Bong Counties,https://bit.ly/3CzAUnI។

IFC នឹងតម្រូវឱ្យបញ្ជូនរបាយការណ៍របស់ថ្នាក់គ្រប់គ្រង ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិដើម្បីពិចារណា ដែលក្នុងនោះនឹងរួមបញ្ចូលផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង (MAP) ក្នុងគោលបំណងដោះស្រាយគំហើញរបស់ ស៊ីអេអូ អំពីភាពមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ MAP រួមមានសកម្មភាពដោះស្រាយតាមពេលវេលាដែលគណៈគ្រប់គ្រងបានស្នើឡើង ។ របាយការណ៍គ្រប់គ្រង គប្បីដាក់បញ្ចូលផងដែរនូវការឆ្លើយតបប្រកបដោយហេតុផលចំពោះការរកឃើញ ឬអនុសាសន៍របស់ស៊ីអេអូ ដែល IFC/MIGA មិនអាចដោះស្រាយបាននៅក្នុង MAP ។ នៅពេលដែលក្រុមប្រឹក្សាភិបាលរបស់ IFC អនុម័ត MAP ស៊ីអេអូ នឹងបោះពុម្ពផ្សាយរបាយការណ៍ស៊ើបអង្កេតនេះ និងរបាយការណ៍គ្រប់គ្រងរបស់ IFC ។ ដូច្នេះ តួនាទីរបស់ស៊ីអេអូ គឺដើម្បីផ្ទៀងផ្ទាត់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសកម្មភាព ដូចមានចែងនៅក្នុង MAP តាមរយៈការត្រួតពិនិត្យតាមដានភាពអនុលោម ។

## ឧបសម្ព័ន្ធ កៈ សកម្មភាព និងព័ត៌មានកម្រិតអនុគម្រោង

ឧបសម្ព័ន្ធនេះសង្ខេបប្រភពព័ត៌មានស្តីពីសកម្មភាពអនុគម្រោងដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់តាមពាក្យបណ្តឹង។ ស៊ីអេអូ បានប្រមូលប្រភពព័ត៌មានទាំងនេះពីប្រភពសាធារណៈ និងកិច្ចសម្ភាសន៍ភាគីពាក់ព័ន្ធ។

### ១.ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សេសានក្រោម២

ក្នុងការរៀបចំសម្រាប់ LS2 អតិថិជន EVNI របស់ធនាគារ ABBank បានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងឆ្នាំ២០០៨ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជា ក្នុងខែមិថុនា ឆ្នាំ២០១០។

### ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការបង្ហាញព័ត៌មាន និងការដោះស្រាយបណ្តឹងសារទុក្ខ

EIA បានរាយការណ៍ថា "ប្រជាពលរដ្ឋប្រហែល ៣០០.០០០ នាក់ រស់នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោមនៃតំបន់គម្រោង" ត្រូវបានចាត់ទុកថារងផលប៉ះពាល់ដោយប្រយោលពីគម្រោងនេះ ខណៈដែលប្រជាពលរដ្ឋប្រមាណ ១.០៥២ គ្រួសារនឹងរងផលប៉ះពាល់ដោយផ្ទាល់។[230] នៅខែកុម្ភៈ ឆ្នាំ២០០៨ ការពិគ្រោះយោបល់ត្រូវបានធ្វើឡើង នៅក្នុងសហគមន៍ចំនួនប្រាំ ដែលគេរំពឹងថានឹងលិចទឹកទាំងស្រុង ឬដោយផ្នែក ដោយអាងស្តុកទឹក។[231]EIA បញ្ជាក់ថា សហគមន៍ទាំងប្រាំដែលបានពិគ្រោះយោបល់ ត្រូវបានជូនដំណឹងអំពីការអភិវឌ្ឍ ដែលបានគ្រោងទុករបស់ទំនប់នេះ និងតំបន់ទឹកជំនន់ដែលអាចកើតមាន និងផលប៉ះពាល់ ព្រមទាំងបានផ្តល់ព័ត៌មានលម្អិតអំពីសំណង ប្រាក់ឧបត្ថម្ភ និងការតាំងទីលំនៅថ្មី។ ការពិគ្រោះយោបល់មានអ្នកចូលរួមចំនួន ៥៨៧នាក់ ក្នុងនោះ ៨៥,១ភាគរយ មិនយល់ស្របនឹងគម្រោងនេះ។[232]

បន្ទាប់ពីកិច្ចប្រជុំទាំងនេះ EVNI បានអញ្ជើញគណៈប្រតិភូអាជ្ញាធរខេត្ត និងប្រធានសហគមន៍ ទៅកាន់ប្រទេសវៀតណាម ដើម្បីសង្កេតមើលតំបន់តាំងទីលំនៅថ្មីទូទៅ ហើយនៅក្នុងខែមេសា ឆ្នាំ២០០៨ ការស្ទង់មតិគ្រួសារ

---

[230] EIA, ទំព័រ ១២១ នាយកដ្ឋាន EIA នៃក្រសួងបរិស្ថាន ពិនិត្យមើល និងត្រួតពិនិត្យតាមដានគោលការណ៍ណែនាំ ក៏ដូចជាលក្ខខណ្ឌនៃសេចក្តីយោងរបស់ EIA ដែលឯកសារទាំងភ្ជាប់ជាមួយ EIA រួមមានលក្ខខណ្ឌតម្រូវទាក់ទងនឹងការចូលរួមរបស់សាធារណៈជន ដែលចាំបាច់ដើម្បីដាក់បញ្ចូល "មតិសាធារណៈចំពោះគម្រោងអភិវឌ្ឍន៍ និងការពិគ្រោះយោបល់" និងការពិគ្រោះយោបល់ជាពីរដំណាក់កាលដើម្បីចែករំលែកព័ត៌មានជាមួយ "ប្រជាជនរងផលប៉ះពាល់ទាំងអស់ និងអាជ្ញាធរមូលដ្ឋាន" និងទទួលបាន "មតិអំពីផលប៉ះពាល់គម្រោង (…) វិធីសាស្ត្រកាត់បន្ថយ"។ សេចក្តីណែនាំអំពីរបាយការណ៍ EIA របស់ក្រសួងបរិស្ថាន ការបកប្រែក្រៅផ្លូវការដោយនាយកដ្ឋាន EIA ភ្ជាប់ជាមួយ EIA ទំព័រ ៣១៦ ff., ទំព័រ ២-៦ និងលក្ខខណ្ឌនៃសេចក្តីយោងសម្រាប់ EIA ។

[231] យោងតាម EIA ការពិគ្រោះយោបល់ជាសាធារណៈលើកទីមួយបានធ្វើឡើងនៅថ្ងៃទី ១, ២, និង ៤ ខែកុម្ភៈ ឆ្នាំ ២០០៨ នៅក្នុងសហគមន៍រងផលប៉ះពាល់ចំនួនប្រាំ ស្ថិតនៅឃុំស្រែគរ តាឡាត់ និងក្បាលរមាស ក្នុងខេត្តស្ទឹងត្រែង ដែលត្រូវបានរំពឹងថានឹងលិចលង់ទាំងស្រុងដោយអាង។ ឃុំភ្លុក ដែលមានទីតាំងនៅខាងក្រោមទំនប់ដែលបានគ្រោងទុក ដែលនឹងត្រូវជន់លិចដោយផ្នែកខ្លះ ដោយអាងស្តុកទឹក និងឃុំស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី ដែលរំពឹងថានៅពេលនោះ នឹងលិចទឹកដោយផ្នែក ដោយអាងស្តុកទឹករបស់គម្រោង។ គោលបំណងនៃការពិគ្រោះយោបល់លើកដំបូងគឺផ្តល់ព័ត៌មានគម្រោងដល់សហគមន៍ និងពិភាក្សាអំពីបញ្ហាបរិស្ថានដែលអាចកើតមាន។ EIA, ៩៤, ១៣៣–៣៤។

[232] EIA ទំព័រ ១៣៤។

ត្រូវបានធ្វើឡើងនៅក្នុងសហគមន៍ចំនួន៤ ក្នុងចំណោមសហគមន៍ចំនួន ៥ ដែលតម្រូវឱ្យមានការតាំងទីលំនៅថ្មីដោយសារតែ LS2 ។[233] EIA រាយការណ៍ថា បន្ទាប់ពីកិច្ចប្រជុំទាំងនេះ "៩៤% (sic) ស្មើនឹង ១.១១២ នាក់ នៃអ្នករងផលប៉ះពាល់ចំនួន ១.៣១៨ នាក់" បានយល់ព្រមជាមួយនឹងគម្រោងនេះ។[234] បន្ថែមពីនេះ នៅខែឧសភា ឆ្នាំ២០០៨ លទ្ធផលនៃការសិក្សាលទ្ធភាពសាងសង់គម្រោង ត្រូវបានបង្ហាញដល់ប្រធាន ឬអនុប្រធានចំនួន ១០ រូប នៃសហគមន៍រងផលប៉ះពាល់ ព្រមទាំងតំណាងអង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ផងដែរ។[235]

ស៊ីអេអូ កត់សំគាល់ថា ទាំង EIA ឆ្នាំ២០០៨ និង CRP ឆ្នាំ២០១១ មិនបានដាក់បញ្ចូលអនុសាសន៍ស្នើឱ្យអ្នកអភិវឌ្ឍន៍ និងអ្នកប្រតិបត្តិទំនប់ អនុវត្តយន្តការបណ្តឹងសារទុក្ខ ជាការអនុវត្តស្តង់ដារល្អសម្រាប់គម្រោងអភិវឌ្ឍន៍។ ព័ត៌មានពីភាគីពាក់ព័ន្ធក្នុងតំបន់បញ្ជាក់ថា គម្រោងនេះមិនមានយន្តការបណ្តឹងសារទុក្ខទេ។

## ការផ្លាស់ទីលំនៅរូបវន្ត និងសេដ្ឋកិច្ច

EIA បានប៉ាន់ប្រមាណថា អាងស្តុកទឹក LS2 នឹងតម្រូវឱ្យមានការតាំងទីលំនៅថ្មីចំនួន ១.០៥៩ គ្រួសារ និងជន់លិចផ្ទៃដីប្រមាណ ៨៣ គីឡូម៉ែត្រការ៉េ នៃព្រៃសហគមន៍ និងសម្បទានព្រៃឈើរួមបញ្ចូលគ្នា និងដីកសិកម្មប្រហែល ១.២៩១ហិកតា។[236]

---

233 EIA ចង្អុលបង្ហាញ៖ (i) គណៈប្រតិភូ "រួមទាំងប្រធានអាជ្ញាធរខេត្ត ឬតំណាងឃុំ និងភូមិដែលរងផលប៉ះពាល់" ត្រូវបានអញ្ជើញដោយ EVNI ឱ្យទៅបំពេញទស្សនកិច្ចការងារទៅកាន់តំបន់តាំងទីលំនៅថ្មីធម្មតាមួយចំនួន នៅក្នុងប្រទេសវៀតណាម (ii) ក្របខ័ណ្ឌគោលនយោបាយស្តីពីសំណង ប្រាក់ឧបត្ថម្ភ និងការតាំងទីលំនៅថ្មីត្រូវបានរៀបចំ និងដាក់ជូនអាជ្ញាធរខេត្ត និង (iii) នៅក្នុងខែមេសា ឆ្នាំ២០០៨ "ការស្ទង់មតិមួយ ត្រូវបានធ្វើឡើងជាមួយនឹងប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងអស់ដោយសារគម្រោង ពីគ្រួសារមួយទៅគ្រួសារមួយ" នៅក្នុងភូមិចំនួន ៤ ក្នុងចំណោម ៥ ភូមិដែលបានរៀបពីខាងដើម។ EIA, ទំព័រ ១៣៥ ។

234 EIA, ទំព័រ ១៣៥។

235 ធលទ្ធផលនៃការសិក្សាលទ្ធភាពអភិវឌ្ឍគម្រោង ត្រូវបានបង្ហាញ នៅក្នុងកិច្ចប្រជុំជាសាធារណៈមួយ នៅក្រុងស្ទឹងត្រែង កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ ខេត្តស្ទឹងត្រែង ដែលរួមមានមន្ត្រីរដ្ឋាភិបាល ២៦នាក់ ប្រជាពលរដ្ឋ ៤នាក់មកពីក្រុមហ៊ុនសម្បទានដីនិងព្រៃឈើ អង្គការមិនមែនរដ្ឋាភិបាល ៥នាក់ និងប្រធាន ឬអនុប្រធាន ១០នាក់ មកពីសហគមន៍រងផលប៉ះពាល់។ យោងតាមរបាយការណ៍ EIA ប្រធាន និង/ឬអនុប្រធានសហគមន៍ មិនបានសួរសំណួរ ឬផ្តល់ធាតុចូលណាមួយក្នុងអំឡុងពេលពិគ្រោះយោបល់នេះទេ។ EIA, ១៣៥ និង ១៣៧ ។

236 EIA បង្ហាញថា "អាងស្តុកទឹក (នឹង) ជន់លិចផ្ទៃដី ៣៣៥ គីឡូម៉ែត្រក្រឡា នៅពេលដែលកម្រិតទឹកក្នុងអាងឡើងដល់ ៧៥ ម៉ែត្រ (តម្រូវឱ្យមានការតាំងទីលំនៅថ្មីចំនួន ១.០៥៩ គ្រួសារ)"។ EIA បញ្ជាក់ថា ភូមិចំនួនបីនឹងត្រូវលិចលង់ទាំងស្រុង ហើយភូមិចំនួនបីទៀតត្រូវជន់លិចដោយផ្នែក។ វាបញ្ជាក់បន្ថែម ផ្ទៃដី ២៩០ គីឡូម៉ែត្រក្រឡា នៃតំបន់ដែលបានកំណត់ទុកសម្រាប់អាងស្តុកទឹកត្រូវបានគ្របដណ្តប់ដោយព្រៃឈើ ហើយថា ៨៣ គីឡូម៉ែត្រក្រឡា (ប្រហែល ៣០ ភាគរយ) នៃព្រៃឈើដែលរងផលប៉ះពាល់ទាំងនេះស្ថិតនៅក្នុងដីសម្បទាន

ទាក់ទងនឹងការផ្លាស់ទីលំនៅរូបវ័ន្ត EIA បានកំណត់ថា:

- ភូមិស្រែគរ និងក្បាលរមាស (ដែលប្រជាពលរដ្ឋគឺជាដើមបណ្តឹងនៅក្នុងសំណុំរឿង ស៊ីអេអូ) នឹងក្លាយជាភូមិរងផលប៉ះពាល់ខ្លាំងជាងគេបំផុត ដែលក្នុងនោះ ១០០ ភាគរយ និង ៩៦ ភាគរយនៃគ្រួសារបាត់បង់ផ្ទះរៀងគ្នា។ គ្រួសារនៅភូមិតាឡាត និងភូមិផ្លុក ក៏នឹងរងផលប៉ះពាល់ដែរ។[237]
- ទីកន្លែងតាំងទីលំនៅថ្មីចំនួនពីរ គួរតែត្រូវបានជ្រើសរើសស្ថិតនៅក្នុងតំបន់មានផ្ទៃដី ៧.០៨៦ ហិចតា "យោងតាមការណែនាំរបស់អភិបាលខេត្ត និងសំណើរបស់សហគមន៍"។ ក្រុមហ៊ុនសេសានក្រោម២ នឹងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធទាំងអស់ រួមមានផ្លូវថ្នល់ សាលារៀន និងការផ្គត់ផ្គង់ទឹក។[238] EIA បានផ្តល់អនុសាសន៍ថា ទីកន្លែងតាំងលំនៅថ្មី "ឆ្លើយតបនឹងកម្រិតជីវភាពរស់នៅប្រហាក់ប្រហែល ឬប្រសើរជាងអ្វីដែលពួកគេមាននាពេលបច្ចុប្បន្ន" ហើយមិនមានផលប៉ះពាល់អវិជ្ជមានលើធនធានធម្មជាតិ និងសង្គម។
- ផែនការសកម្មភាពស្តីពីការដោះស្រាយផលប៉ះពាល់ (RAP) តម្រូវឱ្យមាន ហើយសកម្មភាពតាំងទីលំនៅថ្មីគួរតែត្រូវបានធ្វើឡើង ដោយមាន "ការពិភាក្សា" ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ពីគម្រោង។[239]

---

កសិកម្ម និង/ឬព្រៃឈើ។ EIA, ទំព័រ ៦៦ លើកឡើងថាតំបន់ព្រៃឈើគ្របដណ្តប់ ២៧៧ គីឡូម៉ែត្រក្រឡា។ EIA, ទំព័រ ១០១ លើកឡើងថាព្រៃឈើដែលរងផលប៉ះពាល់នៅក្នុងសម្បទានព្រៃឈើ គ្របដណ្តប់លើផ្ទៃដី ១០៤ គីឡូម៉ែត្រក្រឡា។ វាបានជូនដំណឹងបន្ថែមថា អាងស្តុកទឹកនេះ បានជន់លិចព្រៃសហគមន៍ Nak-Ta Karakan ចំនួន ២០៣ ហិកតា ដែលជាកម្មសិទ្ធិរបស់សហគមន៍ស្រែគរ១ និងស្រែគរ២។ ក្រៅពីតំបន់ព្រៃទាំងនេះ ផ្ទៃដី ២.៩៩០ ហិកតា ត្រូវបានគ្របដណ្តប់ដោយទឹក (ឧ. អាងទន្លេដែលមានស្រាប់) ១.២៩១ ហិកតា ដោយដីកសិកម្ម ២១៩ ហិកតា ដោយវាលស្មៅ ៤៨ ហិកតា ដោយដី និងថ្ម និង ៤៧ ហិចតាដោយដីស្មៅ។ EIA, ទំព័រ ស២, ១៦, ៧១, ៧៨។

[237] EIA, ទំព័រ ១០២។

[238] EIA, ទំព័រ ១៤២។

[239] EIA, ទំព័រ ១៤៨។ EIA បានផ្តល់ថវិកាចំនួន ៥៣,៨ លានដុល្លារអាមេរិកសម្រាប់សកម្មភាពតាំងទីលំនៅថ្មី។ EIA, ទំព័រ ៣១២។

## ផែនទី៥៖ ផែនទី EIA នៃតំបន់ដែលត្រូវជន់លិច ដោយអាងស្តុកទឹក ៧៥ ម៉ែត្រ amsl និងភូមិរងផលប៉ះពាល់




(ប្រភព៖ សេចក្តីព្រាង EIA ឆ្នាំ២០០៨)[240]

ទាក់ទងនឹងការបាត់បង់មុខរបរចិញ្ចឹមជីវិត EIA បានរាយការណ៍ និងស្នើឡើងថា៖

- ដោយសារទឹកជំនន់លិចដីកសិកម្ម គម្រោងនេះនឹងមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរលើផលិតកម្មស្រូវ ដែលត្រូវបានប៉ាន់ប្រមាណថានឹងបាត់បង់ស្រូវ ២.០០០-៣.០០០ តោន/ឆ្នាំ ក្នុងអំឡុងពេលនៃការសាងសង់ទំនប់ និងការតាំងទីលំនៅថ្មី។[241] "ក្រៅពីការបាត់បង់ផលិតកម្មស្រូវ គម្រោងនេះក៏នឹងប៉ះពាល់ដល់ដំណាំផ្សេងទៀត ដូចជា ពោត ចេក ស្វាយចន្ទី និងដើមឈើហូបផ្លែជាច្រើនប្រភេទ ដូចជា ដើមស្វាយ ដូង ល្ហុង ដើមទឹកដោះគោ ខ្នុរ ក្រូច អំពិល ។ល។"[242]

---

[240]ផែនទីនេះត្រូវបានផលិតដោយក្រុមទីប្រឹក្សា EIA ។ ព្រំដែន ពណ៌ ការកំណត់ឈ្មោះនានា និងព័ត៌មានផ្សេងទៀត ដែលបានបង្ហាញនៅលើផែនទីនេះមិនបញ្ជាក់ពីទស្សនៈណាមួយរបស់ក្រុមធនាគារពិភពលោក ទៅលើការវិនិច្ឆ័យលើស្ថានភាពផ្លូវច្បាប់នៃដែនដីណាមួយ ឬការយល់ព្រម ឬការទទួលយកព្រំដែនបែបនេះនោះទេ។

[241]EIA, ទំព័រ ១១២–១៣។

[242]EIA, ទំព័រ ១១៣។

- វិធានការកាត់បន្ថយផលប៉ះពាល់ គួរតែរួមបញ្ចូលការបំពេញទឹកក្នុងអាងស្តុកទឹក បន្ទាប់ពីការប្រមូលផលកសិកម្ម ក្នុងតំបន់ ដើម្បីកាត់បន្ថយការបាត់បង់ដំណាំ ការផ្តល់ដីកសិកម្មនៅតំបន់តាំងទីលំនៅថ្មី និងការផ្តល់សំណងដល់អ្នកភូមិដែលរងផលប៉ះពាល់សម្រាប់ការបាត់បង់ផលិតកម្មកសិកម្ម រួមជាមួយនឹងកម្មវិធីគាំទ្រកសិកម្ម រហូតដល់ពួកគេទទួលបានជីវភាពរស់នៅប្រកបដោយចីរភាព។[243]
- ចំពោះការបាត់បង់ធនធានជលផល ផែនការសំណងប្រចាំឆ្នាំគួរតែផ្អែកលើតម្លៃនៃត្រីបាត់បង់ សម្រាប់គ្រួសាររស់នៅតាមដងទន្លេស្រែពក និងទន្លេសេសាន ដែលនឹងត្រូវរងផលប៉ះពាល់។ ប្រហែល ៩៥ ភាគរយនៃការទទួលទានប្រូតេអ៊ីនប្រចាំថ្ងៃរបស់សហគមន៍នេះ បានមកពីប្រភពត្រីនេះ ហើយ EIA បានផ្តល់អនុសាសន៍ថា សំណងជាទម្រង់នៃការផ្តួចផ្តើមលើកកម្ពស់ជីវភាពរស់នៅ ដោយម្ចាស់គម្រោង គួរតែបន្តរហូតដល់ទទួលបានជោគជ័យ និងមាននិរន្តរភាព ដែលនឹងត្រូវវាយតម្លៃដោយអ្នកវាយតម្លៃឯករាជ្យ។

### *ផលប៉ះពាល់លើជីវចម្រុះ និងការបំលាស់ទីរបស់ត្រី*

អាងទន្លេមេគង្គមានអាកាសធាតុខ្យល់មូសុងត្រូពិច ជាមួយនឹងបរិមាណទឹកក្នុងទន្លេខ្ពស់ជាពិសេស នៅចុងរដូវវស្សា (ខែសីហា និងកញ្ញា) បន្ទាប់មកមានបរិមាណទឹកក៏ទាបខ្លាំង នៅចុងរដូវប្រាំង (ខែមីនា និងមេសា)។ ជួនកាលបរិមាណទឹកខ្ពស់ក្នុងទន្លេមេគង្គអាចលើសពី ៣០ ដងនៃកម្រិតបរិមាណទឹកទាប។ [244] ការផ្លាស់ប្តូរទីជម្រកដ៏សំខាន់នេះរវាងរដូវ គឺជាហេតុផលចម្បង ដែលបណ្តាលឱ្យត្រីជាច្រើនប្រភេទនៅក្នុងអាង យ៉ាងហោចណាស់មានការផ្លាស់ទីជម្រក។ ប្រភេទត្រីភាគច្រើន (ដែលគេស្គាល់ថាជា "ត្រីខ្មៅ") ធ្វើការផ្លាស់ទីក្នុងរយៈចម្ងាយខ្លី ទៅតាមតំបន់លិចទឹកតាមរដូវកាល ដូចជាវាលស្រែ ដីសើម និងអូរ និងតំបន់ដែលលិចទឹកជាអចិន្ត្រៃយ៍។[245] ទោះជាយ៉ាងណាក៏ដោយ ប្រភេទត្រីផ្លាស់ទីឆ្ងាយៗ ផ្សេងទៀត (ជាធម្មតា "ត្រីស") ធ្វើបំលាស់ទីកាន់តែឆ្ងាយ ដើម្បីពងកូន ឬរកចំណី ជួនកាលផ្លាស់ទី លើសពី ១.០០០ គីឡូម៉ែត្រ ក្នុងការធ្វើដំណើរតែម្តង។[246] ទាក់ទិននឹងករណីនេះ ត្រីជាច្រើនប្រភេទ បានធ្វើបំលាស់ទីជាទម្លាប់ទៅក្នុង និងចេញក្រៅទន្លេសេសាន និងស្រែពក ចេញពីទន្លេមេគង្គ តាម

---

[243] EIA, ១១៣។

[244] Peter Cunningham, "ការពង្រីកបណ្តាញសហការគ្រប់គ្រង ដើម្បីសង្គ្រោះមច្ឆាជាតិនៅទន្លេមេគង្គ" ផលចាប់ត្រីនៅទន្លេមេគង្គ និងវារីវប្បកម្ម លេខ ៣ (១៩៩៨), ៦–៧។

[245] Walter J. Rainboth ១៩៩៦។ ជលផលនៃអាងមេគង្គកម្ពុជា ទីក្រុងរ៉ូម៖ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ។

[246] Walter J. Rainboth, Chavalit Vidthayanon, និង Mai DInh Yen, ២០១២ មច្ឆាជាតិនៃប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គ ជាមួយនឹងបញ្ជីឈ្មោះប្រភេទត្រី និងរូបភាពផែនទី។ (Ann Arbor, MI: អត្ថបទបោះពុម្ពរបស់សាកលវិទ្យាល័យ មីឈីហ្គិន សារមន្ទីរសត្វវិទ្យា 2012), ២៩៣។

រដូវកាលផ្សេងៗគ្នា ក្នុងគោលបំណងរកចំណី និងពងកូន។[247] ប្រព័ន្ធទន្លេ 3S ត្រូវបានគេដឹងថាអាចចិញ្ចឹមត្រីយ៉ាងហោចណាស់ ២៤០ ប្រភេទ រួមទាំងប្រភេទត្រីដែលជិតផុតពូជ និងប្រឈមនឹងការផុតពូជធ្ងន់ធ្ងរ មួយចំនួនផងដែរ។[248]

នៅចន្លោះឆ្នាំ ១៩៩៥ ដល់ឆ្នាំ២០០៩ មុនពេលដែល IFC ធ្វើ ESDD របស់ខ្លួន ការសិក្សាបានកំណត់ទៅលើការធ្វើបំលាស់ទីត្រី និងប្រភេទត្រីដែលពាក់ព័ន្ធ រវាងប្រព័ន្ធទន្លេ 3S និងទន្លេមេគង្គ ដូចខាងក្រោម៖

1. ការផ្លាស់ទីត្រីប្រភេទតូចៗ (cyprinid) ភាគច្រើនជាត្រីរៀល (Henicorhynchus lobatus) និងត្រី Paralaubuca typus បង្កើតបានជាដុំជីវម៉ាស។ ពួកវាបំលាស់ទីតាមដងទន្លេជាមួយយ៉ាងហោចណាស់ត្រី ៣០ ប្រភេទផ្សេងទៀត ពីបឹងទន្លេសាបនៅភាគកណ្តាលនៃប្រទេសកម្ពុជា ទៅកាន់ទន្លេមេគង្គ ហើយបន្ទាប់មកឡើងតាមដងទន្លេមេគង្គរហូតដល់ទន្លេសេកុង សេសាន និងស្រែពក ឬបន្តពីទន្លេមេគង្គទៅកាន់ប្រទេសឡាវ និងប្រទេសថៃ។[249] ក្នុងអំឡុងពេលនៃការបំលាស់ទីច្រើន ពួកវាបង្កើតបានជាងពាក់កណ្តាលនៃជីវម៉ាសត្រីដែលនេសាទបាន នៅផ្នែកខ្លះនៃទន្លេមេគង្គ រួមទាំងទន្លេសាប ដែលផ្តល់ជាប្រភពអាហារចម្បងៗ សម្រាប់សត្វមំសាសីជាច្រើនទៀត រួមមានត្រីធំៗ សត្វស្លាប សត្វល្មូន និងផ្សោតអ៊ីរ៉ាវ៉ាឌី។ ពួកវាត្រូវបានគេចាត់ទុកថាជាប្រភេទត្រីមូលដ្ឋាន ព្រោះវាពួកវាបម្រើមុខងារប្រព័ន្ធអេកូឡូស៊ីដ៏សំខាន់។[250]
2. ត្រីគល់រាំងខ្នាតមធ្យម (ត្រីមានស្រកា)[251] ធ្វើបំលាស់ទី រវាងទន្លេសេកុង សេសាន និងទន្លេស្រែពក និងទន្លេ

---

[247]E. Baran, S. Saray, SJ Teoh, និង TC Tran, "ត្រី និងជលផលក្នុងអាងទន្លេសេសាន សេកុង និងស្រែពក (តំបន់ទឹកទន្លេមេគង្គ)" *ស្តីពីការបង្កើនប្រសិទ្ធភាពការគ្រប់គ្រងល្បាក់ ឬប្រព័ន្ធអាងស្តុកទឹកនៅកម្រិតតំបន់មានប្រភពទឹក*, (ហាណូយ ប្រទេសវៀតណាម៖ ICEM, ២០១៤), www.optimisingcascades.org ។

[248] Tyson R. Roberts និង Ian G. Baird "ការនេសាទបែបប្រពៃណី និងបរិស្ថានវិទ្យានៅទន្លេមេគង្គ នៅទឹកធ្លាក់ Khone នៅភាគខាងត្បូងប្រទេសឡាវ"។ ព្រឹត្តិបត្រប្រវត្តិធម្មជាតិនៃសង្គមសៀម ៤៣ (១៩៩៥): ២១៩–២៦២; Ian G. Baird, Mark S. Flaherty, និង Bounpheng Phylavanh, "ចង្វាក់ទឹកទន្លេ៖ ដំណាក់កាលនៃចន្ទគតិ និងការផ្លាស់ទីនៃត្រីប៉ាសេអ៊ី នៅទន្លេមេគង្គ," ព្រឹត្តិបត្រប្រវត្តិធម្មជាតិនៃសង្គមសៀម លេខ ៥១ លេខ ១ (២០០៣), ៥–៣៦ ។

[249] Roberts and Baird, "ការនេសាទបែបប្រពៃណី និងបរិស្ថានវិទ្យា"; Baird, Flaherty, និង Phylavanh, "ចង្វាក់នៃទឹកទន្លេ ;Baird និង Meach, "ការត្រួតពិនិត្យតាមដានជលផលទន្លេសេសានក្នុងខេត្តរតនគិរី"; Baird, ឧត្តមានុវត្តក្នុងការទូទាត់សំណង និងការតាំងទីលំនៅថ្មី សម្រាប់ទំនប់ធំៗ; Ian G.Baird និង Bruce Shoemaker "ប្រជាជន ជីវភាពរស់នៅ និងការអភិវឌ្ឍន៍ក្នុងអាងទន្លេសេកុង នៃប្រទេសឡាវ" (បាងកក៖ សារព័ត៌មានឈូកស ២០០៨)។

[250] Roberts និង Baird, "ការនេសាទបែបប្រពៃណី និងបរិស្ថានវិទ្យា"។

[251] ប្រភេទត្រីនេះរួមមាន ត្រីប៉ាសេអ៊ីដ៏ល្បីល្បាញ ជាប្រភេទត្រីមានតម្លៃខ្ពស់នៅក្នុងប្រទេសកម្ពុជា ហើយពីមុនពេលខ្លះត្រូវបានផ្តល់ជូនជាអំណោយពិសេសសម្រាប់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដោយសារត្រីប្រភេទនេះមិនត្រូវបានរកឃើញនៅក្នុងតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា ក្រៅពីភាគឦសាន។ ប្រភេទត្រីផ្សេងទៀតដែលធ្វើបំលាស់ទីផងម្រកស្រដៀងនេះ រួមមានត្រីប៉ាវ៉ា ត្រីប៉ាវ៉ាមុខពីរ ត្រីឆ្កែង ត្រីឆ្កិត ត្រីផ្កាគរ និងត្រី *Gyrinocheilus pennocki* ។

មេគង្គភាគឦសាននៃប្រទេសកម្ពុជា ភាគខាងត្បូងឡាវ និងភាគឦសានប្រទេសថៃ។[252]

3. ប្រភេទត្រីប្រាខ្នាតធំ និងមធ្យម[253] ធ្វើបំលាស់ទីតាមដងទន្លេ នៅចន្លោះខែមេសា និងកក្កដា។ កូនញាស់តូចៗរបស់វាត្រូវបានគេជឿថាអណ្តែតតាមទឹកនៅខាងលើកម្ពស់នៃរដូវទឹកឡើង បន្ទាប់ពីត្រីនេះបានពងរួច។ [254] ឥឡូវនេះពួកវាជារឿងធម្មតានៅក្នុងទន្លេមេគង្គ ជាងអាង 3S ប៉ុន្តែពីមុនត្រូវបានគេកត់ត្រាថាជាញឹកញាប់វាបានបំលាស់ទីឡើងទៅទន្លេសេកុង សេសាន និងទន្លេស្រែពក។[255]

ការសិក្សាជាច្រើនដែលបានធ្វើឡើងនៅចន្លោះឆ្នាំ២០០៤ ដល់ឆ្នាំ២០១២ បានចងក្រងឯកសារអំពីផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជនរស់នៅតាមដងទន្លេសេសាន និងទន្លេស្រែពក និងដៃទន្លេរបស់ទាំងពីរ ដោយសារឥទ្ធិពលនៃការអភិវឌ្ឍទំនប់ទៅលើលទ្ធភាពទទួលបានត្រីដែលពួកគេទទួលទាន និងលក់។[256]

EIA ឆ្នាំ២០០៨ ដែលបង្កើតឡើងដោយ EVNI បានកំណត់ថា គម្រោងវារីអគ្គិសនី LS2 នឹងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ត្រី និងជលផលនៅក្នុងទន្លេសេសាន ទន្លេមេគង្គក្រោមនៃទំនប់វារីអគ្គិសនី ដីសណ្តទន្លេមេគង្គ និងបឹងទន្លេសាប។ EIA បានប៉ាន់ប្រមាណថា ៦.៤៦៩ គ្រួសារនឹងរងផលប៉ះពាល់ ដោយសារការផ្លាស់ប្តូរជលសាស្ត្រ និងបណ្តាលឱ្យមានការរំខានដល់គំរូនៃការធ្វើបំលាស់ទីរបស់ត្រី។ ពាក់ព័ន្ធនឹងការចោទប្រកាន់ផ្សេងៗនៅក្នុងសំណុំរឿងនេះ វាបានកំណត់ពីផលប៉ះពាល់ជាក់លាក់មួយចំនួន ដូចមានសង្ខេបខាងក្រោម។

*ផលប៉ះពាល់លើការធ្វើបំលាស់ទីជម្រករបស់ត្រី*

---

[252] Terry J. Warren, Greg C. Chapman, និង Douangkham Singhanouvong។ "ការធ្វើបំលាស់ទីជម្រកនៅរដូវប្រាំងខ្សែទឹកខាងលើនៃប្រភេទត្រីសំខាន់ៗមួយចំនួន នៅក្នុងទន្លេមេគង្គក្រោម នៅប្រទេសឡាវ"។ វិទ្យាសាស្ត្រជលផលនៅអាស៊ី ១១ (១៩៩៨), ២៣៩–៥១; Ian G. Baird និង Mark S. Flaherty, "លើសពីព្រំដែនប្រទេសៈ ត្រីគល់រាំងទំហំមធ្យផ្លាស់ទីជម្រកនៅទន្លេមេគង្គដ៏សំខាន់ (Cyprinidae) និងការនេសាទនៅឡាវ និងកម្ពុជា" វិទ្យាសាស្ត្រជលផលនៅអាស៊ី ១៧, លេខ ៣–៤ (២០០៤), ២៧៩–៩៨; Baird និង Meach, "ការត្រួតពិនិត្យតាមដានជលផលទន្លេសេសានក្នុងខេត្តរតនគិរី"; Baird, "ឧត្តមានុវត្តក្នុងការទូទាត់សំណង និងការតាំងទីលំនៅថ្មីសម្រាប់ទំនប់ធំៗ"; Baird និង Bruce Shoemaker "ប្រជាជន ជីវភាពរស់នៅ និងការអភិវឌ្ឍ"។

[253] ដូចជាត្រីកែ ត្រីពោ ត្រីប្រា ត្រីបឹងឡាវ, ត្រី Pangasius bocourti, ត្រី Pangasius macronema និងប្រភេទត្រី pangasid ដែលមានសក្តានុពលផ្សេងទៀត។

[254] Ian G. Baird, Mark S. Flaherty, និង Bounpheng Phylavanh, "ការផ្លាស់ទីរបស់ត្រីរាជនៅទន្លេមេគង្គ និងការនេសាទនៅតំបន់ទឹកធ្លាក់ Khone Falls នៅភាគខាងត្បូងប្រទេសឡាវ, *ប្រវត្តិធម្មជាតិនៃសង្គមសៀម* ៥២, លេខ ១ (២០០៤), ៨១–១០៩; Ian G. Baird, Zeb Hogan, Bounpheng Phylavanh និង Peter Moyle. "នេសាទសមូហភាពសម្រាប់ត្រីប្រាដែលបំលាស់ទីនៅទន្លេមេគង្គ" វិទ្យាសាស្ត្រជលផលអាស៊ាន ១៤ (២០០១), ២៥–៤១; Zeb Hogan, Ian G. Baird, Richard Radtke, និង M. Jake Vander Zanden, "ការផ្លាស់ទីចម្ងាយឆ្ងាយ និងដែនជម្រកក្នុងទឹករបស់ត្រីប៉ុងឡាវ" អត្ថបទអំពីជីវវិទ្យាត្រី ៧១ (២០០៧), ៨១៨–៣២ ។

[255] Baird និង Meach, "ការត្រួតពិនិត្យជលផលទន្លេសេសានក្នុងខេត្តរតនគិរី"; Baird, "ឧត្តមានុវត្តក្នុងការទូទាត់សំណង និងការដោះស្រាយផលប៉ះពាល់សម្រាប់ទំនប់ធំៗ"; Baird និង Bruce Shoemaker "ប្រជាជន ជីវភាពរស់នៅ និងការអភិវឌ្ឍ"។

[256] សូមមើល Baird and Meach និងផ្សេងទៀត "ការត្រួតពិនិត្យតាមដានជលផលទន្លេសេសានក្នុងខេត្តរតនគិរី"; Baran et al., "ត្រី និងជលផលក្នុងអាងទន្លេសេសាន សេកុង និងស្រែពក"; Ziv et al. ។ "ការដោះដូរ ជីវចម្រុះត្រី សន្តិសុខស្បៀង និងវារីអគ្គិសនី"។

EIA បានកំណត់ថា ទំនប់ LS2 នឹងបិទផ្លូវធ្វើបំលាស់ទីជម្រកប្រហែល ៦៦ ភាគរយនៃប្រភេទត្រី ជាពិសេសប្រភេទត្រីដែលបំលាស់ទីជម្រក។[257] វាបានរកឃើញថា ផលប៉ះពាល់ត្រួតបន្ថែមគ្នាលើជីវចម្រុះ និងធនធានធម្មជាតិ ដែលបង្កឡើងដោយទំនប់វារីអគ្គិសនីនៅតំបន់អាងទន្លេសេសាន និងស្រែពក នឹងប៉ះពាល់មិនត្រឹមតែការធ្វើបំលាស់ទីជម្រករបស់ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់បរិមាណ និងគុណភាពទឹក មនុស្ស សត្វព្រៃ និងត្រី និងធនធានជលផល ផងដែរ។

ពាក់ព័ន្ធនឹងវិធីសាស្ត្រ និងលទ្ធផល EIA ដាក់បញ្ចូលការសិក្សាផ្នែកជលផល ដែលបានជ្រើសរើសអ្នកនេសាទចំនួន ១៨ នាក់ នៅទន្លេសេសាន និងស្រែពក ដើម្បីកត់ត្រាក្នុងសៀវភៅកំណត់ហេតុ និងធ្វើការស្ទង់មតិអំពីការនេសាទត្រីរបស់ពួកគេ នៅក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០០៨។[258] ចាប់ពីខែកុម្ភៈ ដល់ខែឧសភា ប្រជាពលរដ្ឋប្រមាណ ២២០នាក់ និង ១៤០គ្រួសារ មកពីភូមិចំនួន ១១ ស្ថិតនៅតាមដងទន្លេសេសាន និងស្រែពក ក្នុងខេត្តស្ទឹងត្រែង ត្រូវបានធ្វើការស្ទង់មតិ និងសម្ភាស។ EIA បានកំណត់ប្រភេទត្រីដែលបានកត់ត្រាចំនួន ៩៩ ប្រភេទ ដោយប្រភេទដែលលេចធ្លោគឺប្រភេទត្រី Cypriniformes។[259] បរិមាណត្រីនេសាទបានសរុប នៅក្នុងទន្លេទាំងពីរ ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ២៤៤,១៤ តោន ក្នុងមួយឆ្នាំ សម្រាប់ ១.៥៣០ គ្រួសារ ដែលក្នុងនោះមាន ៩៥ ភាគរយជាគ្រួសារនេសាទ។

ទាក់ទងនឹងវិធានការកាត់បន្ថយផលប៉ះពាល់ EIA បានពិនិត្យលទ្ធភាពនៃការសាងសង់៖ (i) ផ្លូវត្រី (ii) មជ្ឈមណ្ឌលស្រាវជ្រាវជលផល ដើម្បីតាមដាន ផលិត និងលែងប្រភេទត្រីនៅក្នុងអាងស្តុកទឹក និង (iii) សំណងទៅលើការបាត់បង់ធនធានជលផលដល់ប្រជាពលរដ្ឋនៅតាមដងទន្លេសេសាន និងទន្លេស្រែពក។[260] ក្នុងចំណោមជម្រើសទាំងបី EIA មិនបានផ្តល់អនុសាសន៍ឱ្យបង្កើតច្រកផ្លូវត្រីទេ ដោយផ្អែកការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រកន្លងមក ដែលបង្ហាញពីភាពគ្មានប្រសិទ្ធភាពរបស់វា នៅក្នុងបណ្តាប្រទេសត្រូពិចដែលមានប្រភេទត្រីបំលាស់ទីជម្រកចម្រុះ។[261] សម្រាប់ប្រភេទត្រីមានតាមតំបន់ ជិតផុតពូជ ឬងាយរងគ្រោះចំនួនប្រាំប្រភេទដែលបានកត់សម្គាល់អត្តសញ្ញាណ[262] សំណើកាត់បន្ថយផលប៉ះពាល់ គឺបង្កើតឡើងវិញនូវចំនួនត្រីដូចគ្នា តាមរយៈកម្មវិធីប៉ះប៉ូវ។

---

[257] EIA, ទំព័រ ៩៩។

[258] EIA, ការសិក្សាជលផល, ទំព័រ ៣។ សៀវភៅកត់ត្រាកំណត់ហេតុ រួមមានព័ត៌មានស្តីពីការធ្វើបំលាស់ទីជម្រករបស់ត្រី ប្រភេទត្រី ធនធានជលផល ព្រៃលិចទឹក និងលក្ខណៈផ្សេងៗរបស់ត្រី ដូចជាចំនួនត្រី សកម្មភាពក្នុងវដ្តប្រាំង និងជម្រកនេសាទ ឬទីជម្រក។

[259] EIA, ការសិក្សាជលផល។

[260] EIA, ៩៩–១០០; EIA ស្នើឱ្យបណ្តាក់ទុនចំនួន ១,៨ លានដុល្លារជារៀងរាល់ឆ្នាំសម្រាប់កម្មវិធីគាំទ្រកសិកម្ម រយៈពេល ១០ ឆ្នាំសម្រាប់សកម្មភាពកាត់បន្ថយផលប៉ះពាល់។

[261] EIA, ការសិក្សាអំពីជលផល, ២៥ ។

[262] EIA បានកំណត់ប្រភេទត្រីដែលត្រាំត្រែង និងជិតផុតពូជ និងងាយរងគ្រោះចំនួនប្រាំប្រភេទដូចខាងក្រោម៖ Puntius partipentazona និង Probarbus jullieni (ត្រាំត្រែង); Osphronemus exodon និង Tenualosa thibaudeaui (ជិតផុតពូជ); និង Wallago leeri (ងាយរងគ្រោះ)។ EIA, ការសិក្សាអំពីជលផល, ២១–២២។

EIA មិនបានរួមបញ្ចូលទិន្នន័យមូលដ្ឋានសម្រាប់ជីវចម្រុះ ការវាយតម្លៃនៃទីជម្រកសំខាន់ៗ ឬការវិភាគលើសេវាប្រព័ន្ធអេកូឡូស៊ីទេ។ វារួមបញ្ចូលការសិក្សាដូចបានរៀបរាប់ខាងលើស្តីពីធនធានជលផល ដែលគោលបំណងសំខាន់គឺដើម្បីកំណត់ប្រភេទត្រីលេចធ្លោក្នុងស្រុក និងបរិមាណត្រីនេសាទបានដើម្បីកំណត់វិធានការសំណង។[263] ការសិក្សាផ្នែកជលផលបានកំណត់អត្តសញ្ញាណប្រភេទត្រីចំនួន ១០៦ នៅក្នុងតំបន់គម្រោង ដែលក្នុងនោះ ៣២ ភាគរយជាប្រភេទត្រីបំលាស់ទីជម្រក ប៉ុន្តែវាមិនរាប់បញ្ចូលការវាយតម្លៃអំពីជម្រក ឬការចាត់ថ្នាក់របស់ពួកវានៅក្រោមបញ្ជីក្រហមនៃប្រភេទរងការគំរាមកំហែងរបស់ IUCN នោះទេ។[264]

ការវិភាគទៅលើមធ្យោបាយជំនួសផ្សេងទៀត បានរួមបញ្ចូលទីតាំងផ្សេងគ្នាចំនួនពីរ ប៉ុន្តែផលប៉ះពាល់ជាក់លាក់លើធនធានជលផលមិនត្រូវបានលើកឡើងទេ។ ខណៈពេលដែល EIA ទទួលស្គាល់ថា ផលប៉ះពាល់នៃទំនប់នេះអាចរីករាលដាលពាសពេញប្រព័ន្ធទន្លេមេគង្គ ការសិក្សាជលផលត្រូវបានធ្វើឡើងតែនៅក្នុងសហគមន៍ចំនួនបី

---

[263] គោលបំណងគឺដើម្បីកំណត់ប្រភេទត្រីដែលលេចធ្លោ ដើម្បីសម្រេចថាតើប្រភេទណាដែលត្រូវសិក្សាបន្ថែម ដែលជាផ្នែកនៃកម្មវិធីពង្រឹងស្តុកត្រី ដើម្បីកែលម្អស្តុកត្រីនៅទន្លេសេសាន និងទន្លេស្រែពក។ ជាមួយគ្នានេះ ដើម្បីកំណត់ការនេសាទត្រីរបស់អ្នកនេសាទមូលដ្ឋាន ដើម្បីកំណត់វិធានការផ្តល់សំណង សិក្សាពីការធ្វើបំលាស់ទីជម្រករបស់ត្រីនៅទន្លេសេសាន និងទន្លេស្រែពក ផ្សាភ្ជាប់ជាមួយទន្លេមេគង្គ និងដើម្បីកំណត់ពីផលប៉ះពាល់នៃគម្រោងសេសាន២ HPP ទៅលើធនធានជលផលនៅទន្លេសេសាន និងទន្លេស្រែពក និងផលវិបាកនៅលើ ទន្លេមេគង្គក្រោម ទន្លេសាប និងចរន្តផលិតកម្មត្រីទឹកសាប នៅក្នុងប្រទេសកម្ពុជា និងការបំលាស់ទីជម្រកបឹងទន្លេសាប និងដើម្បីសិក្សាពីលទ្ធភាពបង្កើតផ្លូវត្រី។ EIA, ការសិក្សាអំពីជលផល, ទំព័រ.៣។

[264] ជាផ្នែកនៃដំណើរការវាយតម្លៃបរិស្ថានជាទូទៅ អតិថិជនគួរតែវាយតម្លៃប្រភេទ និងសារៈសំខាន់នៃជីវចម្រុះដែលមានវត្តមាន មិនថាកម្រិតហ្សែន ប្រភេទ ឬប្រព័ន្ធអេកូឡូស៊ីទេ ហើយពិចារណាពីផលប៉ះពាល់សក្តានុពលនៃសកម្មភាពទាក់ទងនឹងគម្រោងទៅលើវា។ ការវាយតម្លៃនៃភាពចម្រុះហ្សែន ពិនិត្យទៅលើហ្សែកង់ និងភាពចម្រុះនៃហ្សែន និង/ឬហ្សែនផ្សេងៗគ្នា។ ភាពចម្រុះនៃប្រភេទ មានន័យថាហ្សែកង់ និងភាពចម្រុះនៃប្រភេទផ្សេងៗគ្នា។ គម្រោងដែលទំនងជាមានផលប៉ះពាល់ធ្ងន់ធ្ងរលើជីវចម្រុះ គួរតែស្ថិតនៅក្រោមការវាយតម្លៃ និងការវិភាគលម្អិតបន្ថែមទៀត ដែលពិចារណាលើបរិបទរយៈពេលខ្លី រយៈពេលវែង និងបូកសរុបនៃផលប៉ះពាល់ទាំងនោះ រួមជាមួយនឹងការវាយតម្លៃផលប៉ះពាល់លើសេវាប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ។ ជាផ្នែកមួយនៃការពិចារណាលើផលប៉ះពាល់ទាំងនេះ អតិថិជនអាចត្រូវការពិគ្រោះជាមួយភាគីពាក់ព័ន្ធសំខាន់ៗ សម្រាប់គោលបំណងអនុវត្តស្តង់ដារ៦ រួមមានសហគមន៍ដែលអាចនឹងរងផលប៉ះពាល់ អាជ្ញាធរសាធារណៈ និងអ្នកជំនាញឯករាជ្យ។ នៅពេលដែលផលប៉ះពាល់ជីវចម្រុះសំខាន់ៗមានសក្តានុពលជាក់លាក់ ត្រូវបានកំណត់អត្តសញ្ញាណ តាមរយៈការវាយតម្លៃ និងការវិភាគ ពួកវាគួរតែត្រូវបានវិភាគបន្ថែមទៀតតាមរយៈការសិក្សាជាក់លាក់ ដែលធ្វើឡើងដោយអ្នកជំនាញមានគុណវុឌ្ឍិ និងបទពិសោធន៍ជ្រាលជ្រៅ ដោយប្រើកម្មវិធី និងឧបករណ៍គំរូស្តង់ដារ។ ក្នុងស្ថានភាពដែលមានការទទួលស្គាល់ថាជាបញ្ហាជីវចម្រុះសំខាន់ៗ ផែនការសកម្មភាពជីវចម្រុះគួរតែត្រូវបានរៀបចំដើម្បីកំណត់ និងដោះស្រាយបញ្ហាជីវចម្រុះក្នុងលក្ខណៈគ្រប់ជ្រុងជ្រោយ។ ផែនការបែបនេះគួរតែរួមបញ្ចូលការសិក្សាជាមូលដ្ឋាន និងការវាយតម្លៃផលប៉ះពាល់ ដែលត្រូវបានជូនដំណឹងដោយការរួមបញ្ចូលគ្នានៃអ្នកជំនាញអន្តរជាតិ និងអ្នកជំនាញក្នុងស្រុក ទៅលើតម្លៃជីវសាស្ត្រនៃតំបន់ដែលមិនសូវស្គាល់ (រួមទាំងការវាយតម្លៃលើតម្លៃនៃជីវចម្រុះចំពោះសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងប្រជាពលរដ្ឋដែលពឹងផ្អែកលើធនធានផ្សេងទៀត)។ តាមរយៈការសិក្សាទិន្នន័យមូលដ្ឋានទាំងនេះ អតិថិជនគួរតែកំណត់ និងទប់ស្កាត់ផលប៉ះពាល់មកលើបរិមាណនៃប្រភេទត្រីដែលត្រូវបានទទួលស្គាល់ថាជាប្រភេទត្រីជិតផុតពូជ ឬទទួលរងគ្រោះខ្លាំង (ស្របតាមបញ្ជីក្រហមរបស់ IUCN ឬបញ្ជីជាតិណាមួយដែលកំណត់ដោយរដ្ឋាភិបាលម្ចាស់ផ្ទះ)។ កំណត់សម្គាល់ការណែនាំ៦ ឆ្នាំ២០០៦ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព (ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៧), កថាខណ្ឌG៣–G៩, G២០, ឧបសម្ព័ន្ធ ក (ផែនការសកម្មភាពជីវចម្រុះ), ឯកសារយោង។

ស្ថិតនៅក្នុងអាងទឹកដែលត្រូវបានស្នើឡើង គឺ ស្រែគរ ក្បាលរមាស និងតាឡាត់ នៅខ្សែទឹកខាងលើនៃអាងស្តុកទឹក ប៉ុណ្ណោះ។[265]

## ផលប៉ះពាល់លើជលសាស្ត្រ

EIA បានកំណត់កត្តាជលសាស្ត្រចំនួនបីដែលគម្រោង LS2 អាចនឹងប៉ះពាល់ ដូចជា៖ ពេលវេលាទឹកជំនន់ រយៈពេលទឹកជំនន់ និងកម្រិតទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃមិនបានរួមបញ្ចូលការសិក្សាជាក់លាក់ដើម្បីកំណត់វិសាលភាពនៃផលប៉ះពាល់លើកត្តានីមួយៗនេះទេ។ ផ្ទុយទៅវិញ ការប្រែប្រួលនៃរបបទឹកដែលអាចនឹងកើតមានឡើង ត្រូវបានគណនាដោយការវាយតម្លៃលើការបញ្ចេញទឹក ពីចេញទន្លេសេសាន និងស្រែពកទៅកាន់ទន្លេមេគង្គ។[266] ជាលទ្ធផល EIA បានរាយការណ៍ថា អាចនឹងមានការប្រែប្រួល ១០ ភាគរយ នៃការបញ្ចេញទឹក ក្នុងអំឡុងពេលដ៏ខ្លីនៅពេលដែលអាងស្តុកមានទឹកពេញ បន្ទាប់មកការបញ្ចេញទឹកតាមខ្សែទឹកខាងក្រោមជាមធ្យម ត្រូវបានគេរំពឹងថានឹងត្រលប់មកកម្រិតធម្មតាវិញ។[267]

EIA បានផ្តល់អនុសាសន៍ឱ្យប្រតិបត្តិករទំនប់វារីអគ្គិសនីបញ្ចេញបរិមាណទឹកតាមខ្សែទឹកខាងក្រោមឱ្យបានគ្រប់គ្រាន់ ដើម្បីរក្សាប្រព័ន្ធអេកូឡូស៊ីទន្លេឱ្យមានសុខភាពល្អ និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានមកលើមនុស្ស ធនធានជលផល សត្វ និងរុក្ខជាតិ។[268] លើសពីនេះ EIA បានផ្តល់អនុសាសន៍ឱ្យដំឡើងប្រព័ន្ធជូនដំណឹងជាមុនដ៏រឹងមាំមួយ សម្រាប់លំហូរនៃការបញ្ចេញទឹកខ្ពស់បំផុតទៅខ្សែទឹកខាងក្រោម ក៏ដូចជាសំណងសម្រាប់សហគមន៍មូលដ្ឋានដើម្បីដោះស្រាយការរំខានណាមួយចំពោះរបបលំហូរនេះ។[269] គុណភាពទឹកក្នុងអំឡុងពេលប្រតិបត្តិការរបស់ទំនប់ ត្រូវបានរំពឹងថានឹងរងផលប៉ះពាល់ ក្នុងរយៈពេលពី ១ ទៅ ៣ ឆ្នាំ ហើយវិធានការកាត់បន្ថយប៉ះពាល់ដែល EIA បានផ្តល់ជាអនុសាសន៍ រួមមានការសម្អាតអាងស្តុកទឹក អនាម័យ និងការត្រួតពិនិត្យតាមដានគុណភាពទឹក។[270]

## ផលប៉ះពាល់បង្ករ

EIA បានកំណត់ពីផលប៉ះពាល់បង្ករយ៉ាងទូលំទូលាយពីទំនប់ចំនួន ១៦ ដែលគ្រោងទុកនៅពេលនោះនៅក្នុងទន្លេសេសាន និងទន្លេស្រែពក ដែលប៉ះពាល់ដល់ការធ្វើបំលាស់ទីជម្រករបស់ត្រី គុណភាព និងបរិមាណទឹក

[265] EIA, ការសិក្សាជលផល, ទំព័រ ៣ ។

[266] EIA, ការសិក្សាជលផល, ទំព័រ ៥–៦។

[267] EIA, ការសិក្សាជលផល, ទំព័រ ២៤។

[268] EIA, ទំព័រ ១១៦។

[269] EIA, ទំព័រ១១៦។

[270] EIA ទំព័រ ១១៦–១១៨ ។

មនុស្ស សត្វព្រៃ និងធនធានជលផល។ ទោះជាយ៉ាងណាក៏ដោយ ការវិភាគតិចតួចត្រូវបានធ្វើឡើងទៅលើលក្ខណៈជាក់លាក់នៃផលប៉ះពាល់បង្គរទាំងនេះ ក្រៅតែពីការទទួលស្គាល់ប៉ះពាល់បង្គរដែលពួកគេតំណាងទៅលើការប្រែប្រួលរបបលំហូរ នៃទន្លេទាំងពីរ លទ្ធភាពនៃការកើនឡើងទឹកជំនន់ និងគ្រោះរាំងស្ងួតបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដោយសារការបាត់បង់គម្របព្រៃឈើ ការថយចុះគុណភាពទឹកនៃទន្លេទាំងពីរ និងផលប៉ះពាល់នានាមកលើសត្វព្រៃ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលពឹងផ្អែកលើទន្លេ។

វិធានការកាត់បន្ថយផលប៉ះពាល់ចម្បងៗ ដែលត្រូវបានផ្តល់អនុសាសន៍នៅក្នុង EIA គឺការសម្របសម្រួល រវាងប្រទេសកម្ពុជា និងវៀតណាម ដែលមានទំនប់ទឹកនៅខ្សែទឹកខាងលើភាគច្រើន ដោយផ្តោតលើបទប្បញ្ញត្តិ និងការត្រួតពិនិត្យតាមដានលំហូរ និងគុណភាពទឹក។ អនុសាសន៍បន្ថែមទៀត រួមមានមជ្ឈមណ្ឌលធនធានត្រីដែលបានពិពណ៌នាខាងលើ និងការដាំដុះព្រៃឈើឡើងវិញ។

**ផែនទី ៦៖ ទំនប់វារីអគ្គិសនីដែលបានសាងសង់ និងគ្រោងទុក ឆ្នាំ២០១០**



(ប្រភព៖ ក្រុមធនាគារពិភពលោក, IBRD, ខែមិថុនា ឆ្នាំ ២០២៤)

ការស៊ើបអង្កេតរបស់ ស៊ីអេអូ មិនបានរកឃើញភស្តុតាងណាមួយដែលថា ផែនការ ឬកម្មវិធីជាក់ស្តែងកាន់តែច្រើន ត្រូវបានបង្កើតឡើង ឬអនុវត្ត ដោយផ្អែកលើអនុសាសន៍របស់ EIA ដើម្បីទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់របស់ LS2 ទៅលើការធ្វើបំលាស់ទីជម្រករបស់ត្រី លំហូរទឹក និងដីល្បាប់ ព្រមទាំងព្រៃឈើ នោះទេ។ សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងទៀត មិនបានដឹងអំពីផែនការដាំដើមឈើឡើងវិញ ឬបទប្បញ្ញត្តិលំហូរ ឬសកម្មភាពត្រួតពិនិត្យតាមដានគុណភាពទឹកនោះទេ។ មជ្ឈមណ្ឌលធនធានជលផល មិនដែលត្រូវបានអនុវត្តឡើយ ប៉ុន្តែប្រតិបត្តិករគម្រោង និងរដ្ឋាភិបាលកម្ពុជា ហាក់ដូចជាបានអនុវត្តវិធានការផ្សេងទៀតជំនួស (សូមមើលផ្នែក៣ ខាងក្រោមទាក់ទងនឹងផ្លូវត្រី ការលែងកូនត្រី និងការបង្កើតសហគមន៍នេសាទ)។

**ផលប៉ះពាល់លើជនជាតិដើមភាគតិច**

ខណៈពេលដែលសហគមន៍ជនជាតិដើមភាគតិចរស់នៅក្នុងខេត្តចំនួន ១៦ ក្នុងចំណោមរាជធានី/ខេត្តទាំង ២៥

របស់ប្រទេសកម្ពុជា ពួកគេភាគច្រើនរស់នៅក្នុងព្រៃខ្ពង់រាប វាលទំនាប និងភ្នំនៃខេត្តភាគខាងជើង និងភាគឦសាន រួមមានខេត្តរតនគិរី ខេត្តស្ទឹងត្រែង ដែលជាទីតាំង LS2 និងតំបន់ខ្សែទឹកខាងលើនៃទំនប់ និងអាងស្តុកទឹក។[271] EIA ដែលត្រូវបានចាត់ចែងដោយអតិថិជនបន្ត របស់ IFC គឺក្រុមហ៊ុន EVNI បានកំណត់អត្តសញ្ញាណជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច ស្ថិតនៅទីតាំងនៅតំបន់អាងស្តុកទឹក និងនៅខ្សែទឹកខាងលើ ដែលនឹងរងផលប៉ះពាល់ដោយគម្រោងនេះ រួមមានជនជាតិចារ៉ាយ ទំពួន កាចក់ ព្នង និងជនជាតិភាគតិចឡាវ។[272]ក្នុងចំណោមក្រុមទាំងនេះ នៅពេលនោះ ជនជាតិចារ៉ាយ ទំពួន កាចក់ និងព្នង ដែលជាដើមបណ្តឹងមកពីភូមិក្បាលរមាសចាស់ និងភូមិស្ថិតនៅខ្សែទឹកខាងលើ ត្រូវបានទទួលស្គាល់ថាជាជនជាតិដើមភាគតិច តាមច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលជាច្បាប់ដំបូងរបស់កម្ពុជាដែលទទួលស្គាល់ជនជាតិដើមភាគតិចជាផ្លូវការ។ [273] លើសពីនេះ ជនជាតិភាគតិចឡាវរស់នៅក្នុងភូមិស្រែគរចាស់ និងនៅខ្សែទឹកខាងលើនៃអាងស្តុកទឹក ត្រូវបានរដ្ឋាភិបាលកម្ពុជាកំណត់ថាជាជនជាតិភាគតិច។ [274]

ទោះបីជាកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចទាំងនេះថាជាប្រជាជនរងផលប៉ះពាល់គម្រោងយ៉ាងណាក៏ដោយ ក៏គ្មានវិធានការពិសេស ផែនការសម្រាប់ជនជាតិដើមភាគតិច ឬការពិចារណាលើសិទ្ធិរបស់ពួកគេ ត្រូវបានដាក់បញ្ចូលនៅក្នុង EIA ដែរ។ ឯកសារយោងជនជាតិដើមភាគតិចជាក់លាក់នៅក្នុង EIA រួមមានដូចខាងក្រោម៖

- យោងតាមច្បាប់ជាតិដែលកំណត់ជនជាតិដើមភាគតិចនៅកម្ពុជា [275] ប៉ុន្តែមិនមានផ្តល់ជាក់លាក់សម្រាប់ការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ព្រមទាំងការចូលរួមដោយទទួលបានព័ត៌មាននៅក្នុងគម្រោងអភិវឌ្ឍន៍ដោយក្រុមជនជាតិដើមភាគតិចទាំងនេះទេ។ EIA ក៏បានកត់សម្គាល់ផងដែរថា ក្រុមជនជាតិភាគតិចនៅតាមដងទន្លេសេសាន មានទំនោររស់នៅប្រមូលផ្តុំគ្នា ដោយ

---

[271]ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ជនជាតិដើមភាគតិច/ជនជាតិភាគតិច និងការកាត់បន្ថយភាពក្រីក្រ នៅប្រទេសកម្ពុជា។ នាយកដ្ឋានការពារបរិស្ថាន និងសង្គម នាយកដ្ឋានអភិវឌ្ឍន៍តំបន់ និងនិរន្តរភាព (ម៉ានីល ប្រទេសហ្វីលីពីន៖ ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០០២)។

[272] EIA, ទំព័រ ៨៤, ១១៣; របាយការណ៍សង្គម-សេដ្ឋកិច្ច ភ្ជាប់ជាមួយ EIA ខែមេសា ឆ្នាំ ២០០៨ ទំព័រ ១,៥,៦, ២១,២៣; បញ្ជីត្រួតពិនិត្យបរិស្ថានសម្រាប់ការអភិវឌ្ឍវារីអគ្គិសនី ភ្ជាប់ជាមួយ EIA ។

[273]របាយការណ៍ជាតិរបស់កម្ពុជា វដ្តទីមួយនៃការពិនិត្យជាសកលតាមកាលកំណត់របស់ UNHRC ក្នុងឆ្នាំ ២០០៩ A/HRC/WG.6/6/KHM/1, ទំពីរ២៤។ https://bit.ly/4ckzTwR ។

[274] Sonia Palmieri, ជនជាតិភាគតិចដែលមិនសូវមានគេស្គាល់៖ ការតំណាងឱ្យជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅកម្ពុជា (សហភាពអន្តរសភា, UNDP, ២០១០) ៣។ https://bit.ly/4cHCa4N ។

[275] មាត្រា ២៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ នៃព្រះរាជាណាចក្រកម្ពុជា៖ "សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមប្រជាជនដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំលៀមទំលាប់នៃការប្រើប្រាស់សមូហភាព។ ក្នុងពេលដែលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះ នឹងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមប្បញ្ញត្តិនៃច្បាប់នេះ"។

មិនមានការបែងចែកច្បាស់លាស់រវាងជនជាតិដើមភាគតិចដែលទទួលស្គាល់ដោយរដ្ឋាភិបាល និងជនជាតិភាគតិចឡើយ។ [276] EIA មិនដាក់បញ្ចូលការពិចារណាលើភាពខុសប្លែកគ្នានៃវប្បធម៌ និងភាពជាបុគ្គលរបស់ពួកគេ ឬផលប៉ះពាល់ខុសៗគ្នារបស់គម្រោងទៅលើសហគមន៍ផ្សេងៗទាំងនេះទេ។

- ការសន្និដ្ឋានថាមិនមានទីតាំងវប្បធម៌ដែលត្រូវបានគេកំណត់អត្តសញ្ញាណ នៅក្នុងតំបន់គម្រោងនេះ ទេ។ ជាលទ្ធផល វិធានការកាត់បន្ថយផលប៉ះពាល់តែមួយមុខគត់ដែលបានស្នើឡើងនៅក្នុង EIA ទាក់ទងនឹងជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិច គឺសម្រាប់អប់រំកម្មករសំណង់ឱ្យគោរពវប្បធម៌ និងប្រពៃណីរបស់ប្រជាជនទាំងនេះ។[277]
- ការទទួលស្គាល់ថា ការតាំងទីលំនៅថ្មីនៃសហគមន៍ទាំងនេះ គឺជា "បញ្ហាចម្បងខ្លាំងណាស់ ដែលត្រូវលើកយកមកពិចារណានៅក្នុងការរៀបចំ និងរចនាគម្រោង" ប៉ុន្តែមិនបានផ្តល់ព័ត៌មានលម្អិតបន្ថែមទេ។[278]

## ២.គោលនយោបាយសំណង និងការតាំងទីលំនៅថ្មីរបស់សេសានក្រោម២

ដោយផ្អែកលើបទប្បញ្ញត្តិទូទៅរបស់ EIA ចន្លោះឆ្នាំ២០១០ ដល់ឆ្នាំ២០១១ EVNI បានរៀបចំគោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ (CRP) សម្រាប់ LS2 ដែលបានព្យាករណ៍ពីតម្រូវការតាំងទីលំនៅថ្មីចំនួន ៧៩៧ គ្រួសារ នៅឆ្នាំ២០១៤។ វាមិនមានភាពច្បាស់លាស់ពីឯកសារគម្រោងដែល ស៊ីអេអូ មានថាតើចំនួនគ្រួសាររងផលប៉ះពាល់បានថយចុះពី ១.០៥៩ គ្រួសារនៅក្នុង EIA មកនៅត្រឹម ៧៩៧ នៅក្នុង CRP ដោយរបៀបណា[279] ។

ជំរឿនទិន្នន័យមូលដ្ឋានមួយ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០១០ ប៉ុន្តែ CRP មិនផ្តល់ព័ត៌មានអំពីវិធីសាស្ត្រអនុវត្តវានោះទេ។[280] ដូចគ្នានេះដែរ គោលនយោបាយមិនមានព័ត៌មានស្តីពីការចូលរួម ឬការពិគ្រោះយោបល់របស់សហគមន៍ ដើម្បីកំណត់កញ្ចប់សំណងសម្រាប់គ្រួសារដែលបានតាំងលំនៅថ្មីនោះទេ។

CRP ឆ្នាំ២០១១ បានដាក់បញ្ចូលគំរូខាងក្រោមនេះ សម្រាប់សំណង។ ទោះជាយ៉ាងណាក៏ដោយ វាមិនបានផ្តល់ព័ត៌មានលម្អិតអំពីរបៀបដែលទិន្នន័យទាំងនេះត្រូវបានគណនា និងមិនមានព័ត៌មានអំពីថាតើជម្រើសសំណងទាំងនេះត្រូវបានបង្ហាញឱ្យដឹង បានពិភាក្សា ឬត្រូវបានធ្វើសុពលកម្ម ដោយប្រជាពលរដ្ឋរងផលប៉ះពាល់ ដែរឬទេ។ ស៊ីអេអូ ក៏កត់សម្គាល់ផងដែរថា CRP របស់ EVNI មិននិយាយអំពីតថភាព និងការបរាជ័យក្នុងការដោះស្រាយតថភាពយ៉ាងសំខាន់នេះដែលសហគមន៍កំពុងប្រឈមនឹងការផ្លាស់ទីលំនៅ រួមមានក្រុមជនជាតិដើមភាគតិច

---

[276] EIA, ទំព័រ ៦, ៨៤, ១០២, ១១៣; របាយការណ៍សេដ្ឋកិច្ចសង្គមសម្រាប់ LS2 ភ្ជាប់ជាមួយ EIA, ទំព័រ ១។

[277] EIA, ទំព័រ ១១៣។

[278] EIA ទំព័រ ១០២ ។

[279] CRP ចាប់ផ្តើមពី ៥១៥ គ្រួសារដែលបានកំណត់ក្នុងឆ្នាំ២០១០ ហើយគម្រោងកើនឡើងដល់ ៧៩៧ គ្រួសារ។ វាមិនច្បាស់ថា ៥១៥ គ្រួសារដំបូងមកពីណាទេ ដោយសារ EIA បានរកឃើញថា ១.០៥៩ គ្រួសារ នឹងត្រូវការតាំងទីលំនៅថ្មី។ EVNI,២០១១ CRP,២–៣។

[280]EVNI, CRP ឆ្នាំ២០១១, ៥ ។

មួយចំនួន ផងដែរ។

<table>
<tr><th colspan="2">តារាង៣៖ សំណង នៅក្នុង CRP ឆ្នាំ ២០១១ របស់ EVNI</th></tr>
<tr><th colspan="2">ដី (AH = គ្រួសារដែលរងផលប៉ះពាល់)</th></tr>
<tr><td>- អាចជាសំណងជាសម្ភារ ចំពោះការបាត់បង់ដី៖ ១.០០០ ម៉ែត្រការ៉េ (ម²) ក្នុងមួយ AH សម្រាប់ទាំងដីលំនៅដ្ឋាន និងចម្ការ និង ៤.០០០ ម² ក្នុងមនុស្សម្នាក់ (ប៉ុន្តែមិនលើសពី ២,៥ ហិកតាក្នុង AH)<br>- ឬសំណងជាសាច់ប្រាក់ (សូមមើលខាងស្តាំ)[281]<br><br>- ប្រសិនបើដីដែលរងផលប៉ះពាល់មានទំហំធំជាងតម្លៃដីជំនួសជាសម្ភារ នោះAH នឹងទទួលបានសំណងជាសាច់ប្រាក់បន្ថែមសម្រាប់ចំណែកអតិរេក។[282]</td><td><table><tr><th>ប្រភេទដី</th><th>ដុល្លារអាមេរិក/ម២</th></tr><tr><td>ដីលំនៅដ្ឋាន</td><td>១,៥៧</td></tr><tr><td>ដីកសិកម្ម</td><td>0,00៨–0,១</td></tr><tr><td>ដីកសិកម្មដុតកាប់ឆ្ការ</td><td>0,0៣</td></tr><tr><td>ដីព្រៃ</td><td>0,0១–0,0១៥</td></tr></table></td></tr>
<tr><td colspan="2">- ដំណាំ និងដើមឈើមានតម្លៃចាប់ពី ០,១០ ដុល្លារ (កប្បាស) ដល់ ៣៥,២០ ដុល្លារ (ស្ករត្នោត)។[283]</td></tr>
<tr><th colspan="2">ផ្ទះ / សំណង់[284]</th></tr>
<tr><td colspan="2">សំណងសម្ភារជាផ្ទះ និងឬសគល់៖</td></tr>
<tr><td colspan="2">- AH មានសមាជិក ១-២ នាក់៖ ផ្ទះទំហំ ៤០ ម²</td></tr>
<tr><td colspan="2">- AH មានសមាជិក ៣-៤ នាក់៖ ផ្ទះទំហំ ៥៥ ម²</td></tr>
<tr><td colspan="2">- AH មានសមាជិក ៥-៧ នាក់៖ ផ្ទះមួយ ៧០ ម²</td></tr>
<tr><td colspan="2">- AH មានសមាជិក ៨ នាក់ ឬច្រើនជាងនេះ៖ ផ្ទះមួយ ៨០ ម²</td></tr>
<tr><td colspan="2">ឬសំណងជាសាច់ប្រាក់[285]</td></tr>
<tr><td>- ផ្ទះឈើ / សំណង់</td><td>$១០,២៤–១៩,៨៧/m2</td></tr>
<tr><td>- ផ្ទះដែក / សំណង់</td><td>$៩,៩៨–៧៨,២២/m2</td></tr>
<tr><td>- ផ្ទះក្បឿង / សំណង់</td><td>$៦២,០៩–១៥៦,៦៤/m2</td></tr>
</table>

[281] EVNI, CRP ឆ្នាំ២០១១, ៨ ។

[282] EVNI, CRP ឆ្នាំ២០១១, ១៨–១៩ ។

[283] EVNI, CRP ឆ្នាំ២០១១, ១២–១៣ ។

[284] EVNI, CRP ឆ្នាំ២០១១, ១៨ ។

[285] EVNI, CRP ឆ្នាំ២០១១, ៩–១២ ។

| | |
|---|---|
| - អណ្តូងខួង | ៨០-១២០ ដុល្លារ |
| - អណ្តូងស្នប់ | ៤៥០ ដុល្លារ |
| - បង្គន់អនាម័យ | ៤៥-៦០ ដុល្លារ /m2 |
| - ផ្ទះអារក្ស | ៥២ ដុល្លារ |
| - ចេតិយជនបទ[286] | ១.៥០០ ដុល្លារ |
| - របង | ០,២០–១៦ ដុល្លារ/ម៉ែត្រ |
| - ជញ្ជាំងតដ្ឋ | ៤៥ ដុល្លារ/ម៉ែត្រ |
| ប្រសិនបើផ្ទះ/សំណង់ដែលរងផលប៉ះពាល់ មានទំហំធំជាងផ្ទះជំនួស នោះ AH នឹងទទួលបានសំណងបន្ថែមជាសាច់ប្រាក់សម្រាប់ផ្នែកអតិរេក។[287] | |
| **ប្រាក់ឧបត្ថម្ភ** [288] | |
| - ការដឹកជញ្ជូន៖ ១០០ដុល្លារ/AH សម្រាប់ការតាំងទីលំនៅថ្មី នៅក្នុងខេត្តស្ទឹងត្រែង និង ២០០ដុល្លារ/AH សម្រាប់ការតាំងទីលំនៅថ្មី ទៅកាន់ខេត្តមួយផ្សេងទៀត។ | |
| - ជីវភាពរស់នៅអន្តរកាលៈ កសិករដែលបាត់បង់ដីកសិកម្មលើសពី ៥០ ភាគរយ អង្ករ ២០ គីឡូក្រាម/នាក់/ខែ រយៈពេល ១២ ខែ។ អ្នកបាត់បង់តិចជាង ៥០ ភាគរយ អង្ករ ១០ គីឡូក្រាមក្នុងមួយខែ។ | |
| - ប្រាក់ឧបត្ថម្ភថែទាំសុខភាព៖ ១០ដុល្លារ/AH, ការទូទាត់សរុបតែម្តងជូន AH នីមួយៗ។ | |
| - ភ្លើង: ១៥ដុល្លារ/AH/ខែ សម្រាប់រយៈពេល ១២ ខែ។ ការទូទាត់សរុបតែម្តងជូន AH នីមួយៗ។ | |
| - ការដាំផ្ទះដំណាំ៖ ៥០ ដុល្លារ ក្នុងពលកម្មមនុស្សម្នាក់ និងការទូទាត់សរុបតែម្តង។ | |
| - ការលើកទឹកចិត្ត៖ ២០០ ដុល្លារ ដល់ AHs ដែលផ្លាស់ប្តូរទីលំនៅ ឬទុកចោលទ្រព្យដែលរងផលប៉ះពាល់របស់ពួកគេ តាមកាលវិភាគ។ | |
| - សហគមន៍ និងភូមិ៖ ការវិនិយោគ ការកែលម្អ ឬសាងសង់សំណង់ថ្មី ដើម្បីធានាបាននូវសកម្មភាពផលិតកម្ម និងជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន - ៥.០០០ ដុល្លារ/ភូមិ។ | |

ក្នុងអំឡុងពេលចុះពិនិត្យមូលដ្ឋាន ស៊ីអេអូ បានទទួលដំណឹងពីមន្ត្រីរដ្ឋាភិបាលមូលដ្ឋានថា ការតាំងទីលំនៅថ្មី ត្រូវបានគ្រោង និងអនុវត្តដោយអ្នកម៉ៅការបន្តរបស់ LS2 និងត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការអន្តរក្រសួងជាន់ខ្ពស់ ជាមួយនឹងការពិគ្រោះយោបល់ជាមួយក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២។ របាយការណ៍ CSR ឆ្នាំ២០២០ របស់ LS2 ដោយវិទ្យាស្ថាន AVI បានបង្ហាញថា "ក្រុមអន្តររដ្ឋាភិបាល និងអន្តរស្ថាប័នមួយ ត្រូវបានបង្កើតឡើង ដើម្បីធ្វើការលើគោលនយោបាយសំណង ក្រោមការសង្កេតពីអង្គការក្រៅរដ្ឋាភិបាលនានា"។[289]

---

[286] ស្តូបរំលឹកតូចមួយ។

[287] EVNI, CRP ឆ្នាំ២០១១, ទំព័រ ១៩។

[288] EVNI, CRP ឆ្នាំ២០១១, ទំព័រ ១៥។

[289]AVI, របាយការណ៍និរន្តរភាព ឆ្នាំ២០២០ (របាយការណ៍ CSR), ១៦។

ស៊ីអេអូ បានដឹងដោយផ្ទាល់ពីអង្គការក្រៅរដ្ឋាភិបាលមួយ ក្នុងចំណោមអង្គការទាំងនេះ ថាសេចក្តីថ្លែងការណ៍នេះគឺមិនត្រឹមត្រូវទេ ហើយថាពួកគេមិនដែលបានសហការ ឬជួយអ្នកបង្កើតគម្រោងជាមួយនឹង "គោលនយោបាយសំណង" នោះទេ។ ស៊ីអេអូ មិនបានទទួលព័ត៌មានណាមួយបន្ថែមទៀតអំពីការងាររបស់ក្រុមនេះទេ ឬថាតើវាមានឥទ្ធិពលលើ ឬកែប្រែ CRP បង្កើតឡើងដោយ EVNI ក្នុងឆ្នាំ២០១១ ដែរឬទេ។[290]

### ៣.ការសិក្សា និងព័ត៌មានបន្ថែមអំពីសេសានក្រោម២

ព័ត៌មានដែលបង្ហាញនៅក្នុងផ្នែកនេះ គ្របដណ្តប់លើការសិក្សាជាបន្តបន្ទាប់ និងសកម្មភាពដែលទាក់ទងនឹង LS2 ដែលទទួលបានតាមរយៈព័ត៌មានសាធារណៈ សក្ខីកម្មសហគមន៍ និងការសម្ភាសន៍របស់ ស៊ីអេអូ ជាមួយភាគីពាក់ព័ន្ធ ក្នុងអំឡុងពេលចុះទៅមូលដ្ឋាន ឆ្នាំ២០២៣ ។ ដោយសារភាពមានកម្រិតក្នុងការទទួលបានកំណត់ត្រានានា ហើយទោះបីជាមានការខិតខំប្រឹងប្រែងម្តងហើយម្តងទៀតរបស់ CAO ដើម្បីចូលរួមដោយផ្ទាល់ជាមួយអតិថិជនបន្តរបស់ IFC និងប្រតិបត្តិកររបស់គម្រោង (សូមមើលផ្នែក២) យ៉ាងណាក៏ដោយ ក៏ការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើព័ត៌មានជាក់លាក់របស់ LS2 មិនអាចធ្វើទៅបានទេ។

### ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការបង្ហាញព័ត៌មាន និងការដោះស្រាយបណ្តឹងសារទុក្ខ

របាយការណ៍ប្រព័ន្ធផ្សព្វផ្សាយបង្ហាញថា ក្នុងខែឧសភា ឆ្នាំ២០១១ តំណាងសហគមន៍មកពីខេត្តរតនគិរី បានចូលរួមការពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីគម្រោងវារីអគ្គិសនី LS2 នៅភ្នំពេញ ជាមួយអង្គការក្រៅរដ្ឋាភិបាល និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលបានលើកឡើងពីអត្ថប្រយោជន៍គម្រោង។[291]

អ្នកភូមិស្រែគរ បានប្រាប់ ស៊ីអេអូ ថា ចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥ តំណាងរដ្ឋាភិបាលជាតិ និងបុគ្គលិកចិនមកពីក្រុមហ៊ុន LS2 ប្រហែលមកពីម្ចាស់ហ៊ុនភាគច្រើននៃក្រុមហ៊ុន Hydrolancang International Energy របស់ China Huaneng Group ដែលបានចូលកាន់តំណែងជាអ្នកដឹកនាំគម្រោង ពី EVNI ក្នុងឆ្នាំ២០១២ បានបង្ហាញជម្រើសសំណង និងការតាំងទីលំនៅថ្មី ទៅដល់សហគមន៍។

កាលពីខែវិច្ឆិកា ឆ្នាំ២០២០ វិទ្យាស្ថានកម្ពុជាមួយ ហៅថា វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) បានបោះពុម្ពផ្សាយ

---

[290] ការសិក្សាពាក់ព័ន្ធសំដៅលើឯកសារគោលនយោបាយបន្ថែមចំនួនពីរ៖ (i) "យន្តការ និងនីតិវិធីនៃការទូទាត់សំណង និងការតាំងទីលំនៅថ្មីនៃសេសានក្រោម២ ក្នុងខេត្តស្ទឹងត្រែង" ដែលចុះហត្ថលេខានៅថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ដោយឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងជាប្រធានគណៈកម្មាធិការអន្តរក្រសួង និង (ii) គោលនយោបាយស្តីពីសំណង និងដំណោះស្រាយលើផលប៉ះពាល់នៃសេសានក្រោម២ រៀបចំដោយក្រុមហ៊ុន Hydropower Lower Sesan2 Co., Ltd។ (NGO Forum on Cambodia ២០១៥៖ ការស្ទង់មតិលើគោលនយោបាយសំណង និងតម្លៃអចលនទ្រព្យនៅលើទីផ្សារ គម្រោងអភិវឌ្ឍន៍ទំនប់ LSS2 គម្រោងអភិវឌ្ឍន៍ទំនប់ LSS2 ស្រុកសេសាន ខេត្តស្ទឹងត្រែង) ។ ដោយសារ ស៊ីអេអូ មិនទាន់មានព័ត៌មានពីក្រុមហ៊ុនគម្រោង ឬ ENVI វាមិនច្បាស់ថាឯកសារទាំងនេះទាក់ទងនឹងអ្វី និង/ឬថាតើពួកគេផលិតឡើងវិញនូវទិន្នន័យ និងបទប្បញ្ញត្តិពី CRP ឆ្នាំ២០១១ របស់ EVNI ដែរឬទេ។

[291] Amy Lieberman, "ស្ត្រីកម្ពុជាក្រោកឡើងនិយាយអំពីការគំរាមកំហែងរបស់ទំនប់" Women's eNews (៤ កក្កដា ២០១១), https://bit.ly/3xEdco2។

របាយការណ៍ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម (CSR) ស្តីពី LS2 ដែលបានចាត់ចែងដោយក្រុមហ៊ុន China Huaneng Group ។ យោងតាមរបាយការណ៍ CSR ឆ្នាំ២០២០ ក្រុមស្រាវជ្រាវមកពី AVI បានធ្វើការសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងជ្រើសរើសគ្រួសារនៅក្នុងភូមិចំនួនបីដែលរងផលប៉ះពាល់គម្រោង (ស្រែគរ ស្រែស្នុក និងក្បាលរមាស)។[292]ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍នេះមិនបានដាក់បញ្ចូលកំណត់ត្រានៃការសម្ភាសន៍ទាំងនេះទេ ហើយនៅក្នុងការទំនាក់ទំនងជាមួយ ស៊ីអេអូ អង្គការក្រៅរដ្ឋាភិបាលមួយ ក្នុងចំណោមអង្គការក្រៅរដ្ឋាភិបាល ដែលវិទ្យាស្ថានលើកឡើង បានបដិសេធមិនចូលរួម ឬសហការជាមួយគម្រោង ឬក្រុមហ៊ុន China Huaneng Group នៅក្នុងដំណើរការណាមួយដែលទាក់ទងនឹង LS2 ។ ខណៈពេលដែលបញ្ជាក់ថាក្រុមហ៊ុននេះបានធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ ដើម្បីដោះស្រាយបណ្តឹងរបស់ពួកគេជុំវិញសិទ្ធិលើកម្មសិទ្ធិឯកជន និងធនធានសហគមន៍ និងបញ្ហាអភិបាលកិច្ច របាយការណ៍ CSR មិនផ្តល់ព័ត៌មានលម្អិតស្តីពីការពិគ្រោះយោបល់ និងការចូលរួមរបស់ភាគីពាក់ព័ន្ធនោះទេ។ [293] ទោះជាយ៉ាងនេះក្តី របាយការណ៍ ធ្វើសេចក្តីសន្និដ្ឋានថា ក្រុមហ៊ុនChina Huaneng Group និងរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវ "ពង្រឹងយន្តការដោះស្រាយជម្លោះ និងការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកភូមិនៅមូលដ្ឋាន ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយសុខដុមរមនា"។[294] ស៊ីអេអូ រកមិនឃើញភស្តុតាងដែលថា យន្តការបណ្តឹងសារទុក្ខ ឬយន្តការដោះស្រាយវិវាទណាមួយ ត្រូវបានអនុវត្តសម្រាប់ LS2 ទេ (សូមមើលផ្នែក 3.2 និង 4 នៅក្នុងតួរបាយការណ៍)។

## ផលប៉ះពាល់លើជីវៈចម្រុះ ធនធានធម្មជាតិ ជលផល និងជីវភាពរស់នៅ

អង្គការក្រៅរដ្ឋាភិបាល និងអ្នកសិក្សាបានលើកឡើងពីក្តីកង្វល់ខ្លាំងអំពីផលប៉ះពាល់ដែលអាចនឹងកើតមានរបស់គម្រោង LS2 ទៅលើជីវចម្រុះ និងធនធានធម្មជាតិ រួមទាំងការធ្វើបំលាស់ទីជម្រករបស់ត្រី មុនពេលការសាងសង់ទំនប់ និងការជន់លិចអាងស្តុកទឹក។ នៅក្នុងឆ្នាំ២០០៩ ការសិក្សាទៅលើភូមិចំនួន ៨៧ ដែលមានទីតាំងនៅខ្សែទឹកខាងលើ និងក្នុងតំបន់អាងស្តុកទឹក និងភូមិចំនួន ៨៦ ផ្សេងទៀតនៅក្នុងដៃទន្លេក្បែរនោះ បានប៉ាន់ប្រមាណថាប្រជាពលរដ្ឋប្រហែល ៧៨.០០០ នាក់ នឹងទទួលរងផលប៉ះពាល់លើសន្តិសុខស្បៀង និងការបាត់បង់ប្រាក់ចំណូល[295] ការវាយតម្លៃផលប៉ះពាល់នេះត្រូវបានចាត់ចែងដោយសម្ព័ន្ធទន្លេកម្ពុជា ដែលជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិលនៅកម្ពុជា។ បីឆ្នាំក្រោយមក បន្ទាប់ពីការវិនិយោគរបស់ IFC នៅក្នុង ABBank អត្ថបទមួយនៅក្នុងដំណើរការនីតិវិធីនៃបណ្ឌិត្យសភាជាតិវិទ្យាសាស្ត្រ បានសន្និដ្ឋានថា LS2 អាចនឹងបង្កផលប៉ះពាល់ទៅលើត្រី និងជលផលនៅក្នុងអាងទន្លេមេគង្គ ច្រើនជាងទំនប់ដែលបានគ្រោងទុកផ្សេងទៀត។ ជាពិសេស អ្នកនិពន្ធបានរកឃើញថា LS2 អាចនឹងកាត់បន្ថយជីវម៉ាសត្រី ៩,៣% នៅតំបន់ទំនាបទឹកជំនន់នៃប្រទេសកម្ពុជា និងវៀតណាម

---

[292] AVI, របាយការណ៍និរន្តរភាព ឆ្នាំ២០២០ (របាយការណ៍ CSR), ii–iii. សូមមើលផងដែរ China Huaneng Group "របាយការណ៍និរន្តរភាពនៃសហគ្រាសចិន នៅកម្ពុជា ត្រូវបានចេញផ្សាយ នៅទីក្រុងប៉េកាំង" ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០២០ https://bit.ly/3YwQwkq ។

[293] AVI, របាយការណ៍និរន្តរភាព ឆ្នាំ២០២០ (របាយការណ៍ CSR), ៨, ២៣–២៥ ។

[294] AVI, របាយការណ៍និរន្តរភាព ឆ្នាំ២០២០ (របាយការណ៍ CSR), ៤១។

[295] Baird ឧត្តមានុវត្តក្នុងការទូទាត់សំណង និងការតាំងទីលំនៅថ្មីសម្រាប់ទំនប់ធំៗ។

ដែលជះឥទ្ធិពលអវិជ្ជមានដល់សន្តិសុខស្បៀង និងប្រាក់ចំណូលសម្រាប់ប្រជាជនមួយចំនួនធំ ព្រមទាំងបណ្តាលឱ្យបាត់បង់ជីវចម្រុះក្នុងទឹកយ៉ាងធ្ងន់ធ្ងរ ។[296]

នៅក្នុងឆ្នាំ២០១៣ បន្ទាប់ពីកិច្ចប្រជុំម្ចាស់ជំនួយក្រៅផ្លូវការនៃគណៈកម្មការទន្លេមេគង្គ ធនាគារពិភពលោក និងម្ចាស់ជំនួយអន្តរជាតិផ្សេងទៀត បានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជារៀបចំគម្រោងមួយនេះឡើងវិញ "ដោយសំអាងលើផលប៉ះពាល់ក្នុងតំបន់ធ្ងន់ធ្ងរដែលនឹងអាចកើតមានចេញពីទំនប់វារីអគ្គិសនីសេសានក្រោម២ នៅក្នុងការរចនានាពេលបច្ចុប្បន្នរបស់វា (រួមទាំងផលប៉ះពាល់ទៅលើការបំលាស់ទីជម្រករបស់ត្រី លំហូរដីល្បាប់ និងការតាំងទីលំនៅថ្មីរបស់សហគមន៍មូលដ្ឋាន)"។ សេចក្តីអំពាវនេះបានបន្ថែមទៀតថា "ដៃគូអភិវឌ្ឍន៍ជំរុញឱ្យរាជរដ្ឋាភិបាលកម្ពុជាពិចារណាឡើងវិញលើការរចនាគម្រោងនេះ។ យើងក៏លើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យយកគម្រោងមកធ្វើការប្រឹក្សាយោបល់ជាមុនដោយស្ម័គ្រ។ ដៃគូអភិវឌ្ឍន៍ត្រៀមខ្លួនរួចជាស្រេចដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត និងនិរន្តរភាពនៃគម្រោងនេះ"។[297]

បន្ទាប់ពីការសិក្សាទាំងនេះ និងការកើនឡើងសម្ពាធសាធារណៈ ដើម្បីដោះស្រាយផលប៉ះពាល់នានារបស់ LS2 លើការធ្វើបំលាស់ទីជម្រករបស់ត្រី ក្រុមហ៊ុនវារីអគ្គិសនីសេសានក្រោម២ បានសាងសង់ផ្លូវត្រីប្រវែង ៣ គីឡូម៉ែត្រ "ដើម្បីការពារអេកូឡូស៊ីត្រី" ស្ថិតនៅលើច្រាំងខាងជើងនៃទន្លេសេសាន និងទំនប់។ ការសាងសង់បានចាប់ផ្តើមនៅឆ្នាំ ២០១៧ ហើយផ្លូវត្រីបានដំណើរការតាំងពីឆ្នាំ២០១៩ មកម្ល៉េះ។ ស៊ីអេអូ មិនមានព័ត៌មានអំពីមូលហេតុ ឬរបៀបដែលការសម្រេចចិត្តនេះត្រូវបានធ្វើឡើងទេ ទោះបីជាមានអនុសាសន៍ពី EIA ជំទាស់នឹងផ្លូវត្រីក៏ដោយ។ យោងតាមព័ត៌មានដែលផ្តល់ដោយក្រុមហ៊ុនដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងឆ្នាំ២០២០ ការធ្វើបំលាស់ទីជម្រករបស់ត្រីត្រូវបានថតដោយឧបករណ៍តាមដានជាវីដេអូ។[298]

---

[296] Ziv, Guy, et al ។ ឆ្នាំ២០១២ ការដោះដូរ- ជីវចម្រុះត្រី សន្តិសុខស្បៀង និងវារីអគ្គិសនី នៅក្នុងអាងទន្លេមេគង្គ។ *ដំណើរការប្រព្រឹត្តទៅនៃបណ្ឌិតសភាវិទ្យាសាស្ត្រ* ១០៩(១៥): ៥៦០៩–៥៦១៤។

[297] គណៈកម្មការទន្លេមេគង្គ របាយការណ៍នៃកិច្ចប្រជុំម្ចាស់ជំនួយក្រៅផ្លូវការ ថ្ងៃទី ២៧-២៨ ខែមិថុនា ឆ្នាំ២០១៣ រាជធានីភ្នំពេញ ប្រទេសកម្ពុជា p. Dene-Hern Chen ម្ចាស់ជំនួយអន្តរជាតិអំពាវនាវឱ្យរៀបចំឡើងវិញនូវទំនប់វារីអគ្គិសនីសេសាន២ ខេមបូឌា ដេលី ខែកក្កដា ឆ្នាំ ២០១៣ https://bit.ly/3VIqGr6 ។

[298] វីដេអូ "គម្រោងវារីអគ្គិសនីសេសានក្រោម២ របស់កម្ពុជា ផ្តល់ជីវិតកាន់តែប្រសើរសម្រាប់អ្នកភូមិតាំងលំនៅថ្មី" ជាវីដេអូដែលផ្សាយដោយ Khmer Times នៅលើ YouTube (ខែវិច្ឆិកា ឆ្នាំ ២០២០)។ https://bit.ly/45NPm62; "ផ្លូវត្រីដំណើរការដោយជោគជ័យក្នុងគម្រោងវារីអគ្គិសនីសេសានក្រោម២" ខ្មែរថាមស៍ (១៥ តុលា ២០១៨)https://bit.ly/45IBnyl ។

**រូបភាព៧៖ ផ្នែកមួយនៃផ្លូវត្រី LS2 ដែលមានទឹកតិចតួចបំផុត និងមិនមានលំហូរទឹកទេ**



រូបភាព៧៖ ផ្នែកនៃផ្លូវត្រី LS2 (រូបថត នៅខែមិថុនា ឆ្នាំ២០២៣ ផ្តល់ជូន ស៊ីអេអូ ដោយភាគីទីបីសម្ងាត់)

ទោះជាយ៉ាងណាក៏ដោយ ស៊ីអេអូ មិនបានរកឃើញភស្តុតាងនៃការសិក្សានានាដើម្បីវាយតម្លៃប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធនេះ និងធានាសមត្ថភាពរបស់ខ្លួនក្នុងការសម្រួលដល់ការបំលាស់ទីរបស់ប្រភេទត្រីសំខាន់ៗដែលបំលាស់ទីជម្រក តាមដងទន្លេសេសាន និងស្រែពក។ មន្ត្រីក្រសួងបរិស្ថានកម្ពុជា បានពន្យល់ប្រាប់ ស៊ីអេអូ ថា ត្រីខ្លះអាចហែលតាមបណ្តាញផ្លូវត្រី LS2 ប៉ុន្តែពួកវាជាច្រើនត្រូវនេសាទ នៅផ្នែកខាងលើនៃផ្លូវត្រី ដោយប្រជាពលរដ្ឋមូលដ្ឋាន។ សំណុចនេះបង្ហាញពីបញ្ហានៅក្នុងការត្រួតពិនិត្យតាមដាន និងប្រសិទ្ធភាពរបស់វាក្នុងការធានាថា ប្រភេទត្រីនានាអាចបញ្ចប់ការធ្វើបំលាស់ទីជម្រករបស់ពួកគេ។ សមាជិកសហគមន៍ និងភាគីពាក់ព័ន្ធនៅក្នុងមូលដ្ឋានផ្សេងទៀតបានជូនដំណឹងដល់ ស៊ីអេអូ ថា ទោះបីមិនមានប្រជាពលរដ្ឋចាប់ត្រីភ្លាមៗនៅពេលពួកគេហែលក៏ដោយ ក៏ផ្លូវត្រីមិនមានដំណើរការត្រឹមត្រូវនោះទេ ព្រោះនៅរដូវប្រាំង ផ្លូវត្រីភាគរីង ហើយគ្មានត្រីណាអាចធ្វើបំលាស់ទីជម្រកបានឡើយ ខណៈដែលនៅក្នុងរដូវវស្សាមានទឹកច្រើនពេក ធ្វើឱ្យត្រីជាច្រើនពិបាកធ្វើចំណាកស្រុក។ ផ្លូវត្រីក៏មិនអាចឱ្យត្រីរស់នៅបាតទឹកបំលាស់ទីបានដែរ។

ដូចដែលបានកត់សម្គាល់ពីខាងដើម EIA ឆ្នាំ២០០៨ មិនបានផ្តល់អនុសាសន៍ឱ្យបង្កើតផ្លូវត្រី ឬផ្លូវឆ្លងកាត់ទេ ដោយសារតែបទពិសោធន៍កន្លងមកនៅក្នុងអាងទន្លេមេគង្គ។ ផ្ទុយទៅវិញ EIA ស្នើឱ្យបង្កើតមជ្ឈមណ្ឌលជលផលដែលមានមូលនិធិគ្រប់គ្រាន់ នៅជិតទំនប់ ដើម្បីគាំទ្រដល់ជលផលអាងស្តុកទឹក។[299] ទោះជាយ៉ាងនេះក្តី

[299] EIA, ទំព័រ ១២០។

មជ្ឈមណ្ឌលជលផលមិនដែលត្រូវបានបង្កើតឡើងនោះទេ។

នៅឆ្នាំ២០១៩ រដ្ឋាភិបាលបានបង្កើត "សហគមន៍នេសាទ" ឬក្រុមតំបន់ការពារនៅក្នុងអាងស្តុកទឹកសម្រាប់ការអភិរក្សប្រភេទសត្វក្នុងទឹក។ វិសាលភាព និងដែន នៃអាណត្តិ សមត្ថភាព និងមុខងាររបស់ក្រុមក្នុងការការពារប្រភេទត្រី និងជីវចម្រុះក្នុងស្រុក គឺមិនមានភាពច្បាស់លាស់ចំពោះ ស៊ីអេអូ ទេ។

សក្ខីកម្មរបស់ភាគីពាក់ព័ន្ធអះអាងថា LS2 មានផលប៉ះពាល់លើចំនួននៃប្រភេទត្រីជាច្រើន ដែលពីមុនបានធ្វើបំលាស់ទីជម្រកពីទន្លេមេគង្គទៅកាន់ទន្លេសេកុង សេសាន និងទន្លេស្រែពក ទៅតាមពេលវេលាផ្សេងៗគ្នានៅក្នុងឆ្នាំ។ អ្នកនេសាទនៅមូលដ្ឋានដែល ស៊ីអេអូ បានសម្ភាស ក្នុងអំឡុងពេលចុះពិនិត្យមូលដ្ឋាននៅឆ្នាំ២០២៣ បានរាយការណ៍ថា ប្រភេទអម្បូរត្រី cyprinids តូចៗ (ដែលជាអម្បូរត្រីមានស្រកា) រួមទាំងត្រីរៀល និងប្រភេទអម្បូរត្រី Paralaubuca typus លែងធ្វើបំលាស់ទីជម្រករបស់ពួកគេនៅលើដងទន្លេសេសានទៀតហើយ។ អ្នកស្រុកក៏ជឿថាការធ្វើបំលាស់ទីជម្រករបស់អម្បូរត្រី Scaphognathops bandanensis ក៏លែងកើតឡើងទៀតដែរ។ អ្នកភូមិនៅតែឃើញអម្បូរត្រីមួយចំនួនតូចនៃត្រីប៉ាសេអ៊ី (Mekongina erythrospila)[300] និង Morulius spp ប៉ុន្តែមានចំនួនតិចជាងមុនឆ្ងាយណាស់។ ការនេសាទត្រីនៅជិតភូមិហាតពោធិ៍ ក្នុងស្រុកវើនសៃ ត្រូវបានគេប៉ាន់ប្រមាណថាមានចំនួន ២០ ភាគរយនៃកម្រិតមុនពេលមានទំនប់។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកបានកត់ត្រាការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃការលក់ត្រីប៉ាសេអ៊ី នៅផ្សារស្ទឹងត្រែង ចន្លោះឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២២ (សូមមើលតារាងខាងក្រោម)។

| តារាង៤៖ ការលក់ប្រភេទអម្បូរត្រីប៉ាសេអ៊ី នៅផ្សារស្ទឹងត្រែង | | | | | | |
|---|---|---|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៨ | ២០១៩ | ២០២១ | ២០២២ |
| ត្រីប៉ាសេអ៊ី | ១១៣,២ គីឡូក្រាម | ៦២,៧ គីឡូក្រាម | ១៩,៤ គីឡូក្រាម | ៦,៤ គីឡូក្រាម | ២៦,៩ គីឡូក្រាម | ៧ គីឡូក្រាម |

(ប្រភព៖ សមាគមអភិរក្សវប្បធម៌ និងបរិស្ថាន(CEPA), ការត្រួតពិនិត្យត្រីទីផ្សារ ២០១៥-២០២២)

រដ្ឋាភិបាលកម្ពុជាបានព្យាយាមកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើជលផលពី LS2 ដោយការលែងកូនត្រីចូលក្នុងអាងដើម្បីបង្កើនបរិមាណត្រី។ ស៊ីអេអូ មិនមានព័ត៌មានពេញលេញអំពីកម្មវិធីនេះ ឬនៅពេលដែលវាបានចាប់ផ្តើមនោះទេ ប៉ុន្តែបានទទួលព័ត៌មានលម្អិតមួយចំនួនពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប នៅកម្ពុជា (IFReDI)។ កូនត្រី ត្រូវបានជ្រើសរើសដើម្បីយកទៅលែង ផ្អែកចម្បងជាទៅលើកូនត្រីញាស់តូចៗ ដែល

[300]ត្រីប៉ាសេអ៊ី ជាប្រភេទត្រីមានតម្លៃខ្ពស់នៅប្រទេសកម្ពុជា និងជាតំណាងនៃចំនួនត្រីនៅភាគឦសាន ប្រទេសកម្ពុជា។ ជួនកាល វាត្រូវបានផ្តល់ជូនជាអំណោយពិសេសសម្រាប់ព្រះមហាក្សត្រកម្ពុជា ព្រោះវាមិនមាននៅតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជាទេ។

អាចរកបាន ជាជាងក្តីព្រួយបារម្ភអំពីជីវចម្រុះ។ ទោះយ៉ាងណាក៏ដោយស្ទើរតែទាំងអស់នៃប្រភេទអម្បូរត្រីដែលបានលែង គឺជាប្រភេទអម្បូរត្រីដើមរស់នៅក្នុងតំបន់នេះ (សូមមើលតារាង) ។ គោលបំណងសំខាន់គឺដើម្បីបង្កើនជីវម៉ាសត្រីដើម្បីជំនួសអ្វីដែលបានបាត់បង់នៅក្នុងការនេសាទត្រីក្នុងស្រុកដោយសារតែទំនប់ ប៉ុន្តែមិនមានការបង្ហាញថាប្រភេទត្រីជំនួសត្រូវបានជ្រើសរើសដើម្បីជំនួសប្រភេទត្រីជាក់លាក់ដែលរងផលប៉ះពាល់ដោយ LS2 នោះទេ។ លើសពីនេះ ប្រភេទកូនត្រីភាគច្រើនត្រូវបានលែងក្នុងបរិមាណតិចតួចបំផុត។ IFReDI មិនបានបង្ហាញថាមានការសិក្សាស្រាវជ្រាវណាមួយត្រូវបានធ្វើឡើងដើម្បីត្រួតពិនិត្យតាមដានផលប៉ះពាល់នៃការលែងត្រីទាំងនេះទេ។

**តារាង៥៖ ប្រភេទត្រីត្រូវបានលែងទៅក្នុងអាងស្តុកទឹក LS2 ក្នុងឆ្នាំ២០២៣**

| កូនត្រី (Fingerling) | (ឯកតាជាក្បាល) | ម្រាមដៃ (ប្រភេទ) | ឯកតា (ក្បាល) |
|---|---|---|---|
| កូនត្រីឆ្ពិន (កូន) | ៣០.០០០ | *Hypsibarbus*ឬ Barbodes sp | ៣០.០០០ |
| កូនត្រីប្រា (កូន) | ៣០.០០០ | *Pangasius conchophilus* | ៣០.០០០ |
| សរុប (total) | **៦០.០០០** | **សរុប** | **៦០.០០០** |
| ត្រីមេពូជ (គីឡូ) | | ការបង្កាត់ពូជត្រី | **ឯកតា (គីឡូក្រាម)** |
| ត្រីច្រកែង | ១៥ | *Puntioplites* sp. | ១៥ |
| ត្រីឆ្ពិន | ១៥ | *Hypsibarbus or Barbodes* sp. | ១៥ |
| ត្រីក្រុស | ៧ | *Osteochilus lini* | ៧ |
| ត្រីក្រឡង់ | ៧ | *Cirrhinus microlepis* | ៧ |
| ត្រីកាហែ | ១០ | *Barbonymus altus* | ១០ |
| ត្រីក្អែក | ៩ | *Hypsibarbus* or *Barbodes* sp. | ៩ |
| ត្រីព្រួល | ៧ | *Cirrhinus microlepis* | ៧ |
| ត្រីរៀល | ៥ | *Henicorhychus* sp. | ៥ |
| ត្រីឆ្លាំង | ៥ | *Hemibagrus wyckioides* | ៥ |
| ត្រីពោ | ១០ | *Pangasius larnaudei* | ១០ |
| ត្រីកំពុលបាយ | ៥ | *Cosmochilus harmandi* | ៥ |
| ត្រីព្រលូង | ៥ | *Leptobarbus hoevenii* | ៥ |
| សរុប | **១០០** | **សរុប** | ១០០ **គីឡូក្រាម** |

(ប្រភព៖IFREDI)

លើសពីនេះ មានរបាយការណ៍ដែលម្ចាស់ភាគហ៊ុនភាគច្រើនរបស់ LS2 គឺក្រុមហ៊ុន Hydrolancang International Energy បានបង្កើតកំណែបន្ថែម ឬបំពេញបន្ថែមនៃ EIA សម្រាប់គម្រោងវារីអគ្គិសនីសេសានក្រោម២ ក៏ដូចជាផែនការកាត់បន្ថយផលប៉ះពាល់ផ្ទៃក្នុង និងការតាំងទីលំនៅថ្មី មួយចំនួនផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ឯក

សារទាំងនេះមិនត្រូវបានចែករំលែកជាមួយសហគមន៍រងផលប៉ះពាល់ ឬក្រុមសង្គមស៊ីវិលទេ បើមិនដូច្នេះទេ ការចែកចាយឯកសារទាំងនេះមានការរឹតត្បិត។[301] ស៊ីអេអូ មិនបានឃើញឯកសារទាំងនេះទេ ហើយក៏មិនបានផ្តល់សិទ្ធិចូលប្រើប្រាស់ពួកវា ដោយអនុគម្រោង LS2 ម្ចាស់ភាគហ៊ុនរបស់អនុគម្រោង ឬភាគីពាក់ព័ន្ធផ្សេងទៀតដែរ។

301 អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ឥទ្ធិពលគម្រោង ឆ្នាំ២០២១"។

## ឧបសម្ព័ន្ធ ខ៖ ផលប៉ះពាល់ទៅលើផលផល រាយការណ៍ដោយសហគមន៍

| ភូមិ | សកម្មភាពកន្លងមក ដែលបានរាយការណ៍ | ស្ថានភាពបច្ចុប្បន្នដែលបានរាយការណ៍ (២០២៣) |
|---|---|---|
| ដើមបណ្ដឹង៖ ស្រែគរចាស់ ក្បាលរមាសចាស់ ក្បាលរមាសថ្មី និងស្រែគរថ្មី | | |
| ភូមិស្រែគរចាស់ ស្រុកសេសាន ខេត្តស្ទឹងត្រែង (សហគមន៍ជនជាតិឡាវ បច្ចុប្បន្នស្ថិតនៅក្នុងតំបន់អាងស្តុកទឹក LS2 ពីមុនតាមដងទន្លេសេសាន) | ត្រីនេសាទបាន បរិភោគ និងលក់ | អ្នកភូមិបានរាយការណ៍ថា ភ្លាមៗបន្ទាប់ពីទំនប់នេះត្រូវបានបិទ ពេលនោះមានត្រីនៅក្នុងអាងនេះច្រើនជាងមុនការសាងសង់។ ទោះជាយ៉ាងនេះក្តី ឥឡូវនេះបរិមាណនេះបានធ្លាក់ចុះយ៉ាងខ្លាំងមកនៅត្រឹម ៧០ ភាគរយនៃការនេសាទត្រី មុនពេលសាងសង់ទំនប់នេះ។<br>ប្រភេទត្រីដែលចូលចិត្តលំហូរទឹកទន្លេ បានបាត់អស់ ហើយការធ្លាក់ចុះត្រូវបានកត់សម្គាល់ភាគច្រើននៅក្នុងប្រភេទត្រីដែលពីមុនបានបំលាស់ទីជម្រកតាមខ្សែទឹកខាងក្រោម ខាងក្រោម LS2 ។<br>ភាគច្រើននៃប្រភេទត្រីនេសាទបានពេលនេះ មិនធ្វើបំលាស់ទីជម្រកទេ រួមទាំងប្រភេទអម្បូរត្រីខ្មៅដូចជា Channa striata និង Channa marulius រួមជាមួយនឹង cyprinids មួយចំនួនដែលអាចរស់បាននៅក្នុងទឹកទ្រឹងមិនហូរ ដូចជា Hypsibarbus ឬ Barbodes sp និង Puntioplites falcifer ។ ត្រីមានតម្លៃថ្លៃជាងគេ ដែលអ្នកភូមិនៅតែអាចនេសាទបានជាប្រចាំគឺត្រី Micronema sp ។<br>អ្នកនេសាទភូមិស្រែគរចាស់ បាននិយាយថា ទឹកក្នុងស្រុកឥឡូវនេះមានត្រីតូចៗជាច្រើន ដែលមិនមានតម្លៃសេដ្ឋកិច្ចពិតប្រាកដ ដូចជាត្រី Pristolepis fasciata និង Parambassis sp ជាដើម។ វាមិនគួរឱ្យភ្ញាក់ផ្អើលទេ ដែលត្រីទាំងនេះបានរីកដុះដាល ដោយសារពួកវាមានដើមកំណើតនៅអាងទន្លេមេគង្គ ហើយមានទំនោររស់នៅក្នុងទឹកដែលមិនហូរ។ |
| ភូមិក្បាលរមាសចាស់ ស្រុកសេសាន ខេត្តស្ទឹងត្រែង (ជនជាតិដើមភាគតិចព្នង បច្ចុប្បន្នស្ថិតនៅតំបន់អាងស្តុកទឹក LS2 ពីមុនតាមដងទន្លេស្រែពក) | ត្រីនេសាទបាន បរិភោគ និងលក់ | អ្នកភូមិបានរាយការណ៍ពីការធ្លាក់ចុះបរិមាណត្រីជារួម និងជាពិសេសប្រភេទត្រីទន្លេដែលធ្វើបំលាស់ទីជម្រក។ ពួកគេបានបញ្ជាក់ថា ស្ថានភាពក្នុងភូមិរបស់ពួកគេស្រដៀងនឹងការរៀបរាប់ខាងលើសម្រាប់ភូមិស្រែគរចាស់។ |

| | | |
|---|---|---|
| ភូមិក្បាលរមាសថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង (ជនជាតិដើមភាគតិចព្នង តាំងទីលំនៅថ្មីពីផ្ទះនៅជាប់មាត់ទន្លេស្រែពក សព្វថ្ងៃរស់នៅពីរបីគីឡូម៉ែត្រពីអាងស្តុកទឹក LS2) | ត្រីនេសាទបាន បរិភោគ និងលក់ | អ្នកភូមិបានរាយការណ៍ពីការកើនឡើងដំបូងនៃការនេសាទត្រីពីអាងស្តុកទឹក បន្ទាប់ពីទំនប់នេះត្រូវបានសាងសង់។<br>ថ្មីៗនេះ ការនេសាទត្រីនៅក្នុងអាងស្តុកទឹកបានធ្លាក់ចុះយ៉ាងខ្លាំង មកនៅក្រោមកម្រិតមុនពេលសាងសង់ LS2 ។ ពួកគេបានរាយការណ៍ពីការធ្លាក់ចុះប្រភេទត្រីជាក់លាក់ដែលពីមុនបានធ្វើបំលាស់ទីជម្រក ទៅខាងលើទន្លេ ចេញពីក្រោម LS2។ |
| ភូមិស្រែគរថ្មី ស្រុកសេសាន ខេត្តស្ទឹងត្រែង (តាំងទីលំនៅថ្មីពីផ្ទះនៅជាប់ទន្លេសេសាន សព្វថ្ងៃរស់នៅពីរបីគីឡូម៉ែត្រពីអាងស្តុកទឹក LS2) | | អ្នកភូមិបានរាយការណ៍ពីការកើនឡើងដំបូងនៃការនេសាទត្រីពីអាងស្តុកទឹក បន្ទាប់ពីទំនប់នេះត្រូវបានសាងសង់ បន្ទាប់មកក៏មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។<br><br>ពួកគេរាយការណ៍ថាប្រភេទត្រីដែលចូលចិត្តលំហូរទឹកទន្លេ បានបាត់បង់ភាគច្រើន ហើយមានការធ្លាក់ចុះប្រភេទត្រីដែលពីមុនបានធ្វើបំលាស់ទីជម្រកតាមខ្សែទឹកខាងលើ ចេញពីខ្សែទឹកខាងក្រោម LS2 ។ ពួកគេបានពន្យល់ថា ប្រភេទត្រីភាគច្រើនដែលពួកគេនេសាទបាននាពេលបច្ចុប្បន្ននេះ មិនធ្វើបំលាស់ទីជម្រកទេ រួមទាំងអម្បូរត្រីខ្មៅ ដូចជាត្រី Channa striata និង Channa marulius ជាមួយនឹងអម្បូរត្រី cyprinids មួយចំនួន ដែលអាចរស់ក្នុងទឹកទ្រឹងមិនហូរ ដូចជា Hypsibarbus ឬ Barbodes sp និង Puntioplites falcifer ជាដើម។ ត្រីថ្លៃបំផុតដែលពួកគេនៅតែអាចនេសាទបានជាទៀងទាត់គឺ Micronema sp។<br><br>ពួកគាត់មានការលំបាកក្នុងការចូលទៅនេសាទ ដោយសារចម្ងាយនៃទីកន្លែងតាំងទីលំនៅថ្មី ឆ្ងាយពីទឹក (២-៤ គីឡូម៉ែត្រ) (អ្នកភូមិ ភូមិស្រែគរចាស់ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៧)។ |
| **អ្នកភូមិខ្សែទឹកខាងលើ** | | |
| ភូមិឡំលាង ឃុំម៉ាលីក ស្រុកអណ្តូងមាស (ជនជាតិដើមភាគតិចចារាយ រស់នៅជាប់ព្រំដែនកម្ពុជា-វៀតណាម និងជាប់ទន្លេសេសាន) | ត្រីនេសាទបាន បរិភោគ និងលក់ | អ្នកភូមិរាយការណ៍ថា ប្រភេទត្រីបំលាស់ទីជម្រកសំខាន់ បានបាត់បង់ រួមមាន ត្រីប្រា Pangasius krempfi និង Pangasius conchophilus និង carps Labeo erythropterus, Incisilabeo behri , Mekongina erythrospila និង Henicorhynchus spp ហើយអម្បូរត្រី Paralaubuca typus ដែលពីមុនបានគ្របដណ្តប់លើការធ្វើបំលាស់ទីជម្រកអម្បូរត្រី cyprinid តូចៗ ពីបឹងទន្លេសាប ក៏បានបាត់បង់ផងដែរ។ |

| | | |
|---|---|---|
| | | អ្នកភូមិបញ្ជាក់ថា នៅមានពពួក Morulius sp., Hypsibarbus sp., និង cf. Garra sp ធ្វើបំលាស់ទីជម្រក នៅជិតភូមិរបស់ពួកគេ ដែលពួកគេជឿថាអាចមកពីអាងស្តុកទឹក LS2 (ដោយហេតុផលថាពួកវាធាត់ជាងប្រភេទត្រីទន្លេធម្មតានៃប្រភេទត្រីដូចគ្នានេះ)។ |
| ភូមិសៀងសាយ ស្រុកតាវែង ខេត្តរតនគិរី (ជនជាតិដើមភាគតិចព្នង មកពីខាងលិចស្រុកតាវែង) | ត្រីនេសាទបានបរិភោគ និងលក់ | អ្នកភូមិបានរាយការណ៍ពីការធ្លាក់ចុះយ៉ាងខ្លាំងនៃប្រភេទត្រីធ្វើបំលាស់ទីជម្រក ដែលទៅដល់ភូមិរបស់ពួកគេ ពីខ្សែទឹកខាងក្រោម LS2 ចាប់តាំងពីទំនប់នេះត្រូវបានសាងសង់ ដែលនាំឱ្យមានការធ្លាក់ចុះយ៉ាងខ្លាំងនៃស្តុកត្រី ការនេសាទត្រី និងជីវចម្រុះត្រី។ |
| ភូមិទឹមលើ ស្រុកវើនសៃ ខេត្តរតនគិរី (ជនជាតិដើមភាគតិចគ្រឹង មកពីមជ្ឈមណ្ឌលស្រុកវើនសៃ តាមដងទន្លេសេសាន) | ត្រីនេសាទបានបរិភោគ និងលក់ | អ្នកភូមិបានរាយការណ៍ថា ត្រីធ្វើបំលាស់ទីជម្រកតែមួយប្រភេទគត់ដែលពួកគេឃើញនៅពេលនេះ គឺជាប្រភេទត្រីធ្វើការបំលាស់ទីជម្រកនៅមូលដ្ឋាន ដូចជាអម្បូរ "ត្រីខ្មៅ" Channa striata និង Clarias sp. ពួកគេមកពីដៃទន្លេសេសាន មិនមែនមកពីខ្សែទឹកខាងក្រោម LS2 ទេ។<br><br>អ្នកភូមិជនជាតិដើមភាគតិចគ្រឹងបានបញ្ជាក់ថា វាកាន់តែពិបាកសម្រាប់ពួកគេក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរទាំងនេះ ជាងសហគមន៍ដែលមិនមែនជាជនជាតិដើមភាគតិច ដោយសារពួកគេមិនសូវមានជំនាញចម្រុះ។ ទោះយ៉ាងណាក៏ដោយ បច្ចុប្បន្នអ្នកភូមិកាន់តែច្រើនត្រូវបានគេរាយការណ៍ថា ធ្វើការជាកម្មករប្រចាំថ្ងៃកាប់ស្មៅ និងដាំដំឡូងមី ដោយសារតែជីវភាពរស់នៅតាមដងទន្លេមិនសូវមានលទ្ធភាពគ្រប់គ្រាន់។ |
| ភូមិហ្វាង ស្រុកវើនសៃ ខេត្តរតនគិរី (ជនជាតិឡាវរស់នៅតាមដងទន្លេ សេសាន ខ្សែទឹកខាងលើឆ្ងាយពីអាងស្តុកទឹក LS2) | ត្រីនេសាទបានបរិភោគ និងលក់ | អ្នកភូមិអះអាងថា ផលនេសាទរបស់ពួកគេបានធ្លាក់ចុះដល់ ១០ ភាគរយនៃកម្រិតមុនមានគម្រោង LS2 ដោយសារការបាត់បង់ត្រីធ្វើបំលាស់ទីជម្រក ដែលធ្លាប់ផ្លាស់ទីទៅកាន់ខ្សែទឹកខាងលើ ពីតំបន់ខាងក្រោមទំនប់ថ្មី។ ទន្លេសេសានក៏កាន់តែរាក់ដែរ ប្រហែលជាដោយសារទំនប់វារីអគ្គិសនី នៅវៀតណាម។<br><br>អ្នកភូមិបានរាយការណ៍ពីបញ្ហាខ្វះខាតត្រី ហើយត្រូវទិញត្រីភាគច្រើនពីផ្សារ។ ឥឡូវនេះ ពួកគេក៏ទទួលទានត្រីតាមរបៀបផ្សេងៗផងដែរ ដូចជាការញ៉ាំប្រហុកជាមួយអន្លក់បន្លែ ជំនួសឱ្យការញ៉ាំត្រីទាំងមូល។ ការធ្លាក់ចុះនៃការបរិភោគត្រីនេះ បានជះឥទ្ធិពលអវិជ្ជមានជាពិសេសទៅលើស្ត្រីដែលលែងលះគ្នា និងស្ត្រីមេម៉ាយក្រីក្រ ដោយសារតែអ្នកជិតខាងធ្លាប់ផ្តល់ឱ្យពួកគេបរិមាណត្រីដ៏ច្រើន |

| | | |
|---|---|---|
| | | ដែលឥឡូវនេះលែងមានទៀតហើយ។<br>ប្រជាពលរដ្ឋបានងាកមកធ្វើស្រែចំការវិលជុំ ឬប្តូរវេននៅតាមព្រៃក្បែរៗនោះ នេសាទតាមដងអូរច្រើនជាងមុន និងប្រើឆក់ត្រីកាន់តែច្រើនឡើង ដោយក្តីអស់សង្ឃឹម ដោយសារការបាត់បង់ជីវភាពរស់នៅពីការថយចុះត្រី នៅក្នុងទន្លេសេសាន។ |
| មជ្ឈមណ្ឌលស្រុកលំផាត់ ស្រុកលំផាត់ ខេត្តរតនគិរី (ជនជាតិឡាវ និងខ្មែររស់តាមដងទន្លេស្រែពក នៅឆ្ងាយពីអាងស្តុកទឹក LS2) | ត្រីនេសាទបានបរិភោគ និងលក់ | អ្នកភូមិរាយការណ៍ថា ផលផលបានធ្លាក់ចុះយ៉ាងខ្លាំង ចាប់តាំងពីទំនប់ LS2 ត្រូវបានសាងសង់ ជាពិសេសសម្រាប់ប្រភេទត្រីធ្វើបំលាស់ទីជម្រក ដូចជា Mekongina erythrospila, Labeo erythropterus និងត្រី Pangasius ។ ឆ្នាំដំបូងបន្ទាប់ពីទំនប់បិទ ពួកគេបានបន្តនេសាទត្រី Henicorhynchus spp ក្នុងបរិមាណគួរសម ប៉ុន្តែការនេសាទបានធ្លាក់ចុះយ៉ាងខ្លាំង នៅឆ្នាំទី២ និងឆ្នាំទី៣ ជាពេលវេលា ដែលពួកវានេសាទបានត្រីប្រភេទនេះតិចតួចបំផុត។ ពួកគេបានរាយការណ៍ថានៅតែនេសាទបានត្រី Scaphognathops bandanensis ប៉ុន្តែបានត្រឹមតែ ៣០-៣៥ ភាគរយនៃការនេសាទពីមុនប៉ុណ្ណោះ។<br>ការបរិភោគត្រីរបស់ភូមិនេះបានរងផលប៉ះពាល់យ៉ាងខ្លាំង។ ពីមុនអ្នកភូមិហូបត្រីបីពេលក្នុងមួយថ្ងៃ ប៉ុន្តែឥឡូវតែមួយពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ហើយពេលខ្លះមានតិចតួចរហូតដល់តែមួយពេលក្នុងមួយសប្តាហ៍ក៏មាន។ ពួកគេជឿផងដែរថា ការនេសាទដោយឆក់កំពុងធ្វើឱ្យបញ្ហាកាន់តែដុនដាបឡើងៗ បង្កឡើងដោយប្រជាជនពលរដ្ឋដែលអស់សង្ឃឹម ដោយសារតែការបាត់បង់ត្រី ដោយសារ LS2 និងទំនប់នៅវៀតណាម ដែលបណ្តាលឱ្យមានការប្រែប្រួលទឹក និងសំណឹកច្រាំងទន្លេ។ ប្រជាពលរដ្ឋឥឡូវតែងតែទិញត្រីពីអ្នកលក់តាមម៉ូតូដឹកដល់សហគមន៍ពួកគេ។<br>លទ្ធផលចុងក្រោយ គឺផលប៉ះពាល់អវិជ្ជមានលើប្រាក់ចំណូល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរួមចំណែកដល់ការកើនឡើងបំណុលរបស់អ្នកភូមិ និងប្រជាពលរដ្ឋមួយចំនួនលក់ដីរបស់ពួកគេ។<br>ដើម្បីប៉ះប៉ូវការបាត់បង់នេះ ប្រជាពលរដ្ឋកាន់តែច្រើនដាំដំឡូងមី ចិញ្ចឹមសត្វ និងធ្វើការជាកម្មករ។<br>អ្នកភូមិពីស្រុកលំផាត់ក៏ជឿថា ទឹកជំនន់កាន់តែអាក្រក់ទៅៗ គឺដោយសារផលប៉ះពាល់ដែលប្រមូលផ្តុំពាក់ព័ន្ធនឹងអាងស្តុកទឹក LS2។ ទោះជាយ៉ាងនេះក្តី វាហាក់បីដូចជាផលប៉ះពាល់ទាំងនេះ គឺ |

| | | |
|---|---|---|
| | | ដោយសារទំនប់ទឹកនៅវៀតណាម។ អ្នកភូមិបានទទួលអង្ករតិចតួច (ចង់ទម្ងន់២៥គីឡូក្រាម) ជាជំនួយសង្គ្រោះគ្រោះធម្មជាតិ ពីម្ចាស់ជំនួយអន្តរជាតិ តាមរយៈរដ្ឋាភិបាលកម្ពុជា។<br>ពួកគេបានរាយការណ៍ទៅមន្ត្រីខេត្តថា ពួកគេជឿថាអាងស្តុកទឹក LS2 កំពុងធ្វើឱ្យទឹកជំនន់កាន់តែអាក្រក់នៅក្នុងភូមិរបស់ពួកគេ ប៉ុន្តែមន្ត្រីរដ្ឋាភិបាលបានឆ្លើយតបថា ពួកគេនៅឆ្ងាយពីអាងស្តុកទឹក LS2 ខ្លាំងណាស់មិនអាចរងផលប៉ះពាល់ទេ។ |
| ភូមិសង្គម (ឬហៅថាភូមិ៥) ស្រុកលំផាត់ ខេត្តរតនគិរី (ជនជាតិខ្មែររស់តាមដងទន្លេស្រែពក ឆ្ងាយពីអាងស្តុកទឹក LS2) | ត្រីនេសាទបាន បរិភោគ និងលក់ | អ្នកភូមិ៥ ក៏ជឿថា ទឹកជំនន់កាន់តែអាក្រក់ឡើងដោយសារផលប៉ះពាល់ដែលប្រមូលផ្តុំពាក់ព័ន្ធនឹងអាងស្តុកទឹក LS2។ ទោះជាយ៉ាងណាក៏ដោយ វាហាក់បីដូចជាផលប៉ះពាល់ទាំងនេះគឺដោយសារទំនប់ទឹកនៅវៀតណាម ដោយសារភូមិ៥ គឺនៅឆ្ងាយខ្លាំងពីអាងស្តុកទឹក និងដូចអ្វីដែលអ្នកភូមិលំផាត់ បានទទួលការឆ្លើយតបពីមន្ត្រីរដ្ឋាភិបាល។<br>អ្នកភូមិ៥ បានទទួលជំនួយមួយចំនួនក្នុងទម្រង់ជាអង្ករ ២៥គីឡូក្រាម ជាការសង្គ្រោះគ្រោះធម្មជាតិពីម្ចាស់ជំនួយអន្តរជាតិ តាមរយៈរដ្ឋាភិបាលកម្ពុជា។<br>អ្នកភូមិភូមិទី៥ បានរាយការណ៍ពីការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃប្រភេទត្រីបំលាស់ទីជម្រក រួមទាំងត្រភេទត្រីផ្លាស់ទីទាំងរដូវប្រាំង និងរដូវវស្សា ដូចជាត្រី carps និងត្រី catfishes ដែលត្រូវបានគេជឿថាត្រូវបាន LS2 រាំងស្ទះមិនឱ្យផ្លាស់ទីឡើងទៅខ្សែទឹកខាងលើទន្លេស្រែពក ពីទន្លេមេគង្គ ។ ម្យ៉ាងវិញទៀត វាបានជះឥទ្ធិពលអវិជ្ជមានដល់ជីវភាពរស់នៅ តាមរយៈការកាត់បន្ថយសន្តិសុខស្បៀង និងប្រាក់ចំណូលពីការលក់ត្រី។ |
| ស្រែអង្គ្រង ស្រុកកូនមុំ ខេត្តរតនគិរី (ជនជាតិខ្មែរ ឡាវ និងជនជាតិដើមភាគតិចមួយចំនួនតូចទៀត រួមមាន ព្នង ទំពួន គ្រឹង ស្ថិតនៅចម្ងាយប្រហែល ៣០ គីឡូម៉ែត្រ ទៅខាងលើទន្លេស្រែពក ពីភូមិក្របៅជ្រុំ) | ត្រីនេសាទបាន បរិភោគ និងលក់ | អ្នកភូមិរាយការណ៍ថា ជលផលបានធ្លាក់ចុះយ៉ាងខ្លាំងចាប់តាំងពីទំនប់ LS2 ត្រូវបានសាងសង់ ជាពិសេសសម្រាប់ប្រភេទត្រីធ្វើការបំលាស់ទីជម្រក រួមមានត្រី Mekongina erythrospila, Labeo erythropterus និងត្រី Pangasius ។ នៅឆ្នាំដំបូងបន្ទាប់ពីទំបន់ទ្វារ LS2 ត្រូវបានបិទ ពួកគេនេសាទបានត្រី Henicorhynchus spp ក្នុងបរិមាណសមរម្យ ប៉ុន្តែការនេសាទត្រីទាំងនោះបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំទីពីរ និងស្ទើរតែគ្មាននៅឆ្នាំទីបី។ ភូមិនានារាយការណ៍ថានៅតែនេសាទបានត្រី Scaphognathops bandanensis ប៉ុន្តែបានត្រឹមតែ ៣០-៣៥ ភាគរយប៉ុណ្ណោះនៃបរិមាណនេសាទពី |

| | | |
|---|---|---|
| | | មុនរបស់ពួកគេ។<br><br>ចំណុចនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការទទួលទានត្រីរបស់ពួកគេ ដែលបានធ្លាក់ចុះពីបីពេលក្នុងមួយថ្ងៃ មកនៅមួយពេលក្នុងមួយថ្ងៃ និងពេលខ្លះទៀតត្រឹមតែមួយពេលប៉ុណ្ណោះក្នុងមួយសប្ដាហ៍។ ដូចអ្នកភូមិលំផាត់ដែរ ពួកគេក៏ជឿថា ការនេសាទដោយឆក់កំពុងធ្វើឱ្យបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗ។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋតែងតែទិញត្រីពីអ្នកលក់តាមម៉ូតូដែលជឹកដល់សហគមន៍ពួកគេ។<br><br>លទ្ធផលចុងក្រោយ គឺផលប៉ះពាល់អវិជ្ជមានលើប្រាក់ចំណូល សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលរួមចំណែកដល់ការកើនឡើងបំណុលរបស់អ្នកភូមិ និងប្រជាជនមួយចំនួនលក់ដីរបស់ពួកគេ។ ដើម្បីប៉ះប៉ូវការបាត់បង់នេះ ប្រជាពលរដ្ឋកាន់តែច្រើននាំគ្នាដាំដំឡូងមី ចិញ្ចឹមសត្វ និងធ្វើការជាកម្មករ។<br><br>អ្នកភូមិបានរាយការណ៍ថា ពួកគេបោះបង់ដីស្រែត្រូវចោល ដោយសារទឹកជំនន់រដូវវស្សាជាប្រចាំដែលពាក់ព័ន្ធនឹងអាងស្តុកទឹក[302] ធ្វើឱ្យពួកគេបាត់បង់ផ្នែកកសិកម្ម។ សហគមន៍ស្ថិតនៅចម្ងាយសមល្មមពីអាងស្តុកទឹក ដែលអាចនឹងរងផលប៉ះពាល់បាន ដែលមិនដូចតំបន់ខ្លះនៅខាងលើទឹកឆ្ងាយនោះទេ។ ប្រជាពលរដ្ឋចំនួន១០គ្រួសារអះអាងថា ពួកគេបានបាត់បង់ដីស្រែទំនាបមួយផ្នែក ដែលពួកគេបានរាយការណ៍ទៅរដ្ឋាភិបាលខេត្តរតនគិរី ដោយមិនទាន់មានការឆ្លើយតបនៅឡើយ។ ត្រូវការធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីវាយតម្លៃអំពីស្ថានភាពនេះ។ |

[302] អ្នកភូមិយល់ថា បញ្ហាចម្បងគឺការទប់និងបម្រុងទឹកទន្លេ ដោយអាងស្តុកទឹក LS2។

## ឧបសម្ព័ន្ធ គ៖ ទិដ្ឋភាពទូទៅនៃដំណើរការស៊ើបអង្កេតរបស់ ស៊ីអេអូ

"គោលបំណងនៃមុខងារភាពអនុលោមភាពរបស់ ស៊ីអេអូ គឺដើម្បីអនុវត្តការពិនិត្យឡើងវិញនៃភាពអនុលោមរបស់ IFC/MIGA ទៅតាមគោលនយោបាយ E&S វាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ និងផ្តល់ជាអនុសាសន៍អំពីវិធានការដោះស្រាយតាមការសមស្រប។"[303] មុខងារភាពអនុលោម មិនវាយតម្លៃពីភាពគ្រប់គ្រាន់ ឬភាពសមស្របនៃគោលនយោបាយ E&S ទេ ហើយក៏មិនបង្កើតគំហើញទាក់ទងនឹងភាពអនុលោមរបស់គម្រោង អនុគម្រោង អតិថិជន ឬអតិថិជនបន្ត ទៅតាមស្តង់ដារសមិទ្ធិកម្ម IFC ទេ។[304] ទោះយ៉ាងណាក៏ដោយ ក្នុងការអនុវត្តតួនាទីរបស់ខ្លួន មុខងារភាពអនុលោម ស៊ីអេអូ នឹងវាយតម្លៃលើការពិនិត្យឡើងវិញ និងការត្រួតពិនិត្យនៃលក្ខខណ្ឌតម្រូវ E&S នៅកម្រិតគម្រោង និងអនុគម្រោង របស់ IFC/MIGA ព្រមទាំងពិចារណាលើការអនុវត្ត E&S កម្រិតគម្រោង ឬអនុគម្រោង។[305]

គួរកត់សម្គាល់ថា ស៊ីអេអូ មិនមានសិទ្ធិអំណាចទាក់ទងនឹងដំណើរការតុលាការទេ។ ស៊ីអេអូ គឺមិនមែនជាតុលាការឧទ្ធរណ៍ យន្តការអនុវត្តច្បាប់ ឬការជំនួសឱ្យប្រព័ន្ធតុលាការអន្តរជាតិ ឬប្រព័ន្ធតុលាការនៅក្នុងប្រទេសម្ចាស់ផ្ទះនោះទេ។

ស្របតាមការរៀបចំអន្តរកាលដែលបានព្រមព្រៀងជាផ្នែកនៃដំណើរការគោលនយោបាយ ស៊ីអេអូ ក្នុងឆ្នាំ ២០២១[306] របាយការណ៍វាយតម្លៃភាពអនុលោម និងការស៊ើបអង្កេត ត្រូវបានរៀបចំឡើងតាមគោលនយោបាយ ស៊ីអេអូ ។ រាល់ការងារមុនទាំងអស់ រួមទាំងការវាយតម្លៃ ត្រូវបានធ្វើឡើង ទៅតាមគោលការណ៍ណែនាំប្រតិបត្តិការឆ្នាំ ២០១៣ របស់ ស៊ីអេអូ ។

### ការស៊ើបអង្កេត

ការស៊ើបអង្កេតភាពអនុលោម ស៊ីអេអូ ផ្តោតលើ IFC/MIGA និងរបៀបដែល IFC/MIGA ធានាបាននូវការអនុវត្ត E&S របស់គម្រោង។ គោលបំណងនៃការស៊ើបអង្កេតភាពអនុលោម គឺដើម្បីកំណត់៖

(1) ថាតើ IFC/MIGA បានអនុលោមតាមគោលការណ៍ E&S របស់ខ្លួន ដែរឬទេ និង

(2) ថាតើមានការបង្កគ្រោះថ្នាក់ ឬលទ្ធភាពគ្រោះថ្នាក់ពាក់ព័ន្ធនឹងភាពមិនអនុលោមណាមួយ របស់ IFC/MIGA ដែរឬទេ។[307]

---

[303] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ៧៦។

[304] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ៧៧ ។

[305] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ៧៧។

[306] ការរៀបចំអន្តរកាលសម្រាប់ករណី ស៊ីអេអូ ។ មាននៅលើគេហទំព័ររបស់ ស៊ីអេអូ ៖https://officecao.org/Transition ។

[307] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១២។

ក្នុងការវាយតម្លៃការអនុវត្ត E&S របស់ IFC/MIGA វាជារឿយៗចាំបាច់សម្រាប់ ស៊ីអេអូ ពិនិត្យមើលសកម្មភាពអតិថិជនរបស់ IFC/MIGA និងផ្ទៀងផ្ទាត់លទ្ធផល E&S នៅតាមវាល។

## វិសាលភាព និងវិធីសាស្ត្រ[308]

វិសាលភាពនៃការស៊ើបអង្កេតភាពអនុលោម ត្រូវបានកំណត់នៅក្នុងលក្ខខណ្ឌយោងនៃការស៊ើបអង្កេត ដែលបានបោះពុម្ពផ្សាយរួមជាមួយនឹងរបាយការណ៍វាយតម្លៃរបស់ ស៊ីអេអូ ។ ការស៊ើបអង្កេតភាពអនុលោម គឺផ្អែកលើព័ត៌មានដែល ស៊ីអេអូ អាចស្វែងរកបានពីឯកសារនានា ការសម្ភាសន៍ សេចក្តីថ្លែងការណ៍ របាយការណ៍ ការឆ្លើយឆ្លង ការសង្កេតរបស់ស៊ីអេអូលើសកម្មភាព និងលក្ខខណ្ឌផ្សេងៗ ព្រមទាំងប្រភពផ្សេងទៀតដែល ស៊ីអេអូ យល់ថាមានភាពពាក់ព័ន្ធ។ របាយការណ៍ស៊ើបអង្កេតរបស់ ស៊ីអេអូ នឹងរួមបញ្ចូលគំហើញ នៃការស៊ើបអង្កេត ទាក់ទងនឹងភាពអនុលោមភាព ភាពមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធណាមួយ។ របាយការណ៍នេះក៏នឹងរួមបញ្ចូលផងដែរនូវបរិបទ ភស្តុតាង និងហេតុផលគាំទ្រគំហើញ និងសេចក្តីសន្និដ្ឋានរបស់ ស៊ីអេអូ ទាក់ទងនឹងមូលហេតុឫសគល់ នៃភាពមិនអនុលោមណាមួយ ដែលបានរកឃើញ។[309]

មានការតម្រូវឱ្យមានភស្តុតាងពាក់ព័ន្ធគ្រប់គ្រាន់ ដើម្បីផ្តល់ជាមូលដ្ឋានសមហេតុផលសម្រាប់គំហើញ និងសេចក្តីសន្និដ្ឋានទៅលើភាពអនុលោម របស់ស៊ីអេអូ ។[310] ស៊ីអេអូ នឹងមិនបង្កើតគំហើញ និងសេចក្តីសន្និដ្ឋាន ដោយផ្អែកលើអ្វីដែលបានដឹងរួចហើយនោះទេ។[311] ផ្ទុយទៅវិញ ស៊ីអេអូ នឹងវាយតម្លៃថាតើមានភស្តុតាងដែល IFC/MIGA បានអនុវត្តលក្ខខណ្ឌ E&S ដែលពាក់ព័ន្ធ ដោយពិចារណាទៅលើប្រភពនៃព័ត៌មានដែលមាន នៅពេលធ្វើសេចក្តីសម្រេចចិត្ត។[312] លើសពីនេះ ខណៈពេលដែល ស៊ីអេអូ អាចនឹងស្វែងរកការបំភ្លឺ ក្នុងអំឡុងពេលស៊ើបអង្កេតនេះ ស៊ីអេអូនឹងមិនទទួលយកការពង្រីកវិសាលភាពឆ្ងាយពីអ្វីដែលបានកំណត់នៅក្នុងលក្ខខណ្ឌនៃឯកសារយោងនោះទេ។ ប្រសិនបើបញ្ហា ឬក្តីកង្វល់បន្ថែមកើតឡើង ក្នុងអំឡុងពេលស៊ើបអង្កេត ទាំងនេះអាចជាកម្មវត្ថុនៃការវាយតម្លៃដាច់ដោយឡែក ទៅតាមឆន្ទានុសិទ្ធិរបស់អគ្គនាយក ស៊ីអេអូ ។

ការស៊ើបអង្កេតភាពអនុលោម ស៊ីអេអូ មិនមែនជាដំណើរការតុលាការ ឬផ្លូវច្បាប់ទេ។[313]ស៊ីអេអូ ដើរតាមគំរូដែលមិនមែនជាគូបដិបក្ខ ដែលក្នុងនោះស៊ីអេអូ "ពិចារណាជាលក្ខណៈប្រព័ន្ធ និងប្រកបដោយសត្យានុម័ត ចំពោះកម្មវត្ថុនៃអង្គហេតុ កាលៈទេសៈ ព័ត៌មាន និងភស្តុតាង ដែលខ្លួនអាចស្វែងរកបាន ពីឯកសារផ្សេងៗ ការសម្ភាសន៍

---

[308] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៥, ១១៧, និង ១១៨។

[309] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១២០(ខ)។

[310] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៧។

[311] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៦។

[312] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៦។

[313] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ៩។

សេចក្តីថ្លែងការណ៍ របាយការណ៍ ការឆ្លើយឆ្លង និងប្រភពផ្សេងទៀត ដូចដែល ស៊ីអេអូ កំណត់ថាមានភាពពាក់ព័ន្ធ" [ បន្ថែមការគូសបញ្ជាក់] ។[314] គំហើញ និងសេចក្តីសន្និដ្ឋានលើភាពអនុលោម របស់ស៊ីអេអូ គឺផ្អែកលើភស្តុតាង "គ្រប់គ្រាន់ និងពាក់ព័ន្ធ" ដូចដែលអាចស្វែងរកបាន។[315] ជាមួយគ្នានេះផងដែរ ក្នុងលក្ខណៈជាដំណើរការមិនមែនជាគូបដិបក្ខ ស៊ីអេអូ ទទួលបានព័ត៌មានពីប្រភពជាច្រើន។ ដើមបណ្តឹងមិនតម្រូវឱ្យដាក់ភស្តុតាង ឬឯកសារគាំទ្រការចោទប្រកាន់របស់ពួកគេឡើយ។ ខណៈពេលដែលដើមបណ្តឹងអាចជ្រើសរើសដាក់បញ្ជូនភស្តុតាង[316] នៅក្រោមគោលនយោបាយ ស៊ីអេអូ ចំណុចនេះមិនមែនជាលក្ខខណ្ឌតម្រូវក្នុងការដាក់ពាក្យបណ្តឹង ឬសម្រាប់ ស៊ីអេអូ ដើម្បីឈានទៅរកគំហើញនៃភាពមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធនោះទេ។

គោលនយោបាយ E&S របស់ IFC បង្កើតទំនួលខុសត្រូវរបស់ IFC និងអតិថិជនរបស់ខ្លួនក្នុងការប្រមូល ឬចងក្រងព័ត៌មានអំពីការអនុវត្ត E&S របស់គម្រោង។[317]ក្នុងការវាយតម្លៃថាតើមានការបង្កគ្រោះថ្នាក់ទាក់ទងនឹងការរកឃើញភាពមិនអនុលោម ស៊ីអេអូ នឹងពិចារណាថាតើ ភាពមិនអនុលោមរបស់ IFC បានរួមចំណែកដល់អវត្តមាននៃទិន្នន័យ ឬព័ត៌មានដែលត្រូវការ ដើម្បីផ្ទៀងផ្ទាត់ការចោទប្រកាន់របស់ដើមបណ្តឹងអំពីគ្រោះថ្នាក់ ដែរឬទេ។ ក្នុងកាលៈទេសៈបែបនេះ ស៊ីអេអូ អាចនឹងរកឃើញថា មាន "ការចង្អុលបង្ហាញអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ" នៅពេលដែលវាទំនងជាហេតុផលដែលថា គ្រោះថ្នាក់ដែលបានលើកឡើងដោយដើមបណ្តឹង បានកើតឡើង ឬអាចនឹងកើតឡើងនាពេលអនាគត។

ទាក់ទងនឹងគំហើញណាមួយនៃភាពមិនអនុលោម IFC/MIGA និងគ្រោះថ្នាក់ពាក់ព័ន្ធ ស៊ីអេអូ នឹងផ្តល់ជាអនុសាសន៍សម្រាប់ IFC/MIGA ដើម្បីពិចារណាក្នុងការអភិវឌ្ឍផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង (MAP) ទាក់ទងនឹងការដោះស្រាយភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ របស់គម្រោង ឬកម្រិតអនុគម្រោង និង/ឬ ជំហានដែលត្រូវអនុវត្តដើម្បីទប់ស្កាត់ភាពមិនអនុលោមនាពេលអនាគត ដែលពាក់ព័ន្ធនៅក្នុងកាលៈទេសៈនានា។[318]អនុសាសន៍នឹងគិតគូរពីផលបច្ច័យនៃច្រកចេញ IFC/MIGA ណាមួយ។[319]

## គំហើញអំពីគ្រោះថ្នាក់

---

[314] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៥ និង ១១៧។

[315] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៧.

[316] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ៣២ និង ៣៤(ឃ)។

[317] សូមមើលឧទាហរណ៍ គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០០៦ កថាខណ្ឌ ១៥ និង ២៦; PS១ ឆ្នាំ២០០៦, កថាខណ្ឌ ៩, ១៤, ១៦, ២១, ២២, ២៤, ២៥, ២៦; គោលនយោបាយនិរន្តរភាពរបស់ IFC ឆ្នាំ២០១២, កថខណ្ឌ ២៨, ៤៥; PS១ ឆ្នាំ ២០១២, កថាខណ្ឌ ៧, ១៤, ២៣, ២៤, ៣០, និង ៣៤។ សូមមើលផងដែរ គោលនយោបាយ ស៊ីអេអូ កថាខណ្ឌ ១១៤ ទាក់ទងនឹងតម្រូវការ របស់ ស៊ីអេអូ ដើម្បីវាយតម្លៃការពិនិត្យមើលឡើងវិញរបស់ IFC និងការត្រួតពិនិត្យលក្ខខណ្ឌតម្រូវ E&S របស់ខ្លួននៅកម្រិតគម្រោង និងអនុគម្រោង នៅពេលពិចារណាលើគំហើញនៃគ្រោះថ្នាក់។

[318] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១២០(គ)។

[319] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១២០(គ)។

ស្តង់ដារដែលយកមកអនុវត្តនៅក្នុងការស៊ើបអង្កេតភាពអនុលោម របស់ ស៊ីអេអូ សម្រាប់ការវាយតម្លៃ "គ្រោះថ្នាក់" ដែលពាក់ព័ន្ធ ត្រូវបានចែងនៅក្នុងគោលនយោបាយ ស៊ីអេអូ ។ វាកំណត់និយមន័យ "គ្រោះថ្នាក់" ជា "ផលប៉ះពាល់បរិស្ថាន និងសង្គមអវិជ្ជមាន មកលើមនុស្ស ឬបរិស្ថាន ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីគម្រោង ឬអនុគម្រោង។ គ្រោះថ្នាក់អាចនឹងកើតមានជាក់ស្តែង ឬទំនងជាអាចនឹងកើតមាននៅពេលអនាគត"។ សេចក្តីយោងផ្សេងៗទៅលើ "គ្រោះថ្នាក់" ដែលមិនត្រូវបានសរសេរជាអក្សរធំ គួរតែត្រូវបានបកស្រាយទៅតាមអត្ថន័យធម្មតា និងជាប្រពៃណីដែលបានផ្តល់ឱ្យពាក្យនេះ។[320]

បន្ទាប់ពីការរកឃើញនៃភាពមិនអនុលោមតាម IFC/MIGA របាយការណ៍ស៊ើបអង្កេតភាពអនុលោម ស៊ីអេអូ នឹងធ្វើការវាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ ដូចខាងក្រោម៖

- មានគ្រោះថ្នាក់ដល់ដើមបណ្តឹង។ អាចធ្វើសេចក្តីសន្និដ្ឋានបែបនេះបាន នៅពេលមានភស្តុតាងពាក់ព័ន្ធគ្រប់គ្រាន់ ដើម្បីផ្តល់ជាមូលដ្ឋានសមហេតុផលមួយសម្រាប់ការសន្និដ្ឋានភាពអនុលោម របស់ ស៊ីអេអូ។
- មានការចង្អុលបង្ហាញផ្សេងៗអំពីគ្រោះថ្នាក់ចំពោះដើមបណ្តឹង។ អាចធ្វើសេចក្តីសន្និដ្ឋានបែបនេះបាន ដោយផ្អែកលើភស្តុតាងដែលអាចស្វែងរកបាន ដែលនឹងបង្ហាញពីលទ្ធភាពដែលថា គ្រោះថ្នាក់កើតឡើងពិតប្រាកដ ឬទំនងជាបានកើតឡើង ឬអាចនឹងកើតឡើងនាពេលអនាគត។ នៅពេលភាពមិនអនុលោមរបស់ IFC/MIGA បានរួមចំណែកដល់អវត្តមានទិន្នន័យ ឬព័ត៌មានដែលត្រូវការ ដើម្បីផ្ទៀងផ្ទាត់ការចោទប្រកាន់របស់ដើមបណ្តឹងអំពីគ្រោះថ្នាក់ ស៊ីអេអូ អាចនឹងរកឃើញថា មាន "ការចង្អុលបង្ហាញអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ" នៅពេលដែលវាទំនងជាថា គ្រោះថ្នាក់ដែលដើមបណ្តឹងបានចោទប្រកាន់ បានកើតឡើងពិតមែន ឬអាចនឹងកើតឡើងនាពេលអនាគត។
- មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីឈានទៅធ្វើសេចក្តីសន្និដ្ឋានអំពីគ្រោះថ្នាក់ចំពោះដើមបណ្តឹង។

## ការបិទបញ្ចប់របាយការណ៍ស៊ើបអង្កេត

នៅពេលទទួលបានមតិយោបល់លើសេចក្តីព្រាងរបាយការណ៍ស៊ើបអង្កេតពី IFC/MIGA និងដើមបណ្តឹងរួចមក ស៊ីអេអូ នឹងបិទបញ្ចប់របាយការណ៍ស៊ើបអង្កេតរបស់ខ្លួន។ នៅពេលដែលរបាយការណ៍ស៊ើបអង្កេតស្ថាពរ ត្រូវបានធ្វើជូនជាផ្លូវការ ជូនដល់គណៈគ្រប់គ្រង IFC/MIGA ហើយបានផ្សព្វផ្សាយទៅកាន់ក្រុមប្រឹក្សាភិបាល គេហទំព័ររបស់ស៊ីអេអូ នឹងជូនដំណឹងដល់សាធារណជនអំពីការបិទបញ្ចប់ការស៊ើបអង្កេតនេះ។[321]

នៅពេលធ្វើជូនជាផ្លូវការរបាយការណ៍ស៊ើបអង្កេតភាពអនុលោម របស់ស៊ីអេអូ ជូនដល់គណៈគ្រប់ IFC/MIGA, គណៈគ្រប់គ្រង IFC/MIGA មានរយៈពេល ៥0 ថ្ងៃនៃថ្ងៃធ្វើការដើម្បីបញ្ជូនរបាយការណ៍គ្រប់គ្រងទៅក្រុមប្រឹក្សាភិបាល ដើម្បីពិចារណា។ របាយការណ៍គ្រប់គ្រង ត្រូវតែរួមបញ្ចូល MAP ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។

---

[320] គោលនយោបាយ ស៊ីអេអូ សទ្ទានុក្រម និងលេខយោង២ នៅក្នុងគោលនយោបាយ ស៊ីអេអូ ។

[321] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១២៨។

MAP គូសបញ្ជាក់ពីសកម្មភាពនានា ដែល IFC/MIGA ស្នើឡើង ក្នុងការឆ្លើយតបទៅនឹងលទ្ធផលស៊ើបអង្កេត របស់ ស៊ីអេអូ ។ IFC/MIGA ត្រូវពិគ្រោះយោបល់ជាមួយដើមបណ្ដឹង និងអតិថិជន ក្នុងអំឡុងពេលនៃដំណើរការរៀបចំ MAP របស់ខ្លួន។[322]

ក្នុងពេលជាមួយគ្នាដែល IFC/MIGA បង្ហាញ MAP ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាភិបាល ស៊ីអេអូ នឹងបញ្ជូនមតិយោបល់ទៅលើ MAP ដែលត្រូវបានស្នើឡើង ទៅកាន់ក្រុមប្រឹក្សាភិបាល។ ក្រោយពេលក្រុមប្រឹក្សាភិបាលអនុម័ត MAP, របាយការណ៍ស៊ើបអង្កេតភាពអនុលោម របាយការណ៍គ្រប់គ្រង និង MAP នឹងត្រូវបានបោះពុម្ពផ្សាយ នៅលើគេហទំព័ររបស់ស៊ីអេអូ ។[323]

---

[322] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៣០–១៣១ និង ១៣៤។

[323] គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៣៥ និង ១៣៨។

## ឧបសម្ព័ន្ធ ឃ៖ គំហើញរបស់ ស៊ីអេអូ អំពីភាពមិនអនុលោម គ្រោះថ្នាក់ពាក់ព័ន្ធ និងអនុសាសន៍

អនុលោមតាមគោលនយោបាយ ស៊ីអេអូ ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតភាពអនុលោមនេះ គណៈគ្រប់គ្រង IFC តម្រូវឱ្យរៀបចំរបាយការណ៍គ្រប់គ្រងមួយ។[324]សម្រាប់គោលបំណងនៃការឆ្លើយតបប្រសិនបើមានណាមួយទៅនឹងគំហើញនៃភាពមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ របស់ ស៊ីអេអូ របាយការណ៍គ្រប់គ្រង នឹងដាក់បញ្ចូលផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រង (MAP) ដែលរួមមានសកម្មភាពដោះស្រាយពេលវេលាកំណត់ដែលបានស្នើឡើងដោយគណៈគ្រប់គ្រង ដើម្បីសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។[325] ជាជម្រើសផ្សេងទៀត របាយការណ៍គ្រប់គ្រងគួរតែរួមបញ្ចូលការឆ្លើយតបដោយមានហេតុផលចំពោះគំហើញ ឬអនុសាសន៍របស់ ស៊ីអេអូ ទាក់ទងនឹងភាពមិនអនុលោម ឬគ្រោះថ្នាក់ពាក់ព័ន្ធ ដែល IFC មិនអាចដោះស្រាយនៅក្នុង MAP។[326] ប្រសិនបើក្រុមប្រឹក្សាភិបាលអនុម័ត MAP នោះការត្រួតពិនិត្យតាមដានរបស់ ស៊ីអេអូ នឹងផ្ទៀងផ្ទាត់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃសកម្មភាពដែលមានចែងនៅក្នុង MAP។[327]ការត្រួតពិនិត្យតាមដានភាពអនុលោម របស់ស៊ីអេអូ នឹងមិនពិចារណាទៅលើគំហើញភាពមិនអនុលោម ដែលមិនមានសកម្មភាពកែតម្រូវដែលត្រូវគ្នា នៅក្នុង MAP នោះទេ។[328]

នៅក្នុងតារាង ឃ.១ ជួរទីមួយបង្ហាញពីគំហើញរបស់ស៊ីអេអូ ស្តីពីភាពអនុលោម និងការវាយតម្លៃលើគ្រោះថ្នាក់ពាក់ព័ន្ធ ។ ស៊ីអេអូ នឹងបំពេញជួរទីពីរ ក្នុងអំឡុងពេលនៃការត្រួតពិនិត្យតាមដានភាពអនុលោមលើកសំណុំរឿងនេះ ដោយផ្អែកលើផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រងអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ IFC ។

នៅក្នុងតារាង ឃ.២[329] ដើម្បីឆ្លើយតបទៅនឹងគំហើញរបស់ស៊ីអេអូ អំពីភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ និងយោងទៅតាមគោលនយោបាយ ស៊ីអេអូ

---

324 គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៣០។
325 គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៣១។
326 គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៣២ ។
327 គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៤០។
328 គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១៤១។
329 គោលនយោបាយ ស៊ីអេអូ, កថាខណ្ឌ ១១៣។

ស៊ីអេអូ សូមផ្ដល់ជាអនុសាសន៍ដូចខាងក្រោម ជូនដល់ IFC ដើម្បីពិចារណានៅពេលបង្កើតផែនការសកម្មភាពសម្រាប់ថ្នាក់គ្រប់គ្រងរបស់ខ្លួន។ អនុសាសន៍ទាំងនេះទាក់ទងនឹងការដោះស្រាយភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ នៅកម្រិតគម្រោង ក៏ដូចជាជំហានចាំបាច់នានាក្នុងការទប់ស្កាត់មិនអនុលោមនាពេលអនាគត។

**តារាង ឃ.១៖ ការរកឃើញរបស់ស៊ីអេអូ ស្ដីពីភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ ព្រមទាំងសកម្មភាពដោះស្រាយសំណង ឬយុត្តិកម្មសម្រាប់ការមិនបន្តសកម្មភាពដោះស្រាយ របស់IFC**

ស៊ីអេអូ រកឃើញថា ការពិនិត្យមើល និងការត្រួតពិនិត្យប្រតិបត្តិការរបស់ ABBank មុនការវិនិយោគរបស់ IFC គឺមិនអនុលោមតាមទំនួលខុសត្រូវរបស់ខ្លួនក្រោមក្របខណ្ឌនិរន្តរភាព។

ពាក់ព័ន្ធនឹងពាក្យបណ្ដឹងដាក់ជូន ស៊ីអេអូ ដោយសហគមន៍រងផលប៉ះពាល់ដោយអនុគម្រោងសេសានក្រោម២ ការពិនិត្យមើល និងការត្រួតពិនិត្យរបស់ IFC លើប្រតិបត្តិការរបស់ធនាគារ ABBank មិនមានលក្ខណៈគ្រប់គ្រាន់ នៅក្នុងផ្នែកដូចបានសង្ខេបខាងក្រោម។ តារាងខាងក្រោមនេះ សង្ខេបគំហើញរបស់ស៊ីអេអូ ទាក់ទងនឹងភាពអនុលោមរបស់ IFC ទៅនឹងគោលនយោបាយ E&S របស់ខ្លួន និងការចោទប្រកាន់របស់ដើមបណ្ដឹងអំពីគ្រោះថ្នាក់ពាក់ព័ន្ធនឹងភាពមិនអនុលោមរបស់ IFC ។

| គំហើញរបស់ស៊ីអេអូ ស្ដីពីភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ | សកម្មភាពដោះស្រាយរបស់ IFC ឬយុត្តិកម្មរបស់ IFC សម្រាប់ការមិនអនុវត្តតាមវិធានការដោះស្រាយ |
|---|---|
| **ការត្រួតពិនិត្យ របស់IFC** | |
| **IFC មិនបានអនុវត្ត ESDD ឱ្យបានគ្រប់គ្រាន់ មុនពេលការវិនិយោគរបស់ខ្លួននៅក្នុង ABBank ទៅតាមលក្ខខណ្ឌតម្រូវ នៅក្នុងគោលនយោបាយនិរន្តរភាព ឆ្នាំ២០០៦ របស់ IFC (កថាខណ្ឌ ២៨) ។**<br><br>ឯកសារនានារបស់គម្រោង បង្ហាញថា IFC បានដឹងថា ABBank បានចូលរួមនៅក្នុងគម្រោងវារីអគ្គិសនី ដែលមានផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គម (E&S) ។ ទោះជាយ៉ាងនេះក្ដី IFC មិនបានពិនិត្យមើលផលប័ត្ររបស់អន្តរការីហិរញ្ញវត្ថុ (FI) សម្រាប់ហានិភ័យ E&S តាមរយៈនីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម(ESRP) ស្របតាមលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងគោលនយោបាយនិរន្តរភាព នោះទេ។ ជាក់ស្ដែង IFC មិនបានកំណត់សកម្មភាពអាជីវកម្មរបស់ ABBank ជាមួយនឹងផលប៉ះពាល់ E&S ដែលមានសក្ដានុពល និងលក្ខខណ្ឌតម្រូវអនុវត្តការងារសមស្របរបស់ពួកគេទេ ហើយក៏មិនបានពិនិត្យមើលផងដែរ ថាតើអនុគម្រោងរបស់ ABBank បំពេញតាមលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធ នៃស្តង់ដារសមិទ្ធិកម្មរបស់ IFC បន្ថែមលើច្បាប់ និងបទប្បញ្ញត្តិជាតិនានាដែលពាក់ព័ន្ធ ដែរឬទេ។<br><br>ការខកខាននេះ បង្កើតបានជាចន្លោះប្រហោងដ៏ចម្បងមួយនៅក្នុងការត្រួតពិនិត្យរបស់ IFC។ ជាលទ្ធផល គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់ IFC បានយល់ព្រមលើការវិនិយោគ ដោយមិនបានយល់ដឹងអំពីហានិភ័យ E&S នៅក្នុងផលប័ត្រអតិថិជនអនាគតរបស់ខ្លួន រួមទាំងនៅក្នុងការវិនិយោគវារីអគ្គិសនីដូចជា LS2។ លើសពីនេះ ស្របពេលដែលគណៈ | |

គ្រប់គ្រងរបស់ IFC បានជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលថា ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ E&S របស់ ABBank មាន "ចំណុចកែលម្អ" នោះ IFC មិនមានមូលដ្ឋានពិតប្រាកដ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌ E&S របស់អតិថិជន នោះទេ ដោយសារតែអតិថិជន មិនមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម(ESMS) គោលនយោបាយ E&S ឬមាន បុគ្គលិក E&S រហូតដល់ក្រោយការវិនិយោគរបស់ IFC ហើយ IFC មិនបានយល់ដឹងអំពីហានិភ័យ E&S របស់ផលប័ត្រ ដែលចាំបាច់ដើម្បីកែលម្អ ESMS របស់អតិថិជន នោះទេ។

ជាងនេះទៅទៀត នៅរយៈពេលនៃការវិនិយោគរបស់ IFC នៅក្នុង ABBank ក្រុមធនាគារពិភពលោក កំពុងស្វែងរក ដំណោះស្រាយហានិភ័យនៃគម្រោងវារីអគ្គិសនី ជាពិសេសគម្រោងដែលពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីធំៗ។ នៅក្នុងបរិបទនេះ IFC គួរតែបានពង្រឹងការត្រួតពិនិត្យរបស់ខ្លួន ដើម្បីកំណត់ហានិភ័យ E&S របស់ធនាគារអតិថិជនដែលខ្លួនបានដឹង៖ (ក) មានការវិនិយោគវារីអគ្គិសនី (ខ) មិនដែលមាន ESMS ឬមន្ត្រី E&S ទេ និង (គ) មិនមានបទពិសោធន៍ក្នុងការពិនិត្យមើលហានិភ័យ E&S នៃការវិនិយោគហិរញ្ញវត្ថុរបស់ខ្លួន។

ដោយផ្អែកលើបរិបទដែលបង្កើតការវិនិយោគនេះ និងផ្អែកលើកង្វះខាតបទពិសោធន៍ និងសមត្ថភាព E&S ដែលបានរាយការណ៍របស់ ABBank ការពិនិត្យឡើងវិញមុនការវិនិយោគរបស់ IFC អាចក្លាយជាឱកាសមួយសម្រាប់ IFC ធ្វើការកំណត់ការចូលរួមរបស់ ABBank នៅក្នុងគម្រោង LS2 និងអាចបង្កើនការការពារ E&S របស់អនុគម្រោងនេះ ខណៈដែលអតិថិជន គឺជាអ្នកផ្តល់ហិរញ្ញប្បទានដ៏សំខាន់មួយរបស់គម្រោង LS2 ។ ការកែលម្អ អាច ធ្វើឡើងទៅលើបញ្ហាពាក់ព័ន្ធមួយចំនួន រួមមាន ការចូលរួមពីភាគីពាក់ព័ន្ធ យន្តការបណ្តឹងសារទុក្ខ ការដោះស្រាយផលប៉ះពាល់ដោយស្ម័គ្រចិត្ត ការវាយតម្លៃផលប៉ះពាល់ជីវចម្រុះ និងផលប៉ះពាល់បង្គរ ព្រមទាំងផលប៉ះពាល់លើប្រជាជន និងជនជាតិដើមភាគតិចដែលងាយរងគ្រោះ ។

| ការត្រួតពិនិត្យលើការអនុវត្ត របស់IFC | |
|---|---|
| **IFC មិនបានតាមដានត្រួតពិនិត្យការប្ដេជ្ញាចិត្តអនុវត្ត E&S នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួនជាមួយធនាគារ ABBank ដូចតាមលក្ខខណ្ឌតម្រូវមានចែងនៅក្នុងគោលនយោបាយនិរន្តរភាព (SP ឆ្នាំ២០០៦, កថាខណ្ឌ ២៦; SP ឆ្នាំ ២០១២, កថាខណ្ឌ ២៤) នោះទេ។**<br><br>កិច្ចព្រមព្រៀងផ្លូវច្បាប់របស់ IFC និង ABBank រួមបញ្ចូលផែនការសកម្មភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន (ហៅថាផែនការ SEMS) ដែលក្នុងនោះ អតិថិជននឹងធានានូវភាពអនុលោម នៃឥណទាន និងការវិនិយោគដែលមានស្រាប់របស់ខ្លួន ស្របតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC រួមទាំងស្តង់ដារសមិទ្ធិកម្ម (PS) ផងដែរ។ ទោះជាយ៉ាងនេះក្តី ក្នុងអំឡុងពេលត្រួតពិនិត្យ IFC មិនបានតម្រូវឱ្យ ABBank អនុវត្ត PS ទៅក្នុងការវិនិយោគដែលមានស្រាប់របស់ខ្លួន រួមទាំង EVNI និង LS2 ឡើយ។ ពេញមួយវដ្តនៃការវិនិយោគនេះ IFC មិនបានធ្វើការតាមដានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់ទៅលើការអនុវត្ត E&S របស់អតិថិជនខ្លួន ដូចទៅនឹងការប្តេជ្ញាចិត្តក្នុងផែនការ SEMS ដូចខាងក្រោម៖<br><br>• ក្នុងឆ្នាំ២០១១ អតិថិជនបានខកខានព្រឹត្តិការណ៍សំខាន់ៗមាននៅក្នុងផែនការ SEMS ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រង E&S ប្រកបដោយប្រសិទ្ធភាព ដែលជាលទ្ធផលធ្វើឱ្យ IFC ខកខានការអនុវត្តសកម្មភាពត្រួតពិនិត្យនានានៅឆ្នាំនោះ។<br><br>• នៅចន្លោះរវាងឆ្នាំ២០១១ ដល់ ២០១៦ ការត្រួតពិនិត្យរបស់ IFC មិនបានត្រួតពិនិត្យឡើងវិញប្រកបដោយប្រសិទ្ធភាពនូវការត្រួតពិនិត្យ E&S របស់ធនាគារ ABBank សម្រាប់ការវិនិយោគរបស់ខ្លួន នៅក្នុងវិស័យដែលមានហានិភ័យខ្ពស់។ កង្វះការត្រួតពិនិត្យនេះ បានរួមចំណែកដល់ការបរាជ័យរបស់អតិថិជនក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រង E&S ដែលមានសមត្ថភាពធានាភាពអនុលោមតាម PS សម្រាប់គម្រោងដែលមានហានិភ័យខ្ពស់ ស្របតាមលក្ខខណ្ឌតម្រូវរបស់គោលនយោបាយនិរន្តរភាព។ | |

| | |
|---|---|
| • រហូតមកដល់ឆ្នាំ ២០១៧ IFC មិនបានពិនិត្យឱ្យបានហ្មត់ចត់នូវព័ត៌មាន E&S ដែលដាក់ជូនដោយ ABBank ទេ ដូច្នេះហើយ មិនបានត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់លើការអនុវត្ត E&S និងការអនុវត្ត PS របស់អតិថិជន នៅក្នុងអនុគម្រោងរបស់ខ្លួនឡើយ។ IFC មិនបានចាត់វិធានការភ្លាមៗ នៅពេលដឹងថា ABBank កំពុងចាត់ថ្នាក់គម្រោងវារីអគ្គិសនីធំៗ ជាការវិនិយោគដោយគ្មានហានិភ័យ E&S ដោយអនុវត្តតែបទប្បញ្ញត្តិ E&S ថ្នាក់ជាតិ និងប្រើប្រាស់ស្តង់ដារសមិទ្ធិកម្ម គ្រាន់តែជាអនុសាសន៍ប៉ុណ្ណោះ។ បញ្ហាដ៏ រ៉ាំរ៉ៃនេះ គឺជាហេតុផលសំខាន់មួយសម្រាប់ IFC បន្ទាបការអនុវត្ត E&S របស់ FI ក្នុងឆ្នាំ២០២០ ប្រាំបួនឆ្នាំបន្ទាប់ពីបានដឹងជាលើកដំបូងអំពីកង្វះខាតនានានៃផែនការ SEMS។<br><br>• ក្នុងឆ្នាំ២០១៧ IFC បានរកឃើញជាលើកដំបូងថា ផលប័ត្ររបស់ ABBank បានរួមបញ្ចូលឥណទាន ដល់វិស័យដែលមានហានិភ័យខ្ពស់ ដូចជាគម្រោងវារីអគ្គិសនី និងបានរកឃើញទៀតថា SEMS របស់ ABBank គឺមិនគ្រប់គ្រាន់ក្នុងការគ្រប់គ្រងបញ្ហាទាំងនោះទេ។ ចាប់ពីពេលនោះ រហូតដល់ឆ្នាំ២០២៤ IFC បន្តលើកទឹកចិត្តអតិថិជនឱ្យត្រលប់មករកភាពអនុលោមវិញ។ ទោះជាយ៉ាងនេះក្តី IFC បានបរាជ័យក្នុងការប្រើប្រាស់អានុភាព និងឥទ្ធិពលរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ ក្នុងនាមជាម្ចាស់ភាគហ៊ុនមួយ ដើម្បីធានាបាននូវភាពអនុលោម ដោយមិនបានកំណត់លក្ខខណ្ឌតម្រូវ E&S សំខាន់ៗ ដូចជាការអនុវត្ត SEMS រហូតដល់ការប្តេជ្ញាចិត្ត ឬការទូទាត់ចំណាយ និងការមិនប្រើប្រាស់ឧបករណ៍ ឬវិធីសាស្រ្តមានឥទ្ធិពលផ្សេងទៀត ទៅលើអតិថិជន ដូចជាកិច្ចប្រជុំម្ចាស់ភាគហ៊ុន ឬការផ្តល់អាទិភាពលើបញ្ហា E&S ក្នុងការតែងតាំងក្រុមប្រឹក្សាភិបាល ដើម្បីបង្កើនការយល់ដឹងអំពីចំណុចខ្វះខាតរបស់ធនាគារ ABBank ទៅលើភាពអនុលោម E&S ។<br><br>• ជាចុងក្រោយ ខណៈដែលការត្រួតពិនិត្យរបស់ IFC មានភាពប្រសើរឡើងបន្ទាប់ពីឆ្នាំ២០១៧ IFC បានបន្តបង្រួមការយកចិត្តទុកដាក់ត្រួតពិនិត្យផែនការ SEMS របស់ខ្លួន ទៅលើការអនុវត្ត និងការជ្រើសរើសបុគ្គលិក E&S និងមិនបានតម្រូវឱ្យ ABBank អនុលោមតាមការប្តេជ្ញាចិត្តនានាដែលមានពេលវេលាកំណត់របស់ផែនការ | |

ដូចបានតម្រូវដោយគោលនយោបាយនិរន្តរភាព និង ESRP ឡើយ។

ដោយសារតែបណ្តាចំណុចដូចបានបង្ហាញខាងលើ IFC ក្នុងអំឡុងពេលនៃត្រួតពិនិត្យរបស់ខ្លួន មិនពេញចិត្តចំពោះការតាមដានត្រួតពិនិត្យទៅលើ EVNI របស់ ABBank ហើយជាលទ្ធផល គម្រោងអនុគម្រោងសេសានក្រោម២ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃស្តង់ដារសមិទ្ធិកម្ម ឆ្នាំ២០០៦ ឡើយ។

ស៊ីអេអូ រកឃើញថា ការត្រួតពិនិត្យមិនគ្រប់គ្រាន់របស់ IFC នាំឱ្យខកខានឱកាសដែលនឹងជះឥទ្ធិពលជាវិជ្ជមានទៅលើការរចនា ការធ្វើផែនការ ការសាងសង់ និងការអនុវត្តរបស់គម្រោង LS2 ដូចជា៖

- ចន្លោះឆ្នាំ ២០១១ ដល់ ២០១២ នៅពេលដែល EVNI គឺជាម្ចាស់ភាគហ៊ុនធំជាងគេ និងជាអ្នកអភិវឌ្ឍគម្រោង LS2 ពេលនោះ IFC និង ABBank មានឱកាសកែសម្រួលការរចនារោងចក្រវារីអគ្គិសនី និងការធ្វើផែនការដំបូង ឱ្យស្របតាមលក្ខខណ្ឌតម្រូវ PS ។ ផ្ទុយទៅវិញ មិនមានការចាត់វិធានការណាមួយ ដើម្បីដោះស្រាយចំណុចខ្វះខាតនៃគោលនយោបាយស្តីពីសំណង និងការដោះស្រាយផលប៉ះពាល់ ឆ្នាំ២០១១ របស់ EVNI ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវរបស់ PS1(ប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃសង្គម និង បរិស្ថាន) និង PS5 (លទ្ធកម្មដីធ្លី និងការដោះស្រាយផលប៉ះពាល់ដោយមិនស្ម័គ្រចិត្ត)។ ចំណុចខ្វះខាតទាំងនេះនៅតែមិនទាន់ដោះស្រាយបាននៅឡើយ។
- ក្រោយពី EVNI បានក្លាយជាម្ចាស់ភាគហ៊ុនតូច នៅក្នុងគម្រោង LS2 ក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ការតម្រូវឱ្យអនុវត្ត PS កាន់តែមានភាពប្រឈម។ ទោះបីជាយ៉ាងនេះក្តី តាមរយៈតំណែងជាបន្តរបស់ EVNI នៅក្នុងក្រុមប្រឹក្សាប្រតិបត្តិការរបស់ក្រុមហ៊ុន IFC នៅតែមានឱកាសខ្លះដើម្បីមានឥទ្ធិពលជាវិជ្ជមានទៅលើការធ្វើផែនការ ការសាងសង់ និងការអនុវត្តគម្រោង LS2 ។ ការមិនផ្តល់ហិរញ្ញប្បទានបន្ថែមរបស់IFC និងគោលបំណងមួយក្នុងចំណោមគោលបំណងចម្បងៗនៃការត្រួតពិនិត្យ E&S របស់ IFC គឺច្បាស់លាស់ណាស់សម្រាប់ IFC ផ្តល់ការណែនាំ និងជំបូន្មានដល់អតិថិជនអំពីរបៀបដោះស្រាយបញ្ហាហានិភ័យ E&S និងកំណត់ឱកាសកែលម្អ និង

| | |
|---|---|
| ឱកាសអនុវត្តល្អៗ ដែលអាចត្រូវបានអនុវត្តចំពោះគម្រោងស្រដៀងគ្នានេះ។ ទោះយ៉ាងណាក៏ដោយ ស៊ីអេអូ បានរកឃើញភស្តុតាងតិចតួចប៉ុណ្ណោះ ដែល បង្ហាញថា IFC បានណែនាំ ឬផ្តល់ការណែនាំដល់ ABBank ឬ EVNI លើការអនុវត្តតាមលក្ខខណ្ឌតម្រូវ PS ក្នុងអំឡុងពេលនេះ។ | |
| **គ្រោះថ្នាក់ដែលពាក់ព័ន្ធ** | |
| ស៊ីអេអូ រកឃើញគ្រោះថ្នាក់ចំពោះដើមបណ្តឹង ពាក់ព័ន្ធនឹងភាពមិនអនុលោមរបស់ IFC អំឡុងពេលនៃការត្រួតពិនិត្យ និងការពិនិត្យលើការ ប្តេជ្ញាចិត្តផ្លូវច្បាប់របស់ ABBank ក្នុងការអនុវត្តផែនការ SEMS របស់ខ្លួន និងស្តង់ដារសមិទ្ធកម្ម ចំពោះការវិនិយោគដែលមានស្រាប់ នៅក្នុង EVNI និងអនុគម្រោងសេសានក្រោម២។ ដូចដែលបានរៀបរាប់ខាងលើ IFC បានខកខានឱកាសដើម្បីបញ្ចៀស កាត់បន្ថយ និង/ឬដោះស្រាយគ្រោះថ្នាក់ដែលសហគមន៍បានជួបប្រទះ ដោយសារអនុគម្រោង ដែលបានបង្កើតឡើងគ្មានការកំណត់អត្តសញ្ញាណត្រឹមត្រូវ និងការកាត់បន្ថយហានិភ័យ E&S និងផលប៉ះនានាទៅលើប្រជាពលរដ្ឋរងផលប៉ះពាល់។<br><br>យោងតាមបណ្តឹងរបស់ក្រុមដើមបណ្តឹងនីមួយៗ ស៊ីអេអូ រកឃើញថា៖<br><br>1. អ្នកភូមិដែលបដិសេធការតាំងលំនៅថ្មី បានរងគ្រោះដោយសារ ខ្វះការពិចារណាអំពីបំណងរបស់ពួកគេចង់តាំងទីលំនៅថ្មីក្នុងដីប្រពៃណីរបស់ខ្លួន ឬទស្សនះរបស់ខ្លួនទៅលើជម្រើសជំនួស ចំពោះគម្រោង LS2 ដោយសារការបាត់បង់ទឹកដីដ៏ពិសិដ្ឋ និងជារបស់ដូនតា និងពិធីសាសនាសំខាន់ៗដែលផ្សារភ្ជាប់ជាមួយពួកគេ ដោយសារកង្វះការពិគ្រោះយោបល់ដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ ព្រោះភាគច្រើនគឺជាជនជាតិដើមភាគតិច ដោយសារគ្មានសំណងសម្រាប់ការផ្លាស់ទីលំនៅរូបវ័ន្ត និងសេដ្ឋកិច្ច ព្រមទាំងដោយសារការបំភិតបំភ័យ និងការសងសឹក ក្នុងអំឡុងឆ្នាំ ២០១៧-២០១៨ នៅពេលដែលការសាងសង់ទំនប់នេះត្រូវបានបញ្ចប់ និង | |

| | |
|---|---|
| ដំណើរការបានចាប់ផ្តើម។ បច្ចុប្បន្ន ការរស់នៅលើទឹកដីប្រពៃណី សហគមន៍ទាំងនេះនៅតែបន្តខ្វះសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។<br><br>2. អ្នកភូមិដែលបានតាំងលំនៅថ្មី បានរងគ្រោះ ដោយសារតែកញ្ចប់ដោះស្រាយផលប៉ះពាល់ មិនផ្អែកលើសារពើភ័ណ្ឌទ្រព្យសកម្ម និងការអង្កេតសេដ្ឋកិច្ចសង្គមគ្រប់ជ្រុងជ្រោយ អំពីទ្រព្យសម្បត្តិមុនពេលផ្លាស់ទីលំនៅ ជាហេតុធ្វើឱ្យសំណងរបស់ពួកគេមិនគ្រប់គ្រាន់។ ពួកគេមិនអាចចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការធ្វើការសម្រេចចិត្តតាំងលំនៅថ្មី ដោយរួមទាំងជនជាតិដើមភាគតិចព្នង ពីក្បាលរមាសចាស់ ហើយបានជួបប្រទះបញ្ហាជាបន្តបន្ទាប់ជាមួយប្លង់ ហេដ្ឋារចនាសម្ព័ន្ធ និងគុណភាពរបស់ទីតាំងតាំងទីលំនៅថ្មី ដែលនៅតែមិនទាន់ដោះស្រាយ។ គម្រោងនេះ ខ្វះយន្តការបណ្តឹងសារទុក្ខ ដែលធ្វើឱ្យ សមត្ថភាពរបស់ពួកគេមានកម្រិត ក្នុងការលើកបញ្ហាទាំងនេះជាមួយប្រតិបត្តិករទំនប់។ សហគមន៍ដែលតាំងលំនៅថ្មី មានទីតាំងជាច្រើនគីឡូម៉ែត្រពីទន្លេ ដែលកម្រិតសកម្មភាពនេសាទ ហើយដីកសិកម្មថ្មីដែលពួកគេទទួលបានមិនមានជីវជាតិដូចដីពីមុនរបស់ពួកគេឡើយ។ ដើម្បីប៉ះប៉ូវដល់ការថយចុះ នៃទិន្នផលនេសាទ និងទិន្នផលកសិកម្ម បច្ចុប្បន្ន ពួកគេទិញរបស់របរជាច្រើនដែលពួកគេធ្លាប់នេសាទបាន ឬធ្វើស្រែចំការបាន ព្រមទាំងត្រូវទិញទឹកផងដែរ។ ពួកគេមិនបានទទួលជំនួយស្តារជីវភាពរស់នៅដើម្បីធ្វើការស្តារជីវភាពរបស់ពួកគេឡើងវិញឱ្យដល់កម្រិតមុនពេលមានគម្រោងទេ។<br><br>3. ភាគច្រើននៃអ្នកភូមិរស់នៅខ្សែទឹកខាងលើ មិនដែលបានទទួលការប្រឹក្សាយោបល់ពីគម្រោងនេះទេ (មានតែបីភូមិប៉ុណ្ណោះក្នុងចំណោមភូមិខ្សែទឹកខាងលើ ចំនួន១៨ភូមិ របស់ដើមបណ្តឹង បានទទួលការប្រឹក្សាយោបល់អំពីដំណើរការ EIA)។ ពួកគេបានជួបប្រទះផលប៉ះពាល់អវិជ្ជមានចំពោះជីវភាពរស់នៅ ដោយសារតែការធ្លាក់ចុះនៃបរិមាណត្រីផ្លាស់ទី និងការប្រែប្រួលលំហូរទឹកទន្លេ ដែលបង្ខំឱ្យពួកគេទិញអាហារ និងទឹក នៅលើទីផ្សារ។ ពួកគេមិនបានទទួលសំណងសម្រាប់ផលប៉ះពាល់ទាំងនេះ ឬការទទួលស្គាល់ថាពួកគេជាអ្នកទទួលរងផលប៉ះពាល់ពីគម្រោងនេះទេ។ | |

## តារាង ឃ.២. អនុសាសន៍កម្រិតគម្រោង និងអនុសាសន៍ជាប្រព័ន្ធ របស់ស៊ីអេអូ

| អនុសាសន៍កម្រិតគម្រោង |
| --- |
| 1. ស្វែងយល់ជាមួយធនាគារអន្តរជាតិសម្រាប់កសាងឡើងវិញ និងអភិវឌ្ឍ (IBRD) នូវលទ្ធភាពដាក់បញ្ចូលសហគមន៍ក្បាលរមាសចាស់ទៅក្នុងគម្រោងបែងចែកដីសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ខ្លួន III (LASED III) ដែលមានធាតុផ្សំប័ណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច (ICLT) ដើម្បីជួយសហគមន៍ក្នុងការបំពេញ និងទទួលបាន ICLT របស់ពួកគេ ដោយមានការយល់ព្រម ពី IFC។ |
| 2. តាមរយៈ ABBank EVNI ឬតាមរយៈការទាក់ទងគម្រោង LS2 ទំនាក់ទំនងម្ចាស់ភាគហ៊ុនរបស់ពួកគេ ឬភាគីពាក់ព័ន្ធក្នុងតំបន់ផ្សេងទៀតដោយផ្ទាល់ ផ្តល់ជំនួយសម្រាប់បង្កើតយន្តការបណ្តឹងសារទុក្ខ ដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ អនុលោមតាមលក្ខខណ្ឌតម្រូវ PS1 និង PS5 ហើយនឹងអនុញ្ញាតឱ្យសហគមន៍រងផលប៉ះពាល់ ដែលក្នុងនោះរួមទាំងសហគមន៍រស់នៅខ្សែទឹកខាងលើ ផ្ញើសំណួរ កង្វល់ និងសារទុក្ខរបស់ពួកគេ។ តាមរយៈយន្តការនេះ គម្រោងអាចទទួលបាន និងសម្របសម្រួលការដោះស្រាយបណ្តឹងពីសហគមន៍រងផលប៉ះពាល់ និងផ្តល់ព័ត៌មានអំពីវិធានការនានារបស់គម្រោង។ |
| 3. តាមរយៈ IBRD ចូលរួមជាមួយអាជ្ញាធររដ្ឋាភិបាលដើម្បីផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រ ដើម្បីធ្វើសវនកម្មបញ្ចប់ដោះស្រាយផលប៉ះពាល់ និងកម្មវិធីស្តារជីវភាពរស់នៅរបស់ LS2 ទៅតាមលក្ខខណ្ឌតម្រូវ PS5 ។ សវនករខាងក្រៅ គប្បីផ្តល់អនុសាសន៍ និងស្នើវិធានការកែតម្រូវ ចំពោះចំណុចខ្វះខាត ណាមួយដែលបានរកឃើញ។ វិធានការទាំងនោះ គប្បីត្រូវបានពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ មានការកំណត់ពេលវេលាច្បាស់លាស់ និងប៉ាន់ស្មានចំណាយ ព្រមទាំងរួមបញ្ចូលការកំណត់ប្រភពហិរញ្ញប្បទានសម្រាប់សកម្មភាពទាំងនោះ តាមលទ្ធភាពដែលអាចធ្វើទៅបាន។ |
| 4. ស្វែងយល់ជាមួយ IBRD និងភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងអាជ្ញាធររដ្ឋាភិបាល ព្រមទាំងការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់ នូវឱកាសបង្កើត និងអនុវត្តផែនការសកម្មភាពជីវចម្រុះសម្រាប់ការស្តារឡើងវិញនូវទីជម្រកតាមដងទន្លេ និងវិធានការកាត់បន្ថយផលប៉ះពាល់គ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបនឹងការបាត់បង់ជីវចម្រុះ។ ផែនការនេះ គួររួមបញ្ចូលតាមការចាំបាច់នូវសកម្មភាពផ្តល់សំណងដល់ |

អ្នកប្រើប្រាស់ពីសហគមន៍រងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ដែលជីវភាពរស់នៅរបស់ពួកគេ បានរងផលប៉ះពាល់ដោយសារការបាត់បង់ជីវចម្រុះ ដោយការយកចិត្តទុកដាក់សមស្របទៅលើផលប៉ះពាល់ផ្សេងៗមកលើជនជាតិដើមភាគតិច និងស្ត្រី។

## អនុសាសន៍ជាប្រព័ន្ធ

1. ពង្រឹងសមត្ថភាព និងនីតិវិធី E&S សម្រាប់ការវិនិយោគ FI ដើម្បីធានាបាននូវការយល់ដឹងគ្រប់គ្រាន់អំពីហានិភ័យ E&S និងសមត្ថភាព E&S របស់អតិថិជន ក្នុងអំឡុងពេលត្រួតពិនិត្យ និងការពិនិត្យ តាមដានដ៏ត្រឹមត្រូវលើការប្តេជ្ញាចិត្តអនុវត្ត E&S ទាំងអស់ ក្នុងអំឡុងពេលត្រួតពិនិត្យការអនុវត្ត។ គប្បី អភិវឌ្ឍសមត្ថភាព ដើម្បីធានាថា IFC មានមន្រ្តីឯកទេសក្នុងការគ្រប់គ្រងហានិភ័យ E&S របស់ FI ជាមួយនឹងការបណ្តុះបណ្តាលចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធ ដើម្បីពិនិត្យ និងតាមដានការវិនិយោគរបស់ FI ។
2. បង្កើត និងផ្សព្វផ្សាយក្នុងចំណោមបុគ្គលិក E&S នូវសេចក្តីណែនាំលម្អិតស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ ត្រួតពិនិត្យ E&S ចំពោះការវិនិយោគមានគោលបំណងទូទៅរបស់អតិថិជន FI ដូចជាការវិនិយោគ លើភាគហ៊ុនជាដើម។ សេចក្តីនាំនេះគួរតែរួមបញ្ចូលការណែនាំច្បាស់លាស់អំពីបណ្តាចំណុចខាងក្រោម ក្នុងចំណោមការរួមបញ្ចូលផ្សេងទៀត៖
    a. របៀបពិនិត្យមើលគំរូសំណាកតំណាងឱ្យការវិនិយោគ ប្រតិបត្តិការ ផលិតផល និងវិស័យនានាដែលមានហានិភ័យខ្ពស់ នៅក្នុងផលប័ត្ររបស់ FI ក្នុងអំឡុងពេលត្រួតពិនិត្យ ដើម្បីកំណត់សមត្ថភាព E&S ដែលត្រូវការសម្រាប់អតិថិជន និងដើម្បីកំណត់ការចំណាយនៃគម្រោងផែនការសកម្មភាពបរិស្ថាន និងសង្គម (ESAP) និងការចំណាយប្រចាំឆ្នាំជាមធ្យមនៃការអនុវត្ត ESMS របស់អតិថិជន។
    b. របៀបវាយតម្លៃបុគ្គលិក E&S ដែលចាំបាច់ក្នុងកម្រិតអប្បបរមា សម្រាប់ FI ដោយផ្អែកលើហានិភ័យ E&S នៃផលប័ត្រ និងចំណូល ព្រមទាំងសមត្ថភាពរបស់ FI ទាក់ទាញការចូលរួមពីបុគ្គលិក E&S ថ្មី។ ក្នុងករណីនេះ និងករណីផ្សេងទៀត ស៊ីអេអូ បានសង្កេតឃើញថា កង្វះខាតសមត្ថភាព E&S របស់អតិថិជន រមែងតែងជាបញ្ហាដែលកើតឡើងដដែលៗ។ IFC គួរបង្កើតឧបករណ៍ និងប៉ារ៉ាម៉ែត្រសម្រាប់បុគ្គលិក E&S របស់ខ្លួន ដើម្បីវាយតម្លៃតម្រូវការបុគ្គលិក E&S របស់អតិថិជនទាក់ទងនឹងផលប័ត្រហានិភ័យ E&S របស់អតិថិជន។

3. ធ្វើការពិនិត្យឡើងវិញនូវផលប័ត្រនៃការវិនិយោគ FI ដែលមានភាគហ៊ុនសកម្មរបស់ IFC ចាប់តាំងពីឆ្នាំ២០០៦ ដោយរួមបញ្ចូលកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ (ESAP ឬចំណុចផ្សេងទៀត) សម្រាប់អតិថិជនដើម្បីអនុវត្ត ESMS របស់ខ្លួន ទៅលើ "ឥណទាន និងការវិនិយោគដែលមានស្រាប់" និងធានាឱ្យមានការតាមដានត្រួតពិនិត្យគ្រប់គ្រាន់ទៅលើការប្តេជ្ញាចិត្តផ្លូវច្បាប់។

4. ធ្វើបច្ចុប្បន្នភាព ESRP របស់ខ្លួនដើម្បីផ្តល់ការណែនាំច្បាស់លាស់បន្ថែមទៀតដល់បុគ្គលិក E&S អំពីរបៀបរៀបចំរចនាសម្ព័ន្ធការវិនិយោគ ដើម្បីប្រើប្រាស់អានុភាពរបស់ IFC ឱ្យបានល្អបំផុត ក្នុងអំឡុងពេលវដ្តនៃការវិនិយោគ ដើម្បីធានាបាននូវភាពអនុលោមរបស់អតិថិជន ទៅតាមលក្ខខណ្ឌតម្រូវ E&S ។ ដូចដែលបានផ្តល់អនុសាសន៍នៅក្នុងសំណុំរឿងមុនៗ ចំណុចនេះគប្បីរួមបញ្ចូលសេចក្តីណែនាំច្បាស់លាស់អំពីតម្រូវការក្នុងការភ្ជាប់ការប្តេជ្ញាចិត្ត E&S នៅក្នុង ESAP ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ ទៅនឹងព្រឹត្តិការណ៍សំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការទូទាត់ចំណាយដំបូង និងការទូទាត់ចំណាយជាបន្តបន្ទាប់ទៀត ដើម្បីធានាថា IFC មានអានុភាពគ្រប់គ្រាន់ដើម្បីទាមទារឱ្យមានបំពេញនូវលក្ខខណ្ឌទាំងនេះ។